មង្គលកថា

មង្គលទី ៣៦

រៀបរៀងដោយ

ភិក្ខុសីលប្យញ្ញោ ឆែ សុផល្លី

ព.ស.២៥៥៧

មङ្គលកថា

មङ្គលទី ៣៦

រៀបរៀងដោយ

ភិក្ខុសីលប្យញ្ញោ ឆែ សុផល្លី

ព.ស.២៥៥៧

ពុទ្ធ្ធ្ធ្ធ្ធ្ធ

ព្រះពុទ្ធ្ធ្ធ្ធ្ធ្ធ

ស្ថានទីតាំ

ស្ថានទីតាំ

ស្ថានទីតាំ

ស្ថានទីតាំ

ស្ថានទីតាំ

ស្ថានទីតាំ

ទេវតាមួយម៉ឺនចក្រវាឡ ចុះមកអារាធនាសូមឱ្យព្រះអង្គសម្តែងមង្គល

រឿងមង្គលនេះទេវតាមួយម៉ឺនចក្រវាឡប្រើពេលអស់១២ឆ្នាំ រកមង្គលតែរកមិនឃើញ លុះដល់ព្រះអង្គបានត្រាស់ដឹងក៏នាំគ្នាចុះមកទូលសួរព្រះអង្គ ។ ព្រះអង្គបានសម្តែងមង្គលទាំង ៣៨ ប្រការ មានកិរិយាមិនសេពគប់បុគ្គលពាល ជាដើម រហូតដល់មានចិត្តក្សេមក្សាន្ត កាលចប់**ទេវតាសម្រេចជាព្រះអរហន្ត រាប់សែនកោដិ ។ សម្រេចជាសោតាបត្តិផល សកទាគামិផល អនាគামិផល រាប់ប្រមាណមិនបាន ។**

មង្គលកថា

មង្គលទី ៣៦

រៀបរៀងដោយ

ភិក្ខុសីលឫទ្ធោ ឆែ សុផល្លី

វត្តនិគ្រោធវ័ន គល់ទទឹង

ព.ស.២៥៥៧

- **ឈ្មោះសៀវភៅ** **មង្គលកថាមង្គលទី ៣៦**

- **រៀបរៀងដោយ** **ភិក្ខុសីលឫទ្ធោ ឆែ សុផល្លី**

- **អនុញ្ញាតឱ្យប្រើប្រាស់កុំព្យូទ័រដោយ** **អគ្គធីរោ** **គង់ សុមិត្ត**

- **ចេញផ្សាយ** លើកទី ១

- **កាលបរិច្ឆេទ** ព.ស. ២៥៥៧

- **ទីកន្លែងធ្វើ** វត្តនិគ្រោធវ៉ន"គល់ទទឹង" ភូមិកោះក្របី

សង្កាត់ព្រែកថ្មី ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ

អារម្ភកថា

មនុស្សនៅលើសកលលោកយើងនេះ សុទ្ធតែជាអ្នកប្រាថ្នានូវសេចក្ដីសុខចម្រើន សិរីសួស្ដី សុភមង្គល ភាពសុខដុមរមនាគ្រប់គ្នា ៗទាំងអស់ មិនចំពោះថា ជាតិសាសន៍ណាឡើយ មានអ្នកខ្លះព្រោះតែចង់បានសេចក្ដីសុខ ចម្រើន សិរីសួស្ដី សុភមង្គលដល់ជីវិតខ្លាំងពេកទៅ រហូតដល់ថ្នាក់ បន់ស្រន់ បួងសួង អារក្សអ្នកតាទេវតា ព្រៃភ្នំ មន្ដអាគមអូមអាមផ្សេង ៗ និងមានអ្នកខ្លះទៀតយល់ថា ទាល់តែមានទ្រព្យ សម្បត្ដិស្ដុកស្ដម្ភ មានយសសក្ដិខ្ពង់ខ្ពស់ មានគេគោរពលើកតម្លើង បរិវារ ហែហម ចោមរោម ការពារគ្រប់ជ្រុងជ្រោយ ទើបជីវិតមាននៅសិរី សួស្ដីសុភមង្គល ។ ទង្វើទាំងអស់នេះ ជាផ្ទុយស្រឡះអំពីគន្លងនៃព្រះពុទ្ធសាសនាទាំងស្រុង ។

នៅក្នុងព្រះធម៌របស់ព្រះអង្គទាំង ៨៤,000 ព្រះធម្មខន្ធដែលមាននៅក្នុងគម្ពីរព្រះត្រៃបិដកទាំង ១១០ ក្បាល ដោយព្រះអង្គសម្ដែងអស់រយៈពេល ៤៥ ព្រះវស្សានោះ ទាំងសម្ដែងឋានទេវតា ឋានមនុស្សគ្រប់ស្រុកតំបន់ផ្សេង ៗនោះ មានព្រះសូត្រមួយឈ្មោះថា **មង្គលសូត្រ** ដែលជាព្រះសូត្រសម្ដែងអំពីវិធីបដិបត្ដិនាំឱ្យកើតនូវសិរីសួស្ដី សុភមង្គលដ៏ខ្ពង្គ ខ្ពង្ហមនៃជីវិត ។ និងជាព្រះសូត្រដែលព្រះអង្គសម្ដែងបើកបង្ហាញដល់មនុស្ស និង

ទេវតានាសម័យនោះ ។ ព្រះសូត្រនេះសំខាន់ខ្លាំងណាស់ សម្រាប់អ្នកដែលប្រាថ្នានូវសិរីសួស្តីដល់ខ្លួនឯង ក្រុមគ្រួសារ ញាតិមិត្ត បងប្អូន និងសង្គមជាតិទាំងមូល ។ ព្រោះព្រះសូត្រនេះ ព្រះមានព្រះភាគទ្រង់ត្រាស់សម្តែងចំតែម្តង អំពីវិធីបដិបត្តិនាំឱ្យកើតនូវសិរីសួស្តី សុភមង្គលដ៏ខ្ពស់ក្នុងជីវិត ។

នៅក្នុងអដ្ឋកថា **មង្គលជាតក** បានពោលអំពីព្រាហ្មណ៍ម្នាក់ អ្នកនៅក្នុងក្រុងនគរោជគ្រឹះ ជាអ្នកប្រកាន់មង្គលភ្ជាក់ផ្ទើលមិនជ្រះថ្លាក្នុងព្រះរតនត្រ័យ ជាបុគ្គលមិច្ឆាទិដ្ឋិ មានភោគសម្បត្តិច្រើន ។

ក្នុងកាលនោះ កណ្តុរបានកាត់នូវសម្ពត់សាដកមួយគូរបស់គាត់ ។ ដល់ពេលគាត់ត្រូវការឱ្យគេយកសំពត់នោះមក ទើបដឹងថាត្រូវកណ្តុរកាត់ដាច់ជាអន្ធើ ១ ១ ទៅហើយ ។ ព្រាហ្មណ៍គិតថា សំពត់នេះជាអពមង្គល បើទុកនៅនឹងផ្ទះនាំឱ្យមានការវិនាសយ៉ាងក្រៃលែង គឺវាដូចជាកាឡកណ្ណីមួយអ៊ីចឹង ទាំងមិនអាចឱ្យដល់បុត្រ ធីតា ឬទាសកម្មករផង ព្រោះសេចក្តីវិនាសនឹងកើតដល់អ្នកទទួលសំពត់នោះទៅគ្រប់គ្នា ត្រូវយកទៅចោលក្នុងព្រៃខ្ចោចទើបបាន ។

ព្រាហ្មណ៍មិច្ឆាទិដ្ឋិ មិនឱ្យពួកទាសកម្មករយកទៅចោលទេ ដោយខ្លាចពួកទាសកម្មករ នាំយកនូវសំពត់នោះទៅប្រើប្រាស់ បណ្តាលឱ្យវិនាសត ១ៗគ្នា ។ ទើបព្រាហ្មណ៍ប្រាប់ឱ្យកូនប្រុសរបស់គាត់យកឈើឆ្នុះទាក់នូវសំពត់នោះ នាំទៅចោលនៅព្រៃខ្មោច ហើយត្រូវដួតទឹកមុជឱ្យលិចក្បាលសឹមត្រឡប់មកផ្ទះវិញ ។

ព្រះបរមសាស្តាសម្មាសម្ពុទ្ធគង់ប្រថាប់នៅវត្តវេឡុវ័ន ទ្រង់ជ្រាបឧបនិស្សរ័យនៃព្រាហ្មណ៍ពីរនាក់ឪពុកនិងកូន ព្រះអង្គបានយាងទៅកាន់ព្រៃខ្មោចនោះ ហើយទ្រង់កាន់យកនូវសំពត់សាដកដែលកូនប្រុសរបស់ព្រាហ្មណ៍បានចោលហើយ ទាំងដែលកូន ប្រុសនោះឃាត់ព្រះអង្គមិនឱ្យចាប់ ដោយអាងថា ជារបស់ចង្រៃ ។ ព្រះបរមសាស្តាទ្រង់កាន់យកនូវសំពត់មួយគូរនោះ រួចត្រឡប់មកកាន់វត្តវេឡុវ័នវិញ ។

កាលដែលកូនប្រុសត្រឡប់មកជម្រាបរឿងរ៉ាវ ដល់ឪពុកហើយ ឪពុកនិងកូនក៏ប្រញាប់នាំគ្នាទៅវត្តវេឡុវ័ន ដើម្បីសូមឱ្យព្រះសម្មាសម្ពុទ្ធចោលនូវសំពត់នោះទៅវិញ ។ ព្រាហ្មណ៍គិតថា បើព្រះសមណគោតម ប្រើសំពត់នេះទៅ វាត្រូវធ្វើឱ្យលំបាកដល់ព្រះអង្គផង ត្រូវវិនាសវត្តវេឡុវ័នផង ម្ល៉ោះហើយគេនិងនិន្ទាស្តីថា

មកដល់យើងជាពិតប្រាដក ដូច្នេះ យើងត្រូវយកសំពត់សាដកថ្មី ១ទៅថ្វាយដល់ព្រះសមណគោតម ដើម្បីសូមឱ្យព្រះសមណគោតម ចោលនូវសំពត់ចង្រៃនោះ ។

នៅពេលដែលព្រាហ្មណ៍ឪពុកនិងកូនប្រុសបានទៅដល់វត្តហើយ ព្រាហ្មណ៍ជាឪពុកបានក្រាបទូលព្រះសម្មាសម្ពុទ្ធដោយសព្វគ្រប់ ។ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ ពួកយើងមានឈ្មោះថាជាបព្វជិតដូច្នេះសំពត់ចាស់ ១ដែលគេចោលនៅព្រៃខ្មោច ឬគំនរសម្រាមជាដើម រមែងសមគួរដល់ពួកយើងឯចំណែកព្រាហ្មណ៍ឯង មិនមែនទើបតែឥឡូវនេះទេ ពីជាតិមុនមក ក៏ធ្លាប់ប្រកាន់នូវលទ្ធិដូច្នេះដែរ ។

កាលដែលព្រាហ្មណ៍អាវធនាហើយ ព្រះអង្គទ្រង់ត្រាស់សម្តែងនូវរឿងរ៉ាងអតីតជាតិ មានសេចក្តីប្រហែលគ្នានឹងបច្ចុប្បន្នដែរគ្រាន់តែកាលណោះ ព្រះបរមពោធិសត្វជាតាបសបានឈានហើយប្រោសព្រាហ្មណ៍ឯព្រាហ្មណ៍ក៏បានយកព្រះបរមពោធិសត្វជាសរណៈ ។

នៅក្នុងបិដកលេខ ៥៨ ទំព័រ ៣៨ **មង្គលជាតក** ព្រះបរមសាស្តាទ្រង់ត្រាស់ថា ៖

មង្គលទាំងឡាយក្តី ឧត្បាតទាំងឡាយក្តី សុបិនទាំងឡាយក្តី លក្ខណៈទាំងឡាយក្តី ដែលបុគ្គលណាបានផ្ចាប់ចង់ហើយ បុគ្គលនោះឈ្មោះថា អ្នកកន្ទ្ធ ងផុតនូវទោសនៃមង្គល(ភ្ជាក់ផ្ទើល) ។ ជាអ្នកគ្របសង្កត់នូវយុគក្ខិលេស(ក្រោធ ១ ការចងគំនុំ ១ ការមិលគុណ ១ និងការវាយឫកស្ម៏ ១ ទាំង ៤ នេះ ហៅថា យុគក្ខិលេស)និងយោគក្ខិលេស(កាមយោគ ១ ភវយោគ ១ ទិដ្ឋិយោគ១អវិជ្ជាយោគ ១)រមែងមិនមកកើតទៀតឡើយ ។

ដោយសេចក្តីថា បុគ្គលណាមិនប្រកាន់មង្គលភ្ជាក់ផ្ទើល មិនប្រកាន់ឧត្បាត មិនប្រកាន់ការយល់សប្ដិ មិនប្រកាន់លក្ខណៈ ជោគល្អ ឬជោគអាក្រក់ បុគ្គលនោះឈ្មោះថា ជាអ្នកកន្ទ្ធ ងផុតនូវទោសនៃការប្រកាន់មង្គលភ្ជាក់ផ្ទើល ។

ព្រះបរមសាស្តា ទ្រង់សម្ដែងធម៏ឱ្យព្រាហ្មណ៏ឪពុក និងកូនបានសម្រេចសោតាបត្ដិផល ។

នៅក្នុងអដ្ឋកថា**នក្ខត្ដជាតក** បានពោលអំពីត្រកូលមួយនៅក្រៅក្រុងសាវត្ដី បានទៅស្ដីដណ្ដឹងកុលធីតាម្នាក់នៅក្នុងក្រុងសាវត្ដី ដើម្បីជាប្រយោជន៏ដល់កូនប្រុសរបស់ខ្លួន ។ គេបានសន្យាថ្ងៃកំណត់មកទទួលយកកូនកូនស្រីទៅកាន់ត្រកូលខាងប្រុស ប៉ុន្ដែ

លុះដល់ថ្ងៃកំណត់ ត្រកូលខាងប្រុសគេបានសួរអាជីវកម្មាក់ដែលបានចូលទៅកាន់ត្រកូលរបស់ខ្លួនថា លោកម្ចាស់ដ៏ចម្រើន ថ្ងៃនេះពួកខ្ញុំនឹងធ្វើនូវមង្គលមួយ តើនក្ខត្តឫក្សល្អដែរទេ ?

អាជីវកមានការខឹងក្រោធជាខ្លាំង ព្រោះគិតថាពួកអស់នេះមិនសួរយើងពីដំបូង ឥឡូវដល់ថ្ងៃទៅហើយទើបតែសួរ យើងនឹងផ្តល់មេរៀនឱ្យគេម្តង ដូច្នេះហើយក៏ពោលថា ថ្ងៃនេះមិនល្អទេ អ្នកទាំងអស់គ្នាកុំធ្វើមង្គលឡើយ បើចេសចេះតែធ្វើនឹងមានការវិនាសធំ ។ ពួកមនុស្សក្នុងត្រកូលក៏ជឿអាជីវកនោះ ហើយក៏មិនបានទៅទទួលយកកូនស្រីក្នុងថ្ងៃហ្នឹងឡើយ ។

ចំណែកត្រកូលខាងស្រី បានចាត់ការមង្គលរៀបចំទទួលភ្ញៀវខាងប្រុស លុះមិនឃើញពួកគេមកតាមសន្យា ក៏លើកធីតាឱ្យទៅត្រកូលជនៃសម្រេចស្រេចបាច់ក្នុងថ្ងៃនោះដែរទៅ ។

ថ្ងៃស្អែកឡើង ត្រកូលក្រៅក្រុងក៏បាននាំគ្នាមកដល់សូមយកកូនស្រីពួកអ្នកក្នុងក្រុងក៏ពោលតិះដៀលថា ពួកអ្នកឯងសមនឹងឈ្មោះ អ្នកក្រៅក្រុងមែនហើយ ជាមនុស្សខ្វះសម្បត្តិរបស់មនុស្សល្អ ជាមនុស្សអាក្រក់ សន្យាគ្នាហើយ មើលងាយពាក្យសន្យា មិនមកតាមកំណត់ អញ្ជើញទៅតាមផ្លូវដែលអ្នកវាស់គ្នា

មកនោះវិញទៅ ពួកយើងលើកកូនស្រីយើងឱ្យអ្នកផ្សេង ៗទៅ
ហើយ ។

ពួកអ្នកក្រៅក្រុង ១ប្រើងឈ្លោះនឹងអ្នកក្រុងអស់មួយសន្ទុ
ធ លុះដឹងប្រាកដថា មិនបានកូនក្រមុំពិតហើយ ក៏នាំគ្នាត្រឡប់
ទៅវិញតាមផ្លូវដែលមកនោះឯង ។

រឿងទាំងអស់នេះបានជ្រាបដល់ព្រះមានព្រះភាគ ព្រះអង្គ
ទ្រង់ត្រាស់ព្រះជាតក ពីអាជីវកនោះធ្លាប់បំផ្លាញមង្គលរបស់គេ
តាំងពីជាតិមុនមកហើយ ។

ក្នុងជាតិមុននោះ អ្នកក្រុងពារាណសី ទៅស្តីដណ្តឹងកូនស្រី
អ្នកជនបទហើយមិនទៅតាមសន្យា ព្រោះជឿតាមពាក្យកុហក
របស់អាជីវក ។ រឿងរ៉ាងមានទំនងដូចគ្នា ១ុសត្រង់ថាអ្នកជនបទ
បានតិះដៀលអ្នកក្រុងពារាណសីថា ពួកអ្នករាល់គ្នាឈ្មោះថាជា
អ្នកក្រុង ប៉ុន្តែ១ុះនូវសម្បត្តិរបស់មនុស្សល្អ ព្រោះមិនគោរពាក្យ
សន្យា ។ ក្នុងកាលណោះ ព្រះបរមពោធិសត្វជាបណ្ឌិត បាន
ពោលថា ផ្ការយទាំងឡាយនិងមានប្រយោជន៍អ្វី ព្រោះការបាន
កូនស្រីក្រមុំជាឫកល្អស្រេចទៅហើយ មិនមែនទេ ? ១ួចហើយ
ទើបព្រះបរមពោធិសត្វពោលនូវគាថា ៖

នៅក្នុងបិដកលេខ ១៥៨ ទំព័រ ២២ **នក្ខត្តជាតក** បណ្ឌិតបុរសពោធិសត្វពោលថា ៖

នក្ខត្តំ បដិមានេន្តំ អត្តោ ពាលំ ឧបច្ចគា

អត្តោ អត្តស្ស នក្ខត្តំ កី ករិស្សន្តិ តារកាតិ ។

ប្រែថា: ប្រយោជន៍រមែងកន្ធងបង់នូវមនុស្សល្ងង់ដែលរាប់អានូវនក្ខត្តឫក្ស ប្រយោជន៍ជានក្ខត្តឫក្សរបស់ប្រយោជន៍ ឯ ផ្ទាយទាំងឡាយនឹងធ្វើអ្វីបាន ។

បណ្តាបទទាំងនោះ បទថា **បដិមានេ្ត** ដោយសេចក្តីថា អ្នកវង់ចាំមើលអធិប្បាយថា រង់ចាំតែវង់ចាំមើល នក្ខត្តឫក្សនឹងមានក្នុងពេលនេះ នឹងមានក្នុងកាលឥឡូវនេះ ។

បទថា **អត្តោ ពាលំ ឧបច្ចគា** ដោយសេចក្តីថា ប្រយោជន៍ពោលគឺការបាននូវកូនក្រមុំ កន្ធងផុតនូវមនុស្សល្ងង់ដែលជាអ្នកក្រុងពារាណសីនោះ ។

បទថា **អត្តោ អត្តស្ស** នក្ខត្តំ ដោយសេចក្តីថា បុគ្គលស្វែងរកនូវប្រយោជន៍ណា ប្រយោជន៍ដែលគេបានហើយនោះ ឯង ឈ្មោះថាជានក្ខត្តឫក្សរបស់ប្រយោជន៍ ។

បទថា **កី ករិស្សន្តិ តារកា** ដោយសេចក្តីថា តើជួងផ្ទាយ

ទាំងឡាយក្នុងអាកាសក្រៅអំពីនេះ នឹងញ៉ាំងប្រយោជន៍ដូចម្តេចឱ្យសម្រេចបាន ។

ម្យ៉ាងទៀត នៅក្នុងបិដកលេខ ៤១, ទំព័រ ៤៧៥ ត្រង់ **មង្គលវគ្គ** ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់ជាមួយនឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្ត ក្នុងវេលាបុព្វណ្ហសម័យ(ពេលព្រឹក) សត្វទាំងនោះ ឈ្មោះថា **មានបុព្វណ្ហសម័យដ៏ល្អ** ។ ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយ ប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្ត ក្នុងវេលាមជ្ឈន្ទិកសម័យ(ពេលថ្ងៃ) សត្វទាំងនោះ ឈ្មោះថា **មានមជ្ឈន្ទិកសម័យដ៏ល្អ** ។ ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចាប្រព្រឹត្តសុចរិតដោយចិត្តក្នុងវេលាសាយណ្ហសម័យ(ពេលល្ងាច) សត្វទាំងនោះ ឈ្មោះថា **សាយណ្ហសម័យដ៏ល្អ** ។

សុនក្ខត្តំ សុមង្គលំ សុបភាតំ សុហុដ្ឋិតំ
សុខណោ សុមុហុត្តោ ច សុយិដ្ឋំ ព្រហ្មចារិសុ ។

ពេលណាដែលសត្វទាំងឡាយ ប្រព្រឹត្តល្អដោយកាយ វាចា ចិត្ត ពេលនោះឈ្មោះថា នក្ខត្តឫក្ខល្អ មង្គលល្អ ពេលភ្ជឿ ស្ងាងល្អ ពេលនៃអរុណរះឡើងល្អ ខណៈល្អ យាមល្អ (ទានដែលបុគ្គលបូជា) ដល់ព្រហ្មចារីបុគ្គលទាំងឡាយ(ក្នុងពេលនោះ) ឈ្មោះថា ជាគ្រឿងបូជាល្អ ។

បឧក្ខិណំ កាយកម្មំ វាចាកម្មំ បឧក្ខិណំ

បឧក្ខិណំ មនោកម្មំ បណិធី តេ បឧក្ខិណា ។

(ក្នុងថ្ងៃនោះ)កាយកម្មឈ្មោះថា នាំឱ្យមានសេចក្ដីចម្រើន វចីកម្មក៏ឈ្មោះថា នាំឱ្យមានសេចក្ដីចម្រើន មនោកម្មក៏ឈ្មោះថា នាំឱ្យមានសេចក្ដីចម្រើន សេចក្ដីប្រាថ្នារបស់អ្នកទាំងនោះ ក៏ឈ្មោះថា នាំឱ្យមានសេចក្ដីចម្រើន ។

បឧក្ខិណានិ កត្វាន លភន្តុត្តេ បឧក្ខិណេ ។

បុគ្គលដែលបានធ្វើនូវកាយកម្ម វចីកម្ម មនោកម្មគួរដល់សេចក្ដីចម្រើនហើយ រមែងបាននូវប្រយោជន៍ដ៏ចម្រើនទាំងឡាយ ។

នៅក្នុង**មង្គល**សូត្រនេះ ព្រះអង្គបានសម្ដែងមានទាំងអស់ ១០ ព្រះគាថា ។ ក្នុងមួយគាថា មាន ៣ ក៏មាន ៤ ក៏មាន ៥ ក៏មាន ។ ញែកជាមាតិកា មានទាំងអស់ ៣៨ ប្រការ ដែលខាង

ដើម ព្រះអង្គទ្រង់ត្រាស់សម្តែងថា **អាសេវនា ច ពាលានំ** មិនឱ្យសេពគប់បុគ្គលពាល រហូតដល់ទាងចុងថា **ឱមំ** ធ្វើចិត្តឱ្យឃ្លាតចាកអំពីកិលេស ដែលហៅថា **ចិត្តក្សេមក្ខន្ត** ។

សរុបមក បើបុគ្គលណាប្រាថ្នានូវសិរីសួស្តី សុភមង្គលភាពសុខដុមរមនាដល់ខ្លួនដល់ក្រុមគ្រួសារជាដើមនោះត្រូវព្យាយាមបដិបត្តិទៅតាមមង្គលទាំង ៣៨ ប្រការនេះចុះ, ឬថា ត្រូវប្រព្រឹត្តឱ្យល្អទៅតាមផ្លូវកាយ វាចា ចិត្ត ឱ្យបានជានិច្ចចុះ នុ៎ះសិរីសួស្តីសុភមង្គល សេចក្តីសុខចម្រើន នឹងកើតមានដល់បុគ្គលនោះឯង ។

សៀវភៅ **មង្គលកថា** ដែលនិយាយអំពីមង្គលទាំង ៣៨ ប្រការនេះ ខ្ញុំព្រះករុណាសង្ឃឹមថា នឹងបានជួយតម្រែតម្រង់មាគ៌ាជីវិតនៃពុទ្ធបរិស័ទគ្រប់វ័យ គ្រប់ស្រទាប់វណ្ណៈទាំងអស់ ឱ្យដើរឈានទៅរកសេចក្តីសុខ និងការកើនចម្រើននៃជីវិតទាំងនៅក្នុងបច្ចុប្បន្ន ទាំងក្នុងបរលោកនាយ រហូតដល់អស់នូវអាសវៈកិលេស ។

ម្យ៉ាងទៀត សៀវភៅនេះ បើសិនជាមានខុសត្រង់អក្ខរៈព្យញ្ជនៈកាសាបាលីសេចក្តីអធិប្បាយត្រង់ចំណុចណាមួយនោះ

សូមមេត្តាខន្តី អភ័យទោសផង ។

ដោយអំណាចមហាកុសលចេតនា ដែលខ្ញុំមានចិត្តជ្រះថ្លាក្នុងព្រះសទ្ធម្មរបស់ព្រះអង្គ ខិតខំកសាងសន្សំព្យាយាមធ្វើសៀវ-ភៅនេះ សូមបានជាឧបនិស្សយដ៏ល្អបានពាល់ត្រូវនូវព្រះនិព្វានក្នុងពេលដ៏ខ្លីខាងមុខនេះផងចុះ តែបើមិនទាន់បានសម្រេចទេ សូមកើតជាតិណា ១ក៏ដោយ សូមកុំឱ្យស្គាល់ពាក្យថាអត់ ពាក្យថាគ្មាន ពាក្យថាក្រ ពាក្យថាលំបាក និងសូមឱ្យមានតែសិរីសួស្ដី មិនមានសេចក្ដីប្រមាទក្នុងជីវិត និងសូមឱ្យខ្ញុំមានបញ្ញាមោះមុតឆាប់ចាក់ធ្លុះនូវអរិយសច្ចធម៌ បានដល់នូវអមតដ្ឋាន **ក្នុងសាសនានៃព្រះសិរីអារ្យមេត្រីយ៍** កុំបីអាក់ខានឡើយ,ម្យ៉ាងទៀត សូមឧទ្ទិសបុណ្យកុសលនេះ ជូនដល់បុព្វការីជនទាំងឡាយ ដែលបានបែកធ្លាយរាងកាយទៅ និងពួកសត្វទាំងឡាយផង សូមបាននូវសេចក្ដីសុខ ចូរជាអ្នកបានសោយរសនៃព្រះសទ្ធម្មរបស់ព្រះមានព្រះភាគចុះ មួយអន្ទើយដោយព្រះកុរុណាគុណម្ចាស់គ្រប់ព្រះអង្គ និងញាតិញោមពុទ្ធបរិស័ទ ។

សូមអនុមោទនា !!!

ថ្ងៃ៧កើត ខែពិសាខ ឆ្នាំម្សាញ់ បញ្ចស័ក ព.ស. ២៥៥៧

ភិក្ខុ សីលឃ្ឫ ឆែ សុផល្លី

បញ្ជីមាតិកា

មាតិកា	មង្គលកថា	ទំព័រ
អារម្ភកថា	... .ក	
មង្គលទី ៣៦ ចិត្តមិនសោក	... ...	១
ចិត្តមិនសោកមានន័យដូចម្តេច ?	... ...	១
ហេតុនាំឱ្យកើតសេចក្តីសោក	... ...	៣
វិសាខាសូត្រ	... ...	៧
បិយជាតិកសូត្រ	... ...	២៣
ឧទ្ទិសូត្រ	... ...	៤៦
មតភោទនជាតក	... ...	៥៣
រឿងព្រះកុណ្ឌលកេសីថេរី	... ...	៥៩
រឿងអភ័យរាជកុមារ	... ...	៧៧
រឿងកុដុម្ពីមួយរូប	... ...	៨១
រឿងព្រាហ្មណ៍ម្នាក់	... ...	៨៥
រឿងនាងវិសាខឧបាសិកា	... ...	៩០
រឿងស្តេចលិច្ឆវី	... ...	៩៣
រឿងអនិត្ថិគន្ធកុមារ	... ...	៩៦
រឿងនាងកិសាគោតមី	... ...	១០៣

មាតិកា **ទំព័រ**

រឿងនាងបជាចារ	១១២
បុរាណលោកសរុបជា-ឲជាស់ត្រឿន	១២៨
វិធីកម្ចាត់បង់សេចក្តីសោក	១២៨
សត្ថិសូត្រ	១៣០
សង្ហាមជិសូត្រ	១៤៧
ឯកបុគ្គសូត្រ	១៥៨
ឧបាសកសូត្រ	១៦៧
រឿងព្រះបាទយតរាជ	១៧៥
រឿងអញ្ញត្រព្រាហ្មណ៍	១៧៨
កាមសូត្រ	១៨៨
ទេវទហសូត្រ	១៨៨
ឧរុគជាតក	១៨៨
មរណស្សតិ	២១៥
វិធីចំរើនមរណស្សតិ	២១៧
ការរលឹកដោយអាការៈ ៨	២១៩
អធិប្បាយអាការៈទី ១	២២០
អធិប្បាយអាការៈទី ២	២២៤

មាតិកា **ទំព័រ**

អធិប្បាយអាការៈទី ៣	២២៦
យសមហាគ្គតោ	១៨៨
បុញ្ញមហាគ្គតោ	២២៨
ថាមមហាគ្គតោ	២២៩
ឥទ្ធិមហាគ្គតោ	២២៩
បញ្ញាមហាគ្គតោ	២៣០
បច្ចេកពុទ្ធតោ	២៣១
សម្មាសម្ពុទ្ធតោ	២៣២
អធិប្បាយអាការៈទី ៤	២៣៤
អធិប្បាយអាការៈទី ៥	២៣៦
អធិប្បាយអាការៈទី ៦	២៣៨
និគមគាថា	២៤២
អធិប្បាយអាការៈទី ៨	២៤៥
មរណស្សតិជ្ឌាន	២៤៦
អានិសង្សនៃការចំរើនមរណស្សតិ	២៤៨
ហេតុនាំឲ្យកើតសេចក្ដីស្រឡាញ់	២៤៩
កលហវិវាទសូត្រ	២៥៤

មាតិកា **ទំព័រ**

សាកេតជាតក	២៧២
ឃេមសូត្រ	២៧៤
ស្រឡាញ់ខ្លួនឯងជាងបុគ្គលដទៃ	២៧៨
មល្លិកាសូត្រ	២៨០
បរមត្ថទីបនី អដ្ឋកថាធម្មបទ ៤៤ ពន្យល់	២៨៥
ឧត្តិបុត្តសមសូត្រ	២៩២
ចំណុចបដិបត្តិ	២៩៧
ចំណុចជាស់គ្រឿន	២៩៨
គម្ពីរជាឧបករណ៍ក្នុងការរៀបរៀងសៀវភៅនេះ	២៩៩

ឆ្នាំ១៥ដ

ពួកជនណា ៗ ទោះបីក្មេងក្តី ចាស់ក្តី ពាលក្តី បណ្ឌិតក្តី អ្នកមានក្តី អ្នកក្រក្តី ជនទាំងអស់នោះ តែងមានសេចក្តីស្លាប់នៅពីខាងមុខ ។ ឆ្នាំងដីដែលស្ងួនឆ្នាំងធ្វើហើយ ទោះបីតូចក្តី ធំក្តី ឆ្ងិនក្តី ឆៅក្តី ឆ្នាំងទាំងអស់នោះ មានកិរិយាបែកធ្លាយជាទីបំផុតយ៉ាងណា ជីវិតរបស់សត្វទាំងឡាយ ក៏យ៉ាងនោះដែរ ។

ព្រះបរមសាស្តា ទ្រង់មានព្រះបន្ទូលដូច្នេះតទៅទៀតថា វ័យរបស់តថាគតចាស់ហើយ ជីវិតរបស់តថាគត មានប្រមាណតិចតថាគតនឹងលះបង់អ្នកទាំងឡាយហើយទៅ ឯទីពឹងរបស់ខ្លួនតថាគតបានធ្វើទុកហើយ ។

ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរកុំប្រមាទត្រូវមានស្មារតីមានសីលល្អ មានតម្រិះតម្កល់ស្មើល្អ ចូររក្សាចិត្តរបស់ខ្លួនឱ្យរឿយ ៗចុះ ។ ភិក្ខុណាមិនប្រមាទហើយនៅក្នុងធម្មវិន័យនេះ ភិក្ខុនោះ នឹងលះបង់ជាតិសង្សារ ហើយធ្វើនូវព្រះនិព្វាន ជាទីបំផុតនៃទុក្ខបានមិនខាន ។ (ព្រះឱវាទក្នុងមហាបរិនិព្វានសូត្រ)

មង្គលទី ៣៦ ចិត្តមិនសោក

សត្វទាំងឡាយ មានសត្វរាជសីហ៍ជាដើម បើបានជាប់អន្ទាក់នាយព្រានហើយ ក៏រមែងអស់កម្លាំង និងអស់អំណាចហើយទទួលបានតែសេចក្តីទុក្ខវេទនាអស់កាលដ៏យូរយ៉ាងណា

មនុស្សយើងគ្រប់គ្នា សូម្បីមានវិទ្ធិអំណាចច្រើនយ៉ាងណាក៏ដោយ ប្រសិនបើជាប់អន្ទាក់ស្នេហ៍ហើយ ក៏រមែងអស់វិទ្ធិអស់អំណាច មានតែសេចក្តីសោកសៅក្រៀមក្រំ ពោរពេញទៅដោយសេចក្តីទុក្ខអស់កាលជាយូរអង្វែង ក៏យ៉ាងនោះដែរ ។

ចិត្តមិនសោកមានន័យដូចម្តេច?

*ពាក្យថា **សោក** មកពីភាសាបាលីថា **សោកៈ** ប្រែថា **ស្ងួត** ។*

*ចិត្តសោក សំដៅដល់ **សភាពចិត្តដែលក្រៀមក្រំ អស់សង្ឃឹម ស្រងេះស្រងោច សេចក្តីសោកសៅ សេចក្តីរីងស្ងួតក្នុងចិត្ត ខូចចិត្ត ឆ្លួតចិត្តរបស់សត្វ ដែលប្រកបដោយសេចក្តីថាវិនាសណាមួយ (ឬ)អ្នកដែលសេចក្តីទុក្ខធម៌ណាមួយ** ពាល់*

ត្រូវហើយ ប្រៀបដូចជាដីស្ងួត ស្ងឹកឈើស្ងួតអស់ សម្រស់ ព្រោះមិនបាន សមតាមសេចក្ដីប្រាថ្នាធ្វើឱ្យមានអាការស្ងិតស្រពោន មានក្នុងរឿងស្នេហាជាដើម ។

ពាក្យថា **ស្នេហា** ប្រែថា **សេចក្ដីស្រឡាញ់**, មកអំពីភាសាបាលីថា **សិនេហៈ** ប្រែថា **ជ័រស្អិត**, ដែលធ្វើឱ្យចិត្តជាប់ជំពាក់ស្រាយពុំរួច ដោះមិនរួច ជាប់ផុង រហូតឆ្ងួត លីលាដោយសារស្នេហ៍ បែកចិត្ត ។

កាលស្រឡាញ់មនុស្ស សត្ត ឬវត្ថុផ្សេង ៗនៅពេលដែលវត្ថុទាំងអស់នោះវិនាសទៅ ក៏រមែងធ្វើឱ្យកើតមានសេចក្ដីសោកទាំងអស់ ដោយច្រើនគឺរឿងស្រឡាញ់របស់ប្រុសកម្លោះស្រីក្រមុំហ្នឹងឯង ។

ដូច្នេះ ពាក្យថា **ចិត្តមិនសោក** បានដល់ ចិត្តរបស់ព្រះខីណាស្រពប៉ុណ្ណោះ ឈ្មោះថា **អសោកៈ** មិនសោកសៅ ។ មែនពិត ចិត្តរបស់ព្រះខីណាស្រពនោះ ឈ្មោះថា **អសោកៈ** ព្រោះមិនមានការសោកសៅ ដែលលោក ពោលដោយន័យជាដើមថា ការសោកសៅ ភាពជាអ្នកសោកសៅ ការរីងរៃ ការរីង

ស្ងួតខាងក្នុងភាពនៃចិត្តដែលត្រូវសេចក្តីសោកសៅ ដុតពោល ។ អាចារ្យពួកខ្លះ ពោលអំពីព្រះនិព្វាន ពាក្យនោះភ្ជាប់សេចក្តីមិនបានជាមួយបទដើម ។ ចិត្តរបស់ព្រះខីណាស្រពប៉ុណ្ណោះឈ្មោះថា **អសោកៈ** ។

ហេតុនាំឲ្យកើតសេចក្តីសោក

សេចក្តីសោកកើតមកអំពីវត្ថុដែលជាទីស្រឡាញ់ ជាទីគាប់ចិត្តជាទីហួងហែង នៅពេលដែលវត្ថុទាំងអស់នោះមានការវិនាសព្រាត់ប្រាសទៅដោយប្រការណាមួយ ។ ពាក្យថា វត្ថុនេះ មានសភាពព្រាត់ប្រាសដោយពិត គឺភាវៈផ្សេង ១ ភាវៈព្រាត់ប្រាសភាវៈទៅជាយ៉ាងដទៃ កាលមាន កាលកាន់ព្រម កាលកើតមាន ។ សមដូចពាក្យនេះដែលព្រះមានបុណ្យទ្រង់ត្រាស់ហើយថា ម្នាលអានន្ទ មិនគួរទេ អ្នកកុំសោក កុំខ្សឹកខ្សួលឡើយ ម្នាលអានន្ទ ក្រែងតថាគតបានពោលហើយក្នុងកាលមុន នូវពាក្យនេះថា ភាវៈផ្សេង ១ ភាវៈព្រាត់ប្រាសភាវៈជាយ៉ាងដទៃចាកសត្វនិងសង្ខារទាំងពួង ជាទីស្រឡាញ់ពេញចិត្តដូច្នេះឬ ម្នាលអានន្ទ បុគ្គលគប្បី

ជានន្ទូវហេតុនោះ ក្នុងសត្វនិងសង្ខារទាំងនោះ អំពីទីណាថា វត្ថុណាកើតហើយ ប្រាកដហើយ តាក់តែងហើយ មានកិរិយាវិនាសជាធម្មតាឱ្យ៉ាំ វត្ថុនោះ កុំវិនាសឡើយដំណើរនោះមិនសមហេតុទេ ។ ព្រោះសេចក្តីប្រែប្រួលជាយ៉ាងដទៃរបស់ខន្ធធាតុ អាយតនៈដែលមានក្នុងកាលមុន ១ ខន្ធ ធាតុ អាយតនៈ ដែលមានក្នុងកាលខាងក្រោយ ១ ក៏រមែងប្រព្រឹត្តទៅ(ដូចគ្នា) ហេតុនោះ (ទ្រង់ត្រាស់ថា) វត្ថុនេះមានសភាពព្រាត់ប្រាសដោយពិត ។

ព្រោះហេតុនោះ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ៖

សោចន្តិ ជនា មមាយិតេន ហិ សន្តិ និច្ចា បរិគ្គហា

វិនាភាវសន្តមេវ ធីរា ន ភាយន្តិ ន សោចន្តិ ។

ពួកជនរមែងសោកស្តាយ ចំពោះវត្ថុដែលហួងហែង ការហួងហែងទាំងឡាយ ពុំមែនជាការទៀងទាត់ទេ វត្ថុនេះមានសភាពព្រាត់ប្រាសដោយពិត បុគ្គលឃើញដូច្នេះហើយ មិនគួរនៅគ្រប់គ្រងផ្ទះឡើយ ។

មរណេនបិ ន ប្បហីយតិ យំ បុរិសោ មមយិតន្តិ មញ្ញតិ

ឯតម្ឫ ១ ១ ១

អសស្សតា ភោគិនោ កាមកាមិ
តស្មា ន សោចាមហំ សោកកាលេ
ឱ្យេតិ អាបូរតិ វេតិ ចន្ទោ
អត្ថំ គមេត្វាន បលេតិ សុរិយោ
វិនិត្វា មយា សត្ថុក លោកធម្មា
តស្មា ន សោចាមហំ សោកកាលេតិ ។
មរណេនបិ តំ បហីយតិ ។

ភោគ:ទាំងឡាយ រមែងលះបង់នូវសត្វក្នុងកាលមុន ក៏មាន សត្វលះបង់ភោគ:ទាំងនោះ មុនជាងទៅទៀត ក៏មាន នៃអ្នកប្រាថ្នាកាម ពួកជនអ្នកមានភោគ: មិនទៀងទេ ព្រោះហេតុនោះ ទើបខ្ញុំមិនសោកស្តាយក្នុងកាលដែលគួរសោកស្តាយព្រះចន្ទ្រះឡើងពេញវង់លិចទៅ ព្រះអាទិត្យ្រះឡើង ហើយអស្តង្គតទៅ នៃអ្នកជាសត្រូវ លោកធម៏ទាំងឡាយ ខ្ញុំដឹងច្បាស់ហើយ ព្រោះហេតុនោះ ខ្ញុំទើបមិនសោកស្តាយ ក្នុងកាលដែលគួរសោកស្តាយ ។

ហេតុនោះ(ទ្រង់ត្រាស់ថា) ១ន្ធបញ្ចកៈរមែងសាបសូន្យ ដោយមរណៈ ។

សរុបសេចក្តីមកប៉ុណ្ណោះ សបញ្ជាក់ឱ្យឃើញថា វត្ថុណា ដែលមានការកើតឡើង វត្ថុទាំងអស់នោះ សុទ្ធតែមានការបែក ធ្លាយទៅវិញជាធម្មតា បុគ្គលដែលជាបណ្ឌិត បានឃើញសេចក្តី នេះ មិនសោសៅឡើយ, តែសម្រាប់បុគ្គលល្ងង់ខ្លៅមិនចេះដឹង នៅក្នុងរឿងទាំងអស់នេះ រមែងកន្ទក់កន្ទេញ មិនសុខចិត្តសោក ស្តាយចំពោះរបស់ទាំងនោះ ព្រោះហេតុនោះ ដើម្បីកម្ចាត់បង់នូវ ហេតុនាំឱ្យកើតសេចក្តីសោកនោះ ត្រូវតែចូលទៅរកបណ្ឌិត សប្បុរស មានព្រះសម្មាសម្ពុទ្ធជាដើម ។

១ិសាខាសូត្រ

នៅក្នុងបិដកលេខ ៥២, ទំព័រ ៣៤៧ ព្រះសម្មាសម្ពុទ្ធជា ម្ចាស់ទ្រង់ត្រាស់អំពី[**ការស្រឡាញ់មានប៉ុនណាទុក្ខមានប៉ុណ្ណោះ**] មានសេចក្តីថា ៖

ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះ

ភាគទ្រង់គង់លើប្រាសាទរបស់មិគារមាតាក្នុងបុព្វារាម ជិតក្រុងសាវត្ថី ។ សម័យនោះឯង ចៅស្រីជាទីស្រឡាញ់ពេញចិត្តរបស់នាងវិសាខាមិគារមាតាធ្វើមរណភាព ។ គ្រានោះ វិសាខាមិគារ-មាតា មានសម្ពត់សើម សក់សើម ចូលទៅគាល់ព្រះមានព្រះភាគទាំងថ្ងៃត្រង់ លុះចូលទៅដល់ក្រាបថ្វាយបង្គំព្រះមានព្រះភាគហើយអង្គុយក្នុងទីសមគួរ ។ លុះនាងវិសាខាមិគារមាតា អង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថាម្នាលវិសាខា ចុះនាងមកពីណា មានសម្ពត់សើម សក់សើម ចូលមកក្នុងទីនេះទាំងថ្ងៃត្រង់ ។ បពិត្រព្រះអង្គដ៏ចម្រើន ចៅស្រីជាទីស្រឡាញ់ពេញចិត្ត របស់ខ្ញុំព្រះអង្គធ្វើមរណភាព ព្រោះហេតុនោះ បានជាខ្ញុំព្រះអង្គមានសម្ពត់សើម សក់សើម ចូលមកក្នុងទីនេះទាំងថ្ងៃត្រង់ ។

(**ព្រះអង្គ**). ម្នាលវិសាខា មនុស្សក្នុងក្រុងសាវត្ថី មានចំនួនប៉ុន្មាន នាងចង់បានកូននឹងចៅប៉ុណ្ណោះឬ ។

(**វិសាខា**). បពិត្រព្រះអង្គដ៏ចម្រើន មនុស្សក្នុងក្រុងសាវត្ថីមានចំនួនប៉ុន្មានខ្ញុំព្រះអង្គចង់បានកូននឹងចៅប៉ុណ្ណោះ ។

៣. ម្នាលវិសាខា ចុះមនុស្សទាំងឡាយក្នុងក្រុងសាវត្ថី

ជាច្រើន តែងធ្វើមរណភាពរាល់ ១ថ្ងៃប៉ុន្មាននាក់ ។

វ. បពិត្រព្រះអង្គដ៏ចម្រើន មនុស្សទាំងឡាយក្នុងក្រុងសាវត្ថីជាច្រើន តែងធ្វើមរណភាពរាល់ ១ថ្ងៃ ១០ នាក់ខ្លះ បពិត្រព្រះអង្គដ៏ចម្រើន មនុស្សទាំងឡាយក្នុងក្រុងសាវត្ថីជាច្រើន តែងធ្វើមរណភាពរាល់ ១ថ្ងៃ ៩ នាក់ខ្លះ បពិត្រព្រះអង្គដ៏ចម្រើន មនុស្សទាំងឡាយក្នុងក្រុងសាវត្ថីជាច្រើន តែងធ្វើមរណភាពរាល់ ១ថ្ងៃ ៨ នាក់ខ្លះ បពិត្រព្រះអង្គដ៏ចម្រើន មនុស្សទាំងឡាយក្នុងក្រុងសាវត្ថីជាច្រើនតែងធ្វើមរណភាពរាល់ ១ថ្ងៃ ៧ នាក់ខ្លះ បពិត្រព្រះអង្គដ៏ចម្រើន មនុស្សទាំយឡាយក្នុងក្រុងសាវត្ថីជាច្រើន តែងធ្វើមរណ-ភាពរាល់ ១ថ្ងៃ ៦ នាក់ខ្លះ បពិត្រព្រះអង្គដ៏ចម្រើន មនុស្សទាំងឡាយក្នុងក្រុងសាវត្ថីជាច្រើន តែងធ្វើមរណភាពរាល់ ១ថ្ងៃ ៥ នាក់ខ្លះ បពិត្រព្រះអង្គដ៏ចម្រើន មនុស្សទាំងឡាយក្នុងក្រុងសាវត្ថីជាច្រើន តែងធ្វើមរណភាពរាល់ ១ថ្ងៃ ៤ នាក់ខ្លះ បពិត្រព្រះអង្គដ៏ចម្រើន មនុស្សទាំងឡាយក្នុងក្រុងសាវត្ថីជាច្រើន តែងធ្វើមរណភាពរាល់ ១ថ្ងៃ ៣ នាក់ខ្លះ បពិត្រព្រះអង្គដ៏ចម្រើន មនុស្សទាំងឡាយ ក្នុងក្រុងសាវត្ថីជាច្រើន តែងធ្វើមរណភាពរាល់ ១ថ្ងៃ ២

នាក់ខ្លះ បពិត្រព្រះអង្គដ៏ចម្រើន មនុស្សទាំងឡាយក្នុងក្រុងសាវត្ថីជាច្រើន តែងធ្វើមរណភាពរាល់ ១ថ្ងៃ ១ នាក់ខ្លះ បពិត្រព្រះអង្គដ៏ចម្រើន ពួកមនុស្សទាំងឡាយក្នុងក្រុងសាវត្ថីជាច្រើន ចេះតែធ្វើមរណភាពមិនដែលស្ងាត់ទេ ។

ព.ម្នាលវិសាខា នាងសម្គាល់ហេតុនោះដូចម្តេច ចុះនាងជាអ្នកមានសម្ពត់សើម សក់សើមក្នុងកាលម្តង ១ទេឬ ។

វ. បពិត្រព្រះអង្គដ៏ចម្រើន ល្មមត្រឹមតែកូនទាំងចៅច្រើនប៉ុណ្ណោះ ។

ព. **ម្នាលវិសាខា** ៖

- **បុគ្គលណា** មានវត្ថុជាទីស្រឡាញ់ ១០០ បុគ្គលនោះ មានសេចក្តីទុក្ខ១០០, (នៅពេលដែលវត្ថុនោះវិនាសទៅ)

- **បុគ្គលណា** មានវត្ថុជាទីស្រឡាញ់ ៩០ បុគ្គលនោះ មានសេចក្តីទុក្ខ ៩០, (នៅពេលដែលវត្ថុនោះវិនាសទៅ)

- **បុគ្គលណា** មានវត្ថុជាទីស្រឡាញ់ ៨០ បុគ្គលនោះ មានសេចក្តីទុក្ខ ៨០, (នៅពេលដែលវត្ថុនោះវិនាសទៅ)

- **បុគ្គលណា** មានវត្ថុជាទីស្រឡាញ់ ៧០ បុគ្គលនោះ

មានសេចក្ដីទុក្ខ ៧០, (នៅពេលដែលវត្ថុនោះវិនាសទៅ)

- **បុគ្គលណា** មានវត្ថុជាទីស្រឡាញ់ ៦០ បុគ្គលនោះ មានសេចក្ដីទុក្ខ ៦០, (នៅពេលដែលវត្ថុនោះវិនាសទៅ)

- **បុគ្គលណា** មានវត្ថុជាទីស្រឡាញ់ ៥០ បុគ្គលនោះ មានសេចក្ដីទុក្ខ ៥០, (នៅពេលដែលវត្ថុនោះវិនាសទៅ)

- **បុគ្គលណា** មានវត្ថុជាទីស្រឡាញ់ ៤០ បុគ្គលនោះ មានសេចក្ដីទុក្ខ ៤០, (នៅពេលដែលវត្ថុនោះវិនាសទៅ)

- **បុគ្គលណា** មានវត្ថុជាទីស្រឡាញ់ ៣០ បុគ្គលនោះ មានសេចក្ដីទុក្ខ ៣០, (នៅពេលដែលវត្ថុនោះវិនាសទៅ)

- **បុគ្គលណា** មានវត្ថុជាទីស្រឡាញ់ ២០ បុគ្គលនោះ មានសេចក្ដីទុក្ខ ២០, (នៅពេលដែលវត្ថុនោះវិនាសទៅ)

- **បុគ្គលណា** មានវត្ថុជាទីស្រឡាញ់ ១០ បុគ្គលនោះ មានសេចក្ដីទុក្ខ ១០, (នៅពេលដែលវត្ថុនោះវិនាសទៅ)

- **បុគ្គលណា** មានវត្ថុជាទីស្រឡាញ់ ៩ បុគ្គលនោះ មានសេចក្ដីទុក្ខ ៩, (នៅពេលដែលវត្ថុនោះវិនាសទៅ)

- **បុគ្គលណា** មានវត្ថុជាទីស្រឡាញ់ ៨ បុគ្គលនោះ

មានសេចក្ដីទុក្ខ ៨, (នៅពេលដែលវត្ថុនោះវិនាសទៅ)

- **បុគ្គលណា** មានវត្ថុជាទីស្រឡាញ់ ៧ បុគ្គលនោះ មានសេចក្ដីទុក្ខ ៧, (នៅពេលដែលវត្ថុនោះវិនាសទៅ)

- **បុគ្គលណា** មានវត្ថុជាទីស្រឡាញ់ ៦ បុគ្គលនោះ មានសេចក្ដីទុក្ខ ៦, (នៅពេលដែលវត្ថុនោះវិនាសទៅ)

- **បុគ្គលណា** មានវត្ថុជាទីស្រឡាញ់ ៥ បុគ្គលនោះ មានសេចក្ដីទុក្ខ ៥, (នៅពេលដែលវត្ថុនោះវិនាសទៅ)

- **បុគ្គលណា** មានវត្ថុជាទីស្រឡាញ់ ៤ បុគ្គលនោះ មានសេចក្ដីទុក្ខ ៤, (នៅពេលដែលវត្ថុនោះវិនាសទៅ)

- **បុគ្គលណា** មានវត្ថុជាទីស្រឡាញ់ ៣ បុគ្គលនោះ មានសេចក្ដីទុក្ខ ៣, (នៅពេលដែលវត្ថុនោះវិនាសទៅ)

- **បុគ្គលណា** មានវត្ថុជាទីស្រឡាញ់ ២ បុគ្គលនោះ មានសេចក្ដីទុក្ខ ២, (នៅពេលដែលវត្ថុនោះវិនាសទៅ)

- **បុគ្គលណា** មានវត្ថុជាទីស្រឡាញ់ ១ បុគ្គលនោះ មានសេចក្ដីទុក្ខ ១, (នៅពេលដែលវត្ថុនោះវិនាសទៅ)

- **បុគ្គលណា** មិនមានវត្ថុជាទីស្រឡាញ់ បុគ្គលនោះក៏

មិនមានសេចក្ដីទុក្ខសោះដែរ តថាគតទើបពោលថា បុគ្គលទាំងនោះ ជាអ្នកមិនមានសោក ជាបុគ្គលប្រាសចាកធូលីគឺកិលេស ជាអ្នកមិនមានសេចក្ដីចង្អៀតចង្អល់ ។

លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្ដីនុ៎ះហើយ ទើបទ្រង់បន្លឺឧទានៃ ក្នុងវេលានោះថា ៖

យេកេចិ សោកា បរិទេវិតា វា
ទុក្ខា ច លោកស្មឺ អនេករូបា
បិយំ បដិច្ច ភវន្តិ ឯតេ
បិយេ អសន្តេ ន ភវន្តិ ឯតេ ។
តស្មា ហិ តេ សុខិនោ វីតសោកា
យេសំ បិយំ នត្ថិ កុហិញ្ចិ លោកេ
តស្មា អសោកំ វិរជំ បត្ថយានោ
បិយំ ន កយិរាថ កុហិញ្ចិ លោកេតិ ។

សេចក្ដីសោកក្ដី សេចក្ដីខ្សឹកខ្សួលក្ដី ណាមួយ ឬសេចក្ដីទុក្ខជាច្រើនយ៉ាងក្នុងលោក ធម៌ទាំងនុ៎ះ រមែងកើតឡើងព្រោះ

អាស្រ័យសត្វនឹងសង្ខារជាទីស្រឡាញ់ កាលបើមិនមានសត្វនឹងសង្ខារជាទីស្រឡាញ់ ធម៌ទាំងនុ៎ះ ក៏រមែងមិនមាន ។ ព្រោះហេតុនោះឯង បុគ្គលណា មិនមានសត្វនឹងសង្ខារជាទីស្រឡាញ់ ក្នុងលោកណាមួយទេ បុគ្គលនោះទើបមានសេចក្តីសុខ ប្រាសចាកសេចក្តីសោក ព្រោះថា បុគ្គលប្រាថ្នាសេចក្តីមិនសោក នឹងការប្រាសចាកធូលីគឺកិលេស មិនគប្បីធ្វើសត្វនឹងសង្ខារឱ្យជាទីស្រឡាញ់ ក្នុងលោកណាមួយឡើយ ។

អដ្ឋកថា

បទថា វិសាខាយ មិគារមាតុយា នត្តា ការណកតា ហោតិ បានដល់ ចៅស្រីអ្នកជាធីតារបស់បុត្រនៃមហាឧបាសិកាឈ្មោះថា វិសាខា ដល់កម្ម ។

បានញ្ញថា ក្មេងស្រីនោះសម្បូរណ៍ដោយវត្ត ជ្រះថ្លាក្រៃលែងក្នុងព្រះសាសនា ជាអ្នកមិនប្រមាទ បានធ្វើការខ្ជាប់ខ្ជួយដែលខ្លួននឹងគប្បីធ្វើ ដល់ភិក្ខុនិងភិក្ខុនីទាំងឡាយ អ្នកចូលទៅកាន់ស្រុករបស់ឧបាសិកា ទាំងវេលាមុនអាហារ និងក្រោយអាហារ ។ បដិបត្តិបណ្តាយតាមចិត្តរបស់យាយខ្លួន ។ ដោយ

ហេតុនោះ មហាឧបាសិកាឈ្មោះថា វិសាខា កាលចេញចាកផ្ទះ ទៅខាងក្រៅ បានប្រគល់នាទីទាំងអស់ដល់ក្មេងស្រីនោះឯងហើយ ទើបទៅ និងលោកក៏មានរូបរាងគួរសរសើរគួរជ្រះថ្លា ដូចនោះ លោក ទើបជាទីស្រឡាញ់ដែលពេញចិត្តដោយពិសេស របស់ វិសាខាមហាឧបាសិកា ។ លោកត្រូវរោគគ្របសង្កត់ ទើបដល់ កម្ម ។ ដោយហេតុនោះ លោកទើបពោលថា ក៏សម័យនោះឯង ចៅរបស់នាងវិសាខាមិគារមាតា អ្នកជាទីស្រឡាញ់ដែលពេញចិត្ត បានដល់ ដល់កម្ម ។

លំដាប់នោះ មហាឧបាសិកា កាលមិនអាចនឹងអត់ធ្មត់ សេចក្តីសោក ព្រោះការស្លាប់របស់ចៅបាន ទើបជាទុក្ខខ្ជូចចិត្ត ឱ្យអ្នកយកសាកសពទៅកប្ជាទុក ហើយចូលទៅគាល់ព្រះ មាន ព្រះភាគ ដោយគិតថា ដូចម្តេចហ្ន៎ ក្នុងវេលាយើងទៅគាល់ព្រះ សាស្តានឹងគប្ជីបានសេចក្តីត្រេកអរនៃចិត្ត ។ ដោយហេតុនោះ លោកទើបពោលថា **អថ ខោ** **វិសាខាមិគារមាតា** ដូច្នេះជា ដើម ។

បណ្តាបទទាំងនោះ បទថា ឧារាឧវស្ស ប្រែថា ក្នុងពេលថ្ងៃអធិប្បាយថា ក្នុងវេលាទៀង ។

ព្រះមានព្រះភាគ កាលទ្រង់ជ្រាបថា នាងវិសាខាត្រេក-អរក្រៃលែងក្នុងវត្ត: ដើម្បីនឹងទ្រង់ធ្វើសេចក្តីសោកសៅរបស់លោកឱ្យស្រាលខ្លះចុះដោយឧបាយ ទើបត្រាស់ពាក្យមានជាដើមថា ម្នាលវិសាខា លោកប្រាថ្នាឬ ។

បណ្តាបទទាំងនោះ បទថា យាវតិកា ប្រែថា មានប្រមាណប៉ុនណា ។ បានញ្ញថា ក្នុងកាលនោះ មនុស្ស ៧ កោដិ អាស្រ័យនៅក្នុងក្រុងសាវត្ថី ដែលព្រះមានព្រះភាគទ្រង់សំដៅត្រាស់សួរថា ម្នាលវិសាខា អ្នកក្នុងក្រុងសាវត្ថីដែលស្លាប់ទៅរាល់ថ្ងៃ ១ មួយថ្ងៃប៉ុនណា ។ នាងវិសាខាទើបទូលតបថា មួយថ្ងៃ ១០ នាក់ខ្លះព្រះអង្គ ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា តីណិកែជា តយោ ប្រែថា ៣ នាក់ ។ ម្យ៉ាងទៀត ចាលីក៏យ៉ាងនេះឯង ។ បទថា អវិវិត្តា ប្រែថា មិនដាក់ ។

លំដាប់នោះ ព្រះមានព្រះភាគកាលនឹងប្រកាសសេចក្តីប្រាថ្នារបស់ព្រះអង្គ ទើបត្រាស់ថា នាងជាអ្នកមិនមានសំពត់ សើម មិនមានសក់សើម គ្រាន់ដែរឬ ។ ព្រះអង្គទ្រង់សម្តែងថា កាលជាដូច្នោះ កាលនាងវិសាខាត្រូវសេចក្តីសោកសៅគ្របសង្កត់ រហូតដល់អស់កាលនាងគប្បីមាន សំពត់ សើម មានសក់សើម ដោយការចុះទឹក ដោយធិតត្រូវនឹងវត្ថុដែលមិនជាមង្គល របស់ បុត្រជាដើម ដែលស្លាប់ទៅមិនមែនឬ ?

ឧបាសិកាបានស្តាប់ដូចនោះហើយ ទើបកើតសេចក្តីសង្វេគ បដិសេធថា មិនជាយ៉ាងនោះព្រះអង្គ ដូច្នេះហើយ ទើបក្រាបទូលថា ចិត្តរបស់ខ្ញុំនត្រឡប់ចាកពីសេចក្តីក្តៅក្រហាយដល់វត្ថុដែលជាទីស្រឡាញ់ចំពោះព្រះសាស្តា ទើបក្រាបទូលថា លួមលះព្រះអង្គដោយពួកបុត្រនិងចៅដែលមានច្រើនដល់ត្រឹមនោះ សម្រាប់នាងខ្ញុំ ។ លំដាប់នោះព្រះមានព្រះភាគ កាលនឹងទ្រង់សម្តែងធម៌ដល់នាងថាដែលឈ្នះថា ទុក្ខនេះមានវត្ថុដែលគួរស្រឡាញ់ជាហេតុ វត្ថុដែលគួរស្រឡាញ់មានប្រមាណត្រឹមណា ទុក្ខក៏មានប្រមាណត្រឹមនោះ ព្រោះដូច្នោះ លោកអ្នកស្រឡាញ់សុខ ស្អប់ទុក្ខ

គប្បីឱ្យចិត្តកើតសេចក្ដីស្ងួតចាកពីវត្ថុដែលជាទីស្រឡាញ់ ដោយប្រការទាំងពួង ទើបត្រាស់ពាក្យមានជាដើមថា ម្នាលវិសាខា អ្នកពួកណាមានវត្ថុដទៃជាទីស្រឡាញ់ ១០០ អ្នកទាំងនោះក៏មានទុក្ខ ១០០ ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា សតំ ២ យានិ បានដល់ វត្ថុដែលជាទីស្រឡាញ់ ១០០ ។ អាចារ្យពួកខ្លះពោល សតំ ២ យំ ដូច្នេះក៏មាន ។ ក៏ក្នុងពាក្យនេះ រាប់តាំងពី ១ ដរាបដល់ ១០ ឈ្មោះថា មានការរាប់ជាប្រធាន ដូច្នោះ បាលីទើបពោលដោយន័យមានជាដើម អ្នកណាមានវត្ថុជាទីស្រឡាញ់ ១០ អ្នកនោះក៏មានទុក្ខ ១០ តែអាចារ្យពួកខ្លះពោលដោយន័យជាដើមថា អ្នកណាមានវត្ថុដែលជាទីស្រឡាញ់ ១០ អ្នកនោះក៏មានទុក្ខ ១០ ។ ពាក្យនោះមិនល្អ ។ ព្រោះហេតុនៃការរាប់តាំងពី ២០ រហូតដល់ ១០០ ឈ្មោះថា មានការរាប់ជាប្រធានដូចគ្នា ដូច្នោះ ព្រោះកាន់យកចំពោះវត្ថុដែលជាទីស្រឡាញ់ ដែលមានការរាប់ជាប្រធានសូម្បីក្នុងសេចក្ដីនោះ បាលីទើបមានដោយន័យមានជាដើមថា យេសំ ២ ១ ២ ១ ២ ១

បាលីរបស់អាចារ្យទាំងពួងថា ជនពួកណា មានវត្ថុដែលជាទីស្រឡាញ់មួយ ជនទាំងនោះក៏មានទុក្ខមួយ ដូច្នេះ តែបាលីថា ទុក្ខសច្ច ដូច្នេះមិនមាន ។ ក៏ក្នុងចំណែកនេះ ទេសនារបស់ព្រះមានព្រះភាគមានរសតែមួយ ពិតមែន ព្រោះដូច្នោះ គប្បីជ្រាបបាលីដែលមានន័យតាមដែលពោល ហើយនោះឯង ។

បទថា **ឯតមត្ថំ វិទិត្វា** សេចក្ដីថា ព្រះអង្គទ្រង់ជ្រាបដោយអាការទាំងពួង ដែលអត្ថនេះថា ទុក្ខផ្លូវចិត្តនិងទុក្ខផ្លូវកាយ មានសោកៈនិងបរិទេវៈជាដើម មានវត្ថុដែលគួរស្រឡាញ់ជាហេតុ រមែងប្រាកដក្នុងកាលមានវត្ថុដែលគួរស្រឡាញ់ រមែងមិនប្រាកដក្នុងកាលវត្ថុដែលគួរស្រឡាញ់មិនមាន ទើបទ្រង់ថ្លែងឧទាននេះ ដែលសម្ដែងសេចក្ដីនោះ ។

ពាក្យនៃឧទាននោះ មានអធិប្បាយដូចតទៅនេះ ធម៌ពួកណាមួយ មានលក្ខណៈធ្វើចិត្តរបស់ជនពាល អ្នកត្រូវសេចក្ដីខ្ជុះខ្ជាយនៃញាតិ ភោគៈ រោគ សីលនិងទិដ្ឋិត្រឹមត្រូវហើយ ស្រអាប់ឆេះនៅក្នុងខាងក្នុង ឱ្យក្ដៅក្រហាយក្ដី សេចក្ដីសោកសៅប្រភេទណាមួយ ផ្សេងដោយភាពខ្សោយ និងកណ្ដាលជាដើមក្ដី

ទុក្ខមានការបៀតបៀនកាយ របស់បុគ្គលដែលមានកាយដែលផ្ទោដ្ឋព្វារម្មណ៍ដែលមិនគួរប្រាថ្នាប៉ះខ្ទប់ហើយក្តីទោមនស្ស និងឧបាយាសជាដើម ដែលកាន់យកដោយ ภ សព្ទ ដែលជាវិកប្ប្ជបត្ត: ដែលមិនបានអធិប្ប្ជាយ ទុកដូច្នោះ ដែលមានរូបជាអនេក គឺមានយ៉ាងផ្សេង ១គ្នា ដោយសេចក្តីផ្សេងនៃនិស្ស្ជយ្ជក្តីរមែងប្រាកដ គឺរមែងកើតឡើងក្នុងសត្ត្ជលោកនេះ ។ សត្ត្ជទាំងនោះសូម្ជីទាំងអស់ រមែងអាស្រ័យ គឺ ពីងផ្ទែកសត្ត្ជនិងសង្ខារដែលជាទីស្រឡាញ់ គឺមានជាតិជាទីស្រឡាញ់ បានដល់ ធ្ជើឱ្ជីជាបច្ជ័យកើតឡើង គឺកើតឡើង ។ កាលវត្ថុដែលជាទីស្រឡាញ់តាមដែលពោលហើយនោះ គឺ កាលសត្ត្ជនិងសង្ខារដែលជាទីស្រឡាញ់មិនមាន បានដល់ លះឆន្ទ្ជរាគ: ដែលធ្ជើសេចក្តីជាទីស្រឡាញ់ សេចក្តីសោកសៅជាដើមទាំងនោះ ក៏រមែងមិនកើតក្នុងពេលខ្ជះ ។ សមពិតដូចពាក្ជ្ជដែលលោកពោលទុកថា សេចក្តីសោកសៅ រមែងកើតពីសត្ត្ជ និងសង្ខារដែលជាទីស្រឡាញ់ ។ ល ។ សេចក្តីសោកសៅ រមែងកើតពីអារម្មណ៍ដែលជាទីស្រឡាញ់ជាដើម ឬថា ៖

ការឈ្លោះ ការវិវាទ សេចក្តីរៀបរាប់ និងសេចក្តីសោកសៅ ដែលកើតពីសត្វនិងសង្ខារដែលជាទីស្រឡាញ់ រមែងមកព្រមជាមួយសេចក្តីកំណាញ់ ដូច្នេះជាដើម ។

ក៏ក្នុងទីនេះ លោកពោលអំពីលិង្គវិបល្លាសថា ឋានេ ទ្វីតា វា ទុក្ខា វា ។ មួយទៀត កាលគួរនឹងពោលថា ឋានេ ទ្វីតានិ វា ទុក្ខានិ វា ដូច្នេះ គប្បីជ្រាបថា លោកធ្វើការលាប់ រៃ ភ្ជាប់ចេញ ។ បទថា តស្មា ហិ តេ សុខិនោ វីតសោកា សេចក្តីថា ព្រោះហេតុដែលសេចក្តីសោកសៅជាដើម ដែលកើតពីសត្វ និងសង្ខារដែលជាទីស្រឡាញ់ រមែងមិនមានដល់ជនពួកណា ដូច្នោះ ជនទាំងនោះឯង ឈ្មោះថាមានសេចក្តីសុខ និងប្រាសចាកសេចក្តីសោកសៅ ។ ក៏អ្នកទាំងនោះគឺ អ្នកណាគឺជនអ្នកមិនមានសត្វ និងសង្ខារដែលជាទីស្រឡាញ់ក្នុងលោកណា ។ អធិប្បាយថា ក៏ជនពួកណា គឺព្រះអរិយៈរមែងមិនមានសត្វនិងសង្ខារដែលជាទីស្រឡាញ់ គឺកាវ:ជាទីស្រឡាញ់ថាបុត្រក្តី ថាបងប្អូនប្រុសក្តី ថាបងប្អូនស្រីក្តី ថាភរិយាក្តី មិនមានក្នុង

លោកណា ១ គឺក្នុងសត្វលោកនិងក្នុងសង្ខារលោកព្រោះប្រាសចាករាគៈដោយប្រការទាំងពួង គឺសត្វនិងសង្ខារដែលជាទីស្រឡាញ់បានដល់ សេចក្តីស្រឡាញ់មិនមានក្នុងសង្ខារលោកថា នេះជារបស់យើង យើងបាននៅ យើងនឹងបានដែលសេចក្តីសុខឈ្មោះនេះដោយវត្ថុនេះ ។ បទថា តស្មា អសោកំ ១ រជំ ១ បជ្ជយានោ ១ ១ ១

ពោលហើយដល់ខ្ញុន ឈ្មោះថា អ្នកប្រាសចាកធូលី គឺភាវៈដែលមិនមានធូលី ព្រោះប្រាសចាកធូលីគឺរាគៈ បានដល់ សេចក្តីជាព្រះអរហន្ត គឺព្រះនិព្វាន ដែលបានឈ្មោះថា **អសោកៈ**និងថា **វិរជៈ** ព្រោះមិនមានសេចក្តីសោកសៅ និងព្រោះហេតុនៃសេចក្តីមិនមានធូលីគឺ រាគៈជាដើម ទើបកើតឆន្ទៈដោយអំណាចសេចក្តីពេញចិត្តក្នុងកុសលគឺ សេចក្តីប្រាថ្នាដើម្បីនឹងធ្វើ មិនគប្បីធ្វើ គឺមិនគប្បីឱ្យសត្វ និងសង្ខារដែលជាទីស្រឡាញ់ គឺ សេចក្តីស្រឡាញ់ឱ្យកើតក្នុងធម៌មានរូបជាដើម ដោយទីបំផុតសូម្បីក្នុងធម៌គឺ សមថៈនិងវិបស្សនាក្នុងលោកណា ១ ។ សមពិតដូច ព្រះតម្រាស់ដែលត្រាស់ទុកថា ភិក្ខុទាំងឡាយសូម្បីធម៌ ពួកលោកក៏គួរលះចេញ នឹងចាំបាច់ពោលទៅថ្លឹងដល់អធម៌ហ្ន៎ ។

ឋិយជាតិកសូត្រ

នៅក្នុងបិដកលេខ ២៤, ទំព័រ ៤៤១ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់អំពី (**សេចក្តីសោកសៅកើតពីវត្ថុ ឬ បុគ្គលដែលជាទីស្រឡាញ់**) មានសេចក្តីថា ៖

ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់សម្រេចព្រះឥរិយាបថក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋីជិតក្រុងសាវត្ថី ។ សម័យនោះឯង គហបតីម្នាក់ មានកូនប្រុសតូចតែមួយជាទីស្រឡាញ់ពេញចិត្ត បានធ្វើមរណកាលទៅ ។ ព្រោះកូននោះធ្វើកាលកិរិយាទៅ ការងារទាំងឡាយ ក៏មិនប្រាកដ ភត្តាហារក៏មិនប្រាកដ (ដល់គាត់)ឡើយ ។ គាត់តែងតែទៅ ឈាបនដ្ឋានយំរកថា **ឱកូនតូចថ្លើមថ្លៃ អ្នកនៅទីណា ឱកូនតូចថ្លើមថ្លៃ អ្នកនៅទីណា ។** គ្រាក្រោយមកគហបតីនោះចូលទៅ គាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះ មានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។

លុះគហបតីនោះ អង្គុយក្នុងទីសមគួរហើយ ព្រះមានបុណ្យទ្រង់ត្រាស់ដូច្នេះថា ម្នាលគហបតី អ្នកតាំងនៅក្នុងចិត្ត របស់ខ្លួន គឺរស់នៅទេ តែហាក់ដូចជាមិនមានឥន្ទ្រិយគឺមនោ-វិញ្ញាណ (ព្រោះ)ឥន្ទ្រិយរបស់អ្នកប្រែសម្បុរប្លែក ។ គហបតីទូលថា ឱព្រះអង្គដ៏ចម្រើន ឥន្ទ្រិយរបស់ខ្ញុំព្រះអង្គ នឹងមិនប្រែពណ៌សម្បុរឯណាក៏បាន បពិត្រព្រះអង្គដ៏ចម្រើន ព្រោះខ្ញុំព្រះ

អង្គមានកូនប្រុសតូចតែមួយ ជាទីស្រឡាញ់ពេញចិត្ត បានធ្វើមរណកាលទៅ ព្រោះវាធ្វើកាលកិរិយាទៅ ការងារក៏មិនប្រាកដ ភត្តាហារក៏មិនប្រាកដ(ដល់ខ្ញុំព្រះអង្គ)សោះ ខ្ញុំព្រះអង្គនោះតែងតែទៅឈាបនដ្ឋាន ហើយយំរកថា **ឱកូនតូចមាសថ្លៃ អ្នកនៅក្នុងទីណា ឱកូមតូចមាសថ្លៃ អ្នកនៅក្នុងទីណា** ។

(**ព្រះអង្គ**). ម្នាលគហបតី ដំណើរនុ៎ះយ៉ាងនោះមែន គហបតី ដំណើរនុ៎ះយ៉ាងនោះមែន គហបតី ពិតមែន គហបតី សេចក្តីសោកស្តាយ ខ្ជឹកខ្ជួល សេចក្តីទុក្ខ តូចចិត្ត ការចង្អៀតចង្អល់ចិត្ត តែងកើតមកអំពីសេចក្តីស្រឡាញ់ មានសេចក្តីស្រឡាញ់ជាដែនកើត ។

(**គហបតី**). បពិត្រព្រះអង្គដ៏ចម្រើន ធម្មតាហេតុនៃសេចក្តីស្រឡាញ់នោះឯង នឹងមានដូច្នោះមែន សេចក្តីសោកស្តាយ ខ្ជឹកខ្ជួល សេចក្តីទុក្ខ តូចចិត្ត ការចង្អៀតចង្អល់ចិត្ត តែងកើតមកអំពីសេចក្តីស្រឡាញ់ មានសេចក្តីស្រឡាញ់ជាដែនកើតដែរ បពិត្រព្រះអង្គដ៏ចម្រើន តែបើតាមដែលពិតនោះ សេចក្តីត្រេកអរនឹងសេចក្តីរីករាយ តែងកើតមានអំពីសេចក្តីស្រឡាញ់

មានសេចក្ដីស្រឡាញ់ជាដែនកើត[1] ។

ខណៈនោះគហបតីនោះ មិនត្រេកអរ មិនយាត់ហាមនូវ
ភាសិតរបស់ព្រះមានបុណ្យទេក៏ក្រោកចាកអាសនៈចេញទៅ ។

[ពួកអ្នកលេងល្បែងភ្នាល់]

សម័យមួយ មានពួកអ្នក លេងល្បែងភ្នាល់ជាច្រើនកំពុង
លេងដោយល្បែងភ្នាល់ទាំងឡាយ ក្នុងទីមិនឆ្ងាយប៉ុន្មានអំពីព្រះ
មានបុណ្យ ។ ចំណែកគហបតីនោះ ក៏ចូលទៅរកអ្នកលេងល្បែង
ភ្នាល់នោះ លុះចូលទៅដល់ហើយ ក៏និយាយទៅរកអ្នកលេងល្បែង
ភ្នាល់នោះដូច្នេះថា នែ៎ អ្នកដ៏ចម្រើនទាំងឡាយអម្បាញ់មិញនេះ
ខ្ញុំបានចូលទៅគាល់ព្រះសមណគោតម លុះចូលទៅដល់ហើយ
ក៏ថ្វាយបង្គំព្រះសមណគោតម រួចអង្គុយក្នុងទីសមគួរ នែអ្នកដ៏
ចម្រើនទាំងឡាយ លុះខ្ញុំអង្គុយក្នុងទីសមគួរ ព្រះសមណគោតម
ទ្រង់ត្រាស់ដូច្នេះថា ម្នាលគហបតី អ្នកឋិតនៅក្នុងចិត្តរបស់ខ្លួន
គឺរស់នៅទេ តែហាក់ដូចជាមិនមានឥន្ទ្រិយ (ព្រោះ)ឥន្ទ្រិយ
របស់អ្នកប្រែសម្បុរប្លែកដូច្នេះ ។ នែ៎ អ្នកដ៏ចម្រើនទាំងឡាយ

---

១. ពាក្យនេះគហបតីអ្នកខ្លួន ឬលើកខ្លួនថាយល់ជាងព្រះបរមគ្រូ ។

កាលព្រះសមណគោតមត្រាស់យ៉ាងនេះ ខ្ញុំក៏បានតបទៅនឹងព្រះសមណគោតមវិញថា ឱ!ព្រះអង្គដ៏ចម្រើនឥន្ទ្រិយរបស់ខ្ញុំព្រះអង្គនឹងមិនប្រែពណ៌សម្បុរឯណាក៏បាន បពិត្រព្រះអង្គដ៏ចម្រើន ព្រោះខ្ញុំព្រះអង្គមានកូនប្រុស តូចតែមួយជាទីស្រឡាញ់ពេញចិត្ត បានធ្វើមរណកាលទៅ ព្រោះវាធ្វើកាលកិរិយាទៅ ព្រោះតែវាធ្វើមរណកាលទៅ ការងារក៏មិនប្រាកដភត្តាហារក៏មិនប្រាកដ(ដល់ខ្ញុំព្រះអង្គ)សោះ ខ្ញុំព្រះអង្គនោះឯង តែងទៅកាន់ឈាបនដ្ឋាន យំរកថា **ឱកូនតូច មាសថ្លៃ អ្នកនៅក្នុងទីណា ឱកូនតូចមាសថ្លៃ អ្នកនៅក្នុងទីណា**ដូច្នេះ ទើបព្រះសមណគោតត្រាស់ថា ដំណើរនុ៎ះយ៉ាងនោះមែន គហបតី ដំណើរនុ៎ះយ៉ាងនោះមែន គហបតី ពិតមែន គហបតី សេចក្តីសោកស្តាយ ខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត្ត ការចង្អៀតចង្អល់ចិត្ត តែងកើតមកអំពីសេចក្តីស្រឡាញ់ មានសេចក្តីស្រឡាញ់ជាដែនកើត (កាលព្រះមានបុណ្យទ្រង់ត្រាស់យ៉ាងនេះ ខ្ញុំក៏ទូលតបវិញ)ថា បពិត្រព្រះអង្គដ៏ចម្រើន ធម្មតា ហេតុនៃសេចក្តីស្រឡាញ់នោះឯង នឹងមានដូច្នោះមែន សេចក្តីសោកស្តាយ ខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត្ត ការចង្អៀតចង្អល់ចិត្ត កើតមកអំពីសេចក្តីស្រឡាញ់ មានសេចក្តីស្រឡាញ់

ជាដែនកើតមែន បពិត្រព្រះអង្គដ៏ចម្រើន តែតាមដែលពិតនោះ សេចក្តីត្រេកអរនឹងសេចក្តីរីករាយ តែងកើតមានអំពីសេចក្តីស្រឡាញ់ មានសេចក្តីស្រឡាញ់ជាដែនកើតដូច្នេះ នែអ្នកដ៏ចម្រើនទាំងឡាយ កាលនោះខ្ញុំក៏មិនត្រេកអរ មិនឃាត់ហាមនូវកាសិតរបស់ព្រះសមណគោមតទេ ខ្ញុំក្រោកចាកអាសនៈហើយក៏ចេញមក ។ ពួកអ្នកលេងល្បែងភ្នាល់ឆ្លើយតបថា បពិត្រលោកគហបតី ពាក្យដែលលោកមានប្រសាសន៍ទុ៎ះ ត្រូវហើយ បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីត្រេកអរនឹងសេចក្តីរីករាយ តែងកើតមកអំពីសេចក្តីស្រឡាញ់ មានសេចក្តីស្រឡាញ់ជាដែនកើតដោយពិត ។ ទើបគហបតីនោះគិតថា ពាក្យរបស់អាត្មាអញសមគ្នានឹងពួកអ្នកលេងល្បែងភ្នាល់ ដូច្នេះ រួចក៏ចេញទៅ ។

គ្រានោះឯង ដំណើរវាចានេះ ក៏ញ្ជូនរត្ងាយតាមលំដាប់ រហូតចូលទៅខាងក្នុងព្រះរាជវាំង ។ លោនោះ ព្រះបាទបសេ-នទិកោសល ទ្រង់ត្រាស់សួរទៅនាងមល្លិការាជទេវីថា សេចក្តីសោកស្តាយ ខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត្ត ការចង្អៀតចង្អល់ចិត្ត តែងកើតមកអំពីសេចក្តីស្រឡាញ់ មានសេចក្តីស្រឡាញ់ជាដែនកើតមែនឬអ្វី ។ ព្រះនាងមល្លិការាជទេវី ក្រាបបង្គំទូលថា បពិត្រ

មហាវាជ បើពាក្យនោះ ព្រះមានបុណ្យទ្រង់សម្តែង មែនដំណើរ ន៏ុះក៏ពិតយ៉ាងនោះឯង ។

ប. ព្រះបាទបសេនទិកោសល ទ្រង់បន្ទោសថា មិនសម បើយ៉ាងនេះ ។សោះ ព្រះសមណគោតម ពោលនូវពាក្យណា មល្ងិកានេះ ហ៊ានទិយាយ ចាក់បណ្តាតាមពាក្យនោះ ។ របស់ ព្រះសមណគោតមនោះថា បពិត្រព្រះមហាវាជ បើពាក្យនោះ ព្រះមានបុណ្យទ្រង់សម្តែងមែន ដំណើរន៏ុះក៏ពិតយ៉ាងនោះ ដូច្នេះ សោះ ប្រៀបដូចអាចារ្យទិយាយពាក្យណា ។ ដល់កូនសិស្ស ។ ក៏ទិយាយចាក់បណ្តាយតាមពាក្យនោះ ។ របស់អាចារ្យនោះ ថា បពិត្រលោកអាចារ្យ ដំណើរន៏ុះយ៉ាងហ្នឹងមែន បពិត្រលោក អាចារ្យ ដំណើរន៏ុះយ៉ាងហ្នឹងមែន សេចក្តីនេះមានឧបមាយ៉ាង ណា នៃមល្ងិកា ព្រះសមណគោតមពោលនូវពាក្យណា ។ នាង ក៏ទិយាយចាក់បណ្តាយតាមពាក្យនោះ ។ របស់ព្រះសមណ-គោតមនោះថា បពិត្រព្រះមហាវាជ បើពាក្យនោះព្រះមានបុណ្យ ទ្រង់ត្រាស់មែន ដំណើរន៏ុះក៏ពិតយ៉ាងនោះ ក៏មានឧបមេយ្ય យ៉ាងនោះដែរ នៃមល្ងិកា ចូរនាងចៀសអំពីមុខអញចេញទៅ

(ព្រោះ)នាងវិលទូចណាស់ ។

[ត្រាស់ហៅនាឡិជङ្ឃព្រាហ្មណ៍]

គ្រានោះ ព្រះនាងមល្លិការាជទេវី មានព្រះសវនីយ៍ទៅកនាឡិជङ្ឃព្រាហ្មណ៍ថា នែព្រាហ្មណ៍ចូរអ្នកមកអាយ ចូរអ្នកចូរទៅគាល់ព្រះភគវន្តមុនី លុះចូលទៅដល់ហើយ ចូរថ្វាយបង្គំព្រះភគវន្តមុនីដោយតួង រួចទូលសួរនូវសេចក្តីមិនមានអាពាធ មិនមានរោគ ការក្រោកឡើងរហ័ស កម្លាំង ការគង់នៅជាសុខ តាមពាក្យខ្ញុំថា បពិត្រព្រះអङ្គដ៏ចម្រើន ព្រះនាងមល្លិការាជទេវី សូមថ្វាយបង្គំព្រះបាទ របស់ព្រះមានព្រះភាគដោយតួង ទាំងសូមទូលសួរនូវការមិនមានអាពាធ មិនមានរោគការក្រោកឡើងរហ័ស កម្លាំង ការគង់នៅជាសុខដូច្នេះ រួចចូរអ្នកទូលសួរយ៉ាងនេះទៀតថា បពិត្រព្រះអङ្គដ៏ចម្រើន ព្រះមានព្រះភាគបានសម្តែងព្រះវាចានេះថា សេចក្តីសោកស្តាយ ខ្សឹកខ្សួលសេចក្តីទុក្ខតូចចិត្ត ការចង្អៀតចង្អល់ចិត្ត តែងកើតមកអំពីសេចក្តីស្រឡាញ់ មានសេចក្តីស្រឡាញ់ ជាដែនកើតដូច្នេះ ឬអ្វី បើព្រះមានព្រះភាគទ្រង់ដោះស្រាយប្រាប់អ្នកយ៉ាងណា ចូរអ្នកចង់ចាំពាក្យនោះឱ្យ

ស្អ ហើយមកជ្រាប់ដល់ខ្ញុំវិញ ព្រោះព្រះតថាគតទាំងឡាយ មិនពោលពាក្យដែលមិនពិតជ្រាកដឡើយ ។

នាឡិជង្ឃព្រាហ្មណ៍ ទទួលព្រះវាចារបស់ព្រះនាងមល្លិ-ការាជទេវីថា ទទួលព្រះសវនីយ៍ការុណាវិសេស ដូច្នេះ រួចក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្ដីរីករាយជាមួយនឹងព្រះមានបុណ្យ លុះបញ្ចប់ពាក្យដែលគួររីករាយ នឹងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះនាឡិជង្ឃព្រាហ្មណ៍ អង្គុយក្នុងទីដ៏សមគួរហើយ ទើបទូលពាក្យនោះចំពោះព្រះមានបុណ្យថា បពិត្រព្រះគោតមដ៏ចម្រើន ព្រះនាងមល្លិការាជទេវី សូមថ្វាយបង្គំព្រះបាទារបស់ព្រះគោតមដ៏ចម្រើនដោយត្បូង ទាំងសូមសួរនូវសេចក្ដីមិនមានអាពាធ មិនមានរោគ ការក្រោកឡើងរហ័ស កម្លាំង ការគង់នៅជាសុខមួយទៀត ព្រះនាងសូមទូលសួរយ៉ាងនេះថា បពិត្រ ព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគបានសម្ដែងព្រះវាចានេះថា សេចក្ដីសោកស្ដាយ ខ្សឹកខ្សួល សេចក្ដីទុក្ខ តូចចិត្ត ការចង្អៀតចង្អល់ចិត្ត តែងកើតមកអំពីសេចក្ដីស្រឡាញ់ មានសេចក្ដីស្រឡាញ់ជាដែនកើត ដូច្នេះ

ឬអ្វី ។ ព្រះអង្គត្រាស់ថា អើ ព្រាហ្មណ៍ពាក្យនុ៎ះតថាគតថាយ៉ាងនោះមែនអើព្រាហ្មណ៍ ពាក្យនុ៎ះ តថាគតថាយ៉ាងនោះមែន ម្នាលព្រាហ្មណ៍ ពិតមែន សេចក្តីសោកស្តាយ ខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត្ត ការចង្អៀតចង្អល់ចិត្ត តែងកើតមកអំពីសេចក្តីស្រឡាញ់ មានសេចក្តីស្រឡាញ់ជាដែនកើតដូច្នេះឬអ្វី ។ ម្នាលព្រាហ្មណ៍ គេត្រូវដឹងថា សេចក្តីសោកស្តាយ ខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត្ត ការចង្អៀតចង្អល់ចិត្ត តែងកើតមកអំពីសេចក្តីស្រឡាញ់ មានសេចក្តីស្រឡាញ់ជាដែនកើត ដូច្នេះ ដោយបរិយាយនេះ ។

[រឿងធ្លាប់មានមកហើយ]

ម្នាលព្រាហ្មណ៍ រឿងធ្លាប់មានមកហើយតើ មានមាតារបស់ស្ត្រីម្នាក់ ក្នុងក្រុងសាវត្ថីនេះឯង បានធ្វើកាលកិរិយាទៅ ។ តាំងអំពីកាលកិរិយានៃមាតានោះ ស្ត្រីនោះក៏ទៅជាឆ្ងួត មានចិត្តរវើរវាយ ដើរសព្វច្រករបាក សព្វផ្លូវត្រែឡែងកែង ស្រែកសួរយ៉ាងនេះថា ឱ!អ្នកទាំងឡាយ បានឃើញមាតាខ្ញុំដែរឬ ឱ! អ្នកទាំងឡាយ បានឃើញមាតាខ្ញុំដែរឬ ។ ម្នាលព្រាហ្មណ៍ ព្រោះបរិយាយនេះហើយ បានជាគេត្រូវដឹងថា សេចក្តីសោកស្តាយ

ខ្ជឹកខ្ជួល សេចក្ដីទុក្ខ គួចចិត្ត ការចង្អៀតចង្អល់ចិត្ត តែងកើតមកអំពីសេចក្ដីស្រឡាញ់ មានសេចក្ដីស្រឡាញ់ជាដែនកើត ។ ម្នាលព្រាហ្មណ៍ រឿងធ្លាប់មានមកហើយតើ មាតាបិតារបស់ស្ត្រីម្នាក់ ក្នុងក្រុងសាវត្ថីនេះឯង បានធ្វើមរណកាល... បងប្អូនប្រុសបានធ្វើមរណកាល... បងប្អូនស្រីបានធ្វើមរណកាល...កូនស្រីបានធ្វើមរណកាល...ស្វាមីបានធ្វើមរណកាល ។ តាំងអំពីកាលកន្លិយានៃស្វាមីនោះ ស្ត្រីនោះក៏ទៅជាឆ្ងត មានចិត្តរវើរវាយ ដើរសព្វច្រកល្អក សព្វផ្លូវត្រែឡែងកែង ស្រែកសួរយ៉ាងនេះថា ឱ!អ្នកទាំងឡាយបានឃើញស្វាមីខ្ញុំដែរឬ ឱអ្នកទាំងឡាយបានឃើញស្វាមីខ្ញុំដែរឬ ។ ម្នាលព្រាហ្មណ៍ ព្រោះបរិយាយនេះហើយ បានជាគេត្រូវដឹងថា សេចក្ដីសោកស្ដាយ ខ្ជឹកខ្ជួល សេចក្ដីទុក្ខ គួចចិត្ត ការចង្អៀតចង្អល់ចិត្ត តែងកើតមកអំពីសេចក្ដីស្រឡាញ់ មានសេចក្ដីស្រឡាញ់ជាដែនកើត ។

ម្នាលព្រាហ្មណ៍ រឿងធ្លាប់មានមកហើយតើ មានមាតាបុរសម្នាក់ ក្នុងក្រុងសាវត្ថីនោះឯង បានធ្វើមរណកាលទៅ ។ តាំងអំពីកាលកន្លិយានៃមាតានោះបុរសនោះក៏ទៅជាឆ្ងត មានចិត្ត

រវើរវាយ ដើរសព្វច្រករហក សព្វផ្លូវត្រែឡែងកែង ស្រែកសួរ យ៉ាងនេះថា ឱអ្នកទាំងឡាយ បានឃើញម្តាយខ្ញុំដែរឬ ឱអ្នកទាំងឡាយបានឃើញម្តាយខ្ញុំដែរឬ ។ ម្នាលព្រាហ្មណ៍ ព្រោះបរិយាយនេះហើយ បានជាគេត្រូវដឹងថា សេចក្តីសោកស្តាយ ខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត្តការចង្អៀតចង្អល់ចិត្ត តែងកើតមកអំពីសេចក្តីស្រឡាញ់ មានសេចក្តីស្រឡាញ់ជាដែនកើត ។ ម្នាលព្រាហ្មណ៍ រឿងធ្លាប់មានមកហើយ មានបិតារបស់បុរសម្នាក់ក្នុងក្រុងសាវត្ថីនេះឯងបានធ្វើមរណកាល... បងប្អូនប្រុសបានធ្វើមរណកាល... បងប្អូនស្រីបានធ្វើមរណកាល... កូនប្រុសបានធ្វើមរណកាល... ស្វាមីធ្វើមរណកាល ។ តាំងអំពីកាលកិរិយានៃស្វាមីនោះ កូនស្រីបានធ្វើមរណកាល.. ប្រពន្ធបានធ្វើមរណកាលទៅ ។ តាំងអំពីមរណកាលនៃភរិយានោះ បុរសនោះក៏ទៅជាឆ្កួត មានចិត្តរវើរវាយ ដើរសព្វច្រករហក សព្វផ្លូវត្រែឡែងកែង ស្រែកសួរ យ៉ាងនេះថា ឱអ្នកទាំងឡាយបានឃើញប្រពន្ធខ្ញុំដែរឬ ឱអ្នកទាំងឡាយបានឃើញប្រពន្ធខ្ញុំដែរឬ ។ ម្នាលព្រាហ្មណ៍ ព្រោះបរិយាយនេះហើយ បានជាគេត្រូវដឹងថា សេចក្តីសោកស្តាយ ខ្សឹកខ្សួល

សេចក្តីទុក្ខ តូចចិត ការចង្អៀតចង្អល់ចិត្ត តែងកើតមកអំពីសេចក្តីស្រឡាញ់ មានសេចក្តីស្រឡាញ់ជាដែនកើត ។

ម្នាលព្រាហ្មណ៍ រឿងធ្លាប់មានមកហើយតើ ក្នុងក្រុងសាវត្ថីនេះ មានស្ត្រីម្នាក់បានទៅកាន់ត្រកូលនៃញាតិ គឺមានប្តី ។ ពួកញាតិទាំងនោះរបស់ស្ត្រីនោះ មានប្រាថ្នានឹងផ្តាច់ប្តីចេញ ហើយលើក(នាងនោះ)ឱ្យទៅបុរសឯទៀតវិញ តែនាងនោះមិនចង់បានបុរសនោះសោះ ។ ទើបស្ត្រីនោះនិយាយនឹងប្តីដូច្នេះថា បពិត្រអយ្យបុត្រ ពួកញាតិរបស់ខ្ញុំនេះ មានប្រាថ្នានឹងផ្តាច់អ្នកចេញ ហើយលើកខ្ញុំឱ្យទៅបុរសឯទៀតវិញ តែខ្ញុំមិនចង់បានបុរសនោះសោះ ។ គ្រានោះ បុរសនោះក៏កាប់ស្ត្រីនោះជាពីរកំណាត់ ហើយវះពោះខ្លួនឯង ដោយប្រាថ្នាថា សូមឱ្យយើងទាំងពីរនាក់ បានជួបគ្នាទៅក្នុងបរលោក ។ ម្នាលព្រាហ្មណ៍ ព្រោះបរិយាយនេះហើយ បានជាគេត្រូវដឹងថា សេចក្តីសោកស្តាយ ខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត ការចង្អៀតចង្អល់ចិត្ត តែងកើតមកអំពីសេចក្តីស្រឡាញ់ មានសេចក្តីស្រឡាញ់ ជាដែនកើត ។

គ្រានោះ នាឡិជង្ឃព្រាហ្មណ៍ ក៏ត្រេកអរអនុមោទនា

ចំពោះកាសិតរបស់ព្រះមានបុណ្យ រួចក្រោកអំពីអាសនៈ ចូលទៅគាល់ព្រះនាងមល្លិការាជទេវី លុះចូលទៅដល់ហើយ ក៏ក្រាបទូលនូវពាក្យដែលខ្លួនបានចរចា ជាមួយនឹងព្រះមានបុណ្យដល់ព្រះនាងមល្លិការាជទេវីដោយសព្វគ្រប់ ។ គ្រានោះព្រះនាងមល្លិការាជទេវី ចូលទៅគាល់ព្រះបាទបសេនទិកោសល លុះចូលទៅដល់ហើយ ក៏ក្រាបទូលសួរព្រះ់ព្រះបាទបសេនទិកោសលដូច្នេះថា បពិត្រព្រះមហារាជ ព្រះអង្គសម្គាល់សេចក្តី នោះថាដូចម្តេច រាជកុមារីព្រះនាមវជីរី ព្រះអង្គសព្វព្រះរាជហឫទ័យឬទេ ។ ព្រះបាទបសេនទិកោសល មានព្រះបន្ទូលតបថា អើ មល្លិកា វជីរីកុមារី អញស្រឡាញ់ ។

ម. នាងមល្លិកាទូលសួរថា បពិត្រមហារាជ ព្រះអង្គសម្គាល់សេចក្តីនោះថាដូចម្តេច (បើ) វជីរីកុមារី ប្រែប្រួលព្រាត់ប្រាសនិវាសទៅ តើសេចក្តីសោកស្តាយ ខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត្ត ការចង្អៀតចង្អល់ចិត្ត នឹងកើតឡើងដល់ព្រះអង្គឬទេ ។

ប. ព្រះបាទបសេនទិកោសល មានព្រះបន្ទូលតបថា អើ មល្លិកា(បើ)នាងវជីរីកុមារី ប្រែប្រួល ព្រាត់ប្រាសនិវាស ទៅ

សូម្បីជីវិតរបស់អញក៏មុខវិបត្តិ ប្រែប្រួលទៅដែរ ចំណង់បើ សេចក្តីសោក ខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត្ត ការចង្អៀតចង្អល់ ចិត្ត នឹងខានកើតឡើងដល់អញឯណាក៏បាន ។

ប. ព្រះនាងមល្លិការាជទេវីទូលថា បពិត្រមហារាជ ព្រះ ភគវន្តអរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ សំដៅយកដំណើរនេះហើយបានជាសម្តែងថា សេចក្តីសោក ខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត្ត ការចង្អៀតចង្អល់ចិត្ត តែងកើតមក អំពីសេចក្តីស្រឡាញ់ មានសេចក្តីស្រឡាញ់ជាដែនកើត ។

បពិត្រមហារាជ ព្រះអង្គសម្គាល់សេចក្តីនោះថាដូចម្តេច នាងវាសភខត្តិយាតើព្រះអង្គសព្វព្រះហឫទ័យដែរឬទេ ។

ប. អើមល្លិកា នាងវាសភខត្តិយា អញស្រឡាញ់ ។

ម. បពិត្រមហារាជ ព្រះអង្គសម្គាល់សេចក្តីនោះថា ដូច ម្តេច (បើ)នាងវាសភខត្តិយា ប្រែប្រួល ព្រាត់ប្រាសនិវាសទៅ តើសេចក្តីសោកស្តាយ ខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត្ត ការចង្អៀត ចង្អល់ចិត្តនឹងកើតឡើងដល់ព្រះអង្គឬទេ ។

ប. មល្លិកា (បើ)នាងវាសភខត្តិយា ប្រែប្រួល ព្រាត់

ប្រាសនិវាសទៅ សូមជីវិតរបស់អញ ក៏មុខជានឹងវិបត្តិប្រែប្រួលទៅដែរ ចំណង់បើសេចក្តីសោក ខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត្ត ការចង្អៀតចង្អល់ចិត្តនឹងខានកើតឡើងដល់អញឯណាក៏បាន ។

ម. បពិត្រព្រះមហារាជ ព្រះភគវន្តអរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ សំដៅយកដំណើរនេះ ហើយបានជាសម្តែងថា សេចក្តីសោក ខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត្ត ការចង្អៀតចង្អល់ចិត្ត តែងកើតមកអំពីសេចក្តីស្រឡាញ់ មានសេចក្តីស្រឡាញ់ជាដែនកើត ។

[បិយបញ្ហា]

បពិត្រមហារាជ ព្រះអង្គសម្គាល់នូវសេចក្តីនោះថា ដូចម្តេចវិឌូឌភសេនាបតី តើព្រះអង្គសព្វព្រះហឫទ័យដែរឬទេ ។

ប. អើមល្ងិកា វិឌូឌភសេនាបតី អញស្រឡាញ់ ។

ម. បពិត្រព្រះមហារាជ ព្រះអង្គសម្គាល់សេចក្តីនោះថា ដូចម្តេច បើវិឌូឌភសេនាបតី ប្រែប្រួល ព្រាត់ប្រាសនិវាសទៅ តើសេចក្តីសោក ខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត្ត ការចង្អៀតចង្អល់ចិត្ត នឹងកើតឡើងដល់ព្រះអង្គឬទេ ។

ប. ឱមល្លិកា (បើ)វិឌូឌភសេនាបតី ប្រៃប្រូល ព្រាត់ប្រាសនិវាសទៅ សូម្បីជីវិតរបស់អញ ក៏មុខជានឹងវិបត្តិប្រៃប្រូលទៅដូចគ្នា ចំណង់បើសេចក្តីសោក ខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត្ត ការចង្អៀតចង្អល់ចិត្តនឹងខានកើតទ្បើងដល់អញឯណាក៏បាន ។

ម. បពិត្រព្រះមហារាជ ព្រះភគវន្តអរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ សំដៅយកដំណើរនេះ ហើយបានជាសម្តែងថា សេចក្តីសោក ខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត្ត ការចង្អៀតចង្អល់ចិត្ត តែងកើតមកអំពីសេចក្តីស្រឡាញ់ មានសេចក្តីស្រឡាញ់ជាដែនកើត ។

បពិត្រព្រះមហារាជ ព្រះអង្គសម្គាល់នូវសេចក្តីនោះថា ដូចម្តេចចុះខ្ញុំម្ចាស់តើព្រះអង្គសព្វព្រះហឫទ័យដែរឬទេ ។

ប. អើមល្លិកា ឯងក៏ជាទីស្រឡាញ់របស់អញដែរ ។

ម. បពិត្រព្រះមហារាជ ព្រះអង្គសម្គាល់សេចក្តីនោះថា ដូចម្តេច បើខ្ញុំម្ចាស់ប្រៃប្រូល ព្រាត់ប្រាសនិវាសទៅ តើសេចក្តីសោក ខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត្ត ការចង្អៀតចង្អល់ចិត្ត នឹងកើតទ្បើងដល់ព្រះអង្គឬទេ ។

ប. ឱមល្លិកា (បើ)ឯងប្រែប្រួល ព្រោះប្រាសនិវាសទៅ សូម្បីជីវិតរបស់អញ ក៏មុខជានឹងវិបត្តិប្រែប្រួលទៅដែរ ចំណង់ បើសេចក្តីសោក ខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត្ត ការចង្អៀតចង្អល់ ចិត្តនឹងខានកើតឡើងដល់អញឯណាក៏បាន ។

ម. បពិត្រព្រះមហារាជ ព្រះភគវន្តអរហន្តសម្មាសម្ពុទ្ធ អង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ សំដៅយកដំណើរនេះ ហើយបានជាសម្តែងថា សេចក្តីសោក ខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត្ត ការចង្អៀតចង្អល់ចិត្ត តែងកើតមកអំពីសេចក្តីស្រឡាញ់ មានសេចក្តីស្រឡាញ់ជាដែនកើត ។

បពិត្រព្រះមហារាជ ព្រះអង្គសម្គាល់នូវសេចក្តីនោះថា ដូចម្តេច ដែនកាសីនឹងដែនកោសល តើព្រះអង្គសព្វព្រះហឫទ័យ ដែរឬទេ ។

ប. អើមល្លិកា ដែនកាសីនឹងដែនកោសល ជាទីស្រឡាញ់ របស់អញ ម្នាលមល្លិកា (ព្រោះ)យើងប្រើវ៉ីមចន្ទន៍ដែលបានមក អំពីដែនកាសី ទ្រទ្រង់ផ្ទាកម្រង គ្រឿងក្រអូប នឹងគ្រឿងលាប ផ្សេង ៗដោយអានុភាពនៃដែនកាសីនឹងដែនកោសល ។

ម. បពិត្រព្រះមហារាជ ព្រះអង្គសម្គាល់សេចក្តីនោះថា ដូចម្តេច បើដែនកាសីនឹងដែនកោសល វិបត្តិប្រែប្រួលជាយ៉ាងដទៃទៅ តើសេចក្តីសោក ខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត្ត ការចង្អៀតចង្អល់ចិត្ត នឹងកើតឡើងដល់ព្រះអង្គឬទេ ។

ប. ឧមល្ជិកា បើដែនកាសីនឹងដែនកោសល វិបត្តិប្រែប្រួលជាយ៉ាងដទៃទៅ សូម្បីជីវិតរបស់អញ ក៏មុខជានឹងវិបត្តិប្រែប្រួលទៅដែរ ចំណង់បើសេចក្តីសោក ខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត្តការចង្អៀតចង្អល់ចិត្ត នឹងខានកើតឡើងដល់អញឯណាក៏បាន ។

ម. បពិត្រព្រះមហារាជ ព្រះភគវន្តអរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ សំដៅយកដំណើរនេះ ហើយបានជាសម្តែងថា សេចក្តីសោក ខ្សឹកខ្សួល សេចក្តីទុក្ខ តូចចិត្ត ការចង្អៀតចង្អល់ចិត្ត តែងកើតមកអំពីសេចក្តីស្រឡាញ់ មានសេចក្តីស្រឡាញ់ជាដែនកើត ។

[ព្រះបាទបសេនទិកោសលបន្ទូលទាន]

ព្រះបាទបសេនទិកោសលមានព្រះរាជឱ្ឋារថា អស្ចារ្យណាស់ មល្ជិកា ចំឡែកណាស់ មល្ជិកា ព្រោះព្រះមានព្រះភាគ

អង្គនោះ ប្រហែលជាទ្រង់ត្រាស់ដឹង ឃើញច្បាស់ដោយប្រាជ្ញាមែន ម្នាលមល្លិកា នាងចូរមកអាយ ចូរនាងឱ្យនូវទឹកសម្រាប់លាងជំរះ(ដល់អញ) ។

តពីនោះមក ព្រះបាទបសេនទិកោសល ក្រោកអំពីអាសនៈ ធ្វើសម្ពត់ឧត្តរាសង្គៈ ឆៀងព្រះអង្សាម្ខាង ប្រណម្យអញ្ជលីឆ្ពោះត្រង់ទីព្រះមានព្រះភាគគង់ បន្ទឹនូវឧទានអស់វារៈ ៣ ដងថា **ខ្ញុំសូមថ្វាយបង្គំចំពោះព្រះភគវន្ត អរហន្តសម្មាសម្ពុទ្ធអង្គនោះ ។**

អដ្ឋកថា

ក្នុងបទទាំងនោះ បទថា នេវ ឥមិ ន្ត្ថ បដិភន្តិ សេចក្តីថា ការងាររមែងមិនប្រាកដ ទាំងអស់ដោយប្រការទាំងពួងគឺ ។ រមែងមិនប្រាកដដោយការកំណត់តាមប្រក្រតី ។

សូម្បីក្នុងបទទីពីរក៏នយនេះ ពិតមែន ។ ក៏បទថា ន បដិភន្តិ ក្នុងព្រះសូត្រនេះ ប្រែថា មិនត្រូវចិត្ត ។

បទថា អាហ្ឍ ន ប្រែថា ព្រៃជាទីចោលសាកសព ។

បទថា អញ្ញ ជ ន ្ត ។ បានដល់ សេចក្តីជាប្រការដទៃ ព្រោះ

មានវណ្ណៈប្លែកៅ ។ ធម៌ដែលនឹងគប្បីដឹងច្បាស់ដោយចិត្ត ឈ្មោះថា **ឥន្ទ្រិយ** ។ តែពាក្យនេះលោកពោលសំដៅដល់ឱកាសដែលឥន្ទ្រិយតាំងនៅហើយ ។

បទថា **ឋិយជាតិកា** សេចក្តីថា រមែងកើតអំពីសេចក្តីស្រឡាញ់ ។

បទថា **ឋិយប្បភូតិកា** សេចក្តីថា មានមកពីរបស់ទីស្រឡាញ់ ។

បទថា **សចេ តំ មហាវាជ** សេចក្តីថា សូម្បីកំណត់សេចក្តីសំដៅរបស់ព្រះតម្រាស់នោះ ទើបពោលយ៉ាងនោះដោយសេចក្តីថា ជាអ្នកមានសទ្ធាក្នុងព្រះសាស្តា ។

បទថា **ចរ ឋិរេ** សេចក្តីថា លោកចូរចៀសទៅផ្លូវដទៃចេញ សំដៅសេចក្តីថា លោកកុំឈរនៅទីនេះក៏បាន ។ មួយទៀត បទថា **ចរ ឋិរេ** គឺលោកចូរទៅផ្លូវដទៃអធិប្បាយថា កុំឈរក្នុងទីនេះខ្លះ ។

បទថា **ទ្វិធា ឆេត្វា** សេចក្តីថា កាត់ធ្វើឱ្យជា ២ ចំណែកដោយដាវ ។

បទថា អត្តានំ ឧប្ជាលេសិ សេចក្ដីថា យកជាវនុ៎ះ ឯងកាត់ពោះរបស់ខ្លួន ។ ក៏បើស្រីនោះមិនជាទីស្រឡាញ់របស់ប្រុសនោះ ឥឡូវនេះប្រុសនោះមិនគប្បីសម្ងាប់ខ្លួនដោយគិតថា "យើងនឹងរកស្រីដទៃ" ។ តែព្រោះស្រីនោះជាទីស្រឡាញ់របស់ប្រុសនោះ ដូច្នោះ ប្រុសនោះប្រាថ្នាសេចក្ដីព្រមព្រៀងនឹងស្រីនោះ សូម្បីក្នុងបរលោក ទើបបានធ្វើយ៉ាងនោះ ។

ពាក្យថា ព្រះកុមារីព្រះនាមថា វជិរី ជាទីប្រាសប្រាណរបស់ព្រះអង្គឬ សេចក្ដីថា បានឮថា ព្រះនាងនោះបានមានត្រិះរិះយ៉ាងនេះ ព្រះនាងពោលយ៉ាងនោះ ព្រោះគិតថា បើយើងនឹងគប្បីពោលពាក្យជាដើមថា បពិត្រមហារាជ រឿងធ្លាប់មានមកហើយ ក្នុងព្រះនគរសាវត្ថីនេះ នៅមានស្រីដទៃទៀត ព្រះអង្គនឹងគប្បីបដិសេធយើងថា អ្នកណាបានធ្វើយ៉ាងនោះដល់អ្នកឯង ចូរថយទៅ ប្រការនោះ រមែងមិនមាន យើងនឹងញ៉ាំងស្រីនោះ ឱ្យយល់ដោយអាការដែលជាទីនៅនោះឯង ។ ក្នុងបទថា **វិបរិណាមញ្ញថា ភាវា** នេះ បណ្ឌិតគប្បីជ្រាបសេចក្ដីប្រែប្រួល ព្រោះសេចក្ដីស្លាប់ គឺសេចក្ដីជាប្រការដទៃ ដោយការគេចជៀសទៅ

ទីងអ្នកណា ๆ ក៏បាន ។

បទថា វាសភាយ សេចក្ដីថា ព្រះទេវីរបស់ព្រះរាជាមួយអង្គ ព្រះនាមថា វាសភា លោកពោលសំដៅដល់ព្រះនាងនោះ ។

បទថា ឥយាតេ អហំ លោកពោលក្នុងខាងក្រោយទាំងអស់ ព្រោះហេតុអ្វី ។

បានឮថា សេចក្ដីត្រិះរិះយ៉ាងនេះបានមានហើយដល់ព្រះនាងនោះ ទើបទូលសួរក្នុងខាងក្រោយទាំងអស់ ដើម្បីឱ្យជាទីតាំងនៃពាក្យថា ព្រះរាជានេះទ្រង់ក្រោធយើង បើយើងនឹងគប្បីសួរមុនអ្នកដទៃទាំងអស់ថា ខ្ញុំម្ចាស់ជាទីស្រឡាញ់របស់ព្រះអង្គ ឬព្រះអង្គក៏នឹងគប្បីត្រាស់ថា អ្នកឯងមិនបានជាទីស្រឡាញ់របស់យើង ចូរជៀសទៅផ្លូវដទៃ កាលជាដូច្នេះ ពាក្យក៏នឹងមិនបានតាំងឡើង ។ បណ្ឌិតគប្បីជ្រាបសេចក្ដីប្រៃប្ដូល ដោយសេចក្ដីជាអ្នកត្រូវចោលទុកក្នុងដែនកាសីកោសល សេចក្ដីជាប្រការដទៃ ដោយនៅក្នុងកណ្ដាប់ដៃព្រះរាជាអ្នកជាបដិបក្ខទាំងឡាយ(រាជសត្រូវ) ។

បទថា **អាចមេហិ** *សេចក្ដីថា អ្នកឯងចូរយកទឹកគ្នុរមាត់មក ។ ព្រះបាទបសេនទិកោសលទ្រង់ខ្ជុរហើយ ទ្រង់លាង ព្រះហស្ដនិងព្រះបាទហើយ ទ្រង់ចិទព្រះឱស្ថហើយប្រាប្ដានឹងនមស្ការ-ការព្រះសាស្ដា ទើបត្រាស់យ៉ាងនោះ ។ ពាក្យដែលសល់ក្នុងទីគ្រប់កន្លែងងាយស្រួលយល់ទាំងនោះឯង ។*

នន្ទិសូត្រ

នៅក្នុងបិដកលេខ ២៩, ទំព័រ ១៣ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់អំពី [***អ្នកមិនមានសេចក្ដីត្រេកអរ***] *មានសេចក្ដីថា ៖*

សាវត្ថីនិទាន, លុះទេវតានោះ ឈរក្នុងទីដ៏សមគួរហើយ ទើបពោលគាថានេះ ក្នុងសំណាក់ព្រះមានព្រះភាគថា ៖

នន្ទ**តិ** **ប**ុ**ត្ដ**េ**ហ**ិ **ប**ុ**ត្ដ**ិ**ម**ា

គោ**ម**ិ**ក**ោ **គ**ោ**ហ**ិ **ត**ថ**េ**វ **ន**ន្ទ**តិ** ។

ឧប**ធ**ិ **ហ**ិ **ន**រ**ស**្ស **ន**ន្ទ**ន**ា

ន **ហ**ិ **ស**ោ **ន**ន្ទ**តិ** **យ**ោ **ន**ិ**រ**ុ**ប**ធ**ីត**ិ ។

អ្នកមានកូន រមែងត្រេកអរនឹងកូនទាំងឡាយ អ្នកមានគោ រមែងត្រេកអរនឹងគោទាំងឡាយ ដូច្នោះដែរ ឧបធិទាំងឡាយ ជាគ្រឿងត្រេកអររបស់ជន អ្នកណាមិនមានឧបធិ អ្នកនោះមិនមានអ្វីត្រេកអរ(នឹងគេបាន) ។

ព្រះអង្គត្រាស់ថា ៖

សោចតិ បុត្តេហិ បុត្តិមា

គោមិគោ គោហិ តថេវ សោចតិ ។

ឧបធិ ហិ នរស្ស សោចនោ

ន ហិ សោ សោចតិ យោ និរុបធីតិ ។

អ្នកមានកូន រមែងសោកសៅនឹងកូនទាំងឡាយ អ្នកមានគោ ក៏មែងសោកសៅនឹងគោទាំងឡាយ ដូច្នោះដែរ ជ្រាតឧបធិទាំងឡាយ ជាគ្រឿងសៅហ្មងរបស់ជន លុះតែអ្នកណាមិនមានឧបធិ ទើបអ្នកនោះមិនសោកសៅ ។

អដ្ឋកថា

បទថា ន**ន្ទតិ** **រមែងរីករាយ** បានដល់ រមែងត្រេកអរ គឺរមែងមានចិត្តជារបស់ ១ ១ ១ ។

បទថា **បុត្តិមា អ្នកមានកូន** បានដល់ មានកូនច្រើន ។ ពិតមែន កូនពួកខ្លះធ្វើកសិកម្មហើយ រមែងញ៉ាំងជង្រុកស្រូវឱ្យពេញ ពួកខ្លះធ្វើការជួញដូរហើយ រមែងនាំប្រាក់ទិដ្ឋមាសមក ពួកខ្លះបម្រុងព្រះរាជា(ទទួលរាជការ) រមែងបានវត្ថុទាំងឡាយ មានយាន ពាហនៈ ស្រុក និគមជាដើម ។ មាតាឬបិតា កាលសោយសិរីដែលកើតឡើង ដោយអានុភាពនៃកូនទាំងនោះ រមែងត្រេកអរ ។ ម្យ៉ាងទៀត ក្នុងថ្ងៃវិកាយជាដើម មាតាឬបិតា រមែងត្រេកអរដែលឃើញកូនទាំងឡាយ អ្នកប្រជាប់តាក់តែងហើយប្រើប្រាស់សម្បត្តិដែលមាន ។ ព្រោះហេតុនោះ ទេវតាសំដៅយកការប្រព្រឹត្តទៅនោះ ទើបពោលថា ឧន្ទតិ **បុត្តេហិ បុត្តិមា អ្នកមានកូន រមែងត្រេកអរនឹងកូន ទាំងឡាយ**ដូច្នេះ ។

បទថា គោហិ ឥជេវ **នឹងគោទាំងឡាយ ដូច្នោះដែរ** សេចក្ដីថា អ្នកមានកូនរមែងត្រេកអរនឹងកូន យ៉ាងណា សូម្បីអ្នកមានគោ ក៏ដូច្នោះ គ្រាឃើញហ្វូងគោច្រើន ព្រោះអាស្រ័យ គោទាំងឡាយ បានបញ្ជូគោរស ទើបឈ្នះថា រមែងត្រេកអរនឹងគោ

ទាំងឡាយ ។

ពាក្យថា **ឧបធិ** ក្នុងបទថា ឧបធីហិ នរស្ស ឥន្ទ្ធ **ឧបធិទាំងឡាយជាគ្រឿងត្រេកអររបស់ជន** នេះ បានដល់ ឧបធិ ៤ យ៉ាង គឺកាមូបធិ (ឧបធិគឺ កាម) ខន្ធូបធិ (ឧបធិគឺខន្ធ) កិលេសូបធិ (ឧបធិគឺ កិលេស) និងអភិសង្ខារូបធិ (ឧបធិ គឺ អភិសង្ខារ) ។

ពិតមែន សូម្បីកាមទាំងឡាយ ព្រះមានព្រះភាគក៏ត្រាស់ហៅថា **ឧបធិ** ព្រោះវចនត្ថៈនេះថា សេចក្តីសុខដែលបុគ្គលចូលទៅតាំងទុកក្នុងកាមគុណនេះ ក៏ព្រោះកាមទាំងនេះជាទីអាស្រ័យនៅនៃសេចក្តីសុខដូចដែលត្រាស់ទុក យ៉ាងនេះថា សេចក្តីសុខ សេចក្តីសោមនស្ស យ៉ាងណា អាស្រ័យកាមគុណ ៥ កើតឡើងនេះឈ្មោះថាសេចក្តីពេញចិត្តក្នុងកាមទាំងឡាយដូច្នេះ ។

សូម្បីខន្ធទាំងឡាយ ក៏ត្រាស់ហៅថា **ឧបធិ** ព្រោះខន្ធទាំងនោះជាទីអាស្រ័យនៅនៃទុក្ខដែលមានខន្ធជាមូល ។ សូម្បីកិលេសទាំងឡាយក៏ត្រាស់ហៅថា **ឧបធិ** ព្រោះកិលេសទាំងនោះ

ជាទីអាស្រ័យនៅនៃទុក្ខក្នុងអបាយ ។ សូម្បីអភិសង្ខារទាំងឡាយ ក៏ត្រាស់ហៅថា **ឧបធិ** ព្រោះអភិសង្ខារទាំងនោះជាទីអាស្រ័យនៅនៃទុក្ខក្នុងភព ។ តែក្នុងទីនេះ លោកប្រាថ្នាយក **កាមូបធិ** ព្រោះកាមគុណ ៥ ដែលបុគ្គលបំរើដោយអំណាចនៃវត្ថុទាំងឡាយ មានការនៅក្នុងប្រាសាទ ៣ រដូវជាដើម មានទីអង្គុយទីដេក អាភរណៈអាវសំពត់ដែលឱ្ឡារមានបរិវារធ្លាប់ បម្រើដោយការរបាំ រាំជាដើមជាហេតុនាំមកនូវបីតិសោមនស្ស រមែងញ៉ាំងនរៈឱ្យត្រេកអរនៅ ដូច្នោះ បុត្រទាំងឡាយនិងគោទាំងឡាយយ៉ាងណា គប្បីជ្រាបថា សូម្បីឧបធិទាំងនេះក៏ដូច្នោះ ព្រោះជាទីត្រេកអរបស់នរៈ ។

បាទនៃគាថាថា ន ហិ សោ នន្ទតិ យោ និរូបធិ **អ្នកណាមិនមានឧបធិ អ្នកនោះមិនមានអ្វីត្រេកអរ** សេចក្ដីថា បុគ្គលណា មិនមានឧបធិ គឺវៀរចាកការដល់ព្រមដោយកាម-គុណ ជាអ្នកក្រខ្សត់ មានអាហារនិងគ្រឿងស្លៀកដណ្ដប់លំបាក រកបានបុគ្គលនោះឯងរមែងមិនមានសេចក្ដីត្រេកអរ ។

សួរថា មនុស្សដូចប្រេត មនុស្សដូចសត្វនរក ដ្ឋានេះនិង

ត្រេកអរយ៉ាងណា ។

ឆ្លើយថា សេចក្តីនេះ ព្រះមានព្រះភាគ ត្រាស់វិសជ្ជនា ទុកហើយ (ក្នុងគាថា ទី ២៧) ។

ព្រះមានព្រះភាគ ទ្រង់ស្តាប់ពាក្យ (ដែលទេវតាពោល) នេះហើយ ទ្រង់ព្រះតម្រិះថា ទេវតានេះ រមែងធ្វើរឿងនៃសេចក្តីសោកសៅនុ៎ះឯង ឱ្យជារឿងគួរត្រេកអរយើងនឹងសម្តែងសេចក្តីដែលវត្ថុទាំងនោះ ជារឿងនៃសេចក្តីសោកសៅដល់លោក ដូច្នេះ កាលនឹងទម្លាយវាទៈរបស់ទេវតានោះ ដោយឧបមានោះឯងដូចបុគ្គលញ៉ាំងពាក្យខ្ទះ ជាហេតុផលឱ្យធ្លាក់ទៅព្រោះហេតុផល ទើបទ្រង់ផ្ទាស់ព្រះគាថា នោះឯង ហើយត្រាស់ថា សោចតិ **រមែងសោកសៅ** ជាដើម ។

បណ្តាបទទាំងនោះ បទថា សោចតិ **បុត្តេហិ រមែងសោកសៅនឹងកូនទាំងឡាយ** សេចក្តីថា កាលបុត្រទាំងឡាយអន្តរធានទៅក្តី សាបសូន្យចេញទៅក្តី ដោយអំណាចនៃការធ្វើដំណើរទៅប្រទេសផ្សេង ៗ សូម្បីមានសេចក្តីសង្ស័យក្នុងកាល

ឥឡូវនេះថា នឹងសាបសូន្យទៅមាតានិងបិតារមែងសោកសៅ ។

មួយទៀត កាលបុត្រស្លាប់ហើយក្តីកំពុងនឹងស្លាប់ក្តីឬត្រូវ រាជបុរស ឬចោរជាដើមចាប់ខ្លួនទៅ ឬថា ចូលទៅកាន់កណ្តាប់ដៃ របស់សត្រូវទាំងឡាយ មាតាឬបិតា ជាអ្នកមានសេចក្តីសង្ស័យ ថា ស្លាប់ហើយក្តី រមែងសោកសៅ ។ កាលបុត្របួតធ្លាក់អំពី ដើមឈើ ឬអំពីភ្នំជាដើម មានដៃនិងជើងបាក់ក្តី របួសជាំក្តី មាន សេចក្តីសង្ស័យថា បែកបាក់ហើយក្តី មាតាឬបិតា រមែងសោក សៅ ។ បុគ្គលមានបុត្រ រមែងសោកសៅព្រោះបុត្រទាំងឡាយ យ៉ាងណា សូម្បីអ្នកមានគោក៏ដូច្នោះ រមែងសោកសៅ ព្រោះគោ ទាំងឡាយ ដោយអាការ ៩ យ៉ាង ។ បានព្រះគាថា ថា ឧបធី ហិ ន រស្ស សោចន **ដ្ឋិត ឧបធិទាំងឡាយជា គ្រឿងសោកសៅ របស់ជន** សេចក្តីថា ដូចយ៉ាងថា បុត្រនិងគោទាំងឡាយយ៉ាង ណា សូម្បីឧបធិគឺ កាមគុណ ៥ ក៏ដូច្នោះ រមែងញ៉ាំងនរៈឱ្យ សោកសៅ ដោយនយ័ដែលត្រាស់ទុកថា ៖

"បើថា សត្វនោះមានសេចក្តីស្រឡាញ់ មានសេចក្តីពេញ

ចិត្តកើតហើយ កាមទាំងនោះ រមែងញ៉ាំងគេឱ្យហិនហោចទៅ ដូចបុគ្គលត្រូវកូនសរចាក់ហើយ រមែងវិនាស ដូច្នោះ” ។

ព្រោះដូច្នោះ បណ្ឌិតគប្បីជ្រាបថា សេចក្តីសោកសៅ របស់នរៈ ក៏គឺរឿងសេចក្តីសោកសៅនុ៎ះឯង ។

បទថា ន ហិ សោ សោចតិ យោ និរូបធិ លុះតែអ្នកណាមិនមានឧបធិ ទើបអ្នកនោះ មិនសោកសៅ សេចក្តីថា ព្រះមានព្រះភាគត្រាស់អធិប្បាយទុកថា ឧបធិ ៤ ទាំងនេះ មិនមានដល់អ្នកណា អ្នកនោះ រមែងមិនមានឧបធិ គឺសេចក្តីសោកសៅ ម្នាលទេវតា ព្រោះហេតុនោះឯង ព្រះមហាវីណាស្រពន់ងសោកសៅ ឬកំពុងសោកសៅមានឬ ដូច្នេះឯង ។

មតរោទនជាតក

[ការទួញយំដល់មនុស្សស្លាប់]

កាលព្រះមានព្រះភាគគង់នៅវត្តជេតពន ទ្រង់ប្រារព្ធកុដុម្ពីក៍ម្នាក់នៅក្នុងក្រុងសាវត្ថី ទ្រង់ត្រាស់ព្រះធម្មទេសនានេះ មានពាក្យជាដើមថា មតមតេ រោទ ដូច្នេះជាដើម ។

បានឮថា បង្ហុស្សរបស់កុដុម្ពីក៍ម្នាក់ បានធ្វើមរណកាលទៅ ពពួកញាតិទាំងឡាយ មានការទួញយំសោកស្តាយស្រណោះអាឡោះអាល័យ ចំពោះការធ្វើមរណកាលរបស់កុដុម្ពីក៍នោះណាស់ គេម្នាក់ ៗមិនងូតទឹក មិនបរិភោគអាហារ ពួកគេតែងតែទៅកាន់ចាំ៉ឆារៀងរាល់ព្រឹក ហើយមានការទួញយំសោកសៅនៅទីនោះរាល់ថ្ងៃ គ្រានោះ ព្រះបរមស្ថាសាទ្រង់ប្រមើលមើល់ឧបនិស្សយរបស់សត្វលោកក្នុងវេលាបច្ចូសសម័យ(វេលា ជិតភ្លឺ) ទ្រង់បានឃើញឧបនិស្សយរបស់កុដុម្ពីក៍ដែលនឹងត្រូវបានសម្រេចនូវសោតាបត្តិផល គ្រានោះទើបទ្រង់ត្រិះរិះថាតថាគត គួរនឹងនាំយកនូវអតីតហេតុមកវម្ងាប់ សេចក្តីសោកសៅរបស់បុគ្គលពួកនោះ កាលបើយើងនាំយកអតីតនិទានមកសម្តែងហើយ កុដុម្ពីក៍នេះនឹងតាំងនៅក្នុងឋានៃសោតាបត្តិផល តែបើវៀរចាកតថាគតចេញហើយ បុគ្គលដទៃមិនអាចឡើយ មានតែតថាគតទេ ដែលជាទីពឹងរបស់កុដុម្ពីក៍នេះ លុះដល់ពេលព្រឹកឡើងព្រះអង្គទ្រង់ត្រឡប់មកអំពីបិណ្ឌបាត្រក្នុងវេលាខាងក្រោយភត្តហើយ ទ្រង់នាំបច្ឆាសមណៈទៅកាន់ផ្ទះរបស់កុដុម្ពីក៍នោះ កុដុម្ពីក៍ព្រមទាំងពពួកញាតិ

ឃើញព្រះស្តាសានិមន្តមកហើយ ទើបពោលថា ពួកអ្នកទាំងឡាយ ចូរក្រាលអាសនៈ ហើយក៏បាននិមន្តព្រះស្តាសាចូលមក ព្រះស្តាសាក៏ស្តេចនិមន្តចូលទៅ ហើយក៏គង់នៅលើអាសនៈដែលគេក្រាលទុក ។ ចំណែកកុដុម្ពីក៍ក៏មក ក្រាបថ្វាយបង្គំព្រះសាស្តា ហើយអង្គុយនៅក្នុងទីសមគួរ លំដាប់នោះ ព្រះសាស្តាទ្រង់ត្រាស់នឹងកុដុម្ពីក៍នោះថា ម្នាលកុដុម្ពីក៍ អ្នកខ្ជិលចិត្តឬ ? កុដុម្ពីក៍ក្រាបទូលថា ព្រះករុណាព្រះអង្គ ខ្ញុំព្រះអង្គខ្ជិលចិត្តតាំងពីកាលដែលបងប្រុសរបស់ខ្ញុំព្រះអង្គស្លាប់ទៅ ព្រះសាស្តាទ្រង់ត្រាស់ថា ម្នាលកុដុម្ពីក៍ **ធម្មតាសង្ខារទាំងឡាយ មិនទៀងទេ គ្រប់របស់ទាំងឡាយដែលកើតហើយ រមែងបែកធ្លាយទៅវិញជាធម្មតាអ្នក មិនគួរខ្ជិលចិត្តចំពោះរឿងនេះទេ** សូម្បីបូរាណបណ្ឌិតទាំងឡាយ កាលបងប្រុសស្លាប់ទៅ ក៏មិនបានខ្ជិលចិត្តទ្បើយ កុដុម្ពីក៍នោះ ក៏ទូលអារាធនានិមន្តឱ្យព្រះអង្គ សម្តែងរឿងអតីតកាល ព្រះអង្គក៏បានសម្តែងថា ៖

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងក្រុងសាវត្ថី កាលនោះព្រះបរមពោធិសត្វចាប់បដិសន្ធិ

នៅក្នុងត្រកូលសេដ្ឋីម្នាក់ មានទ្រព្យសម្បត្តិ ៨០ កោដិ កាលព្រះបរមពោធិសត្វចំរើនវ័យហើយ មាតាបិតាក៏បានធ្វើមរណកាលទៅ បងប្រុសរបស់ព្រះអង្គក៏បានចាត់ចែងទ្រព្យសម្បត្តិជំនួស (គឺចែកទ្រព្យគ្នា) ចំណែកព្រះបរមពោធិសត្វមិនបានចេញទៅណាទេ គឺព្រះអង្គនៅជាមួយនឹងបងប្រុសក្នុងពេលជាខាងក្រោយមក បងប្រុសរបស់ព្រះអង្គនោះក៏បានធ្វើមរណកាលទៅ ដោយជម្ងឺឈឺស្ទាត់ ពពួកញាតិមិត្តនិង អាមាត្រទាំងឡាយនាំគ្នាបីត្រកងទួញយំ មិនមានពួកញាតិណាមួយមិនទួញយំនោះឡើយ ឯចំណែកព្រះបរមពោធិសត្វវិញ មិនសោយសោក មិនទួញយំ សូម្បីតែទឹកភ្នែកមួយដំណក់ក៏មិនធ្លាក់ ពពួកញាតិទាំងឡាយឃើញ ព្រះបរមពោធិសត្ត មិនសោយសោកដូច្នោះ ទើបនាំគ្នាតិះដៀលព្រះបរមពោធិសត្វថា មើលចុះអស់លោកទាំងឡាយអើយ កាលបងប្រុសរបស់ខ្ញុំន ស្លាប់ទៅហើយ អាការៈសូម្បីត្រឹមតែមុខស្រពោន ក៏មិនមានដែរ គេមានចិត្តរីងណាស់ គេប្រាថ្នាឱ្យតែបងប្រុសរបស់គេស្លាប់ ដោយគិតថា យើងនឹងបានប្រើប្រាស់ទ្រព្យសម្បត្តិទាំងពីរចំណែក ពពួកញាតិទាំងឡាយពោលតិះ

ដៀល ព្រះបរមពោធិសត្វថា បងប្រុសស្លាប់ទៅ មិនយំសោកសោះ ព្រះពោធិសត្វបានស្តាប់ពាក្យរបស់អ្នកទាំងអស់នោះហើយ ទើបពោលថា អ្នកទាំងឡាយមិនដឹងនូវលោកធម៌ ៨ ប្រការ[1] ព្រោះសេចក្តីដែលខ្លួនជាមនុស្សល្ងង់ខ្លៅ បានជានាំគ្នាទួញយំថា បងប្រុសរបស់យើងស្លាប់ហើយ សូម្បីខ្ញុំនេះក៏នឹងស្លាប់ដែរ ព្រោះហេតុអ្វី អ្នកទាំងឡាយទើបមិនទួញយំដល់ខ្ញុំថា អ្នកនេះក៏នឹងស្លាប់ សូម្បីតែអ្នកទាំងឡាយ ក៏នឹងស្លាប់ ១ ព្រោះហេតុអ្វីអ្នកទាំងឡាយ មិនទួញយំដល់ខ្លួនឯងខ្លះទៅថា យើងទាំងឡាយ ក៏នឹងស្លាប់ ព្រោះថាសង្ខារទាំងឡាយ ជារបស់មិនទៀងទេ អ្នកទាំងឡាយគឺជាមនុស្សល្ងង់ខ្លៅ មិនដឹងនូវលោកធម៌ ៨ ប្រការទើបនាំគ្នាទួញយំ ព្រោះសេចក្តីមិនដឹង យើងទាំងឡាយទួញយំដើម្បីអ្វី បន្ទាប់មកព្រះបរមពោធិសត្វព្រះអង្គបានពោលព្រះគាថានេះថា ៖

មតមតមេវ ភោ ន ហិតំ ភោ យោ ២ បរិសុ[3]ត[4]

---

១. មានលាភ ២. អត់លាភ ៣. មានយស ៤. អត់យស ៥. សរសើរ ៥. និន្ទា ៧. សុខ ៨. ទុក្ខ ។

សព្វេ សរីរធារិនោ អនុបុព្វេន ជហន្តិ ជីវិតំ ។

អ្នកទាំងឡាយ យំរកបុគ្គលស្លាប់ទៅហើយ ៗតែម្យ៉ាង បុគ្គលណា បម្រុងស្លាប់ អ្នកទាំងឡាយមិនយំរកបុគ្គលនោះ សោះ ពួកសត្វទាំងឡាយ ជាអ្នកទ្រទ្រង់នូវសរីរៈតែងតែលះបង់ នូវជីវិតតាមលំដាប់ ។

ឧភោ មនុស្ស ចតុប្ប្ទា ធាបក្ខិគណា ឧរគា ច ភោគិនោ

យម្ហិ សរីរេ អនិស្ស្ឫរ រមមានាវ ជហន្តិ ជីវិតំ ។

ពួកទេវតា មនុស្ស សត្វជើង ៤ ពួកសត្វស្លាប ពួកពស់ ប្រកបដោយភ្នែន មិនជាធំក្នុងសរីរៈឡើយ តែងលះបង់ជីវិត ទាំងកំពុងត្រេកអរ(ក្នុងហានដែលខ្លួនកើតហើយ) ។

ឯវំ ចលិតំ អសណ្ឋិតំ សុខទុក្ខំ មនុជេសុ អបេក្ខិយ

គន្ធិតំ រុណ្ណតំ និរត្ថកំ ក៏ីវោ សោកគណ្ឌាភិ ក៏ីរេ ។

សុខនិងទុក្ខជាធម្មជាតិកម្រើក មិនតាំងនៅយ៉ាងនេះ បុគ្គលគួរមិលមើលក្នុងពួកមនុស្ស ការកន្ទ្ធ ក់ទ្ទេញ ការយំសោកជារបស់មិនមានប្រយោជន៍ទេ ព្រោះហេតុអ្វី គំនរនៃសេចក្ដីសោកគ្របសង្ក្ដ ត់អ្នកទាំងឡាយ ។

ធុត្តា សោណ្ហា ច អគតា ពាលា សូរា អយោគិនោ
ធីរំ មញ្ញន្តិ ពាលោតិ យេ ធម្មស្ស អកោវិទាតិ ។

ពួកជនណា ជាអ្នកលេង ជាអ្នកស្រវឹង មិនធ្វើ(សេចក្តីចំរើន) ជាមនុស្សពាលក្ងៀវក្ងា មិនមានសេចក្តីព្យាយាម មិនឈ្លាសក្នុងធម៏ ពួកជននោះតែងសម្គាល់នូវអ្នកប្រាជ្ញ(ដែលមិនយំសោកជាដើម) ថាជាមនុស្សពាលទៅវិញ ។

ព្រះស្តាសា គ្រាទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទើបទ្រង់ប្រកាសសច្ចៈ ហើយប្រជុំជាតកក្នុងវេលាចប់សច្ចៈកុដុម្ពីក តាំងនៅក្នុងសោតាបត្តិផល បណ្ឌិតអ្នកសម្តែងធម៏ដល់មហាជន ហើយធ្វើឱ្យមហាជនវិនាសសេចក្តីសោកក្នុងកាលនោះ គឺតថាគតនេះឯង ។

រឿងព្រះកុណ្ឌលកេសីថេរី

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនាងកុណ្ឌកេសី ត្រាស់ព្រះធម៏ទេសនានេះថា "យោចគាថា សតំ ភាសេ" ជាដើម ។

[ធីតាសេដ្ឋីបានចោរជាស្វាមី]

បានឮថា ធីតាសេដ្ឋីម្នាក់នៅក្នុងក្រុងរាជគ្រិះ មានអាយុគ្រប់ ១៦ ឆ្នាំ មានរូបល្អ គួរពិចពិលរមិលមើល ។ ជាទីនាំមកនូវសេចក្តីស្រឡាញ់ ។ **ក៏នារីទាំងឡាយដែលតាំងនៅក្នុងវ័យនោះ តែងតែយកចិត្តទុកជាក់ចំពោះបុរស ១ ទ្បេះទ្បោះក្នុងបុរស ១** ។ គ្រានោះ មាតាបិតាឱ្យធីតានោះ នៅក្នុងបន្ទប់ដ៏មានសីរីលើផ្ទៃជាន់លើនៃប្រាសាទ៧ជាន់,បានប្រគល់ទាសីម្នាក់ប៉ុណ្ណោះឱ្យបំរើនាង ។

គ្រានោះ ពួករាជបុរសចាប់បានចោរម្នាក់ ចងស្ងាបសេកវាយដោយរំពាត់ផ្ដៀម្ខង ៤ រំពាត់ ១ ហើយនាំទៅកាន់ទីសម្ងាប់ ។ ធីតាសេដ្ឋីបានឮសំឡេងរបស់មហាជន ក៏គិតថា មានរឿងអ្វីហ្ន៎ ? ឈរក្រឡេកមើលនៅលើផ្ទៃប្រាសាទ ឃើញចោរនោះហើយ ក៏មានចិត្តប្រតិព័ទ្ធ កើតក្តីស្រឡាញ់ចោរ ក៏ទៅដេកលើគ្រែ ។ លំដាប់នោះមាតាបិតាសួរនាងថានែកូនសម្ងាញ់ កូនឯងកើតអី ?

ធីតាសេដ្ឋី. បើខ្ញុំបានបុរស ដែលត្រូវពួកគេចាប់នាំដោយចោទថាជាចោរនោះខ្ញុំនឹងមានជីវិតរស់នៅបើមិនបានទេ,ជីវិត ខ្ញុំ

ក៏នឹងមិនមាន, ខ្ញុំនឹងស្លាប់ក្នុងទីនេះឯង ។

មាតា. នែកូនសម្លាញ់ កូនឯងកុំធ្វើយ៉ាងនេះឡើយ, កូនឯងនឹងបានស្វាមីដទៃដែលមានជាតនិងភោគៈស្មើយើង ។

ធីតាសេដ្ឋី. ខ្ញុំមិនត្រូវការបុរសដទៃទេ កាលបើមិនបានបុរសអ្នកនេះទេ ខ្ញុំនឹងស្លាប់ ។

មាតា. កាលមិនអាចអង្វរកូនស្រីឱ្យយល់ព្រមបានក៏ប្រាប់លោកសេដ្ឋី ។ សូម្បីសេដ្ឋីក៏មិនអាចញ៉ាំងធីតានោះឱ្យយល់ព្រមបាន ក៏គិតថា តើយើងត្រូវធ្វើដូចម្តេចទៅហ្ន៏ ? លុះគិតដូច្នោះហើយ ក៏បញ្ជូនបង្ហូចទ្រព្យមួយពាន់ដល់រាជបុរស ដែលបញ្ជាឱ្យចាប់ចោរនោះ ដោយពាក្យថា "លោកចូរទទួលទ្រព្យនេះទុកហើយ ឱ្យបុរសនោះ មកខ្ញុំវិញ" ។ រាជបុរសនោះយល់ព្រមដោយពាក្យថា ប្រពៃហើយទទួលកហាបណៈនោះហើយ ដោះលែងចោរនោះទៅ សម្លាប់បុរសដទៃជំនួសហើយ ក្រាបទូលព្រះរាជាថា បពិត្រសម្មតិទេព ខ្ញុំព្រះអង្គ សម្លាប់ចោរនោះហើយ ។ ចំណែកសេដ្ឋីនោះ បានប្រាប់ទៅបុរសនោះថា ឯងត្រូវធ្វើជាស្វាមីឱ្យ សប្បាយរីករាយ ទើបតាក់តែងដោយគ្រឿងប្រដាប់ទាំងពួង ទើបចាត់ចែងយាគូជា

ដើមដល់ចោរ ន៏ុះដោយដៃខ្លួនឯង ។

[ចោរគិតឧបាយនាំភរិយាទៅសម្លាប់]

ដោយកាលកន្លងទៅ ២-៣ ថ្ងៃប៉ុណ្ណោះ ចោរនោះក៏បានគិតថា កាលណាហ្ន៏ ? យើងនឹងបានសម្លាប់ស្ត្រីនេះ ហើយ កាន់យកគ្រឿងប្រដាប់របស់ស្ត្រីនេះ លក់ស៊ីចាយក្នុងរោងសុរាឱ្យបានសប្បាយតែម្តង" ។ ចោរនោះគិតឃើញឧបាយមួយដោយសម្គាល់ថា ឧបាយនេះល្អ អាចប្រើការបាន ទើបទៅដេកលើគ្រែមិនព្រមបរិភោគអាហារ ។ ពេលនោះ នាងចូលទៅរកចោរនោះ ហើយ សួរថា"អ្នកជាម្ចាស់អ្នកមានរឿងអ្វី ?

ចោរ. ម្នាលនាងដ៏ចម្រើន គ្មានរឿងអ្វីទេ ។

ធីតាសេដ្ឋី. ក៏មាតាបិតារបស់ខ្ញុំ ខឹងនឹងអ្នកឬ ?

ចោរ. ម្នាលនាងដ៏ចម្រើន មិនខឹងទេ ។

ធីតាសេដ្ឋី. បើដូច្នោះ រឿងនេះដូចម្តេចទៅ ?

ចោរ. ម្នាលនាងដ៏ចម្រើន ថ្ងៃដែលគេចាប់បងទៅនោះ បងបានបួងសួងទេវតា ដែលអាស្រ័យនៅនឹងភ្នំសម្រាប់ចោលចោរនោះ ទើបមានជីវិតរស់នៅ សូម្បីអ្នកក៏បងបានដោយអានុ

ភាពរបស់ទេវតានោះដែរ, ម្នាលនាងដ៏ចម្រើន បងគិតថា បងនឹងធ្វើពលីកម្មចំពោះទេវតា ។

ធីតាសេដ្ឋី. បពិត្រអ្នកជាម្ចាស់ អ្នកកុំព្រួយឡើយ, ខ្ញុំនឹងជួយចាត់ចែងក្នុងការធ្វើពិធីកម្ម,សូមអ្នកប្រាប់មកត្រូវការអ្វី ?

ចោរ. ត្រូវការមធុបាយាសដែលមានទឹកតិច និងផ្ការឈើដែលមានលាជជាគម្រប់ ៥ ។

ធីតាសេដ្ឋី. ប្រពៃណាស់,ខ្ញុំនឹងចាត់ចែងឱ្យ ។

ធីតាសេដ្ឋីនោះចាត់ចែងពលីកម្មគ្រប់យ៉ាង ហើយពោលថា "បពិត្រអ្នកជាម្ចាស់ មកចុះ, យើងនឹងទៅ" ។

ចោរ.ម្នាលនាងដ៏ចម្រើនបើដូច្នោះនាងឱ្យពួកពពួក ញាតិរបស់នាងត្រឡប់ទៅយកសំពត់ និងគ្រឿងប្រដាប់ដែលមានតម្លៃច្រើន មកប្រដាប់តាក់តែងខ្លួនហើយ, យើងនឹងសើច លេងដើរទៅយ៉ាងសប្បាយ ។

នាងក៏បានធ្វើយ៉ាងនោះហើយ ។ លុះធ្វើដំណើរដល់ជើងភ្នំចោរនោះក៏បានពោលនឹងនាងថា "ម្នាលនាងដ៏ចម្រើន ខាងមុខអំពីនេះ យើងមិនអាចទៅច្រើនគ្នាបានទេ យើងអាចទៅបានតែ

ពីរនាក់ប៉ុណ្ណោះ ដូច្នេះ, ចូរនាងបញ្ឈប់ជនដ៏សេសត្រមទាំងយាន ហើយធ្វើដំណើរទៅពីរនាក់ លើកកាជនៈពលីកម្មទៅដោយខ្លួនឯង" ។ ចោរបានធ្វើដូច្នោះហើយ ចោរនាំនាងទ្បើងកាន់ភ្នំដែលជាកន្លែងចោលចោរ ។

ក៏មនុស្សទាំងឡាយ ទ្បើងកាន់ភ្នំនោះតាមម្ខាងនៃភ្នំ ។ ម្ខាងទៀតជាច្រាំងជាច់, មនុស្សទាំងឡាយឈរលើកំពូលភ្នំហើយ ចោលចោរទាំងឡាយតាមម្ខាងនៃភ្នំនោះ ចោរទាំងនោះ ជាច់ជាកំណាត់តូចធំ ធ្លាក់ចុះទៅលើផែនដី ព្រោះហេតុដូច្នោះ ទើបគេហៅភ្នំនោះថា ភ្នំជាទីចោលចោរ ។ នាងឈរលើកំពូលភ្នំនោះហើយ ពោលថា បពិត្រអ្នកជាម្ចាស់ អ្នកចូរធ្វើពលិកម្មចុះ ។ ចោរនោះ បាននៅស្ងៀម កាលនាងសួរទៀតថា អ្នកជាម្ចាស់ ហេតុអ្វីបានជាអ្នកនៅស្ងៀម ? ទើបប្រាប់នាងថា ខ្ញុំមិនត្រូវការពលិកម្ម អ្វីទេ ខ្ញុំ បញ្ជោតនាងឱ្យមកកាន់ទីនេះទេតើ !

ធីតាសេដ្ឋី. ព្រោះហេតុអ្វី ? អ្នកជាម្ចាស់ ?

ចោរ. ព្រោះយើងត្រូវការសម្លាប់នាង ប្លន់យកគ្រឿងប្រដាប់របស់នាង ។

នាងត្រូវមរណភ័យគ្របសង្កត់ហើយ ក៏ពោលថា បពិត្រអ្នកជាម្ចាស់នាយ នាងខ្ញុំព្រមទាំងគ្រឿងប្រដាប់នាងខ្ញុំ ជារបស់លោកហើយទេតើ ហេតុអ្វី ទើបលោកនិយាយយ៉ាងនេះ ? ចោរនោះសូម្បីនាងអង្វរវើយ ១ថា "លោកកុំធ្វើយ៉ាងនេះឡើយ" ក៏នៅតែពោលថា "ខ្ញុំនឹងសម្លាប់នាងឱ្យទាល់តែបាន" ។ នាងពោលថា "បើដូច្នោះ តើវាមានប្រយោជន៍ដល់លោក ដោយសេចក្តីស្លាប់របស់នាងខ្ញុំនោះ, សូមលោកកាន់យកគ្រឿងប្រដាប់ទាំងនេះហើយ ទុកជីវិតឱ្យនាងខ្ញុំចុះ,ចាប់តាំងពីពេល នោះទៅ លោកចូរចាំនាងខ្ញុំថា ស្លាប់ហើយ ឬថាទុកនាងខ្ញុំជាទាសីរបស់លោកក៏ បាន លុះអង្វរចោរដូច្នេះហើយក៏បានពោលគាថានេះថា ៖

"សង្វាមាសទាំងនេះ សុទ្ធតែសម្រេចហើយដោយកែវពិទូរ្យ,បពិត្រអ្នកដ៏ចម្រើន សូមលោកយកទាំងអស់ ហើយ ចូរប្រកាសថា នាងខ្ញុំជាទាសីចុះ" ។

ចោរស្តាប់ពាក្យនោះហើយ ពោលថា កាលខ្ញុំធ្វើដូច្នោះ, នាងត្រឡប់ទៅផ្ទះវិញ ប្រាប់មាតាបិតារបស់នាង, ខ្ញុំមិនអាចទុកជីវិតឱ្យនាងបានទេ, ខ្ញុំត្រូវតែសម្លាប់នាង ដូច្នេះ នាងកុំខ្ជឹកខ្ជួល

អ៊ី ហើយពោលគាថានេះថា ៖

"នាងកុំខ្ជឹកខ្ជួលឡើយ ចូរវេចទ្រព្យឱ្យឆាប់ ជីវិតរបស់ខ្ញុំនឹងកាន់យកទ្រព្យទាំងអស់ ។

[ធីតាសេដ្ឋីប្រាន់ចោរធ្លាក់ជ្រោះស្លាប់]

នាងគិតថា "ឱកម្មនេះធ្ងន់ណាស់ហ្ន៎, ដែលឈ្មោះថាបញ្ញាមិនមែនសាងមកទុកស្ងាស៊ីទេ ការពិតនោះ សាងមកទុកពិចារណា, យើងនឹងជីងកិច្ចដែលគួរធ្វើចំពោះបុរសនេះ ។

លំដាប់នោះ នាងពោលនឹងចោរនោះថា "បពិត្រអ្នកជាម្ចាស់ កាលលោកត្រូវគេចាប់នាំទៅកាន់ទីពិឃាត ដោយចោទនោះ នាងខ្ញុំបានប្រាប់មាតាបិតារបស់ខ្ញុំ, លោកទាំងពីរនោះលះបង់ទ្រព្យមួយពាន់ ឱ្យគេនាំលោកមកកាន់ផ្ទះ, របស់នាងខ្ញុំហើយបានប្រគល់នាងខ្ញុំ ឱ្យធ្វើជាភរិយារបស់លោកតាំងពីពេលនោះមក នាងខ្ញុំក៏មានឧបការៈចំពោះលោក,ថ្ងៃនេះសូមឱ្យនាងខ្ញុំ មើលលោកឱ្យជាក់ច្បាស់ដើម្បីបានថ្វាយបង្គំលោក ។ ចោរនោះពោលថា "ប្រពៃហើយនាងដ៏ចម្រើន, នាងចូរមើលខ្ញុំឱ្យបានច្បាស់ ហើយថ្វាយបង្គំចុះ លុះពោលដូច្នេះហើយ ក៏ឈរនៅលើកំពូលភ្នំនោះ ។

គ្រានោះនាងដើរប្រទក្សិណ ៣ ជុំ ថ្វាយបង្គំចោរនោះក្នុងទិសទាំង ៤ ហើយពោលថា បពិត្រអ្នកជាម្ចាស់ នេះជាការយើញ គ្រាចុងក្រោយរបស់នាង ខ្ញុំចាប់ពីពេលនេះទៅ កាលដែលលោកយើញនាងខ្ញុំ ឬកាលដែលនាងខ្ញុំយើញលោកមិនមានទៀតទេ" ហើយស្រាវឱ្យចោរ អំពីខាងមុខ ខាងក្រោយ រួចបានឈរពីក្រោយ យកដៃម្ខាងចាប់កចោរ ដែលឈរដោយសេចក្ដីប្រមាទ យកដៃម្ខាងទៀត ចាប់ត្រង់ក្លៀកអំពីខាងក្រោយ ច្រានទម្លាក់ជ្រោះភ្នំ ។ ចោរនោះត្រូវធ្លាក់ចុះទៅ ១ ប៉ះ១ប់ទ្ធ ១ ១ ១

ប្រសិនបើយើងទៅផ្ទះ មាតាបិតានឹងសួរយើងស្វាមីរបស់ នាងទៅណា ? កាលបើយើងឆ្លើយប្រាប់គាត់ថា ខ្ញុំសម្លាញ់ចោលហើយ គាត់នឹងចាក់ដោតយើងដោយលំពែង គឺមាត់ថា ម្នាលស្រីក្បាលរឹង យើងបានឱ្យទ្រព្យមួយពាន់ ទៅរាជបុរស ហើយឱ្យគេនាំបុរសនោះមក ដើម្បីធ្វើស្វាមី តែឥឡូវនេះ នាងបែរជាសម្លាប់គេទៅវិញ ហើយប្រសិនយើងប្រាប់គាត់ថា គេប្រាថ្នានឹងសម្លាប់ខ្ញុំ ដើម្បីយកគ្រឿងអលង្ការ គាត់ក៏មិនជឿ ដូច្នេះ យើងមិនត្រឡប់ទៅផ្ទះវិញទេ លុះគិតដូច្នេះហើយក៏លាក់ គ្រឿងប្រដាប់ទុកក្នុងទីនោះ ហើយដើរចូលទៅកាន់ព្រៃ ដើរទៅដោយលំដាប់ក៏ដល់អាស្រមរបស់បរិព្វាជក ក៏ចូលទៅថ្វាយបង្គំហើយពោលថា បពិត្រលោកដ៏ចម្រើន សូមលោកទាំងឡាយឱ្យខ្ញុំបព្វជ្ជាក្នុងសម្នាក់លោកម្ចាស់ទាំងឡាយផង ។ គ្រានោះបរិព្វាកទាំងឡាយ ក៏ឱ្យនាងបព្វជ្ជា ។

[ធីតាសេដ្ឋីបួសជាបរិពាជិកា]

ធីតាសេដ្ឋីនោះ លុះបួសហើយ ក៏សួរថា បពិត្រលោកម្ចាស់ដ៏ចម្រើន អ្វីដែលជាគុណជាតិដ្ឋិតស់ចំផុតនៃការបួសរបស់

ពួកលោកទាំងឡាយ ។

បរិព្វាជក.ម្នាលនាងដ៏ចម្រើន បុគ្គលធ្វើបរិកម្មក្នុងកសិណ ១០ ហើយញ្ចាំងឈានឱ្យកើតឡើងខ្លះ, រៀនវាទៈមួយពាន់ខ្លះ, នេះជាប្រយោជន៍ដ៏ខ្ពស់បំផុតនៃបព្វជ្ជារបស់ពួកយើង ។

ធីតាសេដ្ឋី. បពិត្រលោកម្ចាស់ដ៏ចម្រើន នាងខ្ញុំមិនអាចនឹងញ្ចាំងឈានឱ្យកើតឡើងបានទេ,ប៉ុន្តែនាងខ្ញុំអាចរៀនវាទៈ មួយ-ពាន់បាន ។

លំដាប់នោះ បរិព្វាជកទាំងនោះ បានឱ្យនាងរៀនវាទៈមួយពាន់ ហើយពោលថា "សិល្បៈដែលនាងរៀននោះចប់ហើយ ឥឡូវនេះ នាងចូរគ្រាច់ទៅកាន់ជម្ពូទ្វីបទាំងមូល ស្វែងរកអ្នកដែលអាចឆ្លើយវាទៈរបស់នាងបាន ហើយឱ្យមែកព្រីងមួយមែកទៅនាង ដោយពាក្យថា ម្នាលនាងដ៏ចម្រើន នាងចូរទៅចុះហើយ បើមានបុគ្គលណាអាចឆ្លើយ បញ្ហារបស់នាងបាន, បើជាគ្រហស្ថ នាងចូរជាបាទបរិចារិកា(ប្រពន្ធ)របស់អ្នកនោះចុះ, បើបព្វជិត នាងចូរបព្វជ្ជាសម្នាក់អ្នកនោះចុះ ។

នាងមានឈ្មោះថា ជម្ពូបរិព្វាជិកា តាមនាម(ឈើ)នាង

ចេញចាកទីនោះហើយ ត្រាច់សួរបញ្ហាចំពោះអ្នកដែលខ្លួនឃើញ ហើយ ១ ។ គ្មានបុគ្គលណាមួយអាចឆ្លើយ បញ្ហាដែលនាងបាន សួរបានឡើយ ។ មនុស្សទាំងឡាយគ្រាន់តែបានឮថា "នាងជម្ពូ ឬ ជិកមកកាន់ទីនេះហើយ ក៏រត់គេចបាត់អស់ ។ នាងចូលទៅ កាន់ស្រុក ឬ ទិគមដើម្បីភិក្ខា ធ្វើគំនរឈ្ងាច់ទុកជិតខ្ទើងទ្វារស្រុក ដោតមែកព្រីងលើគំនរឈ្ងាច់នោះហើយពោលថា "អ្នកណាអាច ដោះស្រាយបញ្ហារបស់យើងបាន ចូរជាន់មែកឈើនេះចុះ រួចក៏ ចូលទៅកាន់ស្រុក ។ គ្មាននរណាម្នាក់ហ៊ានចូលទៅជិតមែកព្រីង របស់នាងឡើយ ។ នាងតែងតែកាន់យកមែកព្រីង ដទៃជំនួស កាលមែកព្រីងនោះចាស់ស្ងួតស្រពោន ត្រាច់ទៅដោយទំនងនេះ រហូតដល់ក្រុងសាវត្ថី ដាក់មែកព្រីងជិតទ្វារនៃស្រុកហើយ និយាយ ដោយន័យដូចពោលមកហើយនោះឯង ហើយចូលទៅកាន់ស្រុក ដើម្បីភិក្ខា ។ ក្មេងជាច្រើនបានទៅឈរចោមរោមមែកព្រីងនោះ ។

[ធីតាសេដ្ឋីមានឈ្មោះថា កុណ្ឌលកេសី]

ក្នុងកាលនោះ ព្រះសារីបុត្តត្ថេរ ត្រាច់ទៅបិណ្ឌបាត ធ្វើ ភត្តកិច្ចហើយ ចេញចាកក្រុង ឃើញក្មេងទាំងនោះឈរឡោម

ព័ន្ធមែកព្រីង ទើបសួរថា មានរឿងអ្វី ? ក្មេងទាំងឡាយប្រាប់រឿងនោះដល់ព្រះថេរៈហើយ ។ ព្រះថេរៈពោលថា "នែក្មេងទាំងឡាយ បើដូច្នោះ ពួកអ្នកចូរជាន់មែកព្រីងចុះ" ។

ពួកក្មេង. បពិត្រលោកម្ចាស់ដ៏ចម្រើន ពួកខ្ញុំព្រះករុណាមិនហ៊ានទេ ។

ព្រះថេរៈ. អ្នកទាំងឡាយកុំខ្លាច បញ្ហាទុកឱ្យអាត្មាជាអ្នកដោះស្រាយ អ្នកទាំងឡាយចូរជាន់ចុះ ។

ក្មេងទាំងនោះមានភាពក្លាហាន ដោយសារពាក្យរបស់ព្រះថេរៈ ធ្វើតាមព្រះថេរៈហើយ នាំគ្នាស្រែកបាចធូលីឡើង ។ នាងបរិព្វាជិកាមកហើយ ជេរក្មេងទាំងនោះ ហើយសួរថា អ្នកទាំងឡាយឆ្លើយបញ្ហារបស់យើងមិនបាន ហេតុអ្វីពួកឯងនាំគ្នាជាន់មែកព្រីងរបស់យើង ។ ក្មេងទាំងនោះឆ្លើយប្រាប់នាងថា ព្រះថេរៈប្រើឱ្យពួកខ្ញុំជាន់" ។

នាងបរិពាជិកា. បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់ប្រើឱ្យ ពួកក្មេងជាន់មែកព្រីងរបស់ខ្ញុំក្ររណាឬ ?

ព្រះថេរៈ. ម្នាលប្អូន ពិតមែនហើយ ។

នាងបរិពាជិកា. បើដូច្នោះ សូមលោកម្ចាស់ឆ្លើយ បញ្ហារបស់ខ្ញុំព្រះកុរុណា ។

ព្រះថេរៈ. ម្នាលប្អូនស្រី ប្រពៃហើយ អាត្មាភាពនឹងឆ្លើយ ។

នៅពេលរសៀលនៃថ្ងៃនោះ នាងបរិពាជិកានោះបានទៅកាន់សំណាក់របស់ព្រះថេរៈដើម្បីសួរបញ្ហា ។

អ្នកនគរទាំងអស់ ក្ងាក់ផ្ទើលថា ពួកយើងនឹងស្តាប់ពាក្យរបស់បណ្ឌិតទាំងពីរ ។

ពួកអ្នកនគរ ក៏បាននាំគ្នាទៅជាមួយនាងបរិពាជិកានោះដែរ ថ្វាយបង្គំព្រះថេរៈហើយ អង្គុយក្នុងទីដ៏សមគួរ ។

នាងបរិពាជិកាពោលនឹងព្រះថេរៈថា"បពិត្រលោកម្ចាស់ ដ៏ចម្រើន ខ្ញុំព្រះកុរុណាសូមសួរបញ្ហាចំពោះលោកម្ចាស់ ។ ព្រះថេរៈពោលថា ម្នាលប្អូនស្រី សួរមកចុះ ។ នាងបានសួរវាទៈមួយពាន់ ។ ព្រះថេរៈបានដោះស្រាយបញ្ហាដែលនាងសួរហើយ ១ ។ គ្រានោះព្រះថេរៈពោលនឹងនាងថា ម្នាលនាងដ៏ចម្រើន បញ្ហារបស់នាងមានត្រឹមតែប៉ុណ្ណេះទេឬ ?ឬក៏នៅមានបញ្ហាដទៃទៀត"

នាងបរិពាជិកា. មានតែប៉ុណ្ណេះឯង លោកម្ចាស់ ។

ព្រះថេរៈ. នាងសួរបញ្ហាអាត្មាយ៉ាងច្រើន, ឥឡូវនេះអាត្មាសូមសួរបញ្ហានឹងនាងមួយ,នាងអាចឆ្លើយបាន ឬមិនបាន ។

នាងបរិពាជិកា. បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់សួរមកចុះបើខ្ញុំព្រះកុរណាដឹងខ្ញុំព្រះកុរណានឹងឆ្លើយ ។

ព្រះថេរៈ.សួរបញ្ហាថាអ្វីឈ្មោះថាមួយ ? នាងបរិព្វាជិកានោះមិនដឹងថា បញ្ហានេះ គួរឆ្លើយយ៉ាងណាទ្បើយ ទើបសួរថាបពិត្រលោកម្ចាស់ដ៏ចម្រើន ន៏ុះជាឈ្មោះនៃអ្វី ?

ព្រះថេរៈ. ម្នាលបួនស្រី នោះជាឈ្មោះនៃពុទ្ធមន្ត ។

នាងបរិពាជិកា. បពិត្រលោកម្ចាស់ ឱ្យបព្វជ្ជាដល់ខ្ញុំព្រះកុរណាចុះ ។

ព្រះថេរៈ. បើនាងនឹងបួសដូចអាត្មា ១នឹងឱ្យ ។

បើដូច្នោះ សូមលោកម្ចាស់ ឱ្យបព្វជ្ជាដល់ព្រះខ្ញុំកុរណាចុះ ។

ព្រះថេរៈបានប្រាប់ភិក្ខុនីទាំងឡាយឱ្យបព្វជ្ជាដល់នាង ។

លុះបានបព្វជ្ជាឧបសម្ប្ទហើយ នាងក៏មានឈ្មោះថាកុណ្ឌលកេសីថេរី នាងបួសបាន ២-៣ ថ្ងៃប៉ុណ្ណោះ ក៏បាន

សម្រេចព្រះអរហត្តព្រមដោយបដិសម្ភិទាទាំងឡាយ ។

[ឈ្នះកិលេសប្រសើរ]

ភិក្ខុទាំងឡាយ សន្ទនាគ្នាក្នុងសាលាធម្មសភាថា "ការស្តាប់ធម៏របស់នាងកុណ្ឌលកេសីថេរី មិនមានច្រើនទេ, ប៉ុន្តែកិច្ចនៃបព្វជិតរបស់នាងដល់ទីបំផុតហើយ, បានញ្ញថា នាងធ្វើមហាសង្គ្រាមនឹងចោរម្នាក់ឈ្នះហើយទើបមកកាន់ ទីនេះ ។

ព្រះសាស្តា ស្តេចយាងមកហើយត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសន្ទនាគ្នាអំពីរឿងអ្វី ?" កាលភិក្ខុទាំងឡាយនោះក្រាបទូលថា "អំពីរឿងឈ្នះនេះ ។ ទើបត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយកុំប្រមាណធម៏ដែលតថាគតសម្តែងហើយថា 'តិចឬច្រើនឱ្យសោះ' បទដែលមិនប្រកបដោយប្រយោជន៏សូម្បីតែមួយបទ ក៏មិនប្រសើរដែរ ។ ចំណែកបទនៃធម៏ដែលប្រកបដោយប្រយោជន៏ សូម្បីតែមួយបទប្រសើរជាង, មួយទៀត កាលបុគ្គលឈ្នះចោរដ៏សេស ក៏មិនឈ្នះថា ជាការឈ្នះដែរ, ចំណែកបុគ្គលអ្នក ឈ្នះចោរគឺកិលេសដែលប្រព្រឹត្តទៅ ខាងក្នុងនោះឯង ទើបឈ្នះថា ជាការ

ឈ្នះ កាលនឹងទ្រង់បន្ទរអនុសន្ធិដើម្បីសម្តែងធម៏ ទើបត្រាស់ព្រះគាថាទាំងនេះថា ៖

យោ ច គាថា សតំ ភាសេ អនត្ថបទសញ្ហិតា
ឯកំ ធម្មបទំ សេយ្យោ យំ សុត្វា ឧបសម្មតិ ។
យោ សហស្សំ សហស្សេន សង្គ្រាមេ មានុសេ ជិនេ
ឯកញ្ច ជេយ្យមត្តានំ ស វេ សង្គ្រាមជុត្តមោ ។

អ្នកណាគប្បីពោលគាថាមួយរយ ជាគាថាប្រកបដោយបទឥតប្រយោជន៏ គាថាដែលអ្នកនោះពោលហើយនោះ ពុំប្រសើរទ្បើយ អ្នកណាស្តាប់បទនៃធម៏ហើយ រមែងស្ងប់រម្ងាប់បាន បទនៃធម៏នោះ សូម្បីតែមួយបទ ក៏ឈ្មោះថា ប្រសើរជាង ។

អ្នកណាគប្បីឈ្នះពួកមនុស្សក្នុងសង្គ្រាម អស់មួយពាន់ ១ ជង គឺ ១លានចំណែកអ្នកណាឈ្នះខ្លួនឯងម្នាក់ឯងបាន អ្នកនោះឈ្មោះថាជាមនុស្សខ្ពង់ខ្ពស់ជាងអ្នកដែលឈ្នះក្នុងសង្គ្រាមនោះ ។

អធិប្បាយគាថា

បណ្តាបទទាំងនោះ ពីរបទថា គាថា សតំ សេចក្តីថា ក៏បុគ្គលណាគប្បីពោលគាថាកំណត់ដោយពាន់គឺជាច្រើន ។

បាទព្រះគាថាថា អនត្ថបទសសញ្ហិតា សេចក្តីថា ប្រកបដោយបទទាំងឡាយ ដែលមិនមានប្រយោជន៍ ដោយអំណាចនៃការពណ៌នាអាកាសជាដើម ។

បទដែលសម្បយុត្តដោយធម៌ មានខន្ធជាដើម ដែលមានប្រយោជន៍ឈ្មោះថា បទធម៌ ។ បណ្តាបទធម៌ទាំង ៤ ដែលព្រះសាស្តាត្រាស់ទុកយ៉ាងនេះថា "ម្នាលបរិព្វាជកទាំងឡាយ បទធម៌ ៤ ទាំងនេះ ៤ គឺអ្វីខ្លះ ? ម្នាលបរិព្វាជកទាំងឡាយ បទធម៌គឺសេចក្តីមិនសម្ងីងរ៉ាវ៉ៃពោសអ្នកដទៃ, បទធម៌គឺសេចក្តីមិនប្រទូស្ត្រ៉ាយ,បទធម៌គឺសេចក្តីរលឹកប្រពៃ បទធម៌ គឺសេចក្តីតាំងចិត្តទុកប្រពៃ,បទធម៌ទាំងនេះ សូម្បីតែមួយបទប្រសើរជាង" ។

បាទគាថាថា យោ សហស្សំ សហស្សេន សេចក្តីថា អ្នកណា គឺអ្នកច្បាំងក្នុងសង្គ្រាម គប្បីឈ្នះមនុស្សមួយពាន់ គុណនឹងមួយពាន់ បានដល់ ឈ្នះមនុស្ស ១ លានក្នុងសង្គ្រាមមួយជង, សូម្បីអ្នកនេះក៏មិនឈ្មោះថា ជាកំពូលនៃជនទាំងឡាយ អ្នកឈ្នះក្នុងសង្គ្រាមដែរ ។

បាទគាថាថា ឯកញ្ចុ ដេយ្យមត្ថានំ សេចក្ដីថា ចំណែកអ្នកណាពិចារណាកម្មដ្ឋាន ដែលប្រព្រឹត្ដទៅខាងក្នុងទីសម្រាក ពេលយប់និងពេលថ្ងៃ គប្បីឈ្នះខ្លួនឯង ដោយការឈ្នះកិលេស មានលោភៈជាដើមរបស់ខ្លួនបាន ។

បាទគាថាថា ស វេ សង្គ្រាមជុត្ដមោ សេចក្ដីថា អ្នកនោះ ឈ្មោះថា ជាកំពូល គឺប្រសើរជាងជនទាំងឡាយអ្នកឈ្នះក្នុងសង្គ្រាម បានដល់ ជាអ្នកច្បាំងដ៏ប្រសើរក្នុងសង្គ្រាម ។

ក្នុងវេលាចប់ទេសនា ជនជាច្រើនបានសម្រេចអរិយ-ផលទាំងឡាយ មានសោតាបត្ដិផលជាដើម ដូច្នេះឯង ។

រឿងអភ័យរាជកុមារ

ព្រះសាស្ដា កាលគង់នៅនាវត្ដវេឡុវ័ន ទ្រង់ប្រារព្ធ អភ័យរាជកុមារ ត្រាស់ព្រះធម៌ទេសនានេះថា "ឯ ជ ម ស្ស ជ ិ ម ំ លោ ក ំ" ជាដើម ។

[ព្រះកុមារបានទទួលព្រះរាជទានរាជសម្បត្ដិ]

បានញ្ជូថា កាលអភ័យរាជកុមារនោះ ទ្រង់បង្ក្រាបបច្ចូ-

ន្ធជនបទឱ្យ ស្ងប់រម្ងាប់ហើយមកកាន់ព្រះនគរវិញ ព្រះបាទពិម្ពិ-
សារជាព្រះបិតា ទ្រង់សព្វព្រះហឫទ័យ ព្រះរាជទានស្រីរបាំម្នាក់
ដែលជាអ្នកឈ្លាសវៃការរាំ និងច្រៀង ហើយបានព្រះរាជទាន
រាជសម្បត្តិឱ្យ ៧ ថ្ងៃ ។ អភ័យរាជកុមារនោះ មិនបានស្តេចចេញ
ទៅខាងក្រៅព្រះរាជមន្ទីរឡើយ ។ សោយសិរីនៃភាពជាព្រះរាជ
អស់ ៧ ថ្ងៃ ស្តេចទៅកាន់កំពង់ទឹកក្នុងថ្ងៃទី ៨ ទ្រង់ស្រង់ព្រះ
កាយហើយ ស្តេចចូលទៅកាន់ព្រះឧទ្យាន ទ្រង់គង់ទតការរបាំ
និងការច្រៀងរបស់ស្រីនោះ ដូចសន្ត្ដិមហាមាត្យដែរ ។ ក្នុង
ខណៈនោះឯង ស្រីរបាំនោះក៏ធ្វើមរណកាល ដោយអំណាចខ្យល់
ដូចជាសស្ត្រា ដូចស្រីរបាំរបស់សន្ត្ដិមហាមាត្យដែរ ព្រះកុមារ
មានសេចក្ដីសោកយ៉ាងខ្លាំង ព្រោះកាលកិរិយារបស់ស្រីរបាំនោះ
ទ្រង់ព្រះតម្រិះថា "អ្នកដទៃ រៀរព្រះសាស្ត្រាចេញហើយ នឹងមិន
មាន អ្នកណាអាចញ៉ាំងសេចក្ដីសោកនេះឱ្យរលត់បានឡើយ"
ហើយក៏ស្តេចចូល ទៅគាល់ព្រះសាស្ត្រា ក្រាបទូលថា "បពិត្រ
ព្រះអង្គដ៏ចម្រើន សូមព្រះអង្គរលត់នូវសេចក្ដីសោករបស់ខ្ញុំព្រះ
អង្គផង" ។

[ឧបាយសម្រាប់សេចក្តីសោក]

ព្រះសាស្តា ទ្រង់លួងលោមព្រះកុមារនោះ ឱ្យធូរចិត្ត ហើយត្រាស់ថា ម្នាលកុមារ ក៏ប្រមាណនៃទឹកភ្នែកទាំងឡាយ ដែលអ្នកទួញយំក្នុងកាលនៃស្រីនេះស្លាប់យ៉ាងនេះ ឱ្យប្រព្រឹត្តទៅ ហើយមិនមានក្នុងសង្សារដែលមានទីបំផុត ដែលអ្នកណា ៗដឹង មិនបានទ្រង់ជ្រាបការៈនៃសេចក្តីសោកជាសភាពស្រាលស្តើង ព្រោះ ទេសនានោះហើយទើបមានព្រះពុទ្ធដីកាថា ម្នាលកុមារ អ្នកកុំសោយ សោកឡើយ, រឿងជាហានៈ សម្រាប់លិចចុះនៃជនពាលទាំងឡាយ ទេលុះទ្រង់ត្រាស់ដូច្នេះហើយក៏ត្រាស់ព្រះគាថានេះថា ៖

ឯថ បស្សថិមំ លោកំ ចិត្តំ រាជរថូបមំ
យត្ថ ពាលា វិសីទន្តិ នត្ថិ សង្គោ វិជានតំ ។

អ្នកទាំងឡាយ ចូរមកមើលនូវលោកនេះ ដ៏ត្រកាលដូច រាជរថជនពាលទាំងឡាយ រមែងលិចលង់ក្នុងលោកណា សេចក្តី ជាប់ជំពាក់ក្នុងលោកនោះ រមែងមិនមានដល់ជនជាបណ្ឌិតទាំង ឡាយ ដែលដឹងច្បាស់ទេ ។

អធិប្បាយគាថា

បណ្តាបទទាំងនោះ ពីរបទថា ឯ៨ បស្ស្ជ ព្រះសាស្តា ត្រាស់សំដៅយកព្រះរាជកុមារនុ៎ះឯង ។ ពីរបទថា ឥមំ លោកំ បានដល់ អត្តភាព ពោលគឺ ខន្ធលោកជាដើមនេះ ។

បទថា ចិត្តំ សេចក្ដីថា ដ៏វិចិត្រដោយគ្រឿងប្រដាប់ មានគ្រឿងប្រដាប់ គឺសំពត់ជាដើម ដូចរាជរថដ៏វិចិត្រដោយគ្រឿងប្រដាប់មានកែវ៧ប្រការជាដើម ។ ពីរបទថា យត្ថ ពាលា សេចក្ដីថាពួកអ្នកល្ងង់ខ្លៅប៉ុណ្ណោះរមែងលិចលង់ចុះក្នុងអត្តភាពណា ។

បទថា វិជានតំ សេចក្ដីថា តែសម្រាប់ពួកអ្នកដឹង គឺបណ្ឌិតទាំងឡាយ មិនមានសេចក្ដីជាប់ជំពាក់ក្នុងកិលេសជាគ្រឿងជាប់ជំពាក់ គឺ រាគៈជាដើមសូម្បីយ៉ាងណាមួយ ក្នុងអត្តភាពនោះទេ ។

ក្នុងវេលាចប់ទេសនា ព្រះរាជកុមារតាំងនៅក្នុងសោតាបត្តិផល ។ ព្រះធម៌ទេសនាបានជាប្រយោជន៍សូម្បីដល់អ្នកប្រជុំគ្នា ដូច្នេះឯង ។

រឿងកុដុម្ពីមួយរូប

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធកុដុម្ពីម្នាក់ត្រាស់ព្រះធម៌ទេសនានេះថា "ឋិយតោ ជាយតី" ជាដើម ។

[ព្រះសាស្តាស្តេចទៅរម្ងាប់សេចក្តីសោករបស់ព្រាហ្មណ៍]

សេចក្តីពិស្តារថា កុដុម្ពីនោះ គ្រាបុត្ររបស់ខ្លួនធ្វើកាល-កិរិយាទៅហើយ, ត្រូវសេចក្តីសោកចំពោះបុត្រគ្របសង្កត់ទៅកាន់ជ្រាលជ្រៃ មិនអាចហាមសេចក្តីសោកចំពោះបុត្របាន ។

ព្រះសាស្តា ទ្រង់ពិចារណាមើលសត្វលោក ក្នុងវេលាជិតភ្លឺ ទ្រង់ឃើញធម៌ដែលជាឧបនិស្សយនៃសោតាបត្តិមគ្គរបស់កុដុម្ពីនោះ លុះទ្រង់ត្រឡប់មកអំពីបិណ្ឌបាតហើយ បានទ្រង់នាំភិក្ខុអ្នកជាបច្ឆាសមណៈមួយរូប ស្តេចទៅកាន់ផ្ទះរបស់កុដុម្ពីនោះ ។ កុដុម្ពីនោះបានឮថា ព្រះសាស្តាស្តេចយាងមកដល់ផ្ទះរបស់ខ្លួន ក៏គិតថា "ព្រះសាស្តានឹងទ្រង់ប្រាថ្នាដើម្បីធ្វើនូវបដិសណ្ឋារជាមួយនឹងអញ" ទើបអារាធនានិមន្តព្រះសាស្តាឱ្យស្តេចទៅកាន់ផ្ទះ ក្រាលអាសនៈត្រង់កណ្តាលផ្ទះ កាលព្រះសាស្តាទ្រង់គង់ហើយ, ក៏

មកថ្វាយបង្គំ ហើយអង្គុយក្នុងចំណែកម្ខាង ។

គ្រានោះព្រះសាស្តាត្រាស់សួរកុដុម្ពីនោះថា "ម្នាលឧបាសក អ្នកកើតទុក្ខព្រោះហេតុអ្វីហ្ន៎ ?" កាលកុដុម្ពីនោះក្រាបទូលថា ខ្ញុំព្រះអង្គកើតទុក្ខ ព្រោះព្រាត់ប្រាសចាកបុត្រដែលជាទីស្រឡាញ់ ព្រះសាស្តាក៏ត្រាស់ថា "ម្នាលឧបាសក អ្នកកុំសោយសោកឡើយ, ព្រោះថា សេចក្តីស្លាប់នេះមិនមែនមានតែក្នុងទីមួយទេ ទាំងមិនមែនមានតែចំពោះបុគ្គលម្នាក់ដែរ ការប្រព្រឹត្តទៅនៃភព នៅមានជរាបណា សេចក្តីស្លាប់ក៏រមែងមានដល់សព្វសត្វជរាបនោះដែរ, សង្ខារ សូម្បីតែមួយ ដែលឈ្មោះថា ទៀង រមែងមិនមាន, ព្រោះហេតុនោះ អ្នកគប្បីពិចារណាដោយឧបាយដ៏ប្រពៃថា "ធម្មជាតិដែលមានសេចក្តីស្លាប់ជាធម្មតាបានស្លាប់ហើយ, ធម្មជាតិដែលមានការបែកធ្លាយជាធម្មតា រមែងបែកធ្លាយហើយ, មិនគួរសោកសៅ, ជ្រៃតថា បុរាណកបណ្ឌិតទាំងឡាយ ក្នុងកាលបុត្រដែលជាទីស្រឡាញ់ ស្លាប់ បានពិចារណាថា "ធម្មជាតិ ដែលមានសេចក្តីស្លាប់ជាធម្មតា ស្លាប់ហើយ,ធម្មជាតិដែលការបែកធ្លាយជាធម្មតា រមែងបែកធ្លាយហើយ ដូច្នេះហើយ មិនត្រូវធ្វើសេចក្តីសោកសៅ

ទ្បើយ គួរតែចម្រើនមរណសរ្សតិតែម្យ៉ាង" កុដុម្ពីកនោះទូលអារាធនាថា "បពិត្រព្រះអង្គដ៏ចម្រើន បណ្ឌិតពួកណាបានធ្វើហើយយ៉ាងនោះ, ហើយបានធ្វើក្នុងកាលណា ? សូមព្រះអង្គត្រាស់ប្រាប់ខ្ញុំព្រះអង្គ" កាលនឹងទ្រង់ប្រកាសនូវសេចក្ដីនោះឱ្យជាក់ច្បាស់ ទើបទ្រង់នាំអតីតនិទានមក ញ្ជាំងឧគក្នុងបញ្ចកនិបាតនេះឱ្យពិស្ដារថា ៖

"កូនរបស់ខ្ញុំ លះបង់នូវសរីរៈទៅហើយ ដូចជាពស់លះបង់នូវសំណកចាស់ កាលបើសរីរៈប្រើប្រាស់មិនបាន ធ្វើកាលកិរិយាទៅកាន់លោកខាងមុខយ៉ាងនេះ រាងកាយ កាលត្រូវគេដុតរមែងមិនដឹងនូវសេចក្ដីខ្សឹកខ្សួលនៃញាតិទាំងឡាយ ព្រោះហេតុនោះទើបខ្ញុំមិនសោកស្ដាយចំពោះកូនន ុ ះគតិណាជារបស់គេ គេក៏ទៅកាន់គតិនោះ" ។

ដូច្នេះហើយ ក៏ទ្រង់ត្រាស់តទៅទៀតថា "បណ្ឌិតក្នុងកាលមុន កាលកូនដែលជាទីស្រឡាញ់ធ្វើកាលកិរិយាហើយយ៉ាងនោះ, មិនត្រាច់ទៅដូចជាអ្នកបោះបង់នូវការងារទាំងឡាយ ហើយមិនបរិភោគអាហារដើរតែយំក្នុងកាលឥឡូវនេះមិនធ្វើសេចក្ដីសោក

ដោយអំណាចមរណសត្វតិកាវនា គឺការចម្រើនមរណសត្វតិ ទទួលទានអាហារហើយ អធិដ្ឋាន(តាំងចិត្តធ្វើ)ការងារទាំងឡាយ ព្រោះហេតុនោះ អ្នកកុំគិតថា "កូនដែលជាទីស្រឡាញ់របស់យើងធ្វើកាលកិរិយាទៅហើយ"ពិតណាស់ សេចក្តីសោកក្តីភ័យក្តី កាលនឹងកើតឡើង រមែងអាស្រ័យវត្ថុដែលជាទីស្រឡាញ់ ដូច្នេះ ហើយក៏ត្រាស់ព្រះគាថានេះថា ៖

ปิยโต ชายตี โสโก ปิยโต ชายตี ภยํ

ปิยโต วิปฺปมุตฺตสฺส นตฺถิ โสโก กุโต ภยํ ฯ

សេចក្តីសោកកើតអំពីសេចក្តីស្រឡាញ់ ភ័យកើតអំពីសេចក្តីស្រឡាញ់ កាលបើរួចស្រឡះចាកសេចក្តីស្រឡាញ់ហើយ សេចក្តីសោកក៏លែងមាន ភ័យនឹងមានមកពីណា ។

អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា ปิยโต *ជាដើម* សេចក្តីថា *សេចក្តីសោកក្តី ភ័យក្តី ដែលមានវដ្ដៈជាមូល កាលនឹងកើតឡើង រមែងកើតឡើងអាស្រ័យសត្ត និងសង្ខារដែលជាទីស្រឡាញ់ ប៉ុណ្ណោះ, ប៉ុន្តែសេចក្តីសោកនិងភ័យ សូម្បីទាំងពីរនោះ រមែង*

មិនមានដល់បុគ្គលអ្នកផុតស្រឡះចាកពីសត្វ និងសង្ខារ ដែលជាទីស្រឡាញ់នោះបានឡើយ ។

ក្នុងកាលចប់ទេសនា ភិក្ខុជុម្ពិកតាំងនៅហើយក្នុងសោតាបត្តិផល ។ ទេសនាបានមានប្រយោជន៍ដល់ជនអ្នកប្រជុំគ្នាហើយដូច្នេះឯង ។

រឿងព្រាហ្មណ៍ម្នាក់

ព្រះសាស្តាកាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រាហ្មណ៍ម្នាក់ ត្រាស់ព្រះធម៌ទេសនានេះថា "តណ្ហាយ ជាយតិ" ជាដើម ។

[ព្រះសាស្តាស្តេចទៅរកព្រាហ្មណ៍មិច្ឆាទិដ្ឋិ]

បានឮថា ព្រាហ្មណ៍នោះជាមនុស្សមិច្ឆាទិដ្ឋិ ថ្ងៃមួយទៅកាន់ផ្នែរស្ទឹងជម្រះស្មៅ ។ ព្រះសាស្តាទ្រង់ឃើញការដល់ព្រម នៃឧបនិស្សយរបស់គាត់ ទើបស្តេចយាងទៅកាន់សំណាក់របស់គាត់ ។ ព្រាហ្មណ៍នោះសូម្បីឃើញព្រះសាស្តា ក៏មិនធ្វើសូម្បីតែសាមីចិកម្ម អង្គុយនៅស្ងៀម ។

គ្រានោះ ព្រះសាស្តាត្រាស់សួរគាត់មុនថា "ម្នាលព្រា-

ហ្មណ៍ អ្នកកំពុងធ្វើអ្វី ?”

ព្រាហ្មណ៍.បពិត្រព្រះគោតមដ៏ចម្រើនខ្ញុំកំពុងជម្រះស្រែ ។

ព្រះសាស្តាត្រាស់សួរត្រឹមតែប៉ុណ្ណោះហើយ ស្តេចក៏ចៀសចេញទៅ សូម្បីក្នុងថ្ងៃស្អែក ព្រះសាស្តាស្តេចទៅកាន់សំណាក់របស់គាត់ដែលមកភ្ជួរស្រែ ត្រាស់សួរថា “ម្នាលព្រាហ្មណ៍ អ្នកកំពុងធ្វើអ្វី ?” ទ្រង់សណ្តាប់ថា “ព្រះគោតមដ៏ចម្រើន ខ្ញុំកំពុងភ្ជួរស្រែ” ដូច្នេះហើយ ស្តេចក៏ចៀសទៅ ។ សូម្បីក្នុងថ្ងៃត ១មក ព្រះសាស្តាក៏ស្តេចទៅទៅកាន់សម្នាក់របស់គាត់ ត្រាស់សួរដូច្នោះដដែល ទ្រង់ព្រះសណ្តាប់ថា “ព្រះគោតមដ៏ចម្រើន ខ្ញុំកំពុងព្រោះ កំពុងបាច់ទឹក កំពុងរក្សាស្រែ”ដូច្នេះហើយក៏ស្តេចចៀសទៅ ។

[ព្រាហ្មណ៍រាប់អានព្រះអង្គដូចជាសម្លាញ់]

គ្រាក្នុងថ្ងៃមួយ ព្រាហ្មណ៍ក្រាបទូលព្រះអង្គថា “ព្រះគោតមដ៏ចម្រើន ព្រះអង្គមកកាន់ទីនេះ ចាប់តាំងពីថ្ងៃដែលខ្ញុំព្រះអង្គជម្រះស្មៅម្ល៉ះ, ប្រសិនបើសន្ទូងរបស់ខ្ញុំព្រះអង្គសម្រេចផល, ខ្ញុំនឹងបែងចែកឱ្យព្រះអង្គខ្លះ មិនទាន់ឱ្យព្រះអង្គ ខ្ញុំនឹងមិនទទួលទានខ្លួនឯងចាប់តាំងពីថ្ងៃនេះទៅ ព្រះអង្គជាសម្លាញ់របស់ខ្ញុំ” ។

[សន្ទូងរបស់ព្រាហ្មណ៍ខ្ជូចអស់]

លុះក្រោយមក សន្ទូងរបស់ព្រាហ្មណ៍សម្រេចផល ។ កាលព្រាហ្មណ៍ធ្វើកិច្ចគ្រប់យ៉ាងដើម្បីប្រួត ដោយតាំងចិត្តថា "សន្ទូងរបស់យើងសម្រេចផលហើយ, យើងនឹងឱ្យគេប្រួតតាំងអំពីថ្ងៃស្អែកនេះទៅ" មហាមេឃញ្ជុំងភ្លៀងឱ្យបង្អុរចុះមក មួយយប់ទល់ភ្លឺនាំយកសន្ទូងរបស់ព្រាហ្មណ៍ទៅអស់ ។ ស្រែប្រាជកស្ទើដោយវត្ថុដែលគេចាំងហើយតាំងទុកដូច្នេះ ។

[ព្រាហ្មណ៍ខ្ជូចចិត្តព្រោះធ្វើស្រែមិនបានផល]

ចំណែកព្រះសាស្តា ព្រះអង្គទ្រង់ជ្រាបតាំងអំពីថ្ងៃដំបូងម្ល៉ះថា "ព្រាហ្មណ៍នឹងមិនបានផល" ។ ព្រាហ្មណ៍ ទៅស្រែតាំងពីព្រលឹមដោយតាំងចិត្តថា "យើងនឹងមើលសន្ទូង" ឃើញតែស្រែទទេ កើតសេចក្តីសោកយ៉ាងខ្លាំង ទើបគិតថា "ព្រះសមណគោតមមកកាន់ស្រែរបស់យើងតាំងអំពីថ្ងៃ ដែលយើងជម្រះស្មៅម្ល៉ះ, ចំណែកយើងក៏បានពោលថា "កាលសន្ទូងរបស់យើងសម្រេចផល យើងនឹងបែងចែកឱ្យព្រះសមណគោតម យើងមិនទទួលទានខ្លួនឯង, ចាប់តាំងពីថ្ងៃនេះទៅ ព្រះអង្គជាសម្ងាញ់របស់ខ្ញុំព្រះ

អង្ក្ត សេចក្ដីប្រាថ្នាក្នុងចិត្តរបស់យើងមិនទាន់ដល់ទីបំផុត" ។ ព្រាហ្មណ៍នោះអត់អាហារដេក នៅនឹងកន្ត្រែតូចមួយ ។

[ព្រះសាស្ដាស្ដេចទៅត្រាស់សួរដំណឹងព្រាហ្មណ៍]

គ្រានោះ ព្រះសាស្ដា ស្ដេចទៅកាន់ទ្វារផ្ទះរបស់ព្រាហ្មណ៍នោះ ។ ព្រាហ្មណ៍ដឹងថា ព្រះសាស្ដាស្ដេចយាងមក ក៏ប្រើ(ជនជាបរិវារ)ថា"ពួកអ្នកឯងចូរទៅនាំសម្លាញ់របស់យើងមកហើយឱ្យអង្គុយទីនេះ" ជនជាបរិវារនោះក៏បានធ្វើហើយ ដោយប្រការដូច្នេះ ។ ព្រះសាស្ដាទ្រង់គង់ហើយ ត្រាស់សួរថា "ព្រាហ្មណ៍ទៅណា ?" កាលគេក្រាបទូលថា "ដេកនៅក្នុងបន្ទប់" ក៏ទ្រង់បញ្ជាដោយព្រះតម្រាស់ថា "ពួកអ្នកចូរទៅហៅព្រាហ្មណ៍មក" ហើយត្រាស់សួរថា ព្រាហ្មណ៍ដែលមកអង្គុយក្នុងទីសម គួរថា ម្នាលព្រាហ្មណ៍ អ្នកកើតអ្វី ?" ។

ព្រាហ្មណ៍. បពិត្រព្រះគោតមដ៏ចម្រើន ព្រះអង្ក្ដបានយាងមកកាន់ស្រែរបស់ខ្ញុំតាំងអំពីថ្ងៃ ដែលខ្ញុំជម្រះស្មៅម្ល៉ះ, ចំណែកខ្ញុំក៏បានពោលថា កាលសន្ទងសម្រេចផល ខ្ញុំនឹងបែងចែកឱ្យព្រះអង្ក្ដ២ះ,សេចក្ដីប្រាថ្នាក្នុងចិត្តរបស់ខ្ញុំមិនសម្រេច ព្រោះហេតុនោះ

ទើបសេចក្តីសោកកើតឡើងដល់ខ្ញុំ សូម្បីតែភត្តក៏ខ្ញុំមិនឃ្លានដែរ ។

[ត្រាស់ហេតុនៃសេចក្តីសោកនិងឧបាយរម្ងាប់សេចក្តីសោក]

គ្រានោះ ព្រះសាស្តាត្រាស់សួរព្រាហ្មណ៍នោះថា ព្រាហ្មណ៍ អ្នកមិនដឹងទេថា សេចក្តីសោកកើតហើយដល់អ្នក ព្រោះអាស្រ័យអ្វី ?"កាលព្រាហ្មណ៍ក្រាបទូលថា"បពិត្រព្រះគោតម ដ៏ចម្រើនខ្ញុំមិនដឹងទេ, អ្នកមិនដឹងឬ ? ទើបត្រាស់ថា "យ៉ាងនោះហើយ ព្រាហ្មណ៍ការពិត សេចក្តីសោកក្តីភ័យក្តីកាលនឹងកើតរមែងកើតឡើងអាស្រ័យតណ្ហា"ដូច្នេះហើយត្រាស់ព្រះគាថានេះថា ៖

តណ្ហាយ ជាយតី សោកោ តណ្ហាយ ជាយតី ភយំ
តណ្ហាយ វិប្ប មុត្តស្ស នត្ថិ សោកោ កុតោ ភយំ ។

សេចក្តីសោកកើតអំពីតណ្ហា ភ័យកើតអំពីតណ្ហា កាលបើរួចស្រឡះចាកតណ្ហាហើយ សេចក្តីសោក ក៏លែងមាន ភ័យនឹងមានមកពីណា ។

អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា តណ្ហាយ បានដល់ តណ្ហាដែលប្រព្រឹត្តទៅក្នុងទ្វារ ៦, អធិប្បាយថា សេចក្តីសោកជាដើម

រមែងអាស្រ័យតណ្ហានោះ កើតឡើង ។

ក្នុងកាលចប់ទេសនា ព្រាហ្មណ៍តាំងនៅហើយ ក្នុងសោតាបត្តិផល ដូច្នេះឯង ។

រឿងនាងវិសាខាឧបាសិកា

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនាងវិសាខឧបាសិកា ត្រាស់ព្រះធម៌ទេសនានេះថា "ឃេមតោ ជាយតិ" ជាដើម ។

នាងវិសាខាសោកចំពោះនាងសុទត្តីដែលធ្វើកាលកិរិយា

បានឮថា នាងវិសាខានោះតាំងទុកនូវកុមារិកាឈ្មោះថាសុទត្តី ជាធីតារបស់បុត្រក្នុងតំណែងរបស់ខ្លួន ឱ្យធ្វើជាអ្នកឲ្យលាងបម្រើព្រះសង្ឆក្នុងផ្ទះ ។

ក្នុងសម័យថ្ងៃក្រោយមក កុមារិកានោះបានធ្វើកាលកិរិយា នាងវិសាខាប្រើគេឱ្យបញ្ជូនសាកសពនាងសុទត្តីនោះហើយ មិនអាចទប់ចិត្តអត់សង្កត់នូវសោកក្តីសោកបាន ជាអ្នកមានទុក្ខទោមនស្ស ទៅកាន់សំណាក់ព្រះសាស្តា ថ្វាយបង្គំហើយអង្គុយក្នុងទីដ៏សមគួរមួយ ។

[ព្រះសាស្តាត្រាស់ឧបាយរម្ងាប់សេចក្តីសោក]

គ្រានោះ ព្រះសាស្តាត្រាស់ទៅកាន់នាងវិសាខាថា ម្នាលនាងវិសាខា ព្រោះហេតុអ្វីហ្ន៎ ទើបនាងកើតទុក្ខរួចចិត្ត មានមុខទទឹកដោយទឹកភ្នែក អង្គុយយំ ? នាងក៏ទូលនូវសេចក្តីនោះហើយ ក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន នាងកុមារីនោះជាទីស្រឡាញ់របស់ខ្ញុំព្រះអង្គ ជាអ្នកដល់ព្រមហើយដោយវត្ត, ឥឡូវនេះ ខ្ញុំព្រះអង្គមិនឃើញនូវកុមារីមានសភាពដូច្នោះ" ។

ព្រះសាស្តា. ម្នាលវិសាខា ក៏ក្នុងក្រុងសាវត្ថីមានមនុស្សប្រមាណប៉ុន្មាន ?

វិសាខា. បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គតែមួយ ត្រាស់ប្រាប់ខ្ញុំព្រះអង្គថា ក្នុងក្រុងសាវត្ថី មានមនុស្ស ៧ កោដិ ។

ព្រះសាស្តា. ប្រសិនបើមនុស្សមានប្រមាណប៉ុណ្ណឹងគប្បីប្រាជកស្មើដោយចៅស្រីរបស់នាង នាងគប្បីប្រាថ្នានូវមនុស្សទាំងនោះឬ ?

នាងវិសាខា. ព្រះករុណា ព្រះអង្គ ។

ព្រះសាស្តា. ក៏មនុស្សដែលនៅក្នុងក្រុងសាវត្ថីធ្វើកាល-

ការិយាមួយថ្ងៃប៉ុន្មានៗ ?

នាងវិសាខា, បពិត្រព្រះអង្គដ៏ចម្រើន ច្រើន ។

ព្រះសាស្តា. កាលបើដូច្នោះ កាលជាទីមិនសោយសោក របស់នាងមិនគប្បីមានឬ ?
នាងគប្បីយំអស់ថ្ងៃនិងយប់មិនមែនឬ ?

នាងវិសាខា. បពិត្រព្រះអង្គដ៏ចម្រើន សូមលើកទុកសិនចុះ, ព្រះអង្គដឹងហើយ ។

គ្រានោះ ព្រះសាស្តា ត្រាស់ទៅកាន់នាងថា "បើដូច្នោះ នាងកុំសោកឡើយ, សេចក្តីសោកក្តី ភ័យក្តី រមែងកើតអំពីសេចក្តីស្រឡាញ់"ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា ៖

បេមតោ ជាយតី សោកោ បេមតោ ជាយតី ភយំ

បេមតោ វិប្ប មុត្តស្ស នត្ថិ សោកោ កុតោ ភយំ ។

សេចក្តីសោកកើតអំពីសេចក្តីស្រឡាញ់ ភ័យកើតអំពីសេចក្តីស្រឡាញ់ ការបើរួចស្រឡះចាកសេចក្តីស្រឡាញ់ហើយ សេចក្តីសោក ក៏លែងមាន ភ័យនឹងមានមកពីណា ។

អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា ឍេមតោ សេចក្តីថា ព្រោះអាស្រ័យសេចក្តីស្រឡាញ់ដែលធ្វើទុកក្នុងបុត្រ និងធីតាជាដើមនុ៎ះឯង ។

ក្នុងកាលចប់ទេសនា ជនជាច្រើនសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង

រឿងស្តេចលិច្ឆវី

ព្រះសាស្តា កាលទ្រង់អាស្រ័យក្រុងវេសាលី ទ្រង់គង់នៅក្នុងកូដាគារសាលា ទ្រង់ប្រារព្ធពួកព្រះបាទលិច្ឆវី ត្រាស់ព្រះធម៌ទេសនានេះថា "រតិយា ជាយតិ" ជាដើម ។

[ពួកស្តេចលិច្ឆវីតែងកាយប្រកួតគ្នា]

បានឮថា ក្នុងថ្ងៃមហោស្រពថ្ងៃមួយ ស្តេចលិច្ឆវីទាំងនោះមួយអង្គផ្សេង ១តាក់តែងព្រះកាយ ដោយគ្រឿងប្រដាប់អលង្ការទាំងឡាយមិនដូចគ្នា ចេញពីព្រះនគរទៅកាន់ឧទ្យាន ។ ព្រះសាស្តាស្តេចចូលទៅបិណ្ឌបាត ទ្រង់ឃើញស្តេចលិច្ឆវីទាំងនោះ

ក៏ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកហើយត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរមើលពួកស្តេចលិច្ឆវីទាំងនោះ ។ ជនទាំងឡាយឯណាមិនធ្លាប់ឃើញទេវតាជាន់តាវត្តិង្ស ក៏ចូរមើលស្តេចលិច្ឆវីទាំងនោះចុះ"ដូច្នេះហើយ ស្តេចចូលទៅកាន់ព្រះនគរ ។

[ស្តេចលិច្ឆវីទាំងឡាយវិវាទគ្នាព្រោះស្ត្រីនគរសោភិណី]

ចំណែកស្តេចលិច្ឆវីទាំងនោះ កាលទៅកាន់ឧទ្យាន បាននាំស្ត្រីនគរសោភិណីម្នាក់ទៅជាមួយ អាស្រ័យស្ត្រីនោះ ត្រូវសេចក្តីច្រណែនគ្របសង្កត់ហើយ ក៏ប្រហារគ្នានិងគ្នា ញ៉ាំងឈាមឱ្យហូរដូចជាស្ទឹង ។

គ្រានោះ ពួករាជបុរសលើកស្តេចលិច្ឆវីទាំងនោះ ដាក់លើគ្រែ ហើយសែងមកវិញ ។ ចំណែកព្រះសាស្តា ទ្រង់ធ្វើភត្តកិច្ចស្រេចហើយ ស្តេចក៏ចេញចាកព្រះនគរ ។ ពួកភិក្ខុឃើញពួកអ្នកសែង សែងស្តេចលិច្ឆវីទាំងនោះទៅដោយប្រការ ដូច្នោះ ក៏ក្រាបទូលព្រះសាស្តាថា "បពិត្រព្រះអង្គដ៏ចម្រើន ស្តេចលិច្ឆវីទាំងនោះ កាលពីព្រឹកប្រជាប់តាក់តែងហើយ ចេញចាកព្រះនគរដូចជាពួកទេវតា, ឥឡូវនេះ អាស្រ័យស្ត្រីម្នាក់ ដល់នូវសេចក្តី

វិនាសហើយយ៉ាងនេះ” ។

[ព្រះសាស្តាត្រាស់ទោសនៃសេចក្តីត្រេកអរក្នុងកាម]

ព្រះសាស្តាត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ សេចក្តីសោក ក្តី ភ័យក្តី កាលនឹងកើត រមែងកើតឡើងអាស្រ័យសេចក្តីត្រេក-អរ” ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា ៖

រតិយា ជាយតី សោកោ រតិយា ជាយតី ភយំ
រតិយា វិប្ប មុត្តស្ស នត្ថិ សោកោ កុតោ ភយំ ។

សេចក្តីសោកកើតអំពីសេចក្តីត្រេកអរ ភ័យកើតអំពីសេចក្តីត្រេកអរ ការបើរួចស្រឡះចាកសេចក្តីត្រេកអរហើយ សេចក្តីសោកក៏លែងមាន ភ័យនឹងមានមកពីណា ។

អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា រតិយា សេចក្តីថា អំពីការត្រេកអរក្នុងកាមគុណ ៥ គឺព្រោះអាស្រ័យសេចក្តីត្រេកអរក្នុងកាមគុណ ៥ នោះ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

រឿងអនិត្ថិគន្ធកុមារ

ព្រះសាស្តា កាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធអនិត្ថិគន្ធកុមារ ត្រាស់ព្រះធម៌ទេសនានេះថា "ការមតោ ជាយតិ" ជាដើម ។

[អនិត្ថិគន្ធកុមារឱ្យជាងធ្វើរូបស្ត្រី]

បានឮថា អនិត្ថិគន្ធកុមារនោះ ជាសត្វដែលចុតិចាកព្រហ្មលោក កើតក្នុងត្រកូលមានភោគៈច្រើន ក្នុងក្រុងសាវត្ថី តាំងពីកើតមក មិនដែលប្រាថ្នានឹងចូលទៅជិតស្ត្រីទេ, ត្រូវស្ត្រីចាប់កាន់ក៏ស្រែកយំ, មាតា(ត្រូវ)ចាប់កាន់កុមារនោះដោយសំពត់ស្បៃហើយ ទើបឱ្យបៅទឹកដោះ ។

កុមារនោះចម្រើនវយហើយ កាលមាតាបិតាពោលថា "នែកូន យើងនឹងធ្វើនូវអាវាហមង្គលដល់កូនឯង" ។ ក៏ហាមឃាត់ "ខ្ញុំមិនត្រូវការស្រីទេ" កាលត្រូវមាតបិតាអង្វរញយ ៗ ក៏ឱ្យគេហៅជាងមាសមក ៥០០ នាក់ ហើយប្រើគេឱ្យ ៗ មាសមានពណ៌ក្រហម(មាសឆ្ងិន) ឱ្យធ្វើជារូបស្ត្រីដោយដុំមាសជាទីនាំមកនូវសេចក្តីជ្រះថ្លាយ៉ាងក្រៃលែង, កាលមាតាបិតាពោលទៀតថា "នែកូន កាលកូនឯងមិនធ្វើអាវាហមង្គល, ត្រកូលរបស់យើងនឹង

តាំងនៅមិនបាន, មាតាបិតានឹងនាំកុមារិកាមកឱ្យកូនឯង" ក៏ពោលថា "បើដូច្នោះ បើលោកទាំងពីរនឹងនាំកុមារិកាមកឱ្យខ្ញុំ, ខ្ញុំនឹងធ្វើតាមពាក្យរបស់លោកទាំងពីរ" ដូច្នេះហើយ ក៏សម្តែងរូបមាសនោះ ។

[បញ្ជូនព្រាហ្មណ៍ទៅរកគូគ្រងរបស់បុត្រ]

គ្រានោះ មាតាបិតារបស់កុមារនោះ ប្រើគេឱ្យអញ្ជើញពួកព្រាហ្មណ៍ល្បី ៗ មកហើយប្រាប់ថា "បុត្ររបស់យើងមានបុណ្យច្រើន, គង់នឹងមានកុមារិកាអ្នកធ្វើបុណ្យរួមជាមួយនឹងបុត្ររបស់យើងជាប្រាកដ, ពួកលោកចូរទៅ,ចូរនាំយករូបមាសនេះទៅ ហើយនាំនាងកុមារិកាដែលមានរូបដូច្នេះមក" លុះពោលដូច្នេះហើយក៏បញ្ជូនព្រាហ្មណ៍ទាំងនោះទៅ ។ ព្រាហ្មណ៍ទាំងនោះទទួលថា "ប្រពៃហើយ" ព្រាហ្មណ៍ទាំងនោះ កាលគ្រាចប់ទៅកាន់ទីចារឹកបានទៅដល់សាគលនគរ ក្នុងដែនមទ្ទ: ។

[ព្រាហ្មណ៍ឃើញស្ត្រីដែលមានរូបដូចរូបមាស ហើយត្រឡប់មកវិញ]

ក៏ក្នុងនគរនោះ មានកុមារិកាម្នាក់ មានរូបស្រស់ស្អាត មានអាយុប្រហែលជា ១៦ ឆ្នាំ ។ មាតាបិតារបស់នាង ឱ្យនាង

នៅពួកដ៏ផ្ទៃខាងលើនៃប្រាសាទ៧ជាន់ ។ ព្រាហ្មណ៍សូម្បីទាំងនោះ គិតគ្នាថា "ប្រសិនបើនៅក្នុងនគរនេះ មានកុមារិកាបែបនេះ, ជនទាំងឡាយឃើញរូបមាសនេះហើយ ក៏នឹងពោលថា រូបចម្លាក់នេះ ស្រស់ស្អាតដូចធីតានៃត្រកូលឯណោះ" ដូច្នេះហើយ ក៏តាំងទុកនូវរូបមាសនោះ ក្បែរផ្លូវជាទីទៅកាន់កំពង់ទឹក ហើយអង្គុយរង់ចាំមើលក្នុងចំណែកម្ខាង ។

គ្រានោះ ស្ត្រីមេដោះរបស់កុមារិកានោះ ងូតទឹកឱ្យកុមារិកានោះហើយ ប្រាប្ដានឹងងូតទឹកខ្លួនឯង ទើបដើរទៅកាន់កំពង់ទឹក ឃើញរូបនោះក៏សម្គាល់ថា "ធីតារបស់ខ្លួន" ក៏ពោលថា "ឌុ! នាងជាស្ត្រីប្រជៀក្រ, យើងទើបតែងូតទឹក ឱ្យនាងហើយ ភ្លាមដើរចេញមក,ឥឡូវនេះនាងមកទីនេះបានមុនយើងទៀត" លុះពោលដូច្នេះហើយ ក៏ប្រហារូបនោះដោយដៃ ដ៏ងថា រូបនោះរ៉ាង ហើយមិនមានវិការ ទើបពោលថា "យើងបានសម្គាល់ថា "នាងនេះជាធីតារបស់យើង នោះជាអ្វីទៅ ?"

គ្រានោះ ព្រាហ្មណ៍ទាំងនោះ សួរស្ត្រីមេដោះនោះថា "ម្នាលមេ ធីតារបស់នាង មានរូបយ៉ាងនេះឬ ?"

មេដោះ. រូបចម្លាក់នេះនឹងមានតម្លៃអ្វីក្នុងសំណាក់ធីតារបស់យើង ។

ព្រាហ្មណ៍.បើដូច្នោះ ចូរនាងសម្តែងធីតារបស់នាង ដល់ពួកយើង ។

មេដោះនោះ ទៅកាន់ផ្ទះជាមួយនឹងព្រាហ្មណ៍ទាំងឡាយនោះហើយ ក៏ជម្រាបម្តាស់ទាំងឡាយ ។ មាតាបិតារបស់កុមារនោះ រីករាយជាមួយនឹងព្រាហ្មណ៍ហើយ ក៏ឱ្យធីតារបស់ខ្លួនចុះឈរជិតរូបមាសនៅប្រាសាទជាន់ក្រោម ។ រូបមាសនោះអស់រស្មីនៅពេលដែលកុមារិកានោះមកឈរជិត ។ ព្រាហ្មណ៍ទាំងនោះឱ្យរូបមាសនោះទៅមាតាបិតា របស់កុមារិកានោះ ហើយញ៉ាំងកុមារិកានោះឱ្យទទួលទុក ហើយទៅប្រាប់ដល់មាតាបិតារបស់អនិត្ថិគន្ធកុមារ ។

[គូគ្រងរបស់អនិត្ថិគន្ធកុមារស្លាប់ក្នុងចន្លោះផ្លូវ]

មាតាបិតានោះមានចិត្តត្រេកអរហើយ ពោលថា "អ្នកទាំងឡាយចូរទៅ, ចូរនាំកុមារិកានោះមកឱ្យឆាប់" លុះពោលដូច្នេះហើយ ក៏បញ្ជូនគ្រឿងសក្ការៈទៅយ៉ាងច្រើន ។

ចំណែកអនិត្តិគន្ធកុមារ បានឮដំណឹងនោះហើយ ក៏ញ៉ាំងសេចក្តីស្រឡាញ់ឱ្យកើតឡើង ដោយអំណាចសេចក្តីត្រេកអរ ថាបានឮថា "មានក្មេងស្រី មានរូបរាងស្រស់ឆើតជាងរូបមាសទៀត"ទើបពោលថា"អ្នកទាំងឡាយចូរនាំនាងឱ្យឆាប់" ។

ចំណែកកុមារិកានោះ កាលគេលើកឡើងកាន់យាននាំមកមានពេគដែលមានឈ្ងល់ជាសមុដ្ឋានក្នុងចន្លោះផ្លូវ ព្រោះនាងជាស្ត្រី ល្ងាសល្ងន់ក្រៃពេក ។

[សេចក្តីស្រឡាញ់បង្កឱ្យកើតទុក្ខ]

ចំណែកកុមារតែងតែសួររឿយ ៗ "មកហើយឬ ?" ជនទាំងឡាយមិនប្រាប់កុមារនោះ ដែលសួរដោយសេចក្តីស្នេហាក្រៃពេកភ្លាម ៗទេ បង្អែបង្ហង់ ២-៣ ថ្ងៃ ទើបប្រាប់រឿងនោះ ។ កុមារនោះកើតទុក្ខទោមនស្សតូចចិត្តថា "យើងមិនបាននៅការរួមរស់នឹងស្ត្រីបែបនោះ"ត្រូវទុក្ខដែលកើតអំពីសេចក្តីសោក ដូចជាភ្នំគ្របសង្កត់ ។

[ព្រះសាស្តាទ្រង់សម្តែងឧបាយរម្ងាប់សេចក្តីសោក]

ព្រះសាស្តា ទ្រង់ឃើញឧបនិស្សយរបស់កុមារនោះ កាលស្តេចទ្រង់ត្រាច់ទៅបិណ្ឌបាត ស្តេចបានយាងទៅកាន់ទ្វារផ្ទះនោះ ។

គ្រានោះ មាតាបិតារបស់កុមារនោះ អាវធនា និមន្ត្រព្រះសាស្តាចូលផ្ទះ ហើយអង្គាសដោយគោរព ។

ក្នុងវេលាសម្រេចភត្តកិច្ច ព្រះសាស្តាត្រាស់សួរថា "អនិត្ថិគន្ធកុមារទៅណា ?"

មាតាបិតា. បពិត្រព្រះអង្គដ៏ចម្រើន អនិត្ថិគន្ធកុមារនោះ អត់អាហារដេកនៅក្នុងបន្ទប់ ។

ព្រះសាស្តា. ចូរទៅហៅគេមក ។

អនិត្ថិគន្ធកុមារនោះ មកថ្វាយបង្គំព្រះសាស្តាហើយអង្គុយក្នុងចំណែកម្ខាង, កាលព្រះសាស្តាត្រាស់សួរថា "ម្នាលកុមារ សេចក្តីសោកដ៏មានកំលាំងកើតឡើងដល់អ្នកឬ ?" ក៏ក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីសោកដ៏មានកំលាំងកើតឡើងដល់ខ្ញុំព្រះអង្គ ព្រោះបានឮថា ស្ត្រីបែបនោះ ធ្វើកាលកិរិយានៅក្នុងចន្លោះផ្លូវសូម្បីតែភត្ត ក៏ខ្ញុំព្រះអង្គក៏មិនបរិភោគដែរ ។

គ្រានោះ ព្រះសាស្តាត្រាស់ទៅកុមារនោះថា ម្នាលកុមារ អ្នកបានដឹងទេថា សេចក្តីសោកកើតឡើងដល់អ្នក ព្រោះអាស្រ័យអ្វី ?"

អនិត្ថិគន្ធកុមារ. ខ្ញុំព្រះអង្គ មិនដឹងទេ ។

ព្រះសាស្តាត្រាស់ថា "ម្នាលកុមារ សេចក្តីសោកដ៏មានកំលាំងកើតឡើងដល់អ្នកនោះ ព្រោះអាស្រ័យកាម, ព្រោះថាសេចក្តីសោកក្តី ភ័យក្តី រមែងកើតឡើងព្រោះអាស្រ័យកាម" ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា ៖

កាមតោ ជាយតី សោកោ កាមតោ ជាយតី ភយំ

កាមតោ វិប្ប មុត្តស្ស នត្ថិ សោកោ កុតោ ភយំ ។

សេចក្តីសោកកើតអំពីកាម ភ័យកើតអំពីកាម កាលបើរួចស្រឡះចាកកាមហើយ សេចក្តីសោក ក៏លែងមាន ភ័យនឹងមានមកពីណា ។

អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **កាមតោ** *សេចក្តីថាវត្ថុកាម និងកិលេសកាម, អធិប្បាយថា សេចក្តីសោកក្តី ភ័យក្តី រមែកើតឡើងអាស្រ័យកាមសូម្បីទាំងពីរយ៉ាងនោះ ។*

ក្នុងកាលចប់ទេសនា អនិត្ថិគន្ធកុមារបានសម្រេច ក្នុងសោតាបត្តិផល ដូច្នេះឯង ។

រឿងនាងកិសាគោតមី

ព្រះសាស្តា កាលទ្រង់ប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនាងកិសាគោតមី ត្រាស់ព្រះធម៏ទេសនានេះថា "យោ ច វស្សសតំ ជីវេ" ជាដើម ។

[ទ្រព្យរបស់សេដ្ឋីក្លាយជាធ្យូង]

បានញ្ជូថា ទ្រព្យ ៤០ កោដិ ក្នុងផ្ទះរបស់សេដ្ឋីម្នាក់ ក្នុងក្រុងសាវត្ថី បានក្លាយជាធ្យូងអស់ ។ សេដ្ឋីឃើញហេតុនោះ ហើយក៏កើតសេចក្តីសោកសៅ ទើបមិនបរិភោគអាហារដេកនៅលើគ្រែ ។ សម្លាញ់ម្នាក់របស់សេដ្ឋីនោះសួរថា "ហេតុអ្វី ទើបលោកសោកសៅហ្ន៎ ? សម្លាញ់" កាលបានស្តាប់ការរៀបរាប់នោះ ហើយ ទើបពោលថា "កុំសោកសៅឡើយ សម្លាញ់, ខ្ញុំដឹងឧបាយមួយ, ចូរធ្វើឧបាយនោះចុះ" ។

សេដ្ឋី. ធ្វើយ៉ាងណា ? សម្លាញ់ ។

សម្លាញ់. សម្លាញ់ លោកចូរក្រាលកន្ទេលផែងនៅផ្សារ ហើយធ្វើធ្យូងនោះឱ្យជាគំនរ ចូរអង្គុយធ្វើដូចជាលក់, បណ្តាមនុស្សដែលមកហើយ ៗ អ្នកណានិយាយយ៉ាងនេះថាជន ដទៃ

គេលក់សំពត់ ប្រេង ទឹកឃ្មុំ និងទឹកអំពៅជាដើម ចំណែកលោកអង្គុយលក់ផ្លែ លោកគប្ប៉ីនិយាយនឹងអ្នកទាំងនោះថា បើយើងមិនលក់របស់ ?តើឱ្យយើងធ្វើអ្វីទៅ ? ចំណែកអ្នកណានិយាយនឹងលោកយ៉ាងនេះថា បុគ្គលដទៃគេលក់សំពត់ ប្រេង ទឹកឃ្មុំ និងទឹកអំពៅជាដើម ចំណែកលោកអង្គុយលក់ប្រាក់និងមាស" លោកគប្ប៉ីនិយាយចំពោះអ្នកនោះថា ប្រាក់និងមាសនៅឯណា ? ក៏កាលគេនិយាយថា នេះលោកគប្ប៉ីនិយាយថា ចូរនាំប្រាក់មាសនោះមកមើល, ហើយទទួលដោយដៃទាំងពីរ របស់ដែលគេឱ្យក្នុងដៃរបស់លោកយ៉ាងនោះ នឹង ក្លាយជាប្រាក់និងមាស ក៏អ្នកនោះ បើជាស្រីជំទង់ក្រមុំ, លោកចូរនាំនាងមកដើម្បីបុត្រក្នុងផ្ទះរបស់លោកប្រគល់ទ្រព្យ ៤០ កោដិឱ្យដល់នាង គប្ប៉ីប្រើប្រាស់ប្រាក់មាសដែលនាងឱ្យចុះ, បើជាប្រុស លោកគប្ប៉ីឱ្យធីតាដែលចម្រើនវ័យហើយក្នុងផ្ទះរបស់លោកដល់គេ ហើយប្រគល់ទ្រព្យ ៤០ កោដិឱ្យដល់គេ ប្រើប្រាស់ទ្រព្យដែលគេឱ្យ ។

សេដ្ឋីនោះពោលថា "ឧបាយល្អ" ទើបនាំផ្ទូងគរទុកក្នុងកន្ទបរបស់ខ្លួន អង្គុយធ្វើដូចជាលក់ ។ ពួកមនុស្សទាំងឡាយ

និយាយនឹងសេដ្ឋីយ៉ាងនោះយ៉ាងនេះថា "ជនទាំងឡាយគេលក់សំពត់ ប្រេង ទឹកឃ្មុំ និងទឹកអំពៅជាដើម, លោកអង្គុយលក់ធ្យូង" សេដ្ឋីបានតបដល់អ្នកទាំងនោះថា "បើខ្ញុំមិនលក់របស់ ១ ២ ៣ ០ ១ ២ ០ ០ ០

ធ្យូងនោះបានក្លាយជាប្រាក់និងមាសទាំងនោះ ។

លំជាប់នោះ សេដ្ឋីបានសួរនាងថា "នាង ផ្ទះនាងនៅទីណា" ។ នាងឆ្លើយថា "នៅឯណោះលោក"កាលដ៏ងសេចក្តីដែលនាងមិនទាន់មានស្វាមីហើយ ទើបរក្សាទ្រព្យនាំនាងមកដើម្បីបុត្ររបស់ខ្លួន ឱ្យទទួលទ្រព្យ ៤០ កោដិទុក ។ ទ្រព្យទាំងអស់បានក្លាយជាប្រាក់និងជាមាសដូចពីដើម ។

ក្រោយមកនាងក៏បានតាំងគភ៌ ។ ដោយកាលកន្ធងទៅ ១០ ខែ នាងប្រសូតបុត្រហើយ ។ បុត្រនោះបានស្លាប់ទៅក្នុងវេលាចេះដើរ ។ នាងមិនឱ្យអ្នកណាមួយនាំបុត្រនោះទៅដុតឡើយ ព្រោះនាងមិនធ្លាប់ឃើញសេចក្តីស្លាប់ ហើយនាង ក៏បានពរបុត្រស្លាប់នោះដោយចង្អុះ ដោយគិតថា "ទ៏ងសួរកថ្នាំដើម្បីបុត្រយើងនេះ" ដើរសួរទៅតាមលំជាប់ផ្ទះថា "លោកទាំងឡាយស្គាល់ថ្នាំដើម្បីបុត្ររបស់ខ្ញុំទេ ?" ភ្លាមនោះមនុស្សទាំងឡាយនិយាយទ៏ងនាងថា"នាង អ្នកជាមនុស្សឆ្កួតហើយឬ ? អ្នកដើរសួរកថ្នាំដើម្បីបុត្រដែលស្លាប់ហើយ" ។ នាងសម្គាល់ថា "ទ៏ងមានអ្នកស្គាល់ថ្នាំដើម្បីបុត្ររបស់ខ្លួនយ៉ាងពិតប្រាកដ"ទើបត្រាច់ទៅ ។

ខណៈនោះ បុរសជាបណ្ឌិតម្នាក់ ឃើញនាងហើយគិតថា "ធីតារបស់យើងនេះប្រសូតបុត្រជាគ្រាដំបូង មិនធ្លាប់ឃើញសេចក្តីស្លាប់,យើងត្រូវតែជួយស្រីនេះទើបសមគួរ"ហើយក៏បាននិយាយថា "នាងខ្ញុំមិនស្គាល់ថ្នាំទេ, តែខ្ញុំស្គាល់អ្នកដឹងថ្នាំ" ។

នាងគោតមី. អ្នកណាដឹង ? លោក ។

បណ្ឌិត. នាង ព្រះសាស្តាទ្រង់ដឹង, ចូរនាងទៅទូលសួរព្រះអង្គចុះ ។

នាងពោលថា "លោក ខ្ញុំនឹងទៅ, នឹងទូលសួរ" ដូចនោះហើយបានចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំហើយឈរក្នុងទីបំផុតម្ខាង ទូលសួរថា "ព្ធថា ព្រះអង្គទ្រង់ដឹងថ្នាំដើម្បីបុត្ររបស់នាងខ្ញុំឬ ? ព្រះអង្គ" ។

ព្រះសាស្តា. អើ តថាគតដឹង ។

នាងគោតមី. បានអ្វី ? ទើបគួរ ។

ព្រះសាស្តា.បានគ្រាប់ស្ពៃត្រឹមតែមួយក្តាប់ដៃ គួរ ។

នាងគោតមី. នឹងបាន ព្រះអង្គ, តែបានក្នុងផ្ទះអ្នកណា ? ទើបគួរ ។

ព្រះសាស្តា. បុត្រឬធីតាណា ១ ក្នុងផ្ទះរបស់អ្នកណា មិន ធ្លាប់ស្លាប់ ១ បានក្នុងផ្ទះរបស់អ្នកនោះ ទើបគួរ ១

នាងទូលទទួលថា "ល្អណាស់ ព្រះអង្គ" ហើយថ្វាយបង្គំ ព្រះសាស្តា ពរបុត្រដែលស្លាប់ហើយដោយចង្កេះចូលទៅខាងក្នុង ស្រុក ឈរត្រង់ទ្វារផ្ទះដំបូងពោលថា "គ្រាប់ស្ពៃក្នុងផ្ទះនេះ មាន ខ្លះទេ ? ដឹងទេថា នោះជាថ្នាំព្យាបាលបុត្ររបស់ខ្ញុំ" ១ កាលគេ ឆ្លើយថា មាន ទើបពោលថា "បើយ៉ាងនោះចូរឱ្យចុះ" កាលអ្នក ទាំងនោះនាំគ្រាប់ស្ពៃមកឱ្យ, ទើបសួរថា ក្នុងផ្ទះនេះ បុត្រឬធីតា ធ្លាប់ស្លាប់មិនមានខ្លះឬ ? នាង កាលគេឆ្លើយថា និយាយអ្វី ហ្នឹង ? នាង ព្រោះអ្នករស់មានតិចតួច អ្នកស្លាប់នោះឯងមាន ច្រើនទើបពោលថា បើយ៉ាងនោះចូរទទួលគ្រាប់ស្ពៃរបស់លោក ទៅវិញចុះ, នោះមិនជាថ្នាំដើម្បីបុត្ររបស់ខ្ញុំទេ ហើយបានឱ្យយប់ កន្លងទៅគ្រាប់សួរដោយទំនងនេះ តាំងពីផ្ទះដំបូងទៅ ១ នាងមិន បានទទួលគ្រាប់ស្ពៃ សូម្បីក្នុងផ្ទះណាមួយឡើយ ក្នុងវេលាល្ងាច នាងគិតថា "ឱ កម្មធ្ងន់, យើងបានធ្វើសេចក្តីសម្គាល់ថា បុត្ត របស់យើងប៉ុណ្ណោះស្លាប់ក៏ ក្នុងស្រុកទាំងអស់ អ្នកដែលស្លាប់

ប៉ុណ្ណោះ ច្រើនជាងអ្នករស់" ។ កាលនាងគិតយ៉ាងនេះ បេះដូងដែលខ្សោយ ដោយសេចក្តីស្រឡាញ់បុត្របានដល់ សេចក្តីវិនហើយ ។ នាងចោលបុត្រទុកក្នុងព្រៃ ហើយក៏បានទៅកាន់សំណាក់ព្រះសាស្តា ថ្វាយបង្គំហើយ បានឈរក្នុងទីបំផុតម្ខាង ។

លំដាប់នោះ ព្រះសាស្តាត្រាស់នឹងនាងថា "នាងបានគ្រាប់ស្ពៃប្រមាណមួយក្តាប់ដៃហើយឬ ?"

នាងគោតមី.មិនបានទេ ព្រះអង្គ, ព្រោះក្នុងស្រុកទាំងអស់ អ្នកស្លាប់នោះឯងច្រើនជាងអ្នករស់ ។

លំដាប់នោះ ព្រះសាស្តាត្រាស់នឹងនាងថា "នឹងយល់ថា 'បុត្ររបស់ខ្ញុំប៉ុណ្ណោះស្លាប់ឬ, សេចក្តីស្លាប់នោះជាធម៌ មានមកយូរហើយសម្រាប់សត្វទាំងអស់, ដោយថា មច្ចុរាជទំពាស៊ីនូវសព្វសត្វទាំងអស់ អ្នកមានឧបនិស្សរ័យមិនទាន់ចាស់ក្លានោះ និងឈានចុះក្នុងសមុទ្រគឺអបាយ ដូចអន្ទង់ទឹកធំដូច្នោះ" កាលនឹងទ្រង់សម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា ៖

"**យមរាជ រមែងនាំជនអ្នកស្រវឹងក្នុងបុត្រ និងសត្វចិញ្ចឹម អ្នកមានចិត្តបញ្ជូនទៅក្នុងអារម្មណ៍ផ្សេង ៗ ដូចអន្ទង់ទឹកធំកួច**

យកអ្នកស្រុកដែលដេកលក់ទៅ ដូច្នោះ ។

ក្នុងកាលចប់គាថា នាងកិសាគោតមីបានតាំងនៅក្នុងសោតាបត្តិផល, សូម្បីជនពួកដទៃជាច្រើន សម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើមដូច្នេះឯង ។

[នាងបួសក្នុងពុទ្ធសាសនា]

ចំណែកនាងកិសាគោតមីនោះ ទូលសូមបព្វជ្ជាចំពោះព្រះសាស្តាហើយ ព្រះសាស្តាទ្រង់បញ្ជូនទៅកាន់សំណាក់របស់ នាងភិក្ខុនីឱ្យបព្វជ្ជាហើយ ។ នាងបានឧបសម្បទហើយប្រាកដឈ្មោះថា "កិសាគោតមីថេរី" ។

ថ្ងៃមួយ នាងដល់វារៈក្នុងរោងឧបោសថ អង្គុយមើលប្រទីបយើញអណ្តាតប្រទីប ឆេះសន្ធោសន្ធៅឡើងនិងរលត់ចុះ បានកាន់ជាអារម្មណ៍ថា "សត្វទាំងនេះក៏យ៉ាងនោះដូចគ្នាកើតឡើងនិងរលត់ទៅដូចអណ្តាតប្រទីប, អ្នកដល់ព្រះនិព្វានមិនប្រាកដយ៉ាងនោះទេ" ។

ព្រះសាស្តា ប្រថាប់នៅក្នុងព្រះគន្ធកុដិនុ៎ះឯង ទ្រង់ផ្សាយព្រះរស្មីទៅ ដូចគង់ត្រាស់ត្រង់ចំពោះមុខនាង ត្រាស់ថា "យ៉ាង

នោះឯងគោតមី សត្វទាំងនោះក៏យ៉ាងនោះ រមែងកើតនិងរលត់ ដូចអណ្តាតប្រទីប, ដល់ព្រះនិព្វានហើយ រមែងមិនប្រាកដយ៉ាងនោះទេ សេចក្តីរស់នៅសូម្បីត្រឹមតែមួយខណៈរបស់អ្នកឃើញ ព្រះនិព្វាន ប្រសើរជាងសេចក្តីរស់នៅអស់ ១០០ ឆ្នាំ របស់អ្នកមិនឃើញព្រះនិព្វាននោះ" ដូច្នេះហើយ កាលនឹងទ្រង់បន្ត អនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា ៖

យោ ច វស្សសតំ ជីវេ អបស្សំ អមតំ បទំ
ឯកាហំ ជីវិតំ សេយ្យោ បស្សតោ អមតំ បទំ ។

បុគ្គលណា រស់នៅមួយរយឆ្នាំ មិនឃើញផ្លូវព្រះនិព្វាន ការរស់នៅសូម្បីតែមួយថ្ងៃ របស់លោកអ្នកឃើញ ផ្លូវព្រះនិព្វាន ប្រសើរជាង ។

អធិប្បាយគាថា

បណ្តាបទទាំងនោះ ពីរបទថា អមតំ បទំ សេចក្តីថា អមតមហានិព្វានដែលជាចំណែកនៃធម៌ប្រាសចាកមរណៈ ។

ពាក្យដ៏សេសដូចគ្នានឹងពាក្យក្នុងកាលមុននោះឯង ។

ក្នុងវេលាចប់ទេសនា នាងកិសាគោតមីគង់នៅកន្លែង

ដ៏ដែលនុ៎ះឯង បានតាំងនៅក្នុងព្រះអរហត្ត ព្រមដោយបដិសម្ភិទាទាំងឡាយ ដូច្នេះឯង ។

រឿងនាងបដាចារា

ព្រះសាស្តាកាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះនាងបដាចារាបើគ្រាស់ព្រះគាថានេះថា "យោ ច វស្ស្ស តំ ជីវេ" ជាដើម ។

[សេចក្ដីស្រឡាញ់មិនជ្រើសរើសវណ្ណៈ]

បានឮថា នាងបដាចារានោះ ជាធីតារបស់សេដ្ឋីអ្នកមានសម្បត្តិ ៤០ កោដិ ដែលមានប្រក្រតីនៅក្នុងក្រុងសាវត្ថី ជាស្ត្រីមានរូបល្អឆើតឆាយ ។ ក្នុងវេលាដែលនាងមានអាយុ ១៦ ឆ្នាំ មាតាបិតារបស់នាង បានឱ្យនាងនៅលើប្រាសាទជាន់ទី ៧ ដើម្បីរក្សានាង ។ សូម្បីដូច្នោះក៏ដោយ នាងក៏នៅតែប្រព្រឹត្តខុសប្រពៃណី ជាមួយនឹងកូនឈ្នួលរបស់នាង ។ គ្រានោះមាតាបិតារបស់នាង លើកនាងឱ្យដល់បុរសកម្លោះម្នាក់ ក្នុងត្រកូលដែលមានជាតិស្មើគ្នា រួចហើយបានកំណត់ថ្ងៃវិវាហមង្គល ។ កាល

ថ្ងៃវិវាហ៍នោះចូលមកដល់, នាងក៏ពោលនឹងកូនឈ្មួលនោះថា មាតាបិតារបស់ខ្ញុំ បានលើកខ្ញុំឱ្យទៅត្រកូលឯណោះ, ក្នុងកាលដែលខ្ញុំទៅកាន់ត្រកូលស្វាមី ពេលនោះសូម្បីលោកកាន់យកបណ្ណាការដើម្បីខ្ញុំក៏មិនអាចចូលទៅកាន់ទីនោះបានដែរ, បើលោក ស្រឡាញ់ខ្ញុំពិតមែននោះ, លោកចូរនាំខ្ញុំចាកចេញអំពីទីនេះ ទៅកាន់ទីណាមួយ ក្នុងកាលឥឡូវនេះចុះ" ។ អ្នកបម្រើនោះយល់ព្រមដោយ "ប្រពៃហើយ នាងជ័ចម្រើន" ហើយពោលថា "បើដូច្នេះ ថ្ងៃស្អែកនេះខ្ញុំនឹងរង់ចាំនាងនៅទីឯណោះនៃទ្វារនគរអំពីព្រឹកព្រលឹម នាងគប្បីចេញទៅដោយឧបាយយ៉ាងណានីមួយ ហើយទៅកាន់ទីនោះចុះ"ដល់ថ្ងៃទី ២ ក៏បានទៅរង់ចាំនាងក្នុងទីដែលបានសន្យាគ្នា ។

[នាងបជាចារគេចចៀសទៅនឹងអ្នកបម្រើ]

ធីតាសេដ្ឋីនោះស្លៀកសំពត់ចាស់ ១ រំសាយសក់យកកន្ទុក់លាបសរីរៈកាន់ក្អមទឹកចេញអំពីផ្ទះ ធ្វើដូចជាដើរទៅជាមួយនឹងពួកទាសីបានទៅកាន់ទីដែលណាត់គ្នា អំពីព្រឹកព្រលឹម ។ បុរសជាអ្នកបម្រើនោះនាំនាងទៅកាន់ទីឆ្ងាយហើយ សម្រេចកិរិយាអាស្រ័យនៅក្នុងស្រុកមួយ ភ្ជួរស្រែក្នុងព្រៃមួយ ហើយបាននាំ

ខ្សនិងបន្ទៃជាដើមមក ។ ឯធីតាសេដ្ឋីនោះវិញ យកក្អមទៅដងទឹកមកហើយ ធ្វើកិច្ចទាំងឡាយ មានការបុកអង្ករ និងដាំបាយជាដើមដោយដៃខ្លួនឯង ។ ពេលដែលនាង មានគកិ៍ចាស់ក៏បានអង្វរស្វាមីថា បពិត្រនាយ បុគ្គលណា ៗដែលជាអ្នកមានឧបការៈដល់យើង មិនមាននៅទីនេះទេ, ធម្មតា មាតាបិតាជាអ្នកមានចិត្តទន់ភ្ជន់ក្នុងបុត្រទាំងឡាយ,សូមលោកនាំខ្ញុំទៅកាន់សម្ងាក់នៃមាតាបិតារបស់ខ្ញុំចុះ, ខ្ញុំនឹងប្រសូតបុត្រនៅទីនោះ" ។ ស្វាមីនោះហាមឃាត់ថា"ម្នាលនាងដ៏ចម្រើន នាងនិយាយអ្វី ? មាតាបិតារបស់នាងឃើញខ្ញុំហើយ គប្បីធ្វើនូវអំពើកម្មទាំងឡាយ មានប្រការផ្សេង ៗ ខ្ញុំមិនអាចទៅកាន់ទីនោះបានទេ" ។ សូម្បីនាងអង្វរយ៉ាងណាក៏ដោយ ស្វាមីរបស់នាងនៅតែមិនព្រមជូននាងទៅដែរ កាលដែលស្វាមីរបស់នាង មិនយល់ព្រមដូច្នោះ ពេលដែលស្វាមីនាងទៅព្រៃ នាងក៏ផ្តាំមនុស្សដែលនៅជិតខាងថា ខ្ញុំទៅកាន់ត្រកូលរបស់ខ្លួនហើយ" លុះផ្តាំដូច្នេះហើយក៏បិទទ្វារផ្ទះចៀសចេញទៅ ។

ចំណែកបុរសដែលជាស្វាមីមកដល់ហើយ មិនឃើញភរិយារបស់ខ្លួន ក៏សួរមនុស្សដែលស្និទ្ធស្នាលទាំងឡាយ លុះ

បានដឹងថា ភរិយារបស់ខ្លួនទៅកាន់ត្រកូលរបស់ខ្លួន ក៏រត់តាមទៅ ដោយគិតថា "នឹងនាំនាងត្រឡប់មកវិញ" ជួបនាងពាក់កណ្តាលផ្លូវហើយ អង្វរនាងឱ្យទៅផ្ទះវិញ សូម្បីអង្វរយ៉ាងណាក៏ដោយ ក៏មិនអាចញុំាងនាងឱ្យត្រឡប់វិញបាន ។ គ្រានោះខ្យល់កម្មជ្ជវាត (ខ្យល់ដែលកើតអំពីកម្ម) របស់នាងកម្រើកឡើងក្នុងទីមួយ ។ នាងចូលទៅក្នុងចន្ទោះគុម្ពឈើមួយគុម្ព ហើយនិយាយថា "បពិត្រនាយ ខ្យល់កម្មជ្ជវាតរបស់ខ្ញុំកម្រើកឡើងហើយ" នាងដេកបម្រះនៀលនៅលើផែនដី ប្រសូត ទារកបានដោយលំបាក លុះប្រសូតហើយក៏គិតថា "យើងទៅកាន់ផ្ទះនៃត្រកូលដើម្បីប្រយោជន៍ណា, ប្រយោជន៍នោះបានសម្រេចហើយ" ក៏ត្រឡប់មកកាន់ផ្ទះជាមួយនឹងស្វាមីរួមរស់នៅ ជាមួយគ្នាតទៅទៀត ។

សម័យក្រោយមកទៀតនាងក៏តាំងគភ៌ម្តងទៀត ។ ពេលដែលនាងមានគភ៌ចាស់ នាងបានអង្វរស្វាមីដោយន័យមុនទុំ:ឯងកាលស្វាមីមិនព្រមជូនទៅក៏នាំយកបុត្រដោយចង្កេះ ចៀសចេញទៅជួចលើកមុននោះឯង សូម្បីស្វាមីរបស់នាងតាមទៅទាន់ហើយ អង្វរយ៉ាងណាក៏ដោយ ក៏នាងមិនប្រាថ្នានឹងត្រឡប់វិញដែរ ។

គ្រានោះ កាលជនទាំងនោះកំពុងដើរទៅ, មហាមេឃដែលមិនមែនជារដូវកាលបានកើតឡើង ។ ផ្ទៃអាកាស ដូចជាឆេះទៅហើយ ដោយផ្លេកបន្ទោរទាំងឡាយ ផ្ទៃមេឃមានទឹកធ្លាក់ចុះមិនមានចន្លោះ ដូចជាបែកដោយការប៉ះទង្គិចគ្នានៃមេឃទាំងឡាយ ។ ក្នុងខណៈនោះខ្យល់កម្មជ្ជវាតរបស់នាងកម្រើកឡើង ។ នាងប្រាប់ស្វាមីរបស់នាងថា "បពិត្រនាយ ខ្យល់កម្មជ្ជវាតរបស់ខ្ញុំកម្រើកឡើងហើយ, ខ្ញុំមិនអាចទ្រាំបានទេ, លោកចូរស្វែងរកទីកន្លែងណា ដែលមិនមានភ្លៀងធ្លាក់ស្រោចខ្ញុំចុះ" ។ ពេលនោះ ស្វាមីរបស់នាងកាន់កាំបិតទៅរក មើលឈើខាងនេះ ខាងនោះ បានឃើញគុម្ពឈើដែលដុះនៅ លើដំបូកមួយកន្លែងផ្តើម នឹងកាប់ ។ លំដាប់នោះ អាសិរពិសមានពិសដ៏ពន្ធឹកវារចេញអំពីដំបូក ១ ១ ១

បាន ក៏ស្រែកទ្រហោយំ ។ នាងយកទារកទាំងពីរនោះ មកជាក់ក្រោមពោះ ត្រាបលើផែនដីដោយជង្គង់ទិងដៃទាំង ២ញ៉ាំងរាត្រីឱ្យកន្លងទៅអស់មួយរាត្រី ។ សរីរៈទាំងអស់របស់នាងមានពណ៌ដូចជា ពណ៌ស្វ៊ីកឈើលឿងដូចជាមិនមានឈាម ។ កាលអរុណរះឡើង នាងនាំបុត្រម្នាក់ដែលមានពណ៌ដូចជាដុំសាច់ដោយចង្កេះដឹកដៃកូនបងហើយពោលថា "មកចុះកូនសម្លាញ់,បិតាកូនឯងទៅតាមផ្លូវនេះ" លុះពោលដូច្នេះហើយ ក៏បីនិងដឹកដៃកូនធ្វើដំណើរទៅតាមផ្លូវដែលស្វាមីដើរទៅឃើញស្វាមីដួលស្លាប់នៅលើដំបូកមានពណ៌ខៀវ សរីរៈរឹងដូចអង្គត់ឧសក៏ទួញ យំ ខ្សឹកខ្សួលថា ព្រោះតែយើង ទើបស្វាមីរបស់យើងស្លាប់តាមផ្លូវស្វាត់យ៉ាងនេះ ដូច្នេះហើយ ក៏ដើរទៅ ។

នាងឃើញស្ទឹងអចិរវតី ពោរពេញទៅដោយទឹកមានប្រមាណត្រឹមជង្គង់ និងប្រមាណត្រឹមដោះ ព្រោះភ្លៀងធ្លាក់រហូតមួយយប់ទល់ភ្លឺ នាងមិនអាចយកទារកទាំងពីរនាក់ឆ្លងស្ទឹងដែលមានទឹកជ្រៅ ទៅព្រមជាមួយគ្នាបានទេ ព្រោះភាវៈនៃខ្លួន ជាស្ត្រីមានស្នាតីទន់ខ្សោយ ទើបជាក់បុត្រច្បងទុកនៅត្រើយខាងអាយ

ហើយនាំបុត្រតូចក្រៅនេះ ទៅកាន់ត្រើយនាយ ក្រាលបំណាច់នៃមែកឈើជាក់ឱ្យបុត្រដេកហើយ គិតថា "នឹងទៅកាន់លំនៅរបស់បុត្រក្រៅនេះ" ដោយមិនអាចលះបង់បុត្រតូចបាន នាងដើរទៅដោយការក្រឡេកមើលកូនខ្ចីនោះរឿយ ៗ ។ លុះនាងដើរទៅកណ្តាលស្ទឹង ខ្ទ្រង់មួយឃើញទារកនោះហើយ ក៏ឆាបចុះមកអំពីអាកាសដោយសម្គាល់ថា "ជាដុំសាច់" ។ នាងឃើញសត្វខ្ទ្រង់វាឆាបចុះ បម្រុងនឹងឆាបយកបុត្រខ្ចីរបស់ខ្លួន ក៏លើកដៃទាំងពីរឡើង ស្រែកដោយមានសំឡេងខ្លាំង ៗ ៣ ដងថា "សូសូសូ" ខ្ទ្រង់មិនបានញ្ញសំឡេងនោះទេ ព្រោះនៅឆ្ងាយ ក៏ឆាបយកកូនខ្ចីនោះហើរឡើងកាន់វេហាស៍ចាត់ទៅ ។ ចំណែកបុត្រដែលឈរនៅត្រើយខាងអាយ ឃើញមាតាលើកដៃទាំងពីរឡើង ស្រែកដោយមានសំឡេងខ្លាំង ៗ នៅកណ្តាលស្ទឹង ក៏លោតចុះស្ទឹងយ៉ាងរហ័ស ដោយសម្គាល់ថា "មាតាហៅខ្លួន" ។ សត្វខ្ទ្រង់ឆាបយកបុត្រតូចរបស់នាងទៅ បុត្រច្បង ត្រូវទឹកបន្ទ្រាត់ទៅដោយប្រការដូច្នេះ ។

[នាងជ្រាបដំណឹងថាមាតាបិតាស្លាប់ទៀត]

នាងធ្វើដំណើរទៅ ដោយទ្ទេញវ៉ូកវ៉ូលថា "បុត្ររបស់យើងម្នាក់ត្រូវខ្វែងឆាបយកទៅ, បុត្រម្នាក់ទៀតត្រូវទ័ពបន្ទាត់ទៅ, ស្វាមីក៏ស្លាប់ក្នុងទីស្ងាត់" ជួបបុរសម្នាក់ដើរមកពីក្រុងសាវត្ថី ទើបសួរថា"ម្នាលអ្នកដ៏ចម្រើនលោកមកអំពី ណា ?"

បុរស. ម្នាលនាងដ៏ចម្រើន ខ្ញុំមកពីក្រុងសាវត្ថី ។

ធីតាសេដ្ឋី. ម្នាលនាងដ៏ចម្រើន ត្រកូលឈ្មោះនេះ នៅជិតថ្នល់ឯណោះ ក្នុងក្រុងសាវត្ថី, លោកស្គាល់ទេ ?

បុរស. ម្នាលនាងដ៏ចម្រើន ខ្ញុំស្គាល់ច្បាស់ណាស់ ប៉ុន្តែសូមកុំសួរដល់ត្រកូលនោះទ្បើយ,បើមនាងចង់ដឹង ត្រកូលដទៃ, ចូរសួរមកចុះ ។

ធីតាសេដ្ឋី.ការចង់ដឹងត្រកូលដទៃរបស់ខ្ញុំមិនមានទេ, ខ្ញុំចង់ដឹងតែត្រកូលនោះប៉ុណ្ណោះឯង ដូច្នោះសូមលោកប្រាប់មក ។

បុរស.ម្នាលនាង ខ្ញុំមិនសមគួរនឹងប្រាប់នាងទ្បើយ ។

ធីតាសេដ្ឋី. ម្នាលអ្នកដ៏ចម្រើន ចូរប្រាប់មកចុះ ។

បុរស. ម្នាលនាងដ៏ចម្រើន ថ្ងៃនេះ នាងមានឃើញភ្លៀង

ជ្ជាក់ចុះមួយយប់ទល់ភ្លឺទេ ?

ធីតាសេដ្ឋី. ម្នាលអ្នកដ៏ចម្រើន ខ្ញុំបានឃើញ, ហើយភ្លៀងនោះបង្អុរចុះមកដើម្បីខ្ញុំប៉ុណ្ណោះ ដល់លោកជាទាងក្រោយ, មេត្តាប្រាប់ការប្រព្រឹត្តទៅនូវព្រឹត្តិការណ៍ក្នុងផ្ទះសេដ្ឋីនោះដល់ខ្ញុំចុះ ។

បុរស. ម្នាលនាងដ៏ចម្រើន ថ្ងៃនេះនៅពាក់កណ្តាលយប់ ផ្ទះរលំសង្ក្តត់ជនទាំងបីនាក់ គឺសេដ្ឋី ១ ភរិយាសេដ្ឋី ១ បុត្រសេដ្ឋី ១,ជនទាំងបីនាក់នោះត្រូវជុតនៅលើជើងថ្ករតែមួយជាមួយនឹងគ្នា,ម្នាលនាងដ៏ចម្រើនទ្ញុ:ផ្សែងនោះនៅប្រាកដនៅឡើយ ។

ក្នុងខណៈនោះ នាងមិនបានដឹងថា សំពត់ដែលនាងស្លៀកនោះ របូតចេញពីខ្លួនឡើយ ដល់ភាពជាមនុស្សវិកលចរិត ឈរនៅមួយកន្លែង ទ្ញយ:ខ្សែកខ្សួលរៀបរាប់ថា ៖

"បុត្រ ២ នាក់ ស្លាប់ហើយ, ស្វាមីរបស់យើងក៏ស្លាប់ត្រង់ផ្លូវស្ងាត់, មាតាបិតានិងបងប្រុសក៏ត្រូវជុតលើជើងថ្ករតែមួយជាមួយនឹងគ្នា" ។

មនុស្សទាំងឡាយឃើញនាងហើយ ក៏ហៅនាងថា "ស្ត្រីឆ្កួត" រួចក៏យកសម្រាម អាចម៍ដី ចាចជាក់លើក្បាលនាងយក

ជុំជីគប់ត្រៃវ៉ែង និងប្រហារដោយប្រការផ្សេង ១ ។

ព្រះសាស្តា ទ្រង់គង់សម្តែងធម៌ នៅក្នុងកណ្តាលបរិស័ទទាំង ៤ ក្នុងវត្តជេតពនមហាវិហារ បានទតឃើញនាងដែលជាអ្នកបំពេញ ចារមីមកមួយសែនកប្ប ដល់ព្រមដោយអភិនីហារកំពុងដើរមក ។

[នាងបានតាំងសេចក្តីប្រាថ្នាទុកក្នុងជាតិមុន]

បានឮថា ក្នុងកាលនៃព្រះពុទ្ធទ្រង់ព្រះនាមថា **បទុមុត្តរៈ** នាងបជាចារនោះ ឃើញព្រះថេរីអ្នកទ្រទ្រង់វិន័យមួយរូបដែលព្រះបទុមុត្តរសាស្តា ទ្រង់តែងតាំងទុកក្នុងតំណែងជាឯតទគ្គៈផ្នែកខាងវិន័យធរ ហាក់ដូចជាបានសក្ការជចាប់ត្រង់ដើមដៃ ទៅជាក់ក្នុងសួនឧទ្យាន ទើបធ្វើសេចក្តីល្អ ប្រាថ្នាទុកថា បពិត្រព្រះអង្គដ៏ចម្រើន សូមឲ្យខ្ញុំព្រះអង្គ ក៏គប្បីបានជាស្ត្រីដ៏ឆ្នើមក្នុងចន្លោះនៃព្រះថេរីអ្នកទ្រទ្រង់វិន័យទាំងឡាយ ក្នុងសំណាក់ព្រះពុទ្ធជាម្ចាស់ ដូចជាព្រះថេរីនេះដែរ, ព្រះបទុមុត្តរជាម្ចាស់ទ្រង់ពិចារណាមើលនូវអនាគត ដោយអនាគតសញ្ញាណទៅ ក៏ទ្រង់ជ្រាបថា សេចក្តីប្រាថ្នារបស់នាងនឹងបានសម្រេច ទើបទ្រង់ព្យាករណ៍ថា "ក្នុងអនាគតកាល ស្ត្រីអ្នកនេះនឹងបានជាស្ត្រីដ៏ឆ្នើមជាងព្រះថេរី អ្នក

ទ្រទ្រង់វិន័យទាំងឡាយ មានឈ្មោះថា បជាចារបៀវក្នុងសាសនានៃព្រះពុទ្ធ ព្រះនាមគោតម ។

ព្រះសាស្តា ទ្រង់ជ្រាបថា នាងជាអ្នកស្ត្រីមានសេចក្តីប្រាថ្នាតាំងទុកហើយយ៉ាងនោះ ជាអ្នកបរិបូណ៌ដោយអភិនីហារកំពុងតែដើរមកអំពីចម្ងាយ ទ្រង់ព្រះតម្រិះថា "រៀរចាកតថាគតហើយអ្នកដទៃដែលឈ្មោះថា អាចជាទីពឹងរបស់ស្ត្រីនេះ រមែងមិនមាន" នាងមានមុខឆ្ពោះទៅកាន់វិហារ ដោយប្រការណា ព្រះសម្មាសម្ពុទ្ធក៏ទ្រង់ធ្វើយ៉ាងនោះ ។

បរិស័ទឃើញនាងហើយ ក៏ពោលថា "ម្នាលអ្នកទាំងឡាយ កុំឱ្យស្ត្រីឆ្កួតនេះមកទីនេះឡើយ" ។

ព្រះសាស្តា ទ្រង់ត្រាស់ថា "ម្នាលអ្នកទាំងឡាយ អ្នកទាំងឡាយចូរចៀសចេញ, កុំហាមឃាត់នាងឡើយ" ក្នុងកាលដែលនាងមកជិតដល់ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា "ម្នាលប្អូនស្រី ចូរនាងមានស្មារតីឡើង" ។ ក្នុងខណៈនោះឯង នាងក៏ត្រឡប់បានស្មារតីដោយពុទ្ធានុភាព ។ ក្នុងពេលនោះនាងក៏បានដឹងថា សំពត់ដែលនាងស្លៀកនោះ របូតចេញអំពីខ្លួននាងហើយញ្ជុំងហិរិឌ្ឍិតប្ប:

ឱ្យកើតឡើង ហើយអង្គុយប្រហោងមុខបរិស័ទទាំងឡាយ ។ គ្រានោះ បុរសម្នាក់បានបោះសំពត់ដណ្តប់ទៅឱ្យនាង ។ នាងស្លៀកសំពត់នោះហើយ ចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំដោយបញ្ចូគ្គប្រតិស្ថានទៀប ព្រះបាទទាំងគូ ដែលមានវណ្ណៈដូចមាស ហើយទូលថា "បពិត្រ ព្រះអង្គដ៏ចម្រើន សូមព្រះអង្គជាទីពឹងដល់នាងខ្ញុំព្រះអង្គផងចុះ ព្រោះថា បុត្ររបស់ខ្ញុំម្នាក់ ត្រូវខ្លែងឆាបយកទៅ, ម្នាក់ទៀតត្រូវទឹកបន្ទាត់ទៅ, ស្វាមីត្រូវស្លាប់ត្រង់ផ្លូវស្ងាត់, មាតាបិតានិងបងប្រុសត្រូវផ្ទុះបាក់សង្ក្ដត់ស្លាប់ គេដុតនៅលើជើងភ្នំជាមួយគ្នា" ។ ព្រះសាស្តាទ្រង់សណ្ដាប់នូវពាក្យរបស់នាងហើយ ក៏ទ្រង់ត្រាស់ថា "ម្នាលនាងបចារ នាងកុំព្រួយ ប្រាជ្ញាឡើយ នាងបានមកកាន់សំណាក់របស់តថាគតអ្នកអាចនឹងជាទីពឹងពំនាក់អាស្រ័យរបស់នាងហើយ, ដូចយ៉ាងថា ឥឡូវនេះ បុត្រម្នាក់របស់នាងត្រូវខ្លែងឆាបយកទៅ ម្នាក់ទៀត ត្រូវទឹកបន្ទាត់ទៅ, ស្វាមីស្លាប់នៅត្រង់ផ្លូវស្ងាត់, មាតាបិតានិងបងប្រុសត្រូវផ្ទុះបាក់សង្ក្ដត់យ៉ាងណា, ទឹកភ្នែកដែលហូរចេញរបស់អ្នកដែលយំ ក្នុងសង្សារវដ្ដនេះ ក្នុងវេលាដែលបិយជនមានបុត្រជាដើមស្លាប់

នោះ ច្រើនជាងទឹកមហាសមុទ្រទាំង ៤ ទៅទៀតដូច្នេះហើយ ទ្រង់ត្រាស់ព្រះគាថានេះថា ៖

"ទឹកក្នុងសមុទ្រទាំង ៤ មានប្រមាណតិច, ទឹកភ្នែករបស់បុគ្គលដែលទុក្ខពាល់ត្រូវហើយ សោយសោក មិនមែនតិច គឺច្រើនជាងទឹកក្នុងមហាសមុទ្រនោះទៅទៀត, ម្នាលនាង ព្រោះហេតុអ្វី ទើបនាងនៅប្រមាទ ។

លុះព្រះសាស្តា ទ្រង់ត្រាស់អនមតគ្គបរិយាយសូត្រយ៉ាងនេះហើយ, សេចក្តីសោកក្នុងចិត្តរបស់នាង បានដល់នូវភាពធុរស្រាល ។

គ្រានោះ ព្រះសាស្តាទ្រង់ជ្រាបថា នាងមានសេចក្តីសោកស្រាលស្តើងហើយ ក៏ទ្រង់ជាស់តឿនទៀត ហើយត្រាស់ថា "ម្នាលបជាបតី ដែលឈ្មោះថា ឧិយជន មានបុត្រជាដើម មិនអាចដើម្បីជាទីពឹងឬជាទីអាង ឬជាទីពួនរបស់បុគ្គល ដែលទៅកាន់បរលោកបានឡើយ, ព្រោះហេតុនោះ សូម្បីមានក៏ឈ្មោះថាមិនមានដោយពិត, គឺមានដូចជាអត់ ចំណែកបណ្ឌិតជម្រះសីលហើយ គួរជម្រះផ្លូវដែលញ៉ាំងសត្វឱ្យដល់និព្វានរបស់ខ្លួនប៉ុណ្ណោះ"

កាលនឹងទ្រង់សម្តែងធម៌បានត្រាស់ព្រះគាថាទាំងនេះថា ៖

"បុត្រទាំងឡាយ មិនមានដើម្បីជាទីពឹង, បិតាក៏មិនមាន សម្រាប់ជាទីពឹងក៏មិនមាន កាលបុគ្គលត្រូវសេចក្តីស្លាប់គ្របសង្កត់ហើយ ភាពជាទីពឹងក្នុងញាតិទាំងឡាយ រមែងមិនមាន បណ្ឌិតជ្រាបអំណាចប្រយោជន៍នោះហើយ សង្រ្តមក្នុងសីល គប្បីជម្រះផ្លូវទៅនិព្វានដោយរហ័សកុំបង្អង់ ។

ក្នុងកាលចប់ទេសនា នាងបដាចារដុតកិលេសមានប្រមាណប៉ុនលម្អងធូលីក្នុងផែនដីដ៏ធំហើយ តាំងនៅក្នុងសោ-តាបត្តិផល, ជនសម្រាប់ពួកជនទៃជាច្រើនសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

[នាងបដាចារទូលសូមបួស]

ចំណែកនាងបដាចារនោះ លុះបានជាសោតាបន្នហើយ ក៏ទូលសូមបព្វជ្ជានឹងព្រះសាស្តា ។ ព្រះសាស្តាទ្រង់បញ្ជូននាងទៅកាន់សំណាក់របស់ពួកភិក្ខុនី ដើម្បីឱ្យភិក្ខុនីទាំងឡាយបំបួសនាង ។ លុះនាងបានឧបសម្បទហើយ មានឈ្មោះថា **បដាចារ** ព្រោះនាងមានការងារធ្លាក់ចុះ គឺ ជាអ្នកប្រព្រឹត្តវៀរចាកផ្ទាំង

សម្ពត់ ។ ថ្ងៃមួយ នាងនាំយកទឹកដោយក្អមមក លាងជើងក្នុងពេលដែលលាងនោះ នាងបានស្រោចនូវទឹក ។ ទឹកដែលនាងស្រោចនោះ ហូរទៅបានបន្ទិចក៏ជ្រាបចូលទៅក្នុងដីអស់ ។ ទឹកដែលនាងស្រោចលើកទី ២ ហូរទៅបានឆ្ងាយជាងទឹកដែល នាងស្រោចលើកដំបូង ទឹកដែលនាងស្រោចលើកទី ៣ ហូរទៅបានឆ្ងាយជាងទឹកដែលនាងស្រោចលើកទី ១-២ ។ នាងកាន់យកទឹកនោះឯងជាអារម្មណ៍កំណត់វិយទាំង ៣ ហើយគិតថា សត្វទាំងនេះ ស្លាប់ក្នុងបឋមវិយក៏មាន ដូចទឹកដែលយើងស្រោចលើកដំបូង, ស្លាប់ក្នុងមជ្ឈិមវិយក៏មាន ដូចទឹកដែលយើងចាក់ចុះគ្រាទី ២ ហូរទៅបានឆ្ងាយជាងនោះ, ស្លាប់ក្នុងបច្ឆិមវិយក៏មាន ដូចទឹកដែលយើងចាក់ចុះគ្រាទី ៣ ហូរទៅបានឆ្ងាយសូម្បីជាងនោះ" ។

ព្រះសាស្តាទ្រង់គង់នៅក្នុងព្រះគន្ធកុដិ ទ្រង់ផ្សាយព្រះរស្មីទៅកាន់សម្ពាក់របស់នាង ហាក់ដូចជាព្រះអង្គទ្រង់គង់នៅចំពោះមុខរបស់នាង ត្រាស់ថា "ម្នាលនាងបជាចារ កាលដែលនាងគិតនោះ យ៉ាងហ្នឹងហើយ, ព្រោះថាការរស់នៅមួយថ្ងៃក្តី មួយខណៈក្តី របស់បុគ្គលដែលឃើញការកើតឡើង និងការរលត់ទៅនៃបញ្ចូ-

ខន្ធទាំងនោះ ប្រសើរជាងការរស់នៅ ១០០ ឆ្នាំ របស់បុគ្គលដែលមិនបានឃើញ ការកើតឡើងនិងការលត់ទៅនៃបញ្ចខន្ធ” លុះទ្រង់សម្តែងដូច្នេះហើយ កាលនឹងទ្រង់បន្តអនុសន្ធិ ដើម្បីសម្តែងធម៏ បានត្រាស់ព្រះគាថានេះថា ៖

យោ ច វស្សសតំ ជីវេ អបស្សំ ឧទយព្ពយំ
ឯកាហំ ជីវិតំ សេយ្យោ បស្សតោ ឧទយព្ពយំ ។

បុគ្គលណារស់នៅ ១០០ ឆ្នាំ មិនឃើញការកើតឡើងនិងការវិនាសទៅ ការរស់នៅសូម្បីតែមួយថ្ងៃ របស់លោកដែលឃើញការកើតឡើង និងការវិនាសទៅ ប្រសើរជាង ។

អធិប្បាយគាថា

បណ្តាបទទាំងនោះ បាទគាថាថា អបស្សំ ឧទយព្ពយំ សេចក្តីថា មិនឃើញការកើតឡើង និងការវិនាសទៅ ដោយលក្ខណៈ ២៥ នៃបញ្ចក្ខន្ធ ។

បាទគាថាថា បស្សតោ ឧទយព្ពយំ សេចក្តីថា ការរស់នៅសូម្បីតែមួយថ្ងៃរបស់បុគ្គលដែលឃើញការកើតឡើង និងសេចក្តី

វិនាសទៅនៃបញ្ចក្ខន្ធទាំងនោះ ប្រសើរជាងការរស់នៅរបស់បុគ្គលក្រៅនេះ ។

ក្នុងកាលចប់ធម៌ទេសនា នាងបជាចារាសម្រេចព្រះអរហត្ត ព្រមដោយបដិសម្ភិទាទាំងឡាយ ដូច្នេះឯង ។

បុរាណលោកសរុបថា ~ ខ្ជាស់ត្បឿនចិត្តថា ÷

ស្រឡាញ់ច្រើនទឹកភ្នែកក៏ច្រើន អត់ស្រឡាញ់អត់ទឹកភ្នែក,
ស្រឡាញ់ច្រើនក៏មានទុក្ខច្រើន អត់ស្រឡាញ់ក៏អត់ទុក្ខដែរ ។
ទុក្ខរមែងមិនមានដល់បុគ្គលដែលអស់នូវអាសវៈទាំងពួង ។

វិធីកម្ចាត់បង់សេចក្តីសោក

សេចក្តីសោក កើតមកអំពីរបស់ដែលជាទីស្រឡាញ់នៅពេលដែលរបស់ព្រាត់ប្រាសទៅ, ធម្មតាបុថុជ្ជន រមែងមិនអាចដើម្បីនឹងជាអ្នកមិនមានសេចក្តីសោក ក្នុងកាលទាំងពួងបានឡើយ ។ រៀរលែងតែព្រះខីណាស្រព ដែលជាអ្នកមិនមានអាសវៈកិលេស មានចិត្តជាប់ស្រឡះ មិនរសេមរសាម មិនជាប់ជំពាក់នៅក្នុងរបស់ទាំងពួងនោះ ។ តែសម្រាប់មនុស្សយើងធម្មតាដែលជាអ្នកមាននូវរាគៈ ទោសៈ មោហៈជាដើមនោះ ត្រូវតែមាន

សេចក្តីសោក តែសេចក្តីសោកនេះ ក៏មិនអាចស្ថិតនៅក្នុងចិត្ត ជាប់រហូតដែរ ថ្ងៃណាមួយ សេចក្តីសោកនេះវានឹងអស់ទៅមិនខាន គ្រាន់តែយូរនឹងឆាប់ប៉ុណ្ណោះ ។ នៅក្នុងព្រះសាសនាព្រះ-សម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់អំពីវិធីដើម្បីកម្ចាត់បង់នូវសេចក្តីសោករបស់សត្វលោក គឺ បុគ្គលដែលត្រូវសេចក្តីសោកគ្របសង្កត់ហើយត្រូវចូលទៅរកសប្បុរសដែលជាបណ្ឌិត ដោយការស្តាប់នូវព្រះធម៏របស់លោកជាដើម ។

ម្យ៉ាងទៀតដើម្បីកម្ចាត់បង់នូវសេចក្តីសោកនោះ គួររៀនពិចារណាឱ្យរឿយ ៗថា ទ្រព្យសម្បត្តិ ញាតិមិត្តបងប្អូន ដែលជាទីស្រឡាញ់របស់យើង នឹងត្រូវព្រាត់ប្រាសទៅ ឬយើងនឹងត្រូវព្រាត់ប្រាសទៅចាកវត្ថុទាំងអស់នោះជាមិនខាន, ត្រូវពិចារណាថាគ្រប់របស់ទាំងពួងមិនមានអ្នកណាមួយជាម្ចាស់នោះទេ ជាម្ចាស់បានត្រឹមតែមួយខណៈប៉ុណ្ណោះ, ត្រូវពិចារណាឱ្យឃើញថាគ្រប់វត្ថុទាំងអស់ ជារបសមិនទៀង ជាទុក្ខ ជាអនត្តា មិនមានសត្វបុគ្គលណាមួយជាម្ចាស់ពិតទេ ។ កាលបើយើងបានចូលទៅសេពគប់ជាមួយសប្បុរសស្តាប់ធម៏សប្បុរស មានសប្បុរសជា

កល្យាណមិត្ត ហើយពិចារណាឱ្យឃើញនូវតួ្ចទាំងពួងថា ជារបស់មិនទៀតជាទុក្ខ ជាអនត្តា មិនមាន សត្ត បុគ្គលណាមួយ ជាម្ចាស់ដូច្នេះហើយ យើងរមែងអាចកម្ចាត់បង់នូវសេចក្តីសោកទាំងពួងបាន ។ ទោះបីជាមានទុក្ខសោកធំប៉ុន្ណាក៏ដោយក៏អាចបន្ទោបង់បានដែរ នេះជាវិធីដើម្បីកម្ចាត់បង់នូវសេចក្តីសោក ។

សញ្ជិសូត្រ

នៅក្នុងបិដកលេខ ២៩, ទំព័រ ៤៣ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់សម្តែងអំពី ***[ការចូលទៅសេពគប់ជាមួយសប្បុរស]*** *មានសេចក្តីថា ៖*

ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិសេដ្ឋី ទៀបក្រុងសាវត្ថី ។

គ្រានោះឯង កាលរាត្រីបឋមយាមកន្លងទៅហើយមានពួកតុលួបកាយិកាទេវតាជាច្រើន មានរស្មីរុងរឿងញ៉ាំងវត្តជេតពនទាំងមូលឱ្យភ្លឺរុងរឿងបានចូលទៅគាល់ព្រះមានព្រះភាគលុះចូលទៅដល់ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយឈរក្នុងទីដ៏សមគួរ ។

លុះទេវតាមួយអង្គ ឈរក្នុងទីដ៏សមគួរហើយ ទើបពោលគាថានេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា ៖

សញ្ជ្ញិវេ សមាសេថ សញ្ជ្ញិ កុព្ភេថ សន្ថវំ

សតំសទ្ធម្ម មញ្ញាយ សេយ្យោ ហោតិ ន ១ បាបិយោ ។

បុគ្គល *គួរអង្គុយរួមជាមួយនឹងពួកសប្បុរសប៉ុណ្ណោះ គួរធ្វើសេចក្ដីស្និទ្ធស្នាលដោយពួកសប្បុរស ព្រោះដឹងច្បាស់នូវព្រះសទ្ធម្មរបស់ពួកសប្បុរសរមែងបានជាបុគ្គលប្រសើរ មិនអាក្រក់ឡើយ ។*

លំដាប់នោះឯង ទេវតាមួយអង្គទៀតបានពោលគាថានេះក្នុងសំណាក់នៃព្រះមានព្រះភាគថា ៖

សញ្ជ្ញិវេ សមាសេថ សញ្ជ្ញិ កុព្ភេថ សន្ថវំ

សតំសទ្ធម្ម មញ្ញាយ បញ្ញំ លភតិ ១ ១ ១

ជនៃទ្បើយ ។

លំដាប់នោះឯង ទេវតាមួយអង្គទៀត ពោលគាថានេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា ៖

សញ្ជ្ជិវេ សមាសេថ សញ្ជ្ជិ ភុ្ជ្ជេថ សន្ថវំ

សតំ សន្ធ្ជ្ជ ម្ម មញ្ញាយ ១ បញ្ញំ លភតិ ១ ១ ១ ។

បុគ្គល គួរតែអង្គុយរួមជាមួយនឹងពួកសប្ប្ជ្ជ ១ ១ ១

ព្រះសទ្ធម្មរបស់ពួកសប្បុរស រមែងរុងរឿងក្នុងកណ្ណាលនៃញាតិ ។

លុះជាប់នោះឯង ទេវតាមួយអង្គទៀត បានពោលគាថានេះក្នុងសំណាក់នៃព្រះមានព្រះភាគថា ៖

សញ្ជ្ញិវេ សមាសេថ សញ្ជ្ញិ ក្ការេថ សន្ថវំ
សតំ សទ្ធម្មមញ្ញាយ សត្ថា ភច្ចន្តិ សុគតិន្តិ ។

បុគ្គល គួរតែអង្គុយរួមជាមួយនឹងពួកសប្បុរសប៉ុណ្ណោះ គួរធ្វើសេចក្ដីស្និទ្ធស្នាលជាមួយពួកសប្បុរស សត្វទាំងឡាយបានដឹងច្បាស់នូវព្រះសទ្ធម្មរបស់ពួកសប្បុរស ហើយ រមែងទៅកាន់សុគតិបាន ។

លុះជាប់នោះឯង ទេវតាមួយទៀត បានពោលគាថានេះក្នុងសំណាក់នៃព្រះមានព្រះភាគថា ៖

សញ្ជ្ញិវេ សមាសេថ សញ្ជ្ញិ ក្ការេថ សន្ថវំ
សតំ សទ្ធម្មមញ្ញាយ សត្ថា តិដ្ឋន្តិ សាតតន្តិ ។

បុគ្គល គួរតែអង្គុយរួមជាមួយនឹងពួកសប្បុរសប៉ុណ្ណោះ គួរធ្វើសេចក្ដីស្និទ្ធស្នាលនឹងពួកសប្បុរស សត្វទាំងឡាយដឹង

ច្បាស់នូវព្រះសទ្ធម្មរបស់ពួកសប្បុរស រមែងឋិតនៅជាសុខអស់កាលយូរ ។

លុះជាប់នោះឯងទេវតាមួយអង្គទៀត បានក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះមានព្រះភាគ ភាសិតអ្នកណាហ្ន៎ ជាសុភាសិត ។

ព្រះមានព្រះភាគទ្រង់ត្រាស់ថា ភាសិតរបស់អ្នកទាំងអស់ជាសុភាសិតដោយបរិយាយដែរហើយ តែអ្នកទាំងឡាយចូរស្តាប់ពាក្យរបស់តថាគតវិញថា ៖

សព្ពិរេ សមាសេថ សព្ពិ ភុញ្ជេថ សន្ថវំ
សតំ សទ្ធម្ម មញ្ញាយ សព្ពទុក្ខា បមុច្ចតីតិ ។

បុគ្គល គួរតែអង្គុយរួមជាមួយនឹងពួកសប្បុរសប៉ុណ្ណោះ គួរធ្វើសេចក្តីស្និទ្ធស្នាលនឹងពួកសប្បុរសបុគ្គលដ៏ឆ្ងាស់នូវព្រះសទ្ធម្មរបស់សប្បុរស រមែងរួចចាកទុក្ខទាំងអស់បាន ។

អដ្ឋកថា

បទថា សតុលួបកាយិកា មានវិគ្រោះថាទេវតាទាំងឡាយដែលឈ្មោះថា **សតុលួបកាយិកា** ព្រោះលើកតម្លើង ដោយ

អំណាចនៃការសមាទានធម៏របស់សប្បុរសហើយកើតឡើងក្នុងសួគ៏ ។ ក្នុងសេចក្តីនោះ មានរឿងដូចតទៅនេះ ៖

រឿងអ្នកសរសើរធម៏សប្បុរស

បានឮថា ជនច្រើននាក់បានធ្វើការលក់ដូរតាមសមុទ្រ ប្រើទូកទៅកាន់សមុទ្រ ។ កាលទូកនៃជនទាំងនោះទៅដោយរហ័ស ដូចកូនធ្នូដែលបុគ្គលបោះទៅហើយក្នុងថ្ងៃទី ៧ ទើបកើតហេតុប្រទូស្តធំត្រង់កណ្តាលសមុទ្រគឺរលកធំតាំងឡើង ហើយក៏ញ្ចាំងទូកឱ្យពេញទៅដោយទឹក ។ កាលទូកកំពុងនឹងលិចចុះ មហាជនទើបនឹកដល់ឈ្មោះទេវតារបស់ខ្លួន ១ ហើយធ្វើកិច្ចដែលមានការអង្វរជាដើម ទួញយំហើយ ។ នៅកណ្តាលនៃជនទាំងនោះ បុរសម្នាក់នឹកថា យើងត្រូវប្រសព្វភ័យដ៏សាហាវបែបនេះពិត ទើបនឹកដល់ធម៏របស់ខ្លួន ឃើញហើយនូវសរណៈទាំងឡាយ និងសីលទាំងឡាយក៏ប្រសុទ្ធិហើយ ទើបអង្គុយចម្រើនសមាធិដូចព្រះយោគី ។ ពួកជនទាំងឡាយទើបសួរគាត់ដល់ហេតុដែលមិនខ្លាចនោះ ។ បុរសជាបណ្ឌិតនោះទើបពោលថា "ម្នាលលោកដ៏ចម្រើនទាំងឡាយ ម៉ែនហើយយើងមិនខ្លាចភ័យបែបនេះ ព្រោះយើងថ្វាយទានដល់ពួកភិក្ខុក្នុងថ្ងៃដែលឡើងទូក យើងបានទទួល

សរណៈទាំងឡាយ និងសីលទាំងឡាយ ព្រោះហេតុនោះ យើងទើបមិនខ្លាច"ដូច្នេះ ។ ជនទាំងនោះទើបពោលថា"បពិត្រលោកដ៏ចម្រើន ក៏សរណៈនិងសីលទាំងនេះសមគួរដល់ជនពួកដទៃខ្លះឬទេ" ។ បណ្ឌិតនោះ ឆ្លើយថា"មែនហើយ ធម៌ទាំងនេះរមែងសមគួរសូម្បីដល់ពួកលោក" ។ ជនទាំងនោះទើបពោលថា"បើយ៉ាងនោះសូមលោកបណ្ឌិត ចូរឱ្យដល់ពួកយើងខ្ញុះ" ។

ជនអ្នកជាបណ្ឌិតនោះ ទើបចាត់ធ្វើពួកមនុស្សទាំងនោះឱ្យជាពួកមួយរយ ១ រួមជា ៧ ពួករួមគ្នា ។ បន្ទាប់ពីនោះក៏ឱ្យសីល ៥ ។ ក្នុងបណ្តាជន ៧ ពួកទាំងនោះ ជនចំនួនមួយរយនាក់ដំបូងតាំងនៅក្នុងទីកត្រឹមកជើង ទើបបានទទួលសីល ។ ពួកទី ២ តាំងនៅក្នុងទីកត្រឹមជង្គង់...ពួកទី ៣ តាំងនៅក្នុងទីកត្រឹមចង្កេះ...ពួកទី ៤ តាំងនៅក្នុងទីកត្រឹមផ្ចិត... ជនពួកទី ៥ តាំងនៅក្នុងទីកត្រឹមដោះ... ពួកទី ៦ តាំងនៅក្នុងទីកត្រឹមក... ពួកទី ៧ ទីកសមុទ្រ កំពុងនឹងហូរចូលមាត់ ទើបបានទទួលសីល ៥ ហើយ ។ ជនអ្នកជាបណ្ឌិតនោះ គ្រាឱ្យសីល ៥ ដល់ជនទាំងនោះហើយ ទើបប្រកាសសំឡេងគឹកកងថា វត្ថុដទៃជាទីពឹងរបស់ពួកលោក មិនមានពួកលោកចូរ

រក្សាសីលប៉ុណ្ណោះ ដូច្នេះ ។ ជនទាំង ៧០០ នាក់នោះធ្វើកាល-
កិរិយាក្នុងសមុទ្រនោះហើយ ទៅកើតឡើងក្នុងភពតាវត្តិង្ស ព្រោះ
អាស្រ័យសីលដែលខ្លួនទទួលយកក្នុងវេលាជិតស្លាប់ ។ វិមាន
ទាំងឡាយរបស់ទេវតាទាំងនោះ ក៏កើតឡើងជាពួកតែមួយ ។
វិមានមាសរបស់អាចារ្យ មានប្រមាណមួយរយយោជន៍ កើតនៅ
ត្រង់កណ្តាលនៃវិមានទាំងអស់ ។ ទេវតាដែលសល់ ជាបរិវារ
របស់ទេវដែលជាអាចារ្យនោះ វិមានដែលទាបជាង វិមានទាំង
អស់នោះក៏នៅ មានប្រមាណដល់ ១២ យោជន៍ ។ ទេវតាទាំង
នោះបានពិចារណាផលកម្មក្នុងខណៈដែលខ្លួនកើតហើយ ជ្រាប
ហើយនូវការបានសម្បត្តិនោះ ព្រោះអាស្រ័យអាចារ្យ ទើបពោល
និងគ្នាថា ពួកយើងនឹងទៅ ពួកយើងនឹងពោលសរសើរគុណនៃ
អាចារ្យរបស់ពួកយើងក្នុងសំណាក់នៃព្រះទសពលដូច្នេះ ហើយ
ចូលទៅគាល់ព្រះមានព្រះភាគ ក្នុងវេលាចន្ទោះមជ្ឈិមយាម ។

ក្នុងបណ្តាទេវតាទាំងនោះ ទេវតា ៦ អង្គ បានពោលគាថា
មួយអង្គមួយគាថា ដើម្បីពណ៌នាគុណអាចារ្យរបស់ខ្លួនដោយ
ពាក្យថា ៖

សញ្ជ្ញិនោ សមាសេថ សញ្ជ្ញិ ភុញ្ជេថ សន្ថវំ
សតំ សទ្ធម្មញ្ញាយ សេយ្យោ ហោតិ ន ចាបិ យោ ។

បុគ្គលគួរអង្គុយរួមនឹងពួកសប្បុរស គួរធ្វើសេចក្តីស្និទ្ធនឹងពួកសប្បុរស បុគ្គលជ្រាបព្រះសទ្ធម្មរបស់ពួកសប្បុរសហើយ មានតែគុណដ៏ប្រសើរមិនមានទោសលាមកឡើយ ។

បណ្តាបទទាំងនោះ បទថា **សញ្ជ្ញិ** *ប្រែថា ពួកបណ្ឌិតគឺ ពួកសប្បុរស ។ ន អក្សរធ្វើនាទីសន្ធិ ។*

បទថា សមាសេថ ប្រែថា គួរអង្គុយរួមក៏ពាក្យថា សមាសេថនេះ ជាគោលនៃទេសនាប៉ុណ្ណោះ ។ អធិប្បាយថា គប្បីសម្រេចឥរិយាបថទាំងពួងរួមនឹងសប្បុរសទាំងឡាយតែម្តង ។

បទថា ភុញ្ជេថ ប្រែថា គួរធ្វើ ។

បទថា **សន្ថវំ** *ប្រែថា សេចក្តីស្និទ្ធ បានដល់ សេចក្តីស្និទ្ធដោយមេត្រីតែសេចក្តីស្និទ្ធដោយតណ្ហាដែលអ្នកណា ៗ មិនគួរធ្វើ ។ សេចក្តីនេះ ព្រះមានព្រះភាគត្រាស់សំដៅយកពាក្យថា បុគ្គលគប្បីធ្វើសេចក្តីស្និទ្ធ មេត្រីចំពោះព្រះសម្មាសម្ពុទ្ធ ព្រះ*

បច្ចេកពុទ្ធនិងព្រះសាវ័កទាំងឡាយ ដូច្នេះ ។

បទថា សតំ ប្រែថា របស់ពួកសប្បុរស ។

បទថា សន្ធុម្ម៉ុ បានដល់ សន្ធម្មផ្សេង ៗ មានសីល ៥ សីល១០ និងសតិប្បដ្ឋាន ៤ ជាដើម ។ តែក្នុងសូត្រនេះលោកប្រាថ្នាយកសីល ៥ ។

បទថា សេយ្យោហោតិ ប្រែថា មានតែគុណដ៏ប្រសើរ គឺមានតែសេចក្ដីចម្រើន ។

បទថា ន ឧបាបិយោ បានដល់ សេចក្ដីលាមក(សេចក្ដីក្រោមយ៉ឺត)អ្វី ៗ រមែងមិនមាន ។

លំដាប់នោះ ទេវតាដទៃទៀតបានពោលគាថានេះក្នុងសំណាក់ព្រះមានព្រះភាគថា បុគ្គលគួរអង្គុយរួមនឹងពួកសប្ប-រស ។ល ។ រមែងបានបញ្ញា មិនបានបញ្ញាពីអ្នកដទៃ (ជនពាល)ទេ ដូច្នេះ ។

បទថា ឧ ញ្ញ ្ ញ ្ ា ្ ្ ្

ដែលបុគ្គលមិនគប្បីបានដោយគ្រួស ១ ១ ១

សប្បុរស ។ ល ។ រមែងរុងរឿងនៅកណ្ដាលនៃញាតិដូច្នេះ ។

បទថា ញាតិមជ្ឌេ វិភោចតិ ប្រែថា រមែងរុងរឿងនៅកណ្ដាលនៃពួកញាតិ គឺថា រមែងល្អដូចសាមណេរឈ្មោះថាអធិមុត្តកៈ អ្នកជាសទ្ធិវិហារិករបស់ព្រះសង្ឆិចត្ថេរ ។

រឿង អធិមុត្តកៈសាមណេរ

បានឮថា សាមណេរនោះជាកូនយរបស់ព្រះសង្ឆិចត្ថេរនោះ ។ ក្នុងកាលគ្រានោះព្រះថេរៈពោលនឹងសាមណេរថាម្នាលសាមណេរ លោកធំហើយ លោកចូរទៅសួរដល់អាយុរបស់លោកហើយត្រឡប់មក យើងនឹងឧបសម្ប្ទាឱ្យ ដូច្នេះសាមណេរទទួលពាក្យថា ល្អហើយលោកម្ចាស់ សំពះព្រះថេរៈហើយកាន់បាត្រនិងចីវរទៅស្រុកបួនស្រី ដែលតាំងនៅជិតព្រៃដែលជាទីអាស្រ័យនៅរបស់ពួកចោរ ហើយក៏ត្រាច់ទៅបិណ្ឌបាត ។ បួនស្រីឃើញលោកហើយសំពះហើយ ទើបនិមន្ដឱ្យទៅអង្គុយក្នុងស្រុកឱ្យឆាន់ភត្តាហារហើយ ។ សាមណេរធ្វើកិច្ចវត្ដរួចស្រេចហើយ ទើបសួរដល់អាយុរបស់ខ្លួន ។ នាងឆ្លើយថា ខ្ញុំម្ចាស់

មិនជ្រាប ម្តាយវមែងជ្រាប ។ សាមណេរពោលថា នាងចូរនៅត្រង់នេះ យើងនឹងទៅកញ្ជោមមាតា ហើយក៏ចូលទៅកាន់ព្រៃ ។ បុរសជាចោរឃើញសាមណេរពីចម្ងាយ ទើបបញ្ជូនសញ្ញាណដល់ពួកចោរ ។ ពួកចោរឱ្យសញ្ញាណដោយពាក្យថា បានឮថា សាមណេរមួយអង្គ ចូលក្នុងព្រៃ ពួកលោកចូរទៅនាំសាមណេរនោះមកដូច្នេះ ។ ចោរពួកខ្លះពោលថា យើងនឹងសម្លាប់ ពួកខ្លះពោលថា យើងនឹងលែង ។ សូម្បីសាមណេរក៏គិតថា យើងជាព្រះសេក្ខៈ នៅមានកិច្ចដែលគួរធ្វើដល់ខ្លួន យើងប្រឹក្សានឹងពួកចោរទាំងនេះហើយ នឹងធ្វើសេចក្តីសួស្តីជាប្រមាណ ទើបហៅប្រធានចោរមកពោលថា ម្នាលលោកអ្នកមានអាយុ យើងនឹងធ្វើសេចក្តីឧបមា(ប្រៀបធៀប)ដល់លោក ដូច្នេះ ហើយបានពោលគាថា ទាំងនេះថា

ក្នុងអតីតកាលដ៏យូរអង្វែង ដែលពួកឈើក្នុងព្រៃធំ ខ្ជាដំបងមួយត្រាច់ស្នាក់ចាប់ចំណីតាមផ្លូវកោង ក្នុងកាលនោះ វាបានសម្លាប់សត្វទន្សាយមួយ ម្រ៉ីគនិងបក្សីទាំងឡាយឃើញទន្សាយស្លាប់ហើយ ស្ងួតចិត្តខ្ជាច នាំគ្នាគេចជៀសទៅក្នុងវេលា

ភត្រី ការធ្វើនេះមិនសមគួរ យ៉ាងណា លោកសម្លាប់សមណៈ ឈ្មោះ អធិមុត្តកៈ អ្នកមិនមានកិលេសជាគ្រឿងកង្វល់ចិត្ត ក៏ដូចគ្នានោះឯង ជនទាំងឡាយអ្នកធ្វើដំណើរនឹងមិនមក ពួកលោកក៏នឹងដាច់ទ្រព្យ សមណៈឈ្មោះថា អធិមុត្តកៈ អ្នកមិនមានកិលេសគ្រឿងកង្វល់ចិត្ត និយាយពាក្យពិត អ្នកធ្វើដំណើរនឹងមិនមក ពួកលោកនឹងសាបសូន្យទ្រព្យ ។

មេចោរពោលថា បើលោកឃើញអ្នកធ្វើដំណើរ មកហើយនឹងមិនប្រាប់ដល់អ្នកណា ។ បពិត្រលោកដ៏ចម្រើន កាលលោកតាមរក្សាសចូ:នេះបាន ក៏ចូរទៅតាមសប្បាយចុះ ។

សារណេរនោះ អ្នកដែលពួកចោរទាំងនោះដោះលែងហើយ ទៅក៏ជួបញាតិទាំងឡាយ មិនបានប្រាប់ឱ្យគេដឹងឡើយ កាលពួកញាតិនោះមកដល់ហើយ ពួកចោរក៏ចាប់គេ ពួកចោរបានពោលនឹងមាតារបស់សាមណេរដែលគត់ទ្រេងទ្រួញយំថា ៖

នាងចូរប្រាប់មក អធិមុត្តកៈត្រូវជាអ្វីនឹងពួកនាងជាអ្នកនៅក្នុងផ្ទះនាងឬ ខ្ញុំសួរនាងហើយចូរប្រាបមកចុះ ពួកយើងនឹងស្គាល់នាង ម្តេចបាន ?

មាតារបស់អធិមុត្តកៈពោលនឹងពួកចោរថា ៖

យើងនេះឯងជាមាតារបស់អធិមុត្តកៈ អ្នកនេះឯងជាបិតា អ្នកនេះជាបួនស្រី អ្នកនេះជាបងប្អូនប្រុសជនទាំងអស់ក្នុងទីនេះ ជាញាតិរបស់អធិមុត្តកៈ ។ អធិមុត្តកៈធ្វើកិច្ចដែលមិនសមគួរ ទ្បើយ ឃើញញាតិក៏មិនហាម នេះជាវត្តបដិបត្តិរបស់សមណៈ ទាំងឡាយអ្នកជាព្រះអរិយៈ អ្នកមានធម៌ជាជីវិតឬហ្ន៎ ។

មេចោរពោលថា ៖

អធិមុត្តកៈមានសច្ចវាចា ឃើញញាតិអ្នកមកក៏មិនហាម ជនទាំងអស់អ្នកជាញាតិរបស់អធិមុត្តកៈជាភិក្ខុ មានសច្ចវាចា ដោយការសន្សំល្អហើយ ទើបដល់ការរួចផុតភ័យ សូមញាតិគ្រប់គ្នាទៅដោយសេចក្តីសួស្តីចុះ ។

ញាតិទាំងនោះ កាលចោរដោះលែងទៅយ៉ាងនេះហើយ បានត្រឡប់ទៅប្រាប់អធិមុត្តកៈសាមណេរថា ៖

លោកម្ចាស់ ពួកយើងទាំងអស់រួចផុតភ័យ ត្រឡប់មកដោយសេចក្តីសួស្តីព្រោះសេចក្តីល្អដែលលោកពោលវាចាសច្ចៈដោយពិត ។

ពួកចោរទាំង ៥០០ ជ្រះថ្លាហើយ ទើបបួសជាមួយនឹងសាមណេរ ។ អធិមុត្តកៈសាមណេរនាំសិស្សទាំងនោះទៅកឧបជ្ឈាយ៍ ហើយខ្លួនសូមឧបសម្បទាមុន ខាងក្រោយទើបសូមឱ្យព្រះថេរៈបំបួសពួកចោរឱ្យជាសិស្សរបស់ខ្លួន ។ អន្តេវាសិកទាំងអស់នោះ ស្តាប់ឱវាទរបស់អធិមុត្តកត្ថេរ សម្រេចនូវព្រះអរហត្តផលដ៏ប្រសើរ ដូច្នេះ ។ ទេវតាកាន់យកសេចក្តីនេះហើយ ក្រាបទូលព្រះមានព្រះភាគថា សតំ សន្ធម្មមញ្ញាយ ញាតិមជ្ឈេ វិរោចតិ **បុគ្គលបានដឹងច្បាស់នូវព្រះសទ្ធម្មរបស់ពួកសប្បុរស រមែងរុងរឿងក្នុងកណ្តាលនៃញាតិ** ដូច្នេះ ។

ក្នុងលំដាប់នោះឯង ទេវតាដទៃទៀត បានពោលគាថានេះក្នុងសំណាក់ព្រះមានព្រះភាគថា បុគ្គលគួរអង្គុយរួមនឹងពួកសប្បុរស ។ល ។ រមែងតាំងនៅសប្បាយរឿយ ៗ ។

ពាក្យថា សាតតំ **អស់កាលយូរ** គឺទេវតា រមែងពោលថា ជនទាំងឡាយ រមែងតាំងនៅសប្បាយរឿយ ៗ ឬថា មានសេចក្តីសុខដែលយឺនយូរ ។

លំដាប់នោះឯង ទេវតាដទៃទៀតបានពោលគាថានេះ ក្នុងសំណាក់ព្រះមានព្រះភាគថា បពិត្រព្រះមានព្រះភាគពាក្យ របស់អ្នកណាហ្ន៎ជាសុភាសិត ។

ព្រះមានព្រះភាគត្រាស់ថា ពាក្យរបស់ពួកលោកទាំងអស់ជាសុភាសិតដោយបរិយាយ ក៏ប៉ុន្តែពួកលោកចូរស្តាប់ពាក្យរបស់យើងខ្ញុះថា ៖

បុគ្គលគួរអង្គុយរួមនឹងពួកសប្បុរស គួរធ្វើសេចក្តីស្និទ្ធនឹងពួកសប្បុរស បុគ្គលជ្រាបនូវព្រះសទ្ធម្មរបស់ពួកសប្បុរសហើយ រមែងផុតពីទុក្ខទាំងពួង ។

បទថា សញ្ញាសំ ភោ **របស់អ្នកទាំងអស់** គឺ របស់ពួកលោកទាំងអស់ ។

បទថា **បរិយាយេន** **ដោយកិរិយាប្រព្រឹត្តទៅជុំវិញ (អម)** បានដល់ ដោយការណៈ ។

បទថា **សព្វទុក្ខា** **បមុចតិ** **រមែងរួចចាកទុក្ខទាំងអស់បាន** សេចក្តីថា មិនមែនប្រសើរតែម្យ៉ាង មិនមែនបានបញ្ញា

តែម្យ៉ាង មិនមែនមិនសោកសៅនៅកណ្តាលអ្នកសោកសៅតែម្យ៉ាង មិនមែនរុងរឿងនៅកណ្តាលនៃញាតិតែម្យ៉ាង មិនមែនកើតក្នុងសុគតិតែម្យ៉ាង ... មិនមែនតាំងនៅសប្បាយអស់កាលយូរតែម្យ៉ាង គឺគេរមែងផុតចាកទុក្ខក្នុងវដ្ដៈទាំងអស់ផង ។

សង្ខារមជិសូត្រ

នៅក្នុងបិដកលេខ ៥២, ទំព័រ ១២៣ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ត្រាស់អំពី **[ការមិនត្រេកអរចំពោះបុត្រនឹងភរិយាចាស់]** មានសេចក្ដីថា ៖

ខ្ញុំបានស្ដាប់យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះ ព្រះសង្ឆាមជិដ៏មានអាយុ បានទៅកាន់នគរសាវត្ថី ដើម្បីជួបព្រះមានព្រះភាគ ។ ឯបុរាណទុតិយិកា របស់ព្រះសង្ឆាមជិដ៏មានអាយុ បានឮដំណឹងថា អើញ្ចថា ព្រះសង្ឆាមជិមកដល់នគរសាវត្ថីហើយ ។ នាងនោះបាននាំទារកទៅឯវត្តជេតពន ។ សម័យនោះព្រះសង្ឆាមជិដ៏មានអាយុ កំពុងអង្គុយនៅក្នុងវេលាថ្ងៃ ក្បែរគល់ឈើមួយដើម ។ លំដាប់

បុរាណទុតិយិការបស់ព្រះសង្ឆាមជិដ៏មានអាយុ បានចូលទៅ
រកព្រះសង្ឆាមជិដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏និយាយ
នឹងព្រះសង្ឆាមជិដ៏មានអាយុថា បពិត្រព្រះសមណៈ សូមលោក
ចិញ្ចឹមខ្ញុំទាំងកូនតូចផង ។ និមិត្តតែបុរាណទុតិយិកានោះ ពោល
យ៉ាងនេះហើយ ព្រះសង្ឆាមជិដ៏មានអាយុនៅស្ងៀម ។ បុរាណ-
ទុតិយិការបស់ព្រះសង្ឆាមជិដ៏មានអាយុ បានពោលនឹងព្រះ
សង្ឆាមជិដ៏មានអាយុ ជាគំរប់ពីរដងយ៉ាងនេះទៀតថា បពិត្រ
សមណៈ សូមលោកចិញ្ចឹមខ្ញុំទាំងកូនតូចផង ។ ព្រះសង្ឆាមជិ
ដ៏មានអាយុនៅស្ងៀមអស់រាវៈពីរដង ។ បុរាណទុតិយិការបស់
ព្រះសង្ឆាមជិដ៏មានអាយុ ក៏ទទួលនិយាយនឹងព្រះសង្ឆាមជិ ដ៏
មានអាយុជាគំរប់បីដងថា បពិត្រសមណៈ សូមលោកចិញ្ចឹម
ខ្ញុំទាំងកូនតូចផង ។ ព្រះសង្ឆាមជិដ៏មានអាយុ ក៏នៅស្ងៀមអស់
រាវៈបីដង ។ លំដាប់នោះ បុរាណទុតិយិការបស់ព្រះសង្ឆាមជិ
ដ៏មានអាយុ បានយកទារកតូចនោះទៅជាក់អំពីមុខ ព្រះសង្ឆាមជិដ៏
មានអាយុ រួចនិយាយថា បពិត្រព្រះសមណៈ នេះជាកូនប្រុស
របស់លោក លោកចិញ្ចឹមវាផងចុះ រួចហើយក៏ដើរចេញទៅ ។
ឯព្រះសង្ឆាមជិដ៏មានអាយុមិនរមិលមើល មិនហៅកន្ទ្រកូនតូច

នោះសោះ ។ លំដាប់នោះ បុរាណទុតិយិការបស់ព្រះសង្ឆាមជិ
ដ៏មានអាយុ កាលដើរចេញទៅមិនឆ្ងាយប៉ុន្មាន ក៏ងាកមើល
មកឃើញព្រះសង្ឆាមជិដ៏មានអាយុ ដែលមិនរមិល មិនហៅរក
កូនតូចនោះសោះ ស្ត្រីនោះលុះឃើញហើយ ក៏មានសេចក្ដីត្រិះរិះ
យ៉ាងនេះថា សមណៈនេះមិនត្រូវការដោយកូនប្រុសទេតើ ។
បុរាណទុតិយិកានោះ ក៏ត្រឡប់អំពីទីនោះ មកយកកូនតូចនោះ
វិញដើរចេញទៅ ។ ព្រះមានព្រះភាគបានទត ឃើញនូវអាការដ៏
ប្លែកប្លែកយ៉ាងនេះ នៃបុរាណទុតិយិការបស់ព្រះសង្ឆាមជិដ៏មាន
អាយុដោយទិព្វចក្ខុដ៏បរិសុទ្ធកន្លងចក្ខុរបស់មនុស្សធម្មតា ។

លុះព្រះមានព្រះភាគ ជ្រាបច្បាស់នូវសេចក្ដីនុ៎ះហើយ
ទើបបន្លឺនូវឧទាននេះ ក្នុងវេលានោះថា ៖

អាយន្តី ឆាភិនន្ទតិ បក្ខាមន្តី ន សោចតិ
សត្ថាសត្ថាមជឺ មុត្តំ តមហំ ព្រូមិ ព្រាហ្មណន្តិ ។

ភិក្ខុណាមិនត្រេកត្រអាលនឹងស្ត្រីដែលមកវាក មិនស្តាយ
ស្ត្រីដែលគេចចេញទៅ តថាគតហៅបុគ្គលនោះថាជាព្រាហ្មណ៍
ដូចជាភិក្ខុឈ្នះសង្ឆាមជិ ដែលរួចស្រឡះហើយចាកគ្រឿងជាប់
គឺកិលេស ។

អដ្ឋកថា

សង្គ្រាមជិសូត្រទី ៨ មានវិនិច្ឆ័យដូចតទៅនេះ ?

បទថា **សង្គ្រាមជិ** *បានដល់ មានឈ្មោះយ៉ាងនេះ ។ ពិតមែន លោកអ្នកមានអាយុនេះ ជាបុត្ររបស់សេដ្ឋីមានសម្បត្តិច្រើនម្នាក់ក្នុងក្រុងសាវត្ថី លោចម្រើនវយ មាតាបិតាឱ្យមានគ្រួសារដោយសមគួរ ប្រគល់ទ្រព្យសម្បត្តិឱ្យ ឱ្យនៅគ្រប់គ្រងផ្ទះ ។ ថ្ងៃមួយ គេឃើញឧបាសកអ្នកក្រុងសាវត្ថីកំពុងថ្វាយទានសមាទានសីលព្រឹក ១ ស្លៀកដណ្ដប់សំពត់សកាន់របស់ក្រអូបនិងផ្ការៃជាដើម ត្រង់ទៅកាន់ព្រះជេតវនដើម្បីស្ដាប់ធម៌ពេលល្ងាចទើបសួរថាលោកទាំងឡាយទៅណា ?កាលគេឆ្លើយថា ទៅសំណាក់ព្រះសាស្ដាក្នុងព្រះជេតវនដើម្បីស្ដាប់ធម៌ ទើបពោលថា បើដូច្នោះ សូម្បីខ្ញុំក៏នឹងទៅ ទើបបានទៅជាមួយពួកអ្នកទាំងនោះ ។ សម័យនោះឯង ព្រះមានព្រះភាគប្រថាប់អង្គុយលើបវរពុទ្ធអាសនៈដែលគេផ្ចិតផ្ចង់ចាត់ចែងទុកក្នុងមណ្ឌប សម្រាប់ស្ដាប់ព្រះសទ្ធម្ម សម្ដែងធម៌នៅត្រង់កណ្ដាលបរិស័ទទាំង ៤ ដូចកេសរៗជសីហ៍ បន្ទឹសីហនាទក្នុងល្អាងមាស ។ គ្រានោះឯងឧបាសកទាំងនោះ*

ថ្វាយបង្គំព្រះមានព្រះភាគហើយអង្គុយ នៅក្នុងចំណែកម្ខាង ។ ចំណែកសង្ឆាមជិកុលបុត្រអង្គុយស្តាប់ធម៏នៅចុងបរិស័ទនោះ ។ ព្រះមានព្រះភាគត្រាស់អនុបុព្វីកថា ប្រកាសសច្ចៈ ៤ ក្នុងវេលាចប់ សច្ចៈសត្វច្រើនពាន់បានត្រាស់ដឹងធម៏ ។

ចំណែកសង្ឆាមជិកុលបុត្រ ក៏សម្រេចសោតាបត្តិផលកាលបរិស័ទចេញទៅហើយ ក៏ចូលទៅគាល់ព្រះមានព្រះភាគ ថ្វាយបង្គំហើយទូលសូមបព្វជ្ជាថា បពិត្រព្រះមានព្រះភាគមេត្តាឱ្យខ្ញុំព្រះអង្គបព្វជ្ជាចុះ ។ ព្រះមានព្រះភាគត្រាស់សួរថា ក៏មាតាបិតាអនុញ្ញាតឱ្យលោកបព្វជ្ជាហើយឬ ។ គេក្រាបទូលថាមិនទាន់បានទទួលអនុញ្ញាតទេ ព្រះអង្គ ។ ព្រះមានព្រះភាគត្រាស់ថា សង្ឆាមជិ ព្រះតថាគតទាំងឡាយមិនព្រមបួសបុត្រដែលមាតាបិតាមិនអនុញ្ញាតទេ ។ គេក្រាបទូលថាបពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះ នឹងធ្វើដោយដែលមាតាបិតាអនុញ្ញាតឱ្យខ្ញុំព្រះអង្គបួសដូច្នេះ ហើយថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណាហើយចូលទៅរកមាតាបិតាពោលថា បពិត្រម៉ែពុក មេត្តាអនុញ្ញាតឱ្យខ្ញុំបួស

ចុះ ។ អំពីនោះ គប្បីជ្រាបតាមន័យដែលពោលមកហើយក្នុងរដ្ឋបាលសូត្រ ។

លំដាប់នោះ គេបដិញ្ញាថា បួសហើយនឹងសម្តែងខ្លួនគ្រាមាតាបិតាអនុញ្ញាតហើយ ចូលទៅគាល់ព្រះមានព្រះភាគទូលសូមបព្វជ្ជា ។ និងគេក៏បានបព្វជ្ជាឧបសម្បទាក្នុងសំណាក់របស់ព្រះដ៏មានព្រះភាគ ។ ក៏ឯលោកឧបសម្បទបានមិនយូរប៉ុន្មាន ខំប្រឹងព្យាយាមដើម្បីមគ្គផលខ្ពស់ ១ នៅចាំវស្សាក្នុងអរញ្ញវាសមួយកន្លែងបានអកិញ្ចា ៦ ចេញវស្សាហើយទៅកាន់ក្រុងសាវត្ថីគាល់ព្រះមានព្រះភាគ និងដោះពាក្យរបស់មាតាបិតា ដែលបានតាំងទុក ។ ហេតុនោះ លោកទើបពោលថា តេន ខោ បនសមយេន អាយស្មា សង្ខ្យាមជិ សាវត្ថី អនុប្ផត្តោ ហោតិ ក៏សម័យនោះឯងព្រះសង្ខ្យាមជិទៅដល់ក្រុងសាវត្ថីហើយ ។

ក៏ព្រះសង្ខ្យាមជិនោះ ត្រាច់បិណ្ឌបាតក្នុងជួរគ្រាមត្រឡប់មកពីបិណ្ឌបាតខាងក្រោយភត្ត ចូលទៅកាន់ព្រះជេតវនគាល់ព្រះមានព្រះភាគ ព្រះអង្គក៏បានធ្វើបដិសណ្ឋារហើយព្យាករណ៍អរហត្តផល ថ្វាយបង្គំព្រះមានព្រះភាគទៀតហើយ ធ្វើប្រទក្សិណ

ចេញទៅ គង់សម្រាកវេលាថ្ងៃនៅទៀបគល់ឈើមួយកន្លែង ។ លុះជាប់នោះ មាតាបិតានិងញាតិមិត្តរបស់លោកជ្រាបថា លោកមកហើយ ក៏រីករាយត្រេកអរថា ដំណឹងថា ព្រះសង្ឆាមជិមកក្នុងទីនេះ ទើបប្រញាប់រៀលទៅកាន់វិហារស្វែងរកឃើញលោកអង្គុយក្នុងទីនោះ ចូលទៅរកធ្វើបដិសណ្ឋារហើយអង្វរថា ព្រះរាជាកុំបានទទួលសម្បត្តិរបស់អ្នកមិនមានបុត្រ ទាយាទគប្បីបានទទួល ល្មមហើយ(ចូរ)កូនលះបព្វជ្ជា សឹកចុះកូន ។ ព្រះថេរៈស្តាប់ដូច្នោះហើយ គិតថា អ្នកទាំងនេះមិនដឹងថា យើងមិនត្រូវការដោយកាមទាំងឡាយ ប្រាថ្នានឹងឱ្យជាប់នៅក្នុងកាមប៉ុណ្ណោះ ដូចអ្នកវ៉ែកលាមកត្រូវការជុំលាមក ដូច្នោះ អ្នកណា ១ មិនអាចនឹងឱ្យអ្នកទាំងនេះយល់ធម្មកថាបាន ទើបអង្គុយធ្វើដូចជាមិនបានឮ ។ អ្នកទាំងនោះអង្វរដោយប្រការផ្សេង ១ ឃើញលោកមិនស្តាប់ពាក្យរបស់ខ្លួនទើបចូលទៅផ្ទះ បង្ហាប់ភរិយារបស់លោកព្រមដោយបុត្រនិងបរិវារបណ្តើរពោលថា ពួកយើងទោះបើជាខំអង្វរយ៉ាងណា ១ក៏យកចិត្ត លោកមិនបាន ទើបនាំគ្នាមក ទៅចុះ កូនចូរអង្វរកស្តារបស់អ្នកឯង ឱ្យយល់ព្រមដោយឃើញដល់បុត្រ ។

បានឮថា កាលនាងតាំងគភ៌ លោកបួស ។ នាងទទួលពាក្យហើយ ទើបបាននាំកូនព្រមដោយបរិវារជាច្រើនទៅកាន់វត្តជេតពន ដែលលោកសំដៅយកពាក្យមានជាដើមថា **អសេ្ឍ្ឍ្ឍ្ឍ្ឍ** **ខោ អាយស្មតោ** **សត្ថ្ឍ្ឍ្ឍ** ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឍ្ឍ្ឍ** សេចក្តីថា កាលមុនគឺក្នុងវេលាជាគ្រហស្ថ នាងបានជាភរិយាចាស់ដោយជាគូបម្រើ ។ អធិប្បាយថា ជាភរិយា ។ ដោយពាក្យថា **ឍ្ឍ** កាលនឹងនិយាយថា ព្រះអយ្យបុត្ត តែនិយាយដោយវោហារដែលសមគួរដល់ឋានៈ ។ ស័ព្ទថា **ឍ** ជានិបាត ប្រើក្នុងអនុសាសនៈ បានឮមក ។

គប្បីជ្រាបសម្ព័ន្ធថា បានឮថា កាលលោកមកដល់ ។ បទថា **ឍ្ឍ** **ហ** **ឍ** **ឍ** **ឍ

និងគ្រឿងស្បៃកដណ្តប់ជាដើម ។ ចំណែកព្រះសង្ឆាមជិសង្ដ្រម ឥន្ទ្រិយមិនសម្ងឹងមើល ទាំងមិនចរចាជាមួយនាង ។ ដោយហេតុនោះ លោកទើបពោលថា ឯវํ ភុត្តេ អាយស្មា សង្ឆាមជิ តុណ្ហី អហោสิ កាលនាងពោលយ៉ាងនោះ ព្រះសង្ឆាមជิក៏បានគង់នៅស្ងៀម ។

នាងពោលដូច្នោះដល់ ៣ គ្រា ឃើញលោកនៅស្ងៀមតែម្យ៉ាង ទើបសម្គាល់ថា ដែលឈ្មោះថា ពួកអ្នកប្រុសមិនអាល័យក្នុងពួកភរិយា តែនៅមានសេចក្ដីអាល័យក្នុងបុត្រ សេចក្ដីស្នេហាក្នុងបុត្រតាំងនៅក្នុងខ្សែដ្ឋានរបស់បិតា ដូច្នោះ លោកនៅក្នុងអំណាចរបស់ខ្ញុំ សូម្បីព្រោះស្រឡាញ់បុត្រ ទើបជាក់បុត្រលើភ្លៅរបស់ព្រះថេរ: ហើយជៀសទៅចំណែកម្ខាងពោលថា លោកសមណ: នេះបុត្ររបស់លោក លោកចូរចិញ្ចឹមគេចុះហើយចេញទៅបានបន្ដិច ។ បានឮថា នាងមិនអាចឈរត្រង់មុខលោកដោយតេជ-សមណ: ។

សូម្បីក្មេង ព្រះថេរ:ក៏មិនសម្ងឹងមើលទាំងមិននិយាយផង ។ ពេលនោះ នាងសូម្បីជាស្ត្រីឈរក្នុងដែលមិនឆ្ងាយ

ក្រឡេកទៅមុខសម្ងឹងមើលអាការព្រះថេរៈ បែរត្រឡប់មកពួ
ក្ខនដោយគិតថា សមណៈនេះមិនត្រូវការបុត្រ ហើយក៏ដៀស
ទៅ ។ ដោយហេតុនោះ លោកទើបពោលពាក្យមានជាដើមថា
អថ ខោ **អាយស្មតោ** **សង្ខាមជិស្ស** **បុរាណទុតិយិកា**
ត្រានោះឯង ព្រះសង្ខ្ចាមជិមានភរិយាចាស់ ។

បណ្ដាបទទាំងនោះបទថា **បុត្ដេនបិ** សេចក្ដីថា សមណៈ
នេះមិនត្រូវការបុត្ដសូម្បីដែលកើតតែពីខ្លួន អធិប្បាយថា នឹងចាំ
ចាប់ពោលទៅថ្ងៃដល់អ្នកដទៃហ្ន៎ ។

ឈ្មោះថា **ទិព្ធ** ក្នុងបទថា **ទិព្ធេន** នេះព្រោះដូចជាទិព្ធ ។

ពិតមែន ទេវតាទាំងឡាយមានចក្ខុបសាទជាទិព្ធ ដែល
កើតពីកម្មមិនប្រលាក់ដោយទឹកល្អ ស្លេស្ម និងឈាមជាដើមអាច
ទទួលអារម្មណ៍បានសូម្បីក្នុងទីឆ្ងាយ ។ អកិញ្ចាចក្ខុសូម្បីនេះកើត
ពីចតុត្ថឌ្ឍានសមាធិ ក៏ជាដូច្នោះ ហេតុនោះ ទើបឈ្មោះថា **ទិព្ធ**
ព្រោះដូចជារបស់ទិព្ធ ។ ម្យ៉ាងទៀត ឈ្មោះថា **ទិព្ធ** ព្រោះមាន
សេចក្ដីរុងរឿងច្រើនឬមានគតិធំដោយទិព្ធនោះ ។ បទថា **ឱ**ស**ុ**ន្ធ

បានដល់ ឈ្មោះថា បរិសុទ្ធដោយល្អ និងប្រាសចាកសង្ខ្លិលេស មានន័យណៈជាដើម ។ បទថា អតិក្ក្ន្ត្ត មានុសកេន បានដល់ កន្ធ៦វិស័យរបស់ពួកមនុស្ស ។ បទថា ឥមំ ឯវ្ហ្ យ ំ ១ ២ ១ ១ ១

ហើយទៅដោយគិតថា អ្នកនេះមិនអាល័យយើងចេញទៅ ។ បទថា ន សោចតិ បានដល់ មិនដល់សេចក្តីក្តៅ ក្រហាយចិត្ត ។ តែដើម្បីសម្តែងហេតុដែលព្រះថេរៈ មិនត្រេកអរ មិនសោកសៅ យ៉ាងនេះ ទើបពោលពាក្យមានជាដើមថា សត្ថា សត្ថាមតី មុត្តំ អ្នកឈ្នះដល់សេចក្តីផុតពីធម៌ជាគ្រឿងជំពាក់ ។

បណ្តាបទទាំងនោះ បទថា សត្ថា សេចក្តីថា ភិក្ខុឈ្មោះ សង្ឆាមជិអ្នកផុតពីធម៌គ្រឿងជំពាក់ ៥ យ៉ាងគឺគ្រឿងជំពាក់គឺ រាគៈ ទោសៈ មោហៈមានៈ និងទិដ្ឋិដោយសមុច្ឆេទវិមុត្តិនិងបដិបស្ស-ទ្ធិវិមុត្តិ ។ បទថា តម្ហំ ព្រូមិ ព្រាហ្មណំ សេចក្តីថា តថាគត ពោលអ្នកនោះ គឺអ្នកដល់សេចក្តីបិតនៅ អ្នកអស់អាសវៈថា ជាព្រាហ្មណ៍ ព្រោះជាអ្នកបណ្តេតបាបដោយប្រការទាំងពួងឯង ។

ឯកបុគ្គលសូត្រ

នៅក្នុងបិដកលេខ ៥២, ទំព័រ ១៤៣ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់អំពី [ការជីកគាស់អាមិនៃមច្ចុរាជ] មានសេចក្តីថា ៖

ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ឧបាសកម្នាក់ មានកូនប្រុសតូចមួយ ជាទីស្រឡាញ់ ជាទីគាប់ចិត្ត ធ្វើមរណភាព ។ គ្រានោះឯង ពួកឧបាសកច្រើននាក់ មានសម្ពត់ទទឹក មានសក់ទទឹក ចូលទៅគាល់ព្រះមានព្រះភាគទាំងថ្ងៃ ហើយក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះឧបាសកទាំងនោះអង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគត្រាស់សួរយ៉ាងនេះថា ម្នាលឧបាសកទាំងឡាយដូចម្តេចហ្ន៎ បានជាអ្នកមានសម្ពត់ទទឹក មានសក់ទទឹក ចូលមកក្នុងទីនេះទាំងថ្ងៃ ។ កាលបើព្រះមានព្រះភាគត្រាស់សួរយ៉ាងនេះហើយ ឧបាសកនោះ បានទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះមានព្រះភាគ កូនប្រុសតូចមួយរបស់ខ្ញុំព្រះអង្គ ជាទីស្រឡាញ់ ជាទីគាប់ចិត្ត ធ្វើមរណភាពទៅ បានជាពួកខ្ញុំព្រះអង្គ មានសម្ពត់ទទឹក មានសក់ទទឹក ចូលមកក្នុងទីនេះទាំងថ្ងៃ ។

លុះព្រះមានព្រះភាគ ទ្រង់បានជ្រាបច្បាស់សេចក្តីនុ៎ះ

ហើយ ទើបទ្រង់បន្ទឺនៃទានក្នុងវេលានោះថា ៖

ឯឯ**ករ**ូ**ប**ស**ត្ត**ា ឧ**ត**ន**ិ**ត**ា **ស**េ **ទ**េ**វ**ា**ក**ា**យ**ា **ប**ុ**ថ**ុ**ម**ា**ន**ុ**ស**ា **ច**

អា**ឃ**ា**ត**ិ**ន**ោ **ប**ិ**ដ**ុ**ន**្**ន**ា **ម**ច្**ច**ុ**ភ**ា**ជ**ស**្**ស** **ว**ส**ํ** **ค**ច្**ឆ**ន្**ត**ិ ។

យេ **ว**ে **ธ**ิ**ว**া **จ** **ร**ត្**ต**ោ **จ** **อ**ป្**ป**ម**ต**្**ต**ា **ช**ห**า**ន្**ต**ិ **ป**ิ**ย**ូ**ป**ํ

ตে **ว**ে **ข**ณ**า**ន្**ต**ิ **อ**ย**ม**ូ**ล**ํ **ม**ច្**ช**ុ**ต**ោ **อ**ា**ม**ิ**ส**ํ **ท**ุ**ร**ត**ิ**ว**ត្**ต**ន្**ต**ิ ។

ពួកទេវតានឹងពួកមនុស្សជាច្រើន ជាប់ជំពាក់ដោយការត្រេកត្រអាលក្នុងរូបជាទីស្រឡាញ់ ជាអ្នកមានសេចក្ដីទុក្ខនឹងសេចក្ដីសោកសូន្យ លុះក្នុងអំណាចមច្ចុរាជ ។ ពួកជនណាមិនធ្វេសប្រហែសទាំងថ្ងៃទាំងយប់លះបង់រូបជាទីស្រឡាញ់ ពួកជននោះឯង ឈ្មោះថា គាស់រលើងឫសគល់នៃទុក្ខជានុយនៃមច្ចុដែលកន្ទងបានដោយក្រ ។

អដ្ឋកថា

បទថា **ឯ**ឯ**ករ**ូ**ប**ស**ត្ត**ោ ប្រែថា បុត្រម្នាក់ ក៏បុត្រនោះ ឈ្មោះថា **ឯ**ឯ**ករ**ូ**ប**ស**ត្ត**ៈ ព្រោះអត្ថថា ដែលគេអនុគ្រោះ, ឈ្មោះថា **ប**ិ**យ**ូ**ป**ํ ព្រោះអត្ថថាដែលគេស្រឡាញ់, ឈ្មោះថា **ม**ោ**ต**ា**ป**ํ ព្រោះ

អត្ថជាទីចម្រើនចិត្ត ។ ម្យ៉ាងទៀត ឈ្មោះថា **ឋិយៈ** ព្រោះអត្ថជាគួរសរសើរ ព្រោះសម្បូរណ៍ ដោយសេចក្តីល្អនៃរាងកាយ, ឈ្មោះថា **មនាបៈ** ព្រោះជា អ្នកមានកល្យាណធម៌ ព្រោះសម្បូ-ណ៍ដោយសីលនិង**អាចារៈ** ។

ឈ្មោះថា **កាលៈ** ព្រោះធ្វើសត្វឱ្យអស់ទៅ បានដល់**មរណៈ** ។ ឈ្មោះថា **កាលង្ខតៈ** ព្រោះធ្វើគឺ ដល់កាលៈនោះ ។ ម្យ៉ាងទៀត ឈ្មោះថា **កាលង្ខតៈ** ព្រោះកាលៈគឺ មកដ្ឋធ្វើហើយ គឺវិនាសទៅហើយ បានដល់ ដល់សេចក្តីមិនឃើញ អធិប្បាយថា ស្លាប់ ។

បទថា **សម្ពហុលា ឧបាសិកា** *សេចក្តីថា ឧបាសកអ្នកក្រុងសាវត្ថីជាច្រើន ទៅតាមក្រោយ ឧបាសកអ្នកដែលមានកូនស្លាប់ដរាបដល់ព្រៃជាទីចោលសាកសព ព្រមដោយសេចក្តីសោកឱ្យធ្វើឈាបនកិច្ចសាកសព ហើយក៏ត្រឡប់ចុះទឹកទាំងដែលស្លៀកដណ្តប់នៅនុ៎ះឯង ច្រមុជក្បាល ច្របាច់សំពត មិនទាន់ទឹងស្ងួតឡើយ ស្លៀកមួយផ្ទាំង ធ្វើឆៀងស្មាមួយផ្ទាំង ឱ្យឧបាសកនោះនាំមុខ គិតនិងស្លាប់ធម៌ដែលជាហេតុបន្ទោបង់នូវ*

សេចក្ដីសោកក្នុងសំណាក់ព្រះសាស្ដា ទើបចូលទៅគាល់ព្រះសាស្ដា ។ ដោយហេតុនោះ លោកទើបពោលពាក្យមានជាដើមថា អលុលកេសា មានសក់ជោគដោយទឹក ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា អលូវត្ថា ប្រែថា មានសំពត់ជោគដោយទឹក ។

បទថា ទិវា ទិវស្ស ប្រែថា ជាវេលាថ្ងៃ អធិប្បាយថា វេលាថ្ងៃត្រង់ ។ ព្រោះហេតុដែលព្រះតថាគតទាំងឡាយ ទ្រង់ជ្រាបត្រាស់សួរក៏មាន ទ្រង់ជ្រាបមិនត្រាស់សួរក៏មាន ។ ទ្រង់ដឹងវេលា ត្រាស់សួរ ទ្រង់ដឹងវេលាមិនត្រាស់សួរក៏មាន ។ ព្រោះដូច្នោះ ព្រះមានព្រះភាគទ្រង់ជ្រាបនៅតែម្ដង កាលនឹងត្រាស់សួរដើម្បីតាំងរឿងឡើង ទើបត្រាស់ពាក្យមានជាដើមថា កិं នุ ខោ តុម្ហេ ឧបាសក ម្នាលឧបាសកទាំងឡាយ ព្រោះហេតុអ្វីហ្ន៎ ពួកលោក ដូច្នេះ ។ ព្រះតម្រាស់នោះមានអត្ថន័យដូច្នេះថា ម្នាលឧបាសកទាំងឡាយ ក្នុងថ្ងៃដទៃ ៗ ពួកលោកកាលមកកាន់សំណាក់របស់តថាគត ស្លៀកសំពត់ស្អាត និងស្អាតមកក្នុងវេលាល្ងាច បទថា តេន មយំ សេចក្ដីថា ព្រោះ

ហេតុនោះ ខ្ញុំព្រះអង្គទាំងឡាយជាយ៉ាងនោះ ព្រោះត្រូវសេចក្ដីសោកយ៉ាងខ្លាំងគ្របសង្កត់ព្រោះសេចក្ដីក្ដៅក្រហាយចិត្ត ដែលកើតពីការព្រាត់ប្រាសចាកបុត្រ ទើបបានមកគាល់ក្នុងទីនេះ ។

បទថា **ឯតមត្ថំ** ១ **ជ**ិ**ត**្**វ**ា សេចក្ដីថា ព្រះមានព្រះភាគទ្រង់ជ្រាបដោយប្រការទាំងពួងដល់រឿងនេះថា សភាវធម៌ មានសោកទុក្ខ និងទោមនស្សជាដើម មានវត្ថុជាទីស្រឡាញ់ជាដែនកើត កាលវត្ថុដែលជាទីស្រឡាញ់មិនមាន សេចក្ដីសោកជាដើមទាំងនោះ រមែងមិនមានដោយប្រការទាំងពួង ទើបទ្រង់បន្ទ្ទ**ុ**ទ្ធ**ា**ននេះ ជាកាលប្រកាសសេចក្ដីនោះ ។

បណ្ដាបទទាំងនោះ បទថា **ប**ិ**យ**ូ**ប**ាតគ**ធ**ិ**ត**ាសេ សេចក្ដីថា ជាប់គឺ មានចិត្តប្រតិព័ន្ធក្នុងសភាវៈដែលជាទីស្រឡាញ់ មានរូបខន្ធជាដើម ដោយសេចក្ដីត្រេកអរក្នុងសុខវេទនា ។ ក៏បទថា **ค**ธิ**ต**าเส សំដៅយក **ค**ธิ**ต**า ន្ទ**ុ**ះ**ข**ង ។ ម្យ៉ាងទៀត សព្ទថា **เส** ត្រឹមតែជានិបាត ។ ចក្ខុបសាទជាដើម និងបិយជនមានបុត្រនិងភរិយាជាដើម ឈ្មោះថា **ป**ิ**ย**ู**ป** ។ សមពិតដូចពាក្យដែលលោកពោលទុកថា អ្វីជា **ป**ิ**ย**ู**ป** **ส**า**ต**ู**ป** ក្នុង

លោក គឺចក្ខុជាបិយរូបសាតរូបក្នុងលោក ។ ល ។ ធម៌ណ្ហ ជាបិយរូបសាតរូបក្នុងលោកនិងថា

អ្នកណាជាប់ជំពាក់កាមជាច្រើនគឺស្រែ សួន ជ្រាក់ គោ សេះ ទាស: ស្រី ប្រុស និងពួកមានអធ្យាស្រ័យត្រូវគ្នា ។

ព្រោះហេតុនោះ អ្នកជាប់ ស្ងប់ អធិប្បាយថា ត្រ៏មត្រូវ ដោយសេចក្ដីត្រេកអរក្នុងបិយរូបទាំងនោះ ។ ដើម្បីនឹងឆ្លើយ ពាក្យសួរថា ជនទាំងនោះ គឺ ពួកជនណាជាប់នៅក្នុងបិយរូបនិង សាតរូប ទើបទ្រង់សម្ដែងជនទាំងនោះថា ទេវកាយា ឬ ទ្ធ-ន្ធុសង្ឆា ច ពួកទេវតានិងមនុស្សជាច្រើន, បានដល់ ពួកទេវតាជា ច្រើន មានទេវតាជាន់ចាតុម្ចហារាជិកាជាដើមនិងមនុស្សជាច្រើន មានអ្នកជម្ពូទ្វីបទាងដើម ។

បទថា អឃាវិនោ បានដល់ អ្នកមានទុក្ខផ្លូវកាយនិងផ្លូវ ចិត្ត ។ បទថា ឋិតុ ១ បានដល់ អ្នកសាបសូន្យពីសម្ដ្ដ មាន សេចក្ដីជាកម្ចោះក្រមុំ និងសេចក្ដីមិនមានរោគជាដើម ព្រោះ សេចក្ដីវិបត្ដិនៃជរានិងរោគជាដើម ។ គប្ប្ជ្ជ្ជ្ជ្ជ្ជ្ជ្ជ

ដែលបានពោលទុកក្នុងទេវតានិងមនុស្សទាំងឡាយ ។ ម្យ៉ាងទៀត ទេវតា ទាំងឡាយព្រមព្រៀងដោយសុខ ដោយចំណែកតែមួយ មិនមានទុក្ខ ជរា និងរោគក៏ពិត ដល់យ៉ាងនោះ សូម្បីទេវតាទាំងនោះ លោកក៏ហៅថា អ្នកមានទុក្ខ និងថា អ្នកមានសេចក្តីសាបសូន្យ ព្រោះមានការមិនផុតចាកពីទុក្ខនោះជាសភាវ: ។ ម្យ៉ាងទៀត គប្បីជ្រាបការកើតមានទុក្ខជាដើម សូម្បីរបស់ទេវតាទាំងនោះ ដោយអំណាចការកើតឡើងនៃបុព្វនិមិត្ត បដិច្ចនជរានិងរោគផ្ទ្រ ចិត្ត ។ បទថា **មចុ្ចរាជស្ស្ស** សំ ** គច្ឆន្តិ** សេចក្តីថា ជនទាំងនោះ ទៅកាន់អំណាចគឺដៃនៃសេចក្តីស្លាប់ ពោលគឺមចុ្ចរាជ ព្រោះមានធាតុ ៣ ជាធំ ហេតុនឹងកើតក្នុងគភ៌រឿយ ៗ ព្រោះញ្ចុំងលះតណ្ហា ដែលមានបិយវត្ថុជាអារម្មណ៍មិនបាន ។

ព្រះមានព្រះភាគ គ្រាទ្រង់សម្តែងវដ្ដ:ដោយហេតុត្រឹមតែ ប៉ុណ្ណោះ ហើយឥឡូវនេះទើបសម្តែងវិវដ្ដ: (និព្វាន) ដោយន័យ មានជាដើមថា **យេ** ។ ។ **ធីរា** ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **យេ** ។ ។ **ធីរា ច រត្តោ ច អប្ប**មត្តា សេចក្តីថា អ្នកមិនប្រមាទយ៉ាងរឹងមាំ រមែងបំពេញ

អប្បមាទបដិបទា ទាំងពេលថ្ងៃនិងពេលយប់ដោយន័យដូចពោលហើយមានជាដើមថា ជម្រះចិត្តឱ្យហ្មត់ចត់ពីធម៌ដែលជាគ្រឿងត្រជាងការពារ ដោយការចង្ក្រមនិងការអង្គុយរហូតដល់អស់មួយថ្ងៃ ។

បទថា ជហន្តិ ឋិយ្យរូបំ សេចក្ដីថា ឱ្យរ្ងាស់ភ្ញាយកម្មដ្ឋានភាវនាដែលសម្បយុត្តដោយសច្ចៈ ៤ លះបង់ឋិយ្យរូប គឺបង់ឋិយ្យ ដ្ឋានចក្ខុបសាទជាដើម ដែលកើតពីសត្ថនិងសង្ខារដែលជាទីស្រឡាញ់ ដោយការលះឆន្ទរាគៈ ដែលជាប់ក្នុងឋិយ្យរូបនោះ ព្រោះសម្រេចព្រះអរិយមគ្គ ។ បទថា តេ វេ ១ណន្តិ អយ-ម្ហូលំ មច្ចុនោអាមិសំ ទុរតិវត្តំ សេចក្ដីថា ព្រះអរិយបុគ្គលទាំងនោះប្រើចបគឺ អរិយមគ្គញាណជីកតណ្ហា ព្រមទាំងអវិជ្ជាដែលជាមូលឫសនៃទុក្ខ គឺវដ្ដទុក្ខឈ្មោះថា ជាអាមិស ព្រោះមច្ចុគឺមរណៈពាល់ត្រូវ ឈ្មោះថា កន្ទងបានលំបាក ព្រោះសមណ-ព្រាហ្មណ៍ពួកណាមួយក្រៅពីសាសនានេះមិនអាចត្រឡប់បាន គឺជកឫសទ្បើងមិនឱ្យនៅសល់តែវត្ថុបន្ទិចបន្ទួចសេចក្ដីនេះ គប្បីឱ្យពិស្ដារដោយសុត្ដបទមានជាដើមថា ៖

អប្ប្រមាទោ អមតំ បទំ ប្រមាទោ មច្ចុនោ បទំ
អប្ប្រមត្តា ន មានយន្តិ យេ ប្រមត្តាយថា មតា ។

សេចក្តីមិនប្រមាទ ជាផ្លូវនៃសេចក្តីមិនស្លាប់ សេចក្តីប្រមាទជាផ្លូវនៃសេចក្តីស្លាប់ អ្នកមិនប្រមាទឈ្មោះថា រមែងមិនស្លាប់ អ្នកប្រមាទដូចអ្នកស្លាប់ហើយឯង ។

ឧបាសកសូត្រ

នៅក្នុងបិដកលេខ ៥២, ទំព័រ ១៤០ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ត្រាស់អំពី **[អ្នកមិនមានគ្រឿងកង្វល់ជាសុខក្នុងលោក]** *មានសេចក្តីថា ៖*

ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ឧបាសកម្នាក់ នៅក្នុងស្រុកឥច្ឆានង្គលៈ បានទៅដល់នគរសាវត្ថី ដោយកិច្ចនីមួយ ។ លុះឧបាសកនោះ បានសម្រេចកិច្ចនោះស្រេច ក្នុងនគរសាវត្ថីហើយ ។ ក៏ឆៀងចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។

លុះឧបាសកនោះអង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគ ត្រាស់យ៉ាងនេះថា ម្នាលឧបាសក ខ្លួនអ្នកធ្វើហេតុជាទំនង ដើម្បីមកទីនេះជាយូរអង្វែងហើយ ។ ឧបាសកនោះទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គប្រុងនឹងចូលមកគាល់ព្រះ មានព្រះភាគជាយូរហើយ ប៉ុន្តែខ្ញុំព្រះអង្គជាអ្នកឲ្យល់ខ្យាយមិនជាច់ដោយកិច្ចការនីមួយ ទើបមិនអាចឆ្ពៀតចូលមកគាល់ព្រះមានព្រះភាគ បានសោះ ។

លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់នូវសេចក្ដីនុ៎ះហើយ ទើបទ្រង់បន្ទូលឧទានក្នុងវេលានោះថា ៖

សុខំ វត តស្ស ន ហោតិ កិញ្ចិ
សច្ចាតធម្មស្ស ពហុស្សុតស្ស
សកិញ្ចនំ បស្ស វិហញ្ញមានំ
ជនោ ជនម្ហិ បដិពទ្ធរូបោតិ ។

កិលេសគ្រៀងឲ្យល់ខ្យាយណាមួយ មិនមានដល់បុគ្គលអ្នកមានធម៌ ពិចារណាហើយ ជាពហូសុ្សត នុ៎ះឯងជាសុខ អ្នកចូរមើលបុគ្គលអ្នកប្រកបដោយកង្ខល់ កំពុងតែលំបាក់ចំពោះ

អ្នកផង ច្រើនតែមានសភាពជាប់ចំពាក់អ្នកផង ។

កើតមកជាមនុស្សបានទាន់ព្រះពុទ្ធសាសនា ត្រូវទំរកការចម្រើនផ្លូវចិត្ត មិនត្រូវគិតរកតែការសប្បាយ ហើយបណ្តោយឱ្យខ្លួននៅតែលង់ភ្លៅនោះទេ ។

អដ្ឋកថា

អដ្ឋកថាឧបាសកសូត្រឧបាសកសូត្រទី ៥ មានវិនិច្ឆ័យដូចតទៅនេះ ?

បទថា ឥច្ឆានङ्गलកោ សេចក្តីថា ស្រុកព្រាហ្មណ៍តំបន់មួយក្នុងដែនកោសលដែលបាននាមថា **ឥច្ឆានङ्गल:**, ឈ្មោះថា **ឥច្ឆានङ्गल:** ព្រោះនៅអាស្រ័យក្នុងស្រុកព្រាហ្មណ៍នោះ ឬព្រោះកើត គឺ មានក្នុងស្រុកព្រាហ្មណ៍នោះ ។ បទថា ឧបាសកោ សេចក្តីថា ឈ្មោះថា ឧបាសក ជាអ្នកប្រកាសភាវៈដែលខ្លួនជាឧបាសកក្នុងសំណាក់របស់ព្រះមានព្រះភាគ ដោយត្រៃសរណគ-មន៍ ជាអ្នកកាន់សិក្ខាបទ ៥ ជាពុទ្ធមាមក: ធម្មាមក: សङ्घមាមក: ។ បទថា ភេនចិទេវ ការណីយេន សេចក្តីថា ដោយការណីយកិច្ចយ៉ាងណាមួយ មានការជម្រះឱ្យហ្មត់ចត់យ៉ាងក្រៃលែងជាដើម

ដែលអ្នកទ្រង់ទុកនឹងគប្បីធ្វើ ។ បទថា ឥតិ ត្វា ប្រែថា ឱ្យ
សម្រេច ។ ធ្លាប់ឮមកថា ឧបាសកនេះ ធ្លាប់ចូលគាល់អង្គុយជិត
ព្រះមានព្រះភាគជាប់ជានិច្ច ។ លោកមិនបានគាល់ព្រះសាស្តា
ព្រោះមានការណ៍យកចិត្តច្រើនដល់ ២-៣ ថ្ងៃ ។ ដោយហេតុនោះ
ព្រះមានព្រះភាគ ទើបត្រាស់ថា ចិរស្សំ ខោ ត្វំ ឧបាសក ឥមំ
បរិយាយមកាសិយ ចិន្ត្យ ឥជ្ជមុតនាយ ឧបាសក លោកបាន
ធ្វើបរិយាយដែលនិងមកក្នុងទីនេះ ហួតដល់អស់កាលយូរឯង ។

បណ្តាបទទាំងនោះ បទថា ចិរស្សំ ប្រែថា ដោយកាល
យូរ ។ បទថា បរិយាយំ ប្រែថា គ្រាមួយ ។ សព្ពំ យ ចិ ទ ជ
ជ ជ ជ ។ សេចក្តីថា យោ អយំ ។ លោកពោលពាក្យ អ ចិ ប ជ
ន ។ លោកធ្វើ ។ ដែលធ្វើ ។ ថ្ងៃ ។ ។ ។

ម្យ៉ាងទៀត បទថា **ភេហិ** បានដល់ កិច្ចយ៉ាងណាមួយ ។ ក្នុងសេចក្តីនោះទ្រង់សម្តែងដល់សេចក្តីអើពើ ។ ពិតមែន កាលលោកជ្រះថ្លាក្រៃលែងក្នុងព្រះសាស្តា មិនបានមានសេចក្តីអើពើក្នុងរឿងដទៃ ដូចក្នុងការគាល់ និងការស្តាប់ធម៌របស់ព្រះសាស្តា ។ បទថា **កិច្ចករណីយេហិ** សេចក្តីថា វត្ថុត្រូវធ្វើពិតប្រាកដក្នុងការគាល់ជាដើម នេះចាត់ជាកិច្ច ក្រៅនេះចាត់ជាករណីយ ។ ម្យ៉ាងទៀត វត្ថុដែលត្រូវធ្វើមុនចាត់ជាកិច្ច ដែលត្រូវធ្វើខាងក្រោយ ចាត់ជាករណីយ ។ មួយទៀត វត្ថុបន្ទិចបន្ទួចចាត់ជាកិច្ច វត្ថុធំចាត់ជាករណីយ ។ បទថា **ញ្ញាវដោ** ប្រែថា ខ្ជិលខ្ជាយ ។ បទថា **ឯវាហំ** សេចក្តីថា ខ្ញុំព្រះអង្គមិនអាចនឹងចូលគាល់ដោយអាការយ៉ាងនេះ គឺដោយប្រការនេះអធិប្បាយថា មិនអាចនឹងចូលគាល់ដោយមិនគោរពជាដើម ។

បទថា **ឯតមត្ថំ ១ ១ ១

សេចក្តីមិនមានសេចក្តីកង្វល់ទេ ។

បទថា ឥមំ ឧទានំ សេចក្តីថា ទ្រង់បន្ទឺឧទាននេះដើម្បីសម្តែងដល់សេចក្តីនោះឯង ។

បណ្តាបទទាំងនោះ បទថា សុខំ វត តស្ស នោ ហោតិ កិញ្ចិ សេចក្តីថា ក្នុងវត្ថុមានរូបជាដើម សូម្បីវត្ថុអ្វី ១ត្រឹមតែម្យ៉ាង រមែងមិនមានគឺ មិនមាននៅសល់ បានដល់ មិនប្រាកដដល់បុគ្គលណា ដោយភាវៈដែលកំណត់ដោយតណ្ហាថា នេះរបស់យើងបុគ្គលនោះ រមែងមានសេចក្តីសុខពិត អធិប្បាយថាមានសេចក្តីសុខគួរអស្ចារ្យតែម្តង បាលីថា ន ហោតិ ដូច្នេះក៏មាន ។ គប្បីជ្រាបសេចក្តីនោះដោយសេចក្តីជាអតីតកាល ។ តែអាចារ្យពួកខ្លះពណ៌នាសេចក្តីនៃបទថា ន ហោតិ កិញ្ចិ ទុក្ខ ដូច្នេះថា កិលេសគ្រឿងកង្វល់មានរាគៈជាដើម រមែងមិនមានដល់អ្នកណា ។ ពាក្យនោះមិនល្អ ព្រោះមកក្នុងទេសនាដោយការកំណត់ធម៌ ។ ដោយពាក្យថា រាគាទិកិញ្ចនំ គប្បីជាកន្លែងដែលលោកពោលតែពាក្យសមរម្យប៉ុណ្ណោះ ក្នុងកាលមានការរួប

រួមសូម្បីធម៌គួរកំណត់ ។ ម្យ៉ាងទៀត អធិប្បាយថា បុគ្គលណា មិនមានកិលេសគ្រឿងកង្វល់ គឺគ្រឿងតោងអ្វី ៗ សូម្បីបន្ទិចបន្ទួច ព្រោះមិនមានកិលេសគ្រឿងកង្វល់ មានរាគៈជាដើមនុ៎ះ ឯង សេចក្តីនោះរបស់បុគ្គលនោះ ដែលមិនមានកិលេសគ្រឿងកង្វល់ ឈ្មោះថា ជាសេចក្តីសុខពិតគឺជាសេចក្តីសុខគួរអស្ចារ្យ ព្រោះជាបច្ច័យនៃសេចក្តីសុខ ។ បើនឹងសួរថា កិលេសគ្រឿងកង្វល់មិនមានដល់អ្នកណាដូច្នេះ ព្រះអង្គទើបត្រាស់ថា **សច្ចានតធម្មស្ស ពហុសិ្សសុតស្ស** ដូច្នេះ ។ បុគ្គលណាមានធម៌ដែលត្រូវប្រាប់ហើយ គឺមានកិច្ចដែលត្រូវធ្វើហើយ ព្រោះសម្រេចកិច្ច ១៦ យ៉ាង ពោលគឺមគ្គទាំង ៤ ឈ្មោះថា **ជាពហុស្សូត** ព្រោះដឹងពហុសច្ចៈច្បាស់លាស់ពីធម៌នោះឯងនៃបុគ្គលនោះ ។

ដូចនោះ ព្រះមានព្រះភាគដើម្បីនឹងទ្រង់ សម្តែងអានិសង្សក្នុងសេចក្តីមិនមានកិលេសគ្រឿងកង្វល់អ្វី ៗ ហើយទើបសម្តែងទោសក្នុងសេចក្តីមានកិលេសគ្រឿងកង្វល់អ្វី ៗ

ទើបត្រាស់ពាក្យ មានជាដើមថា **សកិញ្ចនំ** ជ្ឈ ដូច្នេះ ។

ពាក្យនេះមានសេចក្តីដូចតទៅនេះ ព្រះសាស្តាទ្រង់ដល់

ធម៌សង្ខេបហើយ ទើបគ្រាស់ចំពោះចិត្តរបស់ព្រះអង្គថាលោកចូរមើលបុគ្គលដែលឈ្មោះថា មានកិលេសគ្រឿងកង្វល់ ព្រោះមានកិលេសគ្រឿងកង្វល់មានរាគៈជាដើម និងកិលេសគ្រឿងកង្វល់គឺ អាមិសក្តៅក្រហាយនៅ គឺដល់សេចក្តីចង្អៀតចង្អល់ដោយកិច្ចតូចធំ ព្រោះហេតុនៃការស្វែងរកនិងរក្សាកាមដែលបានហើយនិងមិនទាន់បាន ព្រោះសេចក្តីជាអ្នកមានកិលេសគ្រឿងកង្វល់ទ្ចុះឯង និងដោយអំណាចការប្រកាន់ថាយើងថា របស់យើង ដូច្នេះ ។

បទថា ជនោ ជនស្មឿ បដិពទ្ធរូបោ សេចក្តីថា ខ្ញុំនឯងជាជនដទៃ ជាអ្នកមានសភាវៈជាប់នឹងជនដទៃ ដោយអំណាចតណ្ហាថា យើងជារបស់អ្នកនេះ អ្នកនេះជារបស់យើង ទើបក្តៅក្រហាយ គឺដល់សេចក្តីចង្អៀតចង្អល់ ។ បាលីថា បដិពទ្ធ-ចិត្តោ ដូច្នេះក៏មាន ។ ក៏សេចក្តីនេះគប្បីសម្តែងដោយសុត្តបទមានជាដើមថា ៖

បុត្តា មត្ថិ ធនមត្ថិ ឥតិ ពាលោ វិហញ្ញតិ
អត្តា ហិ អត្តនោ នត្ថិ កុតោ បុត្តា កុតោ ធនំ ។

ជនពាល រមែងក្តៅក្រហាយថា បុត្ររបស់យើងមាន

ទ្រព្យរបស់យើងមាន តែតាមការពិតនោះ ខ្លួនឯងមិនមានផង បុត្រនឹងមានមកពីណា ទ្រព្យនឹងមានមកពីណា ។

រឿងព្រះបាទឃតរាជ

[សម្តែងសេចក្តីមិនសោកដល់ព្រះបាទកោសល]

ក្នុងអតីតកាល ព្រះរាជាក្រុងសាវត្ថី ទ្រង់ព្រះនាមថា ធង្ក: ទ្រង់ដណ្តើមរាជសម្បត្តិក្នុងនគរពារាណសីបាន ហើយទ្រង់ត្រាស់បញ្ជាឱ្យចង់ព្រះរាជានាម **ឃត:** ដោយខ្នោះឃ្នាងទាំងឡាយ ហើយត្រាស់បញ្ជាឱ្យឃុំឃាំងក្នុងពន្ធនាគារ ។ ព្រះបាទឃតរាជ ទ្រង់មិនបានសោកសៅ នឹងរាជសម្បត្តិដែលបានវិនាសបាត់ទៅ ហើយ ទ្រង់បានពិចារណាកសិណ ញ៉ាំងឈានឱ្យកើតឡើង ហើយទ្រង់គង់ចម្រើនសមាធិឮដ៏អាកាស ។

ព្រះរាជាព្រះនាម **ធង្ក:** ទ្រង់កើតសេចក្តីក្តៅក្រហាយក្នុងព្រះសរីរ: ស្តេចក្រោកឡើងហើយ យាងទៅកាន់សំណាក់ព្រះបាទឃតរាជនោះ ទ្រង់ទតឃើញព្រះភក្ត្រនៃព្រះបាទឃតរាជ មានរស្មីភ្លឺថ្លាដូចកញ្ជ្រាក់មាសនិងផ្ការបទុម ទើបទ្រង់ត្រាស់សួរហេតុដែលទ្រង់មិនសោកសៅនឹងព្រះបាទឃតរាជនោះ ។ ព្រះបាទឃតរាជ កាលទ្រង់ត្រាស់ប្រាប់ដល់ព្រះបាទធង្ក:រាជ ទ្រង់បានត្រាស់នូវ

គាថា ទាំងនេះក្នុងធម្មរាជជាតក ក្នុងបញ្ចកនិបាតនោះឯងថា ៖

សេចក្តីសោកនាំមកនូវសេចក្តីសុខ ដែលកន្លងទៅហើយមិនបានទេ នាំមកនូវសេចក្តីសុខ ដែលមិនទាន់មកដល់មិនបានទេ,បពិត្រស្តេចធង្ក: ព្រោះហេតុនោះទើបខ្ញុំមិនសោកសៅ ព្រោះថាភាពជាសំឡាញ់ក្នុងសេចក្តីសោកមិនមានទេ, បុគ្គលកាលសោក រមែងជាអ្នកមានរោគលឿងស្គាំងស្គម, ទាំងបាយរមែងមិនពេញចិត្តដល់បុគ្គលនោះ កាលបើបុគ្គលដែលត្រូវសារគឺសេចក្តីសោកមុតហើយ ក៏ទុក្ខព្រួយ, ពួកជនជាសត្រូវរមែងមានចិត្តត្រេកអរ[1] ។

បណ្តាបទទាំងនោះ ជាពួតីតហេតុ គឺនាំនូវសេចក្តីសុខ ដែលកន្លងទៅហើយមកឱ្យមិនបានទេ ។ ម្យ៉ាងទៀត ចាលីក៏យ៉ាងនោះដូចគ្នា ។ អធិប្បាយថា ធម្មតាសេចក្តីសោកសៅ រមែងនាំមកនូវសុខ ដែលកន្លងទៅហើយ គឺឆ្ងងផុតហើយ រលត់ទៅហើយ សាបសូន្យទៅហើយមកឱ្យទៀតមិនបានសោះឡើយ ។ ភាពជាសំឡាញ់ ឈ្មោះថា ឧតីយតា ។ អធិប្បាយថា ឈ្មោះថា សេចក្តីសោករមែងមិនជាសំឡាញ់ដល់អ្នកណាមួយដោយនាំនូវសេចក្តី

---

១. បិដកភាគ ៥៨, ទំព័រ ៧

សុខដែលកន្លងទៅហើយមកឱ្យឬដោយនាំសេចក្តីសុខដែលមិនទាន់មកដល់មកឱ្យ ។ បទថា សោចំ គឺ កាលសោកសៅ ។ ចាទគាថាថា សល្ហវិទ្ធូសន្ត រុប្ឍតោ មានសេចក្តីថា កាលបើបុគ្គលត្រូវកូនសរ គឺសេចក្តីសោកមុតហើយ គឺត្រូវកូនសរ គឺសេចក្តីសោកនោះមកប៉ះទង្គិច ពួកជនជាសត្រូវ រមែងមានចិត្តត្រេកអរថា ពួកយើងបានឃើញខ្ញុំងបច្ចាមិត្តហើយ តើហ្ន៎ ដូច្នេះ អធិប្បាយថា ព្រោះហេតុនោះឯង ទើបខ្ញុំមិនសោកសៅ ។

ព្រះបាទធង្ករាជ ទ្រង់ព្រះសណ្ឋាប់នូវព្រះរាជឱ្ការឆ្លើយតបនោះហើយ ទ្រង់ញ៉ាំងព្រះបាទយតរាជនោះឱ្យទ្រង់អត់ទោស ឱ្យទ្រង់ថ្វាយរាជសម្បត្តិមកវិញ ហើយស្តេចយាងត្រឡប់ទៅកាន់ទីក្រុងសាវត្ថីដូចដើមវិញ ។ ឯព្រះបាទយតរាជ ទ្រង់បានប្រគល់រាជសម្បត្តិដល់ពួកអាមាត្យស្រេចហើយ ស្តេចយាងទៅកាន់ហិមវន្តប្រទេស ទ្រង់ព្រះផ្នួសមានឈានមិនវិនាសហើយ ត្រង់ស្តេចបានទៅកើតក្នុងព្រហ្មលោកហើយ ។

ព្រះបាទយតរាជនោះ សូម្បីត្រូវទុក្ខធម៌ពាល់ត្រូវហើយ ក៏ទ្រង់មិនសោកសៅទ្រង់បានញ៉ាំងឈានឱ្យកើតឡើងហើយ ។

(មង្គលត្ថទីបនី ភាគ ៤/៣៥០)

រឿងអញ្ញត្រព្រាហ្មណ៍

[ស្រែរបស់ព្រាហ្មណ៍ត្រូវខូច]

បានឮថា ព្រាហ្មណ៍អ្នកនៅទីក្រុងសាវត្ថីម្នាក់ ធ្វើស្រែនៅក្បែរមាត់ស្ទឹងអចិរវតី កាលបើស្រូវទុំហើយ ធ្វើសេចក្តីតាំងចិត្តថា ស្អែកនេះអាត្មាអញនឹងប្រមូតកាត់ ដូច្នេះហើយ ក៏ដេក ។ ក៏ក្នុងយប់នោះ ភ្លៀងធ្លាក់ព្រិល ធ្លាក់ហើយ លើស្ទឹងអចិរវតី ។ ទឹកជំនន់ដ៏ធំ បានកួចយកស្រូវទាំងអស់ឱ្យចូលទៅកាន់សមុទ្រ មិនឱ្យនៅសល់សូម្បីត្រឹមតែមួយនាឡិទ្បើយ ។ កាលបើទឹកជំនន់បានស្រកចុះអស់ហើយ ព្រាហ្មណ៍ឃើញ ការវិនាសខូចខាតនៃស្រូវត្រូវសេចក្តីសោក ដែលមានកម្ទាំងគ្របសង្កត់ហើយ យកដៃអោបដើមទ្រូងដើរទៅផ្ទះហើយដេកថ្ងូររវើរវាយ ។

ព្រះសាស្តា ទ្រង់ទតព្រះនេត្រឃើញឧបនិស្សយនៃមគ្គរបស់ព្រាហ្មណ៍នោះ ទ្រង់ធ្វើកត្តកិច្ចស្រេចហើយ ស្តេចយាងទៅកាន់ផ្ទះរបស់ព្រាហ្មណ៍នោះ តែមួយព្រះអង្គឯង ទ្រង់ស្តេចគង់លើអាសនៈ ដែលព្រាហ្មណ៍ក្រាលថ្វាយហើយ ទ្រង់ត្រាស់សម្តែងនូវកាមសូត្រថា **កាមំ កាមយមានស្ស** ដូច្នេះជាដើម ដោយន័យដែលទ្រង់ត្រាស់ទុកហើយ ក្នុងចតុត្ថវគ្គនៃសុត្តនិបាត ។

ព្រាហ្មណ៍នោះ ត្រឡប់បានសេចក្ដីសប្បាយ ព្រោះការស្តាប់ធម៌ បន្ទយនូវសេចក្ដីសោកបានហើយ ចំរើនវិបស្សនា ក៏បានជាព្រះសោតាបន្ន ចំណែកនាងព្រាហ្មណីរបស់ព្រាហ្មណ៍នោះ ក៏បានសម្រេចជាព្រះសោតាបន្នដែរក្នុងទីបញ្ចប់នៃព្រះធម៌ទេសនា ។

ការមសូត្រ

នៅក្នុងបិដកលេខ ៥៤,ទំព័រ ២៦៥ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់សម្ដែងអំពី [ស្រែរបស់ព្រាហ្មណ៍ត្រូវទ្ធ] មានសេចក្ដីថា ៖

ព្រះមានព្រះភាគត្រាស់ថា ៖

កាមំ កាមយមានស្ស តស្ស ចេ តំ សមិជ្ឈតិ
អទ្ធា ឬ ប្ដីតិមនោ ហោតិ លទ្ធា មច្ចោ យទិច្ឆតិ ។

កាលសត្វប្រាថ្នាកាម បើកាមនោះសម្រេចដល់សត្វនោះ លុះសត្វ(នោះ) បានតាមប្រាថ្នាហើយ រមែងមានចិត្តប្រកបដោយ ឬ ប្ដីតិដោយពិត ។

តស្ស ចេ កាមយានស្ស ឆន្ទជាតស្ស ជន្តុនោ
តេ កាមា បរិហាយន្តិ សល្លវិទ្ធោ វ ឬ ប្ដតិ ។

បើកាលសត្វនោះប្រាថ្នា មានធនុ:កើតហើយ កាមនោះ សាបសូន្យទៅ សត្វក៏សុបសៅទៅ ដូចជាមុត្តជោយសរ ។

យោ កាមេ បរិវជ្ជេតិ សប្ប១ សេ្ស្ស១ បទា សិរោ
សោមំ ១ិសត្ត១ិកំ លោកេ សតោ សមតិ១ត្ត១ិ ។

សត្វណាវៀរកាមទាំងឡាយ ដូចបុគ្គលគេចក្បាលពស់ ដោយជើងរបស់ខ្លួន សត្វនោះជាអ្នកមានសតិ រមែងកន្លងនូវ តណ្ហាជាគ្រឿងផ្សាយទៅនេះ ក្នុងលោកបាន ។

ខេត្តំ ១ត្តុំ ហិ១ញ្ញំ ១ា ១ាសេ្ស្ស ១ាសធោ១ិសំ
ជ១ិយោ ១ន្ធ ១ុជ្ជ ១ាមេ យោ ន១ោ អនុ១ិជ្ឈ១ិ ។

មួយទៀត ជនណាប្រាថ្នាជាប់ជំពាក់ទឹងស្រែ ចម្ការ ក១ន្លែង ប្រាក់ គោ សេះ ទឹងបុរសជាខ្ញុំ ពួកស្ត្រី ពួកផៅពង្សទឹង កាមដ៏ច្រើន ។

អ១លា នំ ១លីយន្ត១ មន្ទ១ន្ត១ំ ១ិ១ិ១ិ
ត១ោ នំ ១ុ១ូ្ខ១ន្ទ១ិ ១ាវ ១ិ១ិ១ិ១ោ១ កំ ។

ពួកកិលេសយ៉ាងខ្សោយ រមែងគ្របសង្កត់ជននោះអន្ទ្រាយ ទាំងឡាយ រមែងញ៉ាំញីបុគ្គលនោះ ឥតមានទៅទុក្ខទឹងជាប់ជន នោះ ដូចជាទឹកហូរចូលទូកដែលបែកធ្លាយ ។

តស្មា ជន្តុ សទា សតោ កាមានិ បរិវជ្ជយេ
តេ បហាយ តរេ ឱឃំ ទ្វាវ សិត្វាវ ១ារគ្ងតិ ។

ព្រោះហេតុនោះ សត្ត្វជនមានសតិគ្រប់កាល គួរវៀរចាកនូវកាមទាំងឡាយ លុះលះបង់កាមទាំងនោះហើយ ទើបឆ្លងអន្លង់ បានដូចបុរសស្ពានទ្ធកហើយ ១ៅដល់ត្រើយ១ាងនាយ ។

អដ្ឋកថា

ការកើតឡើងរបស់ព្រះសូត្រនេះជាយ៉ាងណា ?

មានរឿងដំណាលថា កាលព្រះមានព្រះភាគ ប្រថាប់នៅក្នុងក្រុងសាវត្ថី ព្រាហ្មណ៍ម្នាក់ គិតថា យើងនឹងព្រោះស្រូវជិតប្រាំ១ំ ស្ទឹងអចិរវតី ក្នុងចន្លោះក្រុងសាវត្ថី និងជេតវនមហាវិហារ ទើបភ្ជួរស្រែ ។ ព្រះមានព្រះភាគ ហែហមដោយភិក្ខុសង្ឆ ស្តេចចូលទៅបិណ្ឌបាត ឃើញព្រាហ្មណ៍នោះ ទ្រង់រំពឹងថា ស្រូវរបស់ព្រាហ្មណ៍នោះ នឹងវិនាសអស់ ទើបទ្រង់រំពឹងដល់ឧបនិស្សយសម្បត្តិ របស់ព្រាហ្មណ៍នោះ តទៅ១ៀត ទ្រង់ឃើញឧបនិស្សយនៃសោតាបត្តិមគ្គ របស់ព្រាហ្មណ៍នោះ ទ្រង់រំពឹងថាព្រាហ្មណ៍នេះ នឹងសម្រេចកាលណា ទ្រង់ បានឃើញថាកាលស្រូវវិនាសអស់

ព្រាហ្មណ៍នឹងត្រូវសេចក្តីសោកគ្របសង្កត់ ព្រោះស្តាប់ព្រះធម៌ទេសនា ។ ទ្រង់ត្រិះរិះតទៅថា បើតថាគតនឹងចូលទៅរកព្រាហ្មណ៍ក្នុងពេលនោះ ព្រាហ្មណ៍នឹងមិនសម្គាល់ឱ្យាទរបស់តថាគតដែលគួរនឹងស្តាប់ ព្រោះព្រាហ្មណ៍ទាំងឡាយ មានសេចក្តីស្រឡាញ់ផ្សេង ១ៗគ្នា ណ្ហើយចុះយើងនឹងសង្គ្រោះ តាំងពីឥឡូវនេះតែម្តង ព្រាហ្មណ៍មានចិត្តទន់ក្នុងតថាគតយ៉ាង នេះក៏នឹងស្តាប់ឱ្យាទរបស់តថាគតក្នុងពេលនោះ ហើយស្តេចចូលទៅរកព្រាហ្មណ៍ ត្រាស់សួរថា ព្រាហ្មណ៍លោកធ្វើអ្វី ។ ព្រាហ្មណ៍គិតថា ព្រះសមណគោតមជាអ្នកមានត្រកូលខ្ពស់នៅ ទ្រង់ធ្វើការបដិសណ្ឋារជាមួយនឹងយើងទើបមានចិត្តជ្រះថ្លាក្នុងព្រះមានព្រះភាគភ្លាម ក្រាបទូលថា បពិត្រព្រះសមណគោតមដ៏ចម្រើន ខ្ញុំព្រះអង្គកំពុងភ្ជួរស្រែ និងព្រោះស្រូវព្រះអង្គ ។ លំដាប់នោះព្រះសារីបុត្តគិតថា ព្រះមានព្រះភាគបានទ្រង់ធ្វើបដិសណ្ឋារៈជាមួយព្រាហ្មណ៍ ព្រះតថាគតទាំងឡាយមិនមានហេតុបច្ច័យហើយនិងធ្វើយ៉ាងនោះឡើយ ណ្ហើយចុះ សូម្បីយើងក៏នឹងធ្វើបដិសណ្ឋារៈជាមួយព្រាហ្មណ៍នោះដែរដូច្នេះហើយ ក៏បានចូលទៅរកព្រាហ្មណ៍ ហើយបានធ្វើបដិសណ្ឋារៈយ៉ាងនោះជូចគ្នា ។ ព្រះមហាមោគ្គល្លានត្ថេរៈនិងព្រះមហាសាវ័ក ៨០ ក៏ធ្វើ

យ៉ាងនោះ ។ ព្រាហ្មណ៍ពេញចិត្តយ៉ាងក្រៃលែង ។

លំដាប់នោះ ព្រះមានព្រះភាគជាម្ចាស់កាលចង្ហាន់សម្ផ្ទរណ៍ថ្ងៃមួយសោយភត្តាហារស្រេចហើយ ទ្រង់យាងអំពីក្រុងសាវត្ថីទៅកាន់វត្តជេតពន ទ្រង់យាងចេញពីផ្លូវ ចូលទៅកព្រាហ្មណ៍ត្រាស់ថា ម្នាលព្រាហ្មណ៍ ស្រែស្រូវរបស់អ្នកល្អដែរឬ ? ព្រ-ហ្មណ៍ក្រាបទូលថា បពិត្រព្រះគោតមដ៏ចម្រើន ប្រសិនបើស្រែស្រូវនៅតែល្អសម្ផ្ទរណ៍យ៉ាងនេះ ខ្ញុំព្រះអង្គនឹងបែងចែកថ្វាយដល់ព្រះអង្គខ្លះ ព្រះអង្គ ។ គ្រាក្រោយមកកន្លងទៅបាន ៤ ខែ ស្រែស្រូវរបស់ព្រាហ្មណ៍មានផលបរិបូរណ៍ ។ កាលព្រាហ្មណ៍កំពុងទ្ងល់ទ្ងាយថា យើងនឹងច្រូតថ្ងៃនេះ ឬថ្ងៃស្អែកនេះ មហា-មេឃតាំងឡើងហើយ ភ្លៀងធ្លាក់រហូតដល់អស់មួយយប់ ។ ស្ទឹងអចិរវតី ពេញប្រៀបហូរបក់(កាត់)ស្រូវទៅអស់ ។

ព្រាហ្មណ៍ទ្ងចចិត្តរហូតដល់អស់មួយយប់ លុមភ្លឺក៏ទៅកាន់ត្រើយស្ទឹងឃើញស្រូវវិនាសអស់ កើតសោកក្តីសោកយ៉ាងខ្លាំងថា យើងវិនាសហើយឥឡូវនេះយើងនឹងមាន ជីវិតនៅបានយ៉ាងណា ពេលជិតភ្លឺនៃយប់នោះឯង ព្រះមានព្រះភាគទ្រង់ត្រួតមើលសត្វលោកដោយពុទ្ធចក្ខុ ទ្រង់ជ្រាបថា ថ្ងៃនេះ ដល់វេលា

សម្តែងធម៌ដល់ព្រាហ្មណ៍ហើយ ទើបស្តេចចូលទៅកាន់ក្រុងសាវត្ថី ដោយកិច្ចការវត្ត ប្រថាប់ឈរជិតទ្វារផ្ទះរបស់ព្រាហ្មណ៍ ។ ព្រាហ្មណ៍ឃើញព្រះមានព្រះភាគហើយគិតថា ព្រះសមណគោតម មានព្រះប្រាជ្ញានឹងលួងលោម ចិត្តយើងដែលត្រូវសេចក្តីសោក គ្របសង្កត់ ទើបស្តេចមកហើយក្រាលអាសនៈទទួលបាត្រទូល និមន្តឱ្យទ្រង់គង់ ។ ព្រះមានព្រះភាគទ្រង់ជ្រាប ទើបត្រាស់សួរ ព្រាហ្មណ៍ថា ព្រាហ្មណ៍លោកខ្វល់ចិត្តរឿងអ្វី ។ ព្រាហ្មណ៍ក្រាប ទូលថា បពិត្រព្រះគោតមដ៏ចម្រើន ត្រូវហើយ ព្រះអង្គស្រែស្រូវ របស់ខ្ញុំព្រះអង្គត្រូវទឹកបក់(កាត់)វិនាសអស់ ព្រះអង្គ ។ លំដាប់ នោះ ព្រះមានព្រះភាគត្រាស់ថា **ព្រាហ្មណ៍កាលដល់គ្រាវិបត្តិ ក៏មិនគួរខ្វល់ចិត្ត និងកាលដល់គ្រាសម្បូរណ៍ ក៏មិនគួរសប្បាយ ចិត្តព្រោះឈ្នះថា កាមទាំងឡាយ រមែងសម្បូរណ៍ខ្លះ រមែង វិបត្តិខ្លះ** ដូច្នេះ ទ្រង់ដឹងធម៌ជាទីសប្បាយរបស់ព្រាហ្មណ៍នោះ ទើបបានត្រាស់ព្រះសូត្រនេះ ដោយអំណាចការសម្តែងធម៌ ។ ក្នុងសូត្រនោះ យើងនឹងពណ៌នាត្រឹមតែភ្ជាប់សេចក្តីរបស់បទ ដោយសង្ខេបប៉ុណ្ណោះ ។ ចំណែកសេចក្តីពិស្តារ គប្បីជ្រាបដោយ នយដូចពោលហើយ ក្នុងនិទ្ទេសនោះឯង ។ ក្នុងសូត្រទាំងអស់

ជវៃទ្ធពីនេះក៏ជួចក្នុងសូត្រនេះ ។

ក្នុងបទទាំងនោះបទថា កាមំ បានដល់ វត្ថុកាមគឺធម៌ ប្រព្រឹត្តទៅក្នុងភូមិ ៣ មានរូបដែលគួរស្រឡាញ់ជាដើម ។ បទថា កាមយមានស្ស គឺប្រាថ្នា ។ បទថា តស្ស ចេ តំ សមិជ្ឌតិ សេចក្ដីថា បើវត្ថុកាមនោះ នឹងសម្រេចដល់សត្វអ្នកប្រាថ្នានោះ ។ លោកអធិប្បាយថា បើគេបានវត្ថុកាមនោះ ។

បទថា អទ្ធា ឋីតិមនោ ហោតិ បានដល់ រមែងជាអ្នកមានចិត្តត្រេកអរដោយចំណែកតែមួយ ។ បទថា លទ្ធា ប្រែថា បានហើយ ។ បទថា មច្ចោ គឺសត្វ ។ បទថា យធិច្ចតិ កាត់បទជា យំ ឥច្ចតិ រមែងប្រាថ្នាវត្ថុណា ។ បទថា តស្ស ចេ កាមយានស្ស គឺដល់បុគ្គលនោះអ្នកប្រាថ្នាកាម ។ ឬលើកសរសើរដោយកាម ។ បទថា ឆន្ទជាតស្ស កើតសេចក្ដីពេញចិត្តគឺកើតសេចក្ដីប្រាថ្នា ។ បទថា ជន្តុនោ គឺសត្វ ។ បទថា តេ កាមា បរិហាយន្តិ គឺបើកាមទាំងនោះរមែងសាបសូន្យទៅ សោត ។ បទថា សល្លវិទ្ធោវ រុប្ឌតិ សត្វនោះរមែងក្ដៅក្រហាយដូចត្រូវកូនសរចាក់ គឺតអំពីនោះ រមែងក្ដៅក្រហាយ

ដូចត្រូវកូនសរធ្វើដោយដែកជាដើមចាក់ ។

ក្នុងគាថាទី ៣ មានសេចក្ដីសង្ខេបដូចតទៅនេះ ៖

អ្នកណាវៀរកាមទាំងនេះ ដោយការគ្រប សង្កត់សេចក្ដីតម្រេកដោយសេចក្ដីពេញចិត្ត ឬដោយការកាត់ជាច់ក្នុងកាមនោះ ដូចវៀរក្បាលពស់ ដោយជើងរបស់ខ្លួនអ្នកនោះជាអ្នកមានសតិ រមែងឈានកន្លងតណ្ហានេះ គឺសេចក្ដីប្រាថ្នាក្នុងលោកបាន ព្រោះមិនរលឹកដល់លោកហើយ ។

តពីនេះទៅ ជាសេចក្ដីសង្ខេបនៃគាថា ដែលសម្ដែងហើយ ។ បុគ្គលណាត្រេកអរស្រៃ មានស្រៃស្រួវសាលីជាដើម ទីដី មានទីសង់ផ្ទះជាដើម ប្រាក់ គឹកហាបណៈ គោ សេះ ប្រពៃទគោនិងសេះ ស្រីដែលសម្គាល់ថាជាស្រី ពួកចំណងមានចំណងញាតិជាដើម ឬកាមជាច្រើនមានរូបគួរស្រឡាញ់ ជាដើម ពួកដទៃ កិលេសទាំងឡាយមានកម្លាំងតិច រមែងគ្រប សង្កត់ញ៉ាំញីបុគ្គលនោះបាន ។ អធិប្បាយថា កិលេសទាំងឡាយមានកម្លាំងតិច រមែងគ្របសង្កត់បុគ្គលនោះ អ្នកមានកម្លាំងតិច ព្រោះវៀរចាកកម្លាំងសទ្ធាជាដើម ឬព្រោះមិនមានកម្លាំង ។ កាលជា

ដូច្នោះ អន្ធភាយដែលប្រាកដមានរាជសីហ៍ជាដើម និងអន្ធភាយដែលមិនប្រាកដ មានកាយទុច្ចរិតជាដើមរមែងញ៉ាំញ៉ីបុគ្គលនោះ អ្នកប្រាថ្នាក្នុងកាមក្សាកាមនិងស្វែងរកកាម ។

អំពីនោះ ទុក្ខមានជាតិជាដើម រមែងជាប់តាមបុគ្គលនោះ ដែលត្រូវអន្ធភាយ មិនប្រាកដគ្របសង្កត់ ដូចទឹកហូរចូលកាន់ទូកដែលបែកហើយដូច្នោះ ព្រោះដូច្នោះ សត្វគប្បីជាអ្នកមានសតិគ្រប់កាល ដោយការចម្រើន កាយគតាសតិជាដើម កាលវៀរកិលេសកាម សូម្បីទាំងអស់ក្នុងវត្ថុកាម មានរូបជាដើម ដោយការគ្របសង្កត់និងការកាត់ជាច់ គប្បីវៀរកាមទាំងឡាយ សត្វលះកាម ទាំងនោះបានយ៉ាងនេះហើយ គប្បីឆ្លងគឺអាចឆ្លងឱ្យ:សូម្បី ៤ យ៉ាង ដោយមគ្គដែលធ្វើការលះកាមនោះចេញបាន ។ អំពីនោះគប្បីស្ពានទូក គឺអត្តភាពដែលធ្ងន់ដោយទឹក គឺកិលេស គប្បីដល់ត្រើយដោយអត្តភាពដែលស្រាលគប្បីដល់និព្វានដែលជាត្រើយនៃធម៏ទាំងពួង និងគប្បីដល់ដោយការសម្រេចព្រះអរហត្ត រមែងបរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ដូចជាបុរសស្ពានទូកដែលពេញដោយទឹក ហើយគប្បីដល់ត្រើយ គឺទៅដល់ត្រើយដោយទូកដែលស្រាល ដោយសេចក្តីលំបាកបន្ទិច

បន្ទួចប៉ុណ្ណោះ ដូច្នោះ ។

ព្រះមានព្រះភាគ ទ្រង់ចប់ទេសនាដោយធម៌ដែលជាកំពូល គឺព្រះអរហត្ត ។

កាលចប់ទេសនា ព្រាហ្មណ៍និងព្រាហ្មណីតាំងនៅក្នុងសោតាបត្តិផល ។

ទេវទហសូត្រ

នៅក្នុងបិដកលេខ ៣៣, ទំព័រ ១១ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់សម្តែងអំពី [**ការកម្ចាត់បង់ឆន្ទរាគៈក្នុងខន្ធ ៥**] មានសេចក្តីថា ៖

ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងនិគមឈ្មោះ ទេវទហៈ របស់ពួកសក្យៈ ក្នុងដែនសក្តៈ ។ គ្រានោះឯង ពួកភិក្ខុច្រើនរូបដែលមានដំណើរ ត្រូវទៅបច្ឆាភូមិ បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះពួកភិក្ខុនោះ អង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំប្រាថ្នានឹងទៅកាន់ជនបទឈ្មោះ បច្ឆាភូមិនឹងសម្រេចការ

នៅអាស្រ័យក្នុងបច្ចាភូមិជនបទ ។

ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ បានលាសារីបុត្រហើយឬ ។ បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំមិនបានលាព្រះសារីបុត្តមានអាយុទេ ។ ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយលាសារីបុត្តផង ម្នាលភិក្ខុទាំងឡាយ (ព្រោះ)សារីបុត្តជាបណ្ឌិតជាអ្នកអនុគ្រោះពួកភិក្ខុ ជាសព្រហ្ម-ចារី ។ ភិក្ខុទាំងនោះទទួលព្រះពុទ្ធដីកាព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

សម័យនោះឯង សារីបុត្តមានអាយុ អង្គុយនៅក្បែរគុម្ពវៃទ៏កមួយ មិនឆ្ងាយអំពីព្រះមានព្រះភាគ ។ គ្រានោះឯង ភិក្ខុទាំងនោះ ត្រេកអរ រីករាយនឹងភាសិតរបស់ព្រះមានព្រះភាគហើយ ក្រោកចាកអាសនៈ ក្រាបថ្វាយបង្គំព្រះមានព្រះភាគធ្វើប្រទក្សិណ ហើយចូលទៅរកព្រះសារីបុត្តមានអាយុ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្ដីរីករាយជាមួយនឹងព្រះសារីបុត្តមានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយ នឹងពាក្យដែលគួរញ្ជក់ហើយ អង្គុយក្នុងទីដ៏សមគួរ ។ លុះភិក្ខុទាំងនោះ អង្គុយក្នុងទីដ៏សមគួរហើយ ក៏និយាយនឹងព្រះសារីបុត្តមានអាយុយ៉ាងនេះ ម្នាល

អាវុសោសារីបុត្ត យើងប្រាថ្នានឹងទៅកាន់បច្ចាភូមិជនបទ នឹងសម្រេចការនៅអាស្រ័យក្នុងបច្ចាភូមិជនបទ ។ (ព្រះសារីបុត្តពោលថា) ពួកលោកបានលាព្រះសាស្តាហើយឬ ។ ម្នាលអាវុសោ គង់មានពួកខត្តិយបណ្ឌិតខ្លះ ព្រាហ្មណបណ្ឌិតខ្លះ គហបតិបណ្ឌិតខ្លះ សមណបណ្ឌិតខ្លះ ជាអ្នកសួរប្រស្នា ចំពោះភិក្ខុដែលទៅក្នុងដែនដទៃផ្សេង ។ ព្រោះថា ពួកមនុស្សជាបណ្ឌិតជាអ្នកពិចារណារកប្រយោជន៍(តែងសួរថា) ព្រះសាស្តារបស់ពួកលោកមានអាយុនោះ តើលទ្ធិដូចម្តេចប្រៀនប្រដៅដូចម្តេច ។ លោកមានអាយុទាំងឡាយ លោកបានស្តាប់ដោយប្រពៃ រៀនដោយប្រពៃ យកចិត្តទុកដាក់ដោយប្រពៃ ចាំជាក់លាក់ ចាក់ធ្លុះដោយប្រពៃ ដោយប្រាជ្ញានូវធម៌ទាំងឡាយដែរឬ ពួកលោកមានអាយុកាលនឹងដោះស្រាយយ៉ាងណាដែលឈ្មោះថាសម្តែងតាមធម៌ដែលព្រះមានព្រះភាគត្រាស់ ហើយផង កុំពោលបង្កាច់ព្រះមានព្រះភាគ ដោយពាក្យមិនពិតផង ព្យាករនូវធម៌សមគួរដល់ធម៌ផងលំអាននៃពាក្យបន្ទិច បន្ទូចដែលប្រកបដោយធម៌ មិនគប្បីដល់នូវហេតុដែលគួរតិះ ដៀលផង ។

ភិក្ខុ. ម្នាលអាវុសោពួកយើងខ្ញុំមកអំពីទីឆ្ងាយ បម្រុងអង្វរ

សូមព្រះសារីបុត្តមានអាយុ បកប្រែសេចក្តីនៃភាសិតនេះឱ្យ១ទាន ។

សារីបុត្ត. ម្នាលអាវុសោ បើដូច្នោះ ចូរលោកទាំងឡាយ ស្តាប់ ចូរយកចិត្តទុកជាក់ឱ្យប្រពៃចុះ ខ្ញុំនឹងសម្តែងប្រាប់ ។ ភិក្ខុ ទាំងនោះក៏ទទួលពាក្យព្រះសារីបុត្តមានអាយុថា ការណាអាវុសោ គង់មានពួកខត្តិយបណ្ឌិតខ្លះ ព្រាហ្មណបណ្ឌិតខ្លះគហបតិបណ្ឌិត ខ្លះ សមណបណ្ឌិតខ្លះ ជាអ្នកសួរប្រស្នាចំពោះភិក្ខុដែលទៅក្នុង ដែនដទៃផ្សេង ១មិនខាន ម្នាលអាវុសោ ព្រោះពួកមនុស្សជា បណ្ឌិត ជាអ្នកពិចារណារកប្រយោជន៍(តែងសួរថា) ព្រះសាស្តា របស់ពួកលោកមានអាយុនោះ តើលទ្ធិដូចម្តេច ប្រដៅធម៌អ្វី ។ ម្នាលអាវុសោ ពួកលោកត្រូវគេសួរយ៉ាងនេះ ហើយត្រូវដោះ ស្រាយយ៉ាងនេះថា ម្នាលអាវុសោ ព្រះសាស្តារបស់យើង ជាអ្នក ប្រដៅឧបាយកម្ចាត់បង់នូវឆន្ទរាគ ។ ម្នាលអាវុសោ ព្រះសាស្តា របស់យើង ត្រូវដោះស្រាយយ៉ាងនេះហើយ ពួកខត្តិយបណ្ឌិតខ្លះ ព្រាហ្មណបណ្ឌិតខ្លះ គហបតិបណ្ឌិតខ្លះ សមណបណ្ឌិតខ្លះ ជា អ្នកសួរប្រស្នាចំពោះភិក្ខុដែលទៅក្នុងដែនដទៃផ្សេង ១ មិនខាន ម្នាលអាវុសោ ព្រោះពួកមនុស្សជាបណ្ឌិត ជាអ្នកពិចារណារក ប្រយោជន៍(តែងសួរថា) ព្រះសាស្តា របស់ពួកលោកមាន

អាយុនោះ តើលទ្ធិដូចម្តេចប្រជៀងធម៌អ្វី ។ ម្នាលអាវុសោ ពួកលោកត្រូវសួរយ៉ាងនេះហើយ ត្រូវដោះស្រាយយ៉ាងនេះថា ម្នាលអាវុសោ ព្រះសាស្តារបស់យើងជាអ្នកប្រជៀងឧបាយកម្ចាត់បង់នូវឆន្ទរាគ ។ ម្នាលអាវុសោ កាលបើពួកលោកដោះស្រាយយ៉ាងនេះហើយ ពួកខត្តិយបណ្ឌិតខ្លះ ព្រាហ្មណបណ្ឌិតខ្លះ គហបតិបណ្ឌិតខ្លះ សមណបណ្ឌិតខ្លះ ជាអ្នកពិចារណារកប្រយោជន៍ (សមជានឹងសួរថា) ព្រះសាស្តារបស់លោកមានអាយុប្រជៀងឧបាយកម្ចាត់បង់នូវឆន្ទរាគ តើក្នុងវត្ថុអ្វី ។ ម្នាលអាវុសោ ពួកលោកត្រូវគេសួរយ៉ាងនេះ គួរដោះស្រាយយ៉ាងនេះថា ម្នាលអាវុសោ ព្រះសាស្តាទ្រង់ប្រជៀងឧបាយឱ្យកម្ចាត់បង់នូវឆន្ទរាគក្នុងរូប, ក្នុងវេទនា, ក្នុងសញ្ញា, ក្នុងសង្ខារទាំងឆ្លាយ ។ ព្រះសាស្តាទ្រង់ប្រជៀងឧបាយកម្ចាត់បង់នូវឆន្ទរាគក្នុងវិញ្ញាណ ។ ម្នាលអាវុសោ កាលបើពួកលោកដោះស្រាយយ៉ាងនេះហើយ ពួកខត្តិយបណ្ឌិតខ្លះ ព្រាហ្មណបណ្ឌិតខ្លះ គហបតិបណ្ឌិតខ្លះ សមណបណ្ឌិតខ្លះ សមជានឹងសួរប្រស្នាតទៅទៀត ម្នាលអាវុសោ ព្រោះមនុស្សជាបណ្ឌិត តែងពិចារណារកប្រយោជន៍ (តែងសួរថា) ព្រះសាស្តារបស់លោកមានអាយុ ទ្រង់ឃើញទោសដូចម្តេច បានជា

ប្រជៅឧបាយកម្ចាត់បង់នូវឆន្ទរាគក្នុងរូប ។ ក្នុងវេទនា ។ ក្នុងសញ្ញា ។ ក្នុងសង្ខារទាំងឡាយ ។ ព្រះសាស្តាទ្រង់ប្រជៅឧបាយកម្ចាត់បង់នូវឆន្ទរាគក្នុងវិញ្ញាណ ។ ម្នាលអាវុសោ ពួកលោកត្រូវគេសួរយ៉ាងនេះហើយ គួរដោះស្រាយយ៉ាងនេះថា ម្នាលអាវុសោ សេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្សនិងសេចក្តីចង្អៀតចង្អល់ចិត្ត រមែងកើតឡើងដល់បុគ្គលដែលមិនទាន់ប្រាសចាករាគៈ មិនទាន់ប្រាសចាកឆន្ទៈ មិនទាន់ប្រាសចាកសេចក្តីស្រឡាញ់ មិនទាន់ប្រាសចាកសេចក្តីស្រេកតណ្ហាក្នុងរូប ព្រោះតែរូបនោះប្រែប្រួលទៅ ប្លែកទៅ ។ ក្នុងវេទនា ។ ក្នុងសញ្ញា ។ មិនទាន់ប្រាសចាកតម្រេកក្នុងសង្ខារទាំងឡាយ ។ បេ ។ សេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងសេចក្តីចង្អៀតចង្អល់ចិត្ត រមែងកើតឡើងដល់បុគ្គលដែលមិនទាន់ប្រាសចាកតណ្ហា ព្រោះតែសង្ខារទាំងឡាយនោះប្រែប្រួលទៅ ប្លែកទៅ ។ សេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស រមែង កើតឡើងដល់បុគ្គលដែលមិនទាន់ប្រាសចាករាគៈ មិនទាន់ប្រាសចាកឆន្ទរាគៈ មិនទាន់ប្រាសចាកសេចក្តីស្រឡាញ់ មិនទាន់ប្រាសចាកសេចក្តីស្រេកឃ្លាន មិនទាន់ប្រាសចាកសេចក្តីក្តៅក្រហាយ មិនទាន់ប្រាសចាកតណ្ហាក្នុង

វិញ្ញាណ ព្រោះតែវិញ្ញាណនោះប្រែប្រួលទៅ ប្លែកទៅ ។

ម្នាលអាវុសោ ព្រះសាស្តារបស់យើងទាំងឡាយ ទ្រង់ឃើញទោសនេះឯង បានជាទ្រង់ប្រដៅឧបាយកម្ចាត់បង់នូវឆន្ទ-រាគក្នុងរូប ។ ក្នុងវេទនា ។ ក្នុងសញ្ញា ។ ក្នុងសង្ខារទាំងឡាយ ព្រះសាស្តា ទ្រង់ប្រដៅឧបាយកម្ចាត់បង់នូវឆន្ទរាគក្នុងវិញ្ញាណ ។ ម្នាលអាវុសោ កាលបើពួកលោកដោះស្រាយយ៉ាងនេះហើយ ពួកខត្តិយបណ្ឌិតខ្លះ ព្រាហ្មណបណ្ឌិតខ្លះ គហបតិបណ្ឌិតខ្លះ សមណ-បណ្ឌិតខ្លះ សមជានិងសួរប្រស្នាតទៅទៀត ម្នាលអាវុសោ ព្រោះមនុស្សជាបណ្ឌិត តែងពិចារណារកប្រយោជន៍ (តែងសួរថា) ព្រះសាស្តារបស់លោកមានអាយុ ទ្រង់ឃើញទោសដូចម្តេច បានជាប្រដៅឧបាយកម្ចាត់បង់នូវឆន្ទរាគក្នុងរូប ។ ក្នុងវេទនា ។ ក្នុងសញ្ញា ។ ក្នុងសង្ខារទាំងឡាយ ។ ព្រះសាស្តាទ្រង់ប្រដៅឧបាយកម្ចាត់បង់ក្នុងឆន្ទរាគក្នុងវិញ្ញាណ ។ ម្នាលអាវុសោ ពួកលោកត្រូវគេសួរយ៉ាងនេះហើយ គួរព្យាករយ៉ាងនេះថា ម្នាលអាវុសោ សេចក្តីសោកខ្សឹកខ្សួល ទុក្ខ ទោមនស្សនិងសេចក្តីចង្អៀតចង្អល់ចិត្ត រមែងមិនកើតឡើងដល់បុគ្គលដែលប្រាសចាករាគៈ ប្រាសចាកឆន្ទៈ ប្រាសចាកសេចក្តីស្រឡាញ់ ប្រាសចាកសេចក្តីស្រេក

ឃ្លាន ប្រាសចាកសេចក្តីក្តៅក្រហាយ ប្រាសចាកតណ្ហាក្នុងរូប ព្រោះតែរូបនោះប្រែប្រួលទៅ ប្លែកទៅក្នុងវេទនា ។ ក្នុងសញ្ញា ។ សេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងសេចក្តីចង្អៀតចង្អល់ចិត្ត រមែងមិនកើតឡើងដល់បុគ្គលដែលប្រាសចាករាគៈ ប្រាសចាកសេចក្តីស្រឡាញ់ ប្រាសចាកសេចក្តីស្រេកឃ្លានប្រាសចាកសេចក្តីក្តៅក្រហាយ ប្រាសចាកតណ្ហាក្នុងសង្ខារទាំងឡាយ ព្រោះតែសង្ខារទាំងនោះប្រែប្រួលទៅ ប្លែកទៅក្នុងវេទនា ។ សេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងសេចក្តីចង្អៀតចង្អល់ចិត្ត រមែងមិនកើតឡើងដល់បុគ្គលដែលប្រាសចាករាគៈ ប្រាសចាកសេចក្តីស្រឡាញ់ ប្រាសចាកសេចក្តីស្រេកឃ្លាន ប្រាសចាកសេចក្តីក្តៅក្រហាយ ប្រាសចាកតណ្ហាក្នុងវិញ្ញាណទាំងឡាយ ព្រោះតែសង្ខារទាំងនោះប្រែប្រួលទៅ ប្លែកទៅក្នុងវេទនា ។ ម្នាលអាវុសោ ព្រះសាស្តារបស់យើងទាំងឡាយ ទ្រង់ឃើញអានិសង្សនេះឯង បានជាទ្រង់ប្រដៅឧបាយកម្ចាត់បង់ នូវឆន្ទរាគក្នុងរូប ។ ក្នុងវេទនា, ក្នុងសញ្ញា, ក្នុងសង្ខារទាំងឡាយ ។ ព្រះសាស្តាទ្រង់ប្រដៅឧបាយកម្ចាត់បង់នូវឆន្ទរាគក្នុងវិញ្ញាណ ។

ម្នាលអាវុសោ មួយទៀត កាលបើបុគ្គលបាននូវអកុ-

សល ធម៏ទាំងឡាយហើយ ការនៅជាសុខ ឥតទុក្ខ ចង្អៀត ចង្អល់ចិត្តមិនក្តៅក្រហាយក្នុងបច្ចុប្បន្នមិនមានផង លុះបែកធ្លាយ ស្លាប់ទៅ ត្រូវទៅកើតឋានសុគតិជាប្រាកដផង សមជាព្រះមាន ព្រះភាគមិនសរសើរ ការលះបង់នូវអកុសលធម៏នេះទេ ។ ម្នាល អាវុសោ ព្រោះហេតុតែបុគ្គលបាននូវអកុសលធម៏ទាំងឡាយ ហើយ ការនៅជាទុក្ខ ប្រកបដោយសេចក្តីលំបាកប្រកបដោយ សេចក្តីក្តៅក្រហាយក្នុងបច្ចុប្បន្នក៏មានផង លុះទម្លាយរាងកាយ ស្លាប់ទៅ ត្រូវទៅកើតក្នុងទុគ្គតិជាប្រាកដផង បានជាព្រះមានព្រះ ភាគទ្រង់សរសើរការលះបង់នូវអកុសលធម៏ទាំងឡាយ ។

ម្នាលអាវុសោ មួយទៀត កាលបើបុគ្គលបាននូវអកុ-សលធម៏ទាំងឡាយហើយ ការនៅជាទុក្ខ ប្រកបដោយសេចក្តី លំបាក ប្រកបដោយសេចក្តីចង្អៀតចង្អល់ចិត្ត ប្រកបដោយ សេចក្តីក្តៅក្រហាយក្នុងបច្ចុប្បន្ននឹងមានផង លុះទម្លាយរាងកាយ ស្លាប់ទៅ ត្រូវទៅកើតក្នុងទុគ្គតិជាប្រាកដផង សមជាព្រះមានព្រះ ភាគទ្រង់មិនសរសើរ នូវការបំពេញកុសលធម៏នេះទេ ។ ម្នាល អាវុសោ ព្រោះហេតុតែបុគ្គលបាននូវកុសលធម៏ ទាំងឡាយ

ហើយ ការនៅជាសុខ ឥតទុក្ខ មិនចង្អៀតចង្អល់ចិត្ត មិនក្តៅ ក្រហាយក្នុងបច្ចុប្បន្នក៏មានផង លុះទម្លាយរាងកាយស្លាប់ទៅ ត្រូវទៅកើតក្នុងសុគតិជាប្រាកដផង បានជាព្រះមានព្រះភាគទ្រង់ សរសើរ ការលះបង់នូវកុសលធម៌ទាំងឡាយ ។ ព្រះសារីបុត្ត មានអាយុសម្តែងភាសិតនេះចប់ហើយ ។ ភិក្ខុទាំងនោះ ជាអ្នក មានសេចក្តីត្រេកអរនឹងភាសិត របស់ព្រះសារីបុត្តមានអាយុ ។

អដ្ឋកថា

ក្នុងទេវទហសូត្រទី ២ មានវិនិច្ឆ័យដូចតទៅនេះ ៖

ស្តេចទាំងឡាយលោកហៅថា **ទេវ:** ស្រះដែលជាមង្គល របស់ស្តេចទាំងនោះឈ្មោះថា**ទេវទហ:** ន័យមួយទៀតស្រះនោះ កើតឯង ព្រោះហេតុដូច្នោះ លោកទើបហៅថា ទេវទហ: និគម មាននៅក្នុងទីមិនឆ្ងាយស្រះទេវទហ:នោះ ទើបថា ទេវទហ:នោះឯង ដោយជានបុំសកលិङ्गបទថា **បច្ចាភូមកាមិកា** បានដល់ អ្នក ប្រាថ្នានឹងទៅកាន់បច្ចាភូមិ ជនបទដែលតាំងនៅក្នុងទិសដទៃទៀត បទថា **និវាសំ** បានដល់នៅចាំវស្សារហូតដល់អស់ ៣ ខែ បទថា **អបលោកិតោ** ប្រែថា ប្រាប់លាបទថា **អបលោកេថ** ប្រែថា

សូមលោកចូរប្រាប់លាសួរថា ព្រោះហេតុអ្វីទើបឱ្យព្រះថេរៈប្រាប់លា ? ឆ្លើយថា ព្រោះមានពុទ្ធប្រាជ្ញានឹងធ្វើឱ្យលោកទាំងនោះមានការៈនាទី ពិតមែន អ្នកណាសូម្បីកាលនៅក្នុងវិហារជាមួយគ្នាក៏មិនទៅកាន់សំណាក់ កាលនឹងជៀសទៅ ក៏ជៀសទៅដោយមិនប្រាប់លា អ្នកនេះឈ្មោះថា និញ្ជាតោ មិនមានការៈ អ្នកណាសូម្បីនៅក្នុងវិហារជាមួយគ្នា ក៏មកជួបគ្នាបាន កាលនឹងជៀសចេញត្រូវប្រាប់លា អ្នកនេះឈ្មោះថា មានការៈ ភិក្ខុសូម្បីទាំងនេះ មិនជាដូច្នោះ ព្រះមានព្រះភាគទ្រង់ព្រះតម្រិះថា ភិក្ខុទាំងនេះនឹងចម្រើនដោយគុណ មានសីលជាដើម សូម្បីដោយអាការយ៉ាងនេះ ទើបមានព្រះពុទ្ធប្រាជ្ញានឹងទ្រង់នាំភិក្ខុទាំងនោះ ឱ្យមានការៈនាទី ទើបទទួលបង្គាប់ឱ្យប្រាប់លា ។ បទថា បណ្ឌិតោ សេចក្ដីថា អ្នកប្រកបដោយសេចក្ដីជាបណ្ឌិត ៤ យ៉ាង មានសេចក្ដីថា ជាអ្នកឈ្លាសក្នុងធាតុជាដើម ។ បទថា អនុគ្គាហកោ បានដល់ អ្នកអនុគ្រោះដោយការអនុគ្រោះ ២ យ៉ាង គឺអនុគ្រោះដោយអាមិសនិងអនុគ្រោះដោយធម៌ បានពួកថា ព្រះថេរៈ មិនទៅបិណ្ឌបាតពីព្រឹកព្រលឹមដូចភិក្ខុពួកដទៃ កាលភិក្ខុទាំងពួងទៅហើយក៏ដើរត្រួតទៅតាមលំដាប់ទូទៅសង្ឆ្យាវាម ដោសកន្លែងដែលមិនបានដោស

ទាំងសម្រាមដែលនៅមិនបានចោល រក្សាទុកជាក់ គ្រែ តាំង គ្រឿងឈើនិងគ្រឿងដី ដែលរក្សាទុកមិនល្អក្នុងសង្ឆ្យាវាម សួរ ថា ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះប្រាថ្នាថា អនត្ថិរ្ថិយអ្នកចូលទៅកាន់វិហារ ឃើញកុំធ្វើសេចក្តីមើលងាយ បន្ទាប់ពីនោះបានទៅកាន់សាលា ភិក្ខុឃ្លី លួងលោមចិត្តភិក្ខុឃ្លី សួរថា ត្រូវការអ្វី ទើបរកភិក្ខុ ក្ងោះនិងសាមណេរបស់ភិក្ខុទាំងនោះ ទៅដើម្បីប្រយោជន៍ តាមដែលប្រាថ្នាហើយស្វែងរកកេសជ្ជៈដោយភិក្ខាចារវត្ត ក្នុង ទីដែលអ្នកស្រឡាញ់រាប់អានគ្នា ប្រគេនដល់ភិក្ខុទាំងនោះ ទើប បញ្ជូនភិក្ខុទាំងនោះទៅដោយពោលថា ដែលឈ្មោះការបម្រុង ភិក្ខុឃ្លី ព្រះពុទ្ធនិងព្រះបច្ចេកពុទ្ធសរសើរហើយ ទៅចុះ លោក សប្ប្ស ពួកលោកកុំប្រមាទ ហើយខ្លួនឯងក៏ត្រាច់ទៅបិណ្ឌបាត ឬធ្វើភត្តកិច្ចក្នុងត្រកូលឧបដ្ឋាក ហើយទៅកាន់វិហារ ប្រការនេះ ព្រោះព្រះថេរៈនោះ ធ្លាប់ប្រព្រឹត្តមកក្នុងស្ថានទីនៅប្រចាំមុន ក៏ កាលព្រះមានព្រះភាគស្តេចចារិកទៅ ព្រះថេរៈគិតថា "យើងជា ព្រះអគ្គសាវក" ទើបមិនដើរពាក់ស្បែកជើងចាំងឆត្រទៅខាង

មុ១ ។ ក៏ក្នុងបណ្ដាភិក្ខុទាំងនោះ ភិក្ខុពួកណាជាអ្នកចាស់ ជាអ្នកជម្ងឺ ឬនៅកម្ចោះពេក ព្រះថេរៈឱ្យយកប្រេងលាបត្រង់កន្លែងឈឺ របស់ភិក្ខុទាំងនោះ ហើយឱ្យភិក្ខុកម្ចោះនិងសាមណេរ របស់ខ្លួនកាន់ចាត្រនិងចីវរ ថ្ងៃនោះ ឬថ្ងៃស្អែក ក៏នាំភិក្ខុទាំងនោះ ក្នុងថ្ងៃមួយ ព្រះសាស្ដាទ្រង់ឃើញលោកទាំងនេះឯង មិនបានសេនាសនៈអង្គុយនៅក្នុងមុង ព្រោះមកដល់វេលាវិកាលពេកទៅ ថ្ងៃស្អែកទើបឱ្យប្រជុំភិក្ខុសង្ឆ្ស សម្ដែងរឿងជ្រី ស្ងាទិងសត្ងទ ហើយទ្រង់បញ្ញត្តិសិក្ខាបទថា លោកគប្ជីប្រើសេនាសនៈ តាមលំដាប់អ្នកចាស់ ។ ដើមដំបូង ព្រះអង្គទ្រង់អនុគ្រោះដោយអាមិស ដោយប្រការដូច្នេះ ក៏ឯព្រះអង្គកាលនឹងទ្រង់ឱ្យ ១ ១ ១

មិនបានជាឧបជ្ឈាយ៍ មិនបានជាអាចារ្យ មិនបានជាសម្លាញ់ឃើញ សម្លាញ់សេពគប់គ្នាមកដូច្នោះយើងនឹងធ្វើក្នុងសំណាក់ ការងារ របស់លោកដូច្នេះហើយ មិនបានព្រងើយទេ ទើបទទួលព្រះ តម្រាស់ព្រះសាស្តាថា "ការុណា ព្រះអង្គ"

បទថា ឯលគលាគុម្ពេ បានដល់ ពេងដែលប្រក់ចាំង ដោយស្លែទឹកបានពួថា គុម្ពស្លែទឹកនោះកើតក្នុងទីមានទឹកជក់ឃ្លរ ១ គ្រានោះភិក្ខុទាំងនោះ ធ្វើពេងសសរ ៤ ក្នុងទីនោះហើយលើក គុម្ពស្លែទឹកនោះ ទ្បើងទុកលើពេងនោះស្លែទឹក នោះបិទចាំងពេង នោះ ពេលនោះភិក្ខុទាំងនោះ ទើបបូកឥដ្ឋទុកខាងក្រោមពេងនោះ ចាក់ពោយឧ្យាច់ក្រាលអាសនៈទុក ឧ្យាល់រំភើយ ១ បក់ត្រជ្ជូវ សម្រាកពេលថ្ងៃក្នុងមួយ ត្រជាក់ព្រះថេរៈអង្គ្ឃយក្នុងទីនោះ ដែល លោកសំដៅយកពោលទុកថា ត្រង់គុម្ពស្លែទឹក ។ បទថា នានា-រ ដ្ឋគតំ សេចក្តីថា បានដល់ ប្រទេសផ្សេង ១ ក្រៅអំពីប្រទេស ព្រះរាជាមួយអង្គ ។ បទថា វិរដ្ឋំ បានដល់ ប្រទេសដទៃ ដូច អាវាសដទៃក្រៅអំពីអាវាសរបស់ខ្លួនចេញទៅ ឈ្មោះថា វិទេស (អាវាសផ្សេង ១) យ៉ាងណា ប្រទេសដទៃក្រៅអំពីប្រទេស

ដែលធ្លាប់នៅអាស្រ័យឈ្មោះវិជ្ជ:(ប្រទេសផ្សេង ១)ដូច្នោះ ។

ប្រទេសផ្សេង ១នោះ លោកហៅថា **វេរជ្ជ:** ។ បទថា **ខត្តិយបណ្ឌិតា** បានដល់ ព្រះរាជាអ្នកជាបណ្ឌិត មានព្រះបាទពិម្ពិសារនិងព្រះបាទកោសលជាដើម ។

បទថា **ព្រាហ្មណបណ្ឌិតា** បានដល់ ព្រាហ្មណ៍ជាបណ្ឌិត មានចង្កីព្រាហ្មណ៍និងតារុក្ខព្រាហ្មណ៍ជាដើម ។ បទថា **គហបតិបណ្ឌិតា** បានដល់ គហបតីជាបណ្ឌិត មានចិត្តគហបតី និងសុទត្តគហបតីជាដើម ។ បទថា **សមណបណ្ឌិតា** បានដល់ អ្នកបួសជាបណ្ឌិតមានសញ្ជ័យបរិព្វាជកនិងបិលោ- តិកបរិព្វាជកជាដើម ។ បទថា **ឱមំសកា** បានដល់ អ្នកស្វែងរកប្រយោជន៍ ។ បទថា **ឧជ្ជាគរ** បានដល់ លោកពោលសេចក្តីឃើញរបស់ខ្លួនថា យ៉ាងណា អធិប្បាយថា អ្នកមានលទ្ធិថា យ៉ាងណា ។

បទថា **ឧមក្ខាយ** បានដល់ ប្រាប់ឱវាទនិងអនុសាសន៍ដល់សាវកទាំងឡាយថា យ៉ាងណា ។ បទថា **ធម្មស្ស ចានុ-**

ធម្មំ បានដល់ ព្យាករណ៍តាមព្យាករណ៍ដែលព្រះមានព្រះភាគ ត្រាស់ហើយ ។ បទថា សហធម្មិកោ បានដល់ អ្នកប្រព្រឹត្តទៅ ព្រមដោយហេតុ ។ បទថា វាចានុវាទោ បានដល់ ពោលតាម វាទ:ដែលព្រះមានព្រះភាគត្រាស់ ។ បាលីថា **វាចានុវាតោ** ដូច្នេះ ក៏មាន ។ អធិប្បាយថា ធ្លាក់ទៅតាម បណ្តាយតាម ប្រព្រឹត្ត ទៅតាម ។ សូម្បីដោយបទនេះ ជាការដែលលោកសម្តែង ចំពោះវាទ: ដែលបណ្តាយតាមវាទ: នុ៎ះឯង ។

ក្នុងបទថា **អវីតរាគសទ្ធ** គប្បីជ្រាបអត្ថដោយតណ្ហានុ៎ះ ឯង ព្រោះដូច្នោះ តណ្ហានេះឯង លោកហៅថា រាគ: ព្រោះតម្រេក, ថា **ឆន្ទ:** ព្រោះពេញចិត្ត, ថា **បេម:** ព្រោះអត្ថថា ប្រព្រឹត្ត ស្រទ្ធាញ់,ថា **ចិបាសា** ព្រោះអត្ថថា ប្រាថ្នានឹងផឹក, ថា **បរិឡាហ:** ព្រោះអត្ថថា តាមដុត ។

សួរថា ព្រោះហេតុអ្វី លោកទើបផ្តើមពាក្យជាដើមថា អកុសលេ ចាវុសោ ធម្មេ ។ ឆ្លើយថា ដើម្បីសម្តែងទោស របស់អ្នកមិនប្រាសចាករាគ: និងអានិសង្សរបស់អ្នកប្រាសចាក

ភាគ:ក្នុងខន្ធ ៥ ។ បណ្តាបទទាំងនោះ បទថា អវិឃាតো បានដល់ អ្នកអស់ទុក្ខហើយ ។ បទថា អនុបាយាសោ បានដល់ អ្នកអស់សេចក្តីក្តៅក្រហាយ ។

បទថា អបរិឡាហោ បានដល់ អ្នកមិនមានសេចក្តីក្តៅឈួល គប្បីជ្រាបសេចក្តីគ្រប់បទដូចពោលមកនេះ ។

១រុគជាតក

(អ្នកដែលមិនមានសេចក្តីសោក)

ព្រះសាស្តា កាលទ្រង់គង់នៅវត្តជេតពន ទ្រង់ប្រារព្ធចំពោះឧបាសកម្នាក់ ទើបទ្រង់ត្រាស់ពាក្យជាដើមថា ឧរគោវ ត្វចំ ជិណ្ណំ ដូច្នោះជាដើម ។

បានឮថា ក្នុងក្រុងសាវត្ថី បុត្ររបស់ឧបាសកម្នាក់បានដល់នូវកម្ម ។ ព្រោះហេតុតែបុត្រស្លាប់ ឧបាសកនោះ ទើបដល់នូវសេចក្តីសោកសៅ ចេញទៅខាងក្រៅ មិនអាចនឹងធ្វើការងារអ្វី ១បាន ទើបនៅតែក្នុងផ្ទះប៉ុណ្ណោះ ។ លុះវេលាព្រឹកឡើង ព្រះសាស្តាស្តេចចេញអំពីព្រះមហាករុណាសមាបត្តិ ទ្រង់ត្រួត

ពិនិត្យមើលសត្វលោក ដោយពុទ្ធចក្ខុទ្រង់ក៏បានឃើញឧបាសក នោះក្នុងវេលាព្រឹក គ្រានោះទ្រង់ក៏បានស្លៀកស្បង់ ប្រដាប់បាត្រ និងចីវរ បានស្តេចយាងទៅកាន់ផ្ទះរបស់ឧបាសកនោះហើយ ប្រថាប់ឈរនៅត្រង់ទ្វារផ្ទះ ។ រីឯឧបាសកជ្រាបថាព្រះសាស្តា ស្តេចយាងមក ទើបក្រោកឡើងទៅទទួលបាត្រអំពីព្រះហស្តព្រះ អង្គហើយបាននិមន្តព្រះអង្គចូលផ្ទះឱ្យគេក្រាលអាសនៈថ្វាយ ។ កាលព្រះមានព្រះភាគគង់លើអាសនៈ ដែលគេក្រាលថ្វាយហើយ ចំណែកឧបាសកថ្វាយបង្គំព្រះមានព្រះភាគ ហើយក៏អង្គុយក្នុងទី ដ៏សមគួរ ។ ព្រះមានព្រះភាគត្រាស់នឹងឧបាសកនោះថា ម្នាល ឧបាសក ហេតុអ្វីបានជាអ្នកសោកសៅ ។ ឧបាសកក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន បុត្រជាទីស្រឡាញ់របស់ខ្ញុំព្រះអង្គស្លាប់ ព្រោះហេតុនោះបានជាខ្ញុំព្រះអង្គសោកសៅ ។ លំដាប់នោះ ព្រះ មានព្រះភាគ កាលទ្រង់បន្ទោបង់នូវសេចក្តីសោករបស់គេ ទើប ត្រាស់ឧរគជាតកថា ៖

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តគ្រប់គ្រងរាជសម្បត្តិនៅ ក្នុងក្រុងពារាណសី ព្រះពោធិសត្ត បានចាប់កំណើតក្នុងត្រកូល

ព្រាហ្មណ៍ នៅក្នុងស្រុកកែ្សត្រទ្ធានគរពារាណសីនោះ សន្សំទ្រព្យ សម្ដ្ដ្ដ

ថ្ងៃមួយ ព្រះពោធិសត្វទៅស្រែជាមួយបុត្រដើម្បីភ្ជួរស្រែ បុត្រប្រមូលសម្រាមមកដុត ផ្សែងភ្លើងហុយប៉ះភ្នែកអាសិរពិសនោះ អាសិរពិសវាក្រោធលួនចេញមកគិតថា ភ័យកើតដល់យើងព្រោះអាស្រ័យមនុស្សម្នាក់នេះ ទើបទាំបុត្រប្រុសលិចទាំង ៤ ចង្កូម ដួលចុះស្លាប់មួយរំពេច ព្រះពោធិសត្វ ក្រឡេកមើលឃើញបុត្រប្រុសនោះដួលចុះ ទើបបញ្ឈប់គោ ហើយប្រញាប់ទៅរកបុត្រជីងថា បុត្រប្រុសនោះស្លាប់ហើយទើបលើកបុត្រនោះឡើង ឱ្យដេកនៅក្បែរគល់ឈើមួយ រុំដណ្តប់សម្ពត់ទុក មិនយំ មិនខ្សឹកខ្សួលឡើយ ។ ភ្ជួរស្រែបណ្តើរ កំណត់ដឹងចំពោះនូវភាពជា **អនិច្ចំ** ថា ក៏របស់ណាដែលមានការបែកធ្លាយជាធម្មតា ក៏បែកទៅហើយ របស់ដែលមានសេចក្តីស្លាប់ជាធម្មតាក៏ស្លាប់ទៅ សង្ខារទាំងពួងមិនទៀង សម្រេចដោយសេចក្តីស្លាប់ ព្រះពោធិសត្វនោះឃើញបុរស ម្នាក់ធ្លាប់ស្គាល់គ្នា ដើរតាមផ្លូវជិតស្រែទើបសួរថា អ្នកនឹងទៅផ្ទះឬ ? កាលគេឆ្លើយថា បាទ ! ទើបពោលថា បើដូច្នោះ លោកគប្បីឈាងចូលទៅកាន់ផ្ទះរបស់ខ្ញុំ ប្រាប់ដំណឹងដល់នាងព្រាហ្មណីថា ថ្ងៃនេះ មិនបាច់នាំភត្តាហារទៅដើម្បីមនុស្សពីរនាក់ដូចមុនទេ គប្បីនាំអាហារទៅចំពោះ

សម្រាប់មនុស្សតែម្នាក់ ប៉ុណ្ណោះបានហើយ ។ ហើយពេលមុនទាស៊ី តែម្នាក់ប៉ុណ្ណោះ ប៉ុន្តែថ្ងៃនេះ មនុស្សទាំង ៤ នាក់ គប្បីស្លៀកជណ្តប់សម្ពត់ស កាន់គ្រឿងក្រអូបហើយមក ។ បុរសនោះទទួលពាក្យហើយទៅប្រាប់ដល់ព្រាហ្មណីយ៉ាងនោះនាង ព្រាហ្មណីនោះបានដឹងថា បុត្ររបស់យើងស្លាប់ហើយ សូម្បីសេចក្តីវិប្បរិតត្រឹមតែការញាប់ញ័រចិត្ត ក៏មិនមានដល់នាងព្រាហ្មណីនោះ ។ នាងក៏មានចិត្តអប់រំទុកល្អហើយយ៉ាងនេះ ស្លៀក ជណ្តប់សម្ពត់ សកាន់គ្រឿងនិងផ្ការឈើ ឱ្យគេកាន់យកអាហារ ហើយទៅព្រមគ្នាជាមួយនិងមនុស្សដ៏សេស ។ សូម្បីមនុស្សតែម្នាក់ ក៏មិនមានការយំ ឬការខ្សឹកខ្សួលឡើយ ។ ព្រះពោធិសត្វអង្គុយក្នុងម្ជុំកែ្សរបុត្រប្រុស ដែលដេកស្លាប់នោះឯង បរិភោគអាហារក្នុងវេលាសម្រេច ការបរិភោគអាហារអ្នកទាំងអស់គ្នា ក៏ជញ្ជូនខ្ទុសមក លើកបុត្រប្រុសនោះដាក់លើជើងថ្ម ឬជាដោយគ្រឿងក្រអូបនិងផ្ការឈើហើយដុត ។ ទឹកភ្នែកសូម្បីត្រឹមតែមួយកំណាត់មិនបាន មានដល់នរណា ៗម្នាក់ឡើយ ។ ព្រោះជនទាំងអស់គ្នាជាអ្នកចម្រើនទ្រមរណសត្វតិទុកល្អហើយ ។ ដោយតេជៈនៃសីលរបស់គេទាំងនោះ ភពនៃសក្ក្ទេវរាជ ទើបសម្តែងអាការៈក្តៅឡើង

ស្តេចសក្ក្ទេវរាជ ទ្រង់ពិចារណាថា នរណាហ្ន៏ ! បំណងនឹងឱ្យ
យើងឃ្លាតចាកទីកន្លែងទ្រង់ជ្រាបថា ហានក្តៅ ព្រោះតេជៈនៃគុណ
របស់ជនទាំងនោះជាអ្នកមានចិត្តជ្រះថ្លា ទ្រង់ព្រះតម្រិះថា យើង
ទៅកាន់សំណាក់របស់ជនទាំងនោះ ធ្វើឱ្យគេបន្ទឹសីហនាថក្នុង
វេលាស្រេចអស់កាលបន្ទឹសីហនាថ ទើបធ្វើនិវេសន៍របស់ជន
ទាំងនោះឱ្យពេញដោយរតន: ៧ ប្រការហើយ ទើបត្រឡប់មក
រមែងសមគួរ ទើបយាងទៅកាន់ទីនោះយ៉ាងប្រញាប់ហើយប្រថាប់
ឈរ ក្បែរទីប៉ាតាត្រាស់ថា នែ ! ពួកលោកដ៏ចម្រើន ពួកលោក
កំពុងធ្វើអ្វីហ្ន៏ ? សក្ក្ទេវរាជត្រាស់ថា ពួកលោកមិនដុតមនុស្ស
ទេ តែសម្ងាប់ម្រ៉ីគមួយក្បាលហើយ ទើបអាង ។ ជនទាំងនោះ
ពោលថា នាយ រឿងនោះ មិនពិតទេ ពួកយើងកំពុងដុតមនុស្ស
ប៉ុណ្ណោះ ។ បើដូច្នោះគេគង់នឹងជាមនុស្សដែលមានពៀរនឹងពួក
លោក លំដាប់នោះព្រះពោធិសត្ត ទើបពោលនឹងសក្ក្ទេវរាជនោះ
ថា នាយ ! គេជាបុត្រដែលកើតពីទ្រូងរបស់ពួកយើង មិនមែន
ជាអ្នកមានពៀរនឹងគ្នាទេ ។ សក្ក្ទេវរាជត្រាស់ថា បើដូច្នោះ គេ
គង់នឹងជាបុត្រដែលមិនជាទីស្រឡាញ់របស់លោក ព្រះពោធិសត្ត
ពោលថា នាយ ! គេជាបុត្រជាទីស្រឡាញ់ក្រៃលែងរបស់ខ្ញុំ ។

សក្ក្ទេវរាជគ្រាស់ថា បើដូច្នោះព្រោះហេតុអ្វី ទើបមិនយំ ព្រះពោធិសត្វកាលនឹង ប្រាប់ដល់ហេតុដែលមិនយំ ទើបពោលគាថាទី១ ដូច្នេះថា ៖

ឧរគោ រតនំ ជិណ្ណំ ហិត្វា គច្ឆតិ សន្ត្ដនុំ
ឯវំ ជីរេ និព្ពោគេ ឃេតេ ការ្ដកតេ ជ្ជតិ
ទយ្ហមានោ ន ជានាតិ ញ្ជាតីនំ ២ រ្ដ្ដ
ត្ដ្ដ ២ ២ ២

អនញ្ញាតោ តតោ អាគា ជានុញ្ញោតាតតោ គតោ
យថា គតោ តថា គតោ តត្ត កា បរិទេវនា
ឧយ្ហមានោ ន ជានាតិ ញាតីនំ បរិទេវិតំ
តស្មាឯតំ ន សោចামិ គតោ សោតសរ្ស យាគតិ ។

កូន(របស់ខ្ញុំ) ដែលមកអំពីបរលោក ខ្ញុំក៏មិនបានអង្វរគេទៅអំពីលោកនេះ ក៏ខ្ញុំមិនអនុញ្ញាត គេមកយ៉ាងណាគេក៏ទៅយ៉ាងនោះ ខ្សឹកខ្សួលធ្វើអ្វី ព្រោះការដែលគេទៅនោះ រាងកាយកាលត្រូវគេដុត រមែងមិនដឹងនូវសេចក្តីខ្សឹក ខ្សួលនៃញាតិទាំងឡាយទេ ព្រោះហេតុនោះ ទើបខ្ញុំមិនសោកនឹងកូនទុ៏ះ គតិណាជារបស់គេ គេក៏ទៅកាន់គតិនោះ ។

ស្តេចសក្ក្ទេវរាជ បានសួរទៅកាន់នាងព្រាហ្មណីជា ប្អូនទៀត នាងពោលថា ៖

សចេ ភោ ទេ ការីសា អស្ស ត្ត ស្ស ្ត ្ត ្ត

តស្មាឯតំ សោចាមិ គតោ សោ តស្ស យាគតិ ។

បើខ្ញុំយំទួញ ខ្ញុំនឹងស្គាំងស្គម កាលខ្ញុំយំទួញនោះ នឹងមានផលដូចម្តេច សេចក្តីមិនត្រេកអរបស់ពួកញាតិមិត្តនិងសំឡាញ់របស់យើង គប្បីមានដោយក្រៃលែង រាងកាយ កាលត្រូវគេដុត រមែងមិនដឹងនូវសេចក្តីខ្វីកខ្ជួលនៃញាតិទាំងឡាយទេ ព្រោះហេតុនោះ ទើបខ្ញុំមិនសោកនឹងកូនទុ៎ះ គតិណាជារបស់គេ គេក៏ទៅកាន់គតិនោះ ។

ស្តេចសក្ក្ទេវរាជ បានសួរទៅកាន់ភរិយារបស់បុរសនោះ ទៀត នាងភរិយាពោលថា ៖

យថាបិ ធារកো ចន្ទំ គচ্ছন্តំ អনুរোধতি
ឯវំ សម្ឆធមេវេតំ យো បេតមনুសোচতি
ទយ្ហមানো ন ជানাতি ញাតীនំ ปริเธวิตំ
តស្មា ឯតំ ন សোচামি គតোសোតস্স យাগতি ។

ទារកយំទារព្រះច័ន្ទដែលកំពុងចរទៅយ៉ាងណា បុគ្គលដែលយំសោករកអ្នកស្លាប់ទៅកាន់លោកខាងមុខ នេះឯងជាគ្រឿង

ប្រៀបធៀបយ៉ាងនោះដែរ រាងកាយកាលត្រូវគេដុត រមែងមិនដឹងនូវសេចក្ដីខ្វល់ខ្វាយនៃញាតិទាំងឡាយទេ ព្រោះហេតុនោះ ទើបខ្ញុំមិនសោកនឹងកូនទ្ញុ:គតិណាជារបស់គេ គេក៏ទៅកាន់គតិនោះ ។

បន្ទាប់មកទៀត ស្ដេចសក្ដទេវរាជបានសួរទៅកាន់ទាសីទៀត នាងពោលថា ៖

យថាបិ ឧទកកុម្ភោ ភិន្នោ អប្ប:ដិសន្ធ:យោ
ឯវំ សម្ប:ទមេវេតំ យោ បេតមនុសោចតិ
ទយ្ហមានោ ន ជានាតិ ញាតីនំ ប:រិទេវិតំ
តស្មា ឯតំ ន សោចামិ គតោ សោតស្ស យាគតិ ។

ក្អមទឹកដែលបែកធ្លាយហើយ តវិញមិនជាប់យ៉ាងណា បុគ្គលសោកស្ដាយនឹងអ្នកស្លាប់ទៅកាន់លោកខាងមុខ នេះឯងជាគ្រឿងប្រៀបយ៉ាងនោះដែរ រាងកាយកាលត្រូវគេដុត រមែងមិនដឹងនូវសេចក្ដីខ្វល់ខ្វាយនៃញាតិទាំងឡាយទេ ព្រោះហេតុនោះ ទើបខ្ញុំមិនសោកនឹងម្ចាស់ទ្ញុ:គតិណាជារបស់គេ គេក៏ទៅកាន់គតិនោះ ។

ស្ដេចសក្ដទេវរាជ ទ្រង់ព្រះសណ្ដាប់នូវធម្មកថា របស់ជន

ទាំងអស់ហើយ ទ្រង់ជ្រះថ្លាទ្រង់ត្រាស់ថា ចាប់ផ្តើមអំពីថ្ងៃនេះទៅ ពួកអ្នកកុំធ្វើការងារដោយដៃខ្លួនឡើយ ខ្ញុំជាស្តេចសក្ក្ទេវរាជនឹងធ្វើរតនៈទាំង ៧ ប្រការ មិនមានប្រមាណទុកនៅក្នុងផ្ទះរបស់អ្នកទាំងឡាយ ពួកអ្នកចូរឱ្យទាន ចូររក្សាសីល ចូរទៅរក្សាឧបោសថ-សីលចុះដូច្នេះហើយ ទ្រង់ធ្វើដូច្នោះឯង ហើយស្តេចយាងទៅកាន់ទីស្ថានរបស់ព្រះអង្គដូចដើមវិញ ។ ជនទាំង ៥ នាក់នោះ ត្រឡប់បានទ្រព្យរាប់មិនអស់ ដែលមានសេចក្តីមិនសោកសៅជាមួលហេតុដោយប្រការដូច្នេះឯង ។

ឯព្រះសាស្តា លុះទ្រង់នាំយករឿងអតីតកាលមកនេះដើម្បីនឹងទ្រង់នាំចេញនូវសេចក្តីសោកសៅ របស់ឧបាសកម្នាក់ ដែលមាននូវកូនស្លាប់ចោលហើយ ទើបទ្រង់ត្រាស់ប្រកាសនូវសច្ចៈធម៌ទាំងឡាយក្នុងទីបញ្ចប់នៃព្រះធម្មទេសនា ឧបាសកនោះបន្ទយនូវសេចក្តីសោកសៅហើយបានសម្រេចនូវព្រះសោតាបត្តិផល ។

(ខុរគជាតកអដ្ឋកថាភាគ ៥៩ ទំព័រ ១២២)

មរណស្សតិ

[**អនុស្សតិកម្មដ្ឋាននិទ្ទេស**]

ក្នុងកាលឥឡូវនេះ ការសំដែងចេញនូវកិរិយាចំរើននូវ**មរណស្សតិ** បន្ទាប់អំពីទេវតានុស្សតិនេះ ដល់ហើយតាមលំដាប់ ។ ការចូលទៅផ្តាច់បង់នូវជីវិតិន្ទ្រិយ ដែលលោកវាប់បញ្ចូលហើយក្នុងភពមួយ ឈ្មោះថា **មរណៈ** ក្នុងពាក្យថា "**មរណស្សតិ**" នោះ ។ ចំណែកខាងមរណៈនេះណាពោលគឺកិរិយាចូលទៅផ្តាច់បង់នូវទុក្ខក្នុងវដ្ត នៃព្រះអរហន្តទាំងឡាយ**មរណស្សតិ**នោះ ឈ្មោះថា **សមុច្ឆេទមរណៈ** **មរណៈ**ណាពោលគឺកិរិយាបែកធ្លាយក្នុងខណៈនៃសង្ខារទាំងឡាយ **មរណៈ**នោះ ឈ្មោះថា **ខណិកមរណៈ** **មរណៈ**ណាក្នុងប្រយោគទាំងឡាយមានប្រយោគ ដូច្នេះជាដើមថា ឈើងាប់ លោហៈងាប់ **មរណៈ**នោះ ឈ្មោះថា **សម្មតិមរណៈ** ។ **មរណៈ** ៣ ប្រការនោះ គឺព្រះមានព្រះភាគ មិនទ្រង់ព្រះបំណងយកហើយក្នុងនិទ្ទេសនេះ ។ ចំណែកខាង**មរណៈ**នេះណា ដែលព្រះដ៏មានព្រះភាគទ្រង់ព្រះ

បំណងយកហើយ មរណៈនោះ មាន ២ ប្រការគឺ កាលមរណៈ ១ អកាលមរណៈ ១ ។

បណ្តាមរណៈទាំង ២ ប្រការនោះ កាលមរណៈ រមែងមានព្រោះកិរិយាអស់បុណ្យខ្លះ ព្រោះអស់អាយុខ្លះ ព្រោះអស់បុណ្យ និងអាយុទាំង ២ ខ្លះ, អកាលមរណៈ រមែងមានដោយអំណាចនៃកម្មដែលចូលទៅផ្តាច់បង់នូវកម្ម ។ ក៏បណ្តាមរណៈទាំង ២ នោះ មរណៈណា នាកាលកិរិយាដល់ព្រមនៃបច្ច័យជាគ្រឿង-តនូវអាយុ ទុកជាកាលមាន រមែងមានព្រោះភាវៈនៃកម្មដែលញ៉ាំងបដិសន្ធិឱ្យកើតជាកម្ម មានវិបាកឆ្ងិនដោយវិសេសតែប៉ុណ្ណោះ មរណៈនេះ ឈ្មោះថា មរណៈ ព្រោះអស់បុណ្យ ។ មរណៈណារមែងមានដោយអំណាចនៃកិរិយាអស់ ទៅនៃអាយុ មានប្រមាណត្រឹមតែមួយរយឆ្នាំ បីដូចជាអាយុរបស់បុរសក្នុងពេលសព្វថ្ងៃនេះ ព្រោះកិរិយាមិនមាននៃសម្ផត្តិ មានគតិ កាល និងអាហារជាដើម មរណៈនេះ ឈ្មោះថា មរណៈព្រោះអស់អាយុ ។ ចំណែកមរណៈណាមានដល់បុគ្គលទាំងឡាយអ្នកមានបច្ច័យជាគ្រឿង-ត(នូវអាយុ) ត្រូវកម្មដែលអាចក្នុងកិរិយាញ៉ាំង

សត្វឱ្យឃ្លាតចាកទីក្នុងខណៈនោះឯង ចូលទៅផ្ទាប់បង់ ដូចជាមនុស្សបាបទាំងឡាយ មានព្រះបាទទុសីមារ និងព្រះបាទកលាពុ ជាដើមក្តីដល់បុគ្គលទាំងឡាយអ្នកមានបច្ច័យ ជាគ្រឿង-ត (នូវអាយុ) ចូលទៅផ្ទាប់បង់ដោយសេចក្តីព្យាយាម មានកិរិយាប្រើនូវគ្រឿងសម្ត្រាជាដើមដោយអំណាចនៃកម្មដែលមានក្នុងកាលមុនក្តី មរណៈនេះ ឈ្មោះថា **អកាលមរណៈ** ។ មរណៈទាំងអស់នោះ គឺលោកសង្ត្រោះហើយ ដោយកិរិយាចូលទៅផ្ទាប់បង់នូវជីវិតិន្ទ្រិយ មានប្រការដូចបានពោលមកហើយ ។ សេចក្តីរលឹកនូវសេចក្តីស្លាប់ពោល គឺកិរិយាចូលទៅផ្ទាប់បង់នូវជីវិតិន្ទ្រិយដូចថ្លែងមកនេះ ឈ្មោះថា **មរណស្សតិ** ។

វិធីចំរើនមរណស្សតិ

ព្រះយោគាវចរ អ្នកមានបំណងដើម្បីចំរើនមរណស្សតិនោះ គប្បីទៅក្នុងទីស្ងាត់ គេចចេញចាកអារម្មណ៍ សម្ងំនៅទោះបីញ្ជាំងមនសិការឱ្យប្រព្រឹត្តទៅ ដោយឧបាយនៃប្រាជ្ញាថា សេចក្តីស្លាប់ នឹងមានជីវិតិន្ទ្រិយនឹងដាច់សូន្យ:ដូច្នេះក្តីឬថា **មរណៈ** ។ ដូច្នេះក្តី ។ ព្រោះថា កាលព្រះយោគាវចរញ្ជាំងមនសិការឱ្យប្រព្រឹត្ត

ទៅ ដោយឧបាយមិនជាប្រាជ្ញាសេចក្តីសោក រមែងកើតឡើងក្នុងកិរិយារលឹកវើយ ១ នូវសេចក្តីស្លាប់ នៃជនជាទីស្រឡាញ់ ដូចជាសេចក្តីសោកកើតឡើងក្នុងកិរិយារលឹកវើយ ១ នូវសេចក្តីស្លាប់នៃកូនជាទីស្រឡាញ់ របស់មាតាបង្កើតយ៉ាងដូច្នោះឯង, សេចក្តីបាមោជ្ជរមែងកើតឡើងក្នុងការរលឹកវើយ ១ នូវសេចក្តីស្លាប់នៃជនមិនជាទីស្រឡាញ់ ដូចជាសេចក្តីបាមោជ្ជកើតឡើងដល់ជនអ្នកមានពៀរទាំងឡាយក្នុងការរលឹកវើយ ១ នូវសេចក្តីស្លាប់នៃជនអ្នកមានពៀរទាំងឡាយដូច្នោះដែរ, សេចក្តីសង្វេគនឹងមិនកើតឡើងក្នុងកិរិយារលឹកវើយ ១ នូវសេចក្តីស្លាប់នៃជនជាកណ្តាលដូចជាសេចក្តីសង្វេគ មិនកើតឡើងដល់ជនអ្នកជុតនូវសាកសពក្នុងកិរិយាឃើញនូវសាកសពនៃខ្ទេចដូច្នោះ, សេចក្តីតក់ស្លុតរមែងកើតឡើងក្នុងកិរិយារលឹកវើយ ១ នូវសេចក្តីស្លាប់របស់ខ្លួន ដូចជាសេចក្តីតក់ស្លុតកើតឡើង ដល់ជនអ្នកប្រកបដោយជាតិជាអ្នកខ្លាច ព្រោះឃើញនូវពេជ្ឈឃាតដែលមានជាវង្ងាឡើង ១ ការកើតឡើងនៃសេចក្តីសោកជាដើម ទាំងអស់នេះ នោះរមែងមាន ដល់បុគ្គលអ្នកដែលនៅប្រាសចាកសតិសង្វេគ

និងញាណ ។ ព្រោះហេតុនោះ ព្រះយោគាវចរគប្បីរមិលមើលនូវ
សត្វដែលត្រូវគេសម្លាប់ និងសត្វដែលស្លាប់ហើយក្នុងទីនោះ ។
ហើយ ពិចារណានូវសេចក្តីស្លាប់របស់ពួកសត្វដែលស្លាប់ហើយ
មានសម្បត្តិដែលខ្លួនធ្លាប់ឃើញហើយ ហើយប្រកបនូវសតិសង្វេគ
និងញាណហើយញ៉ាំងមនសិការឱ្យប្រព្រឹត្តទៅ ដោយនំយជា
ដើមថា សេចក្តីស្លាប់នឹងមាន ដូច្នេះ ។ ព្រោះថា ព្រះយោគាវ-
ចរនឹងជាច់សូន្យ ដូច្នេះក្តី ឬថា មរណៈ ដូច្នេះក្តី ។ ព្រោះថា
កាលព្រះយោគាវចរ កាលញ៉ាំងមនសិការឱ្យប្រព្រឹត្តទៅយ៉ាងនេះ
ឈ្មោះថាឱ្យប្រព្រឹត្តទៅដោយឧបាយនៃប្រាជ្ញា អធិប្បាយថា ឱ្យ
ប្រព្រឹត្តទៅដោយឧបាយ ។ ពិតមែនហើយ កាលព្រះយោគាវចរ
ពួកខ្លះញ៉ាំងមនសិការឱ្យប្រព្រឹត្តទៅយ៉ាងដូច្នេះឯង នីវរណៈទាំង
ឡាយ រមែងស្ងប់រម្ងាប់សតិដែលមានមរណៈជាអារម្មណ៍ រមែង
តាំងនៅព្រម,កម្មដ្ឋានរមែងដល់នូវឧបចារៈ មែនពិត ។

ការរលឹកដោយអាការៈ ៨

តែថា **កម្មដ្ឋាន** មិនមានដល់ព្រះយោគាវចរណាដោយ
ហេតុមានប្រមាណប៉ុណ្ណោះ ព្រះយោគាវចរនោះ គប្បីរលឹក

រឿយ ៗនូវសេចក្ដីស្លាប់ ដោយអាការៈ ៨ នេះ គឺ ៖

- ១. ដោយកិរិយាប្រាកដដូចជាពេជ្ឈឃាត ១,
- ២. ដោយវិបត្តិនៃសម្បត្តិ ១,
- ៣. ដោយសេចក្ដីប្រៀបធៀប ១
- ៤. ដោយកាយជាសាធារណៈដល់សត្វច្រើន ១
- ៥. ដោយអាយុមានកម្លាំងខ្សោយ ១,
- ៦. ដោយជីវិតមិនមានគ្រឿងសម្គាល់ ១,
- ៧. ដោយកិរិយាកំណត់នូវកាល ១
- ៨. ដោយជីវិតមានខណៈតិច ១ ។

អធិប្បាយអាការៈទី ១

បណ្ដាបទទាំងនោះ បទថា **វធកប្បច្ចុបដ្ឋានតោ** មានសេចក្ដីថា ដោយកិរិយាប្រាកដដូចជាពេជ្ឈឃាត ។ អធិប្បាយថា ព្រះយោគាវចរគប្បីរលឹករឿយ ៗថា ពេជ្ឈឃាតគិតថា អញនឹងកាត់នូវក្បាលនៃបុរសនេះ ដូច្នេះហើយ ចាប់យកជាវមកផ្ទាប់ត្រង់ក ឈរនៅប្រាកដយ៉ាងណាមិញ, សូម្បីសេចក្ដីស្លាប់ក៏ប្រាកដយ៉ាងនោះដែរ ។

សួរថា ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះសេចក្តីស្លាប់មកហើយ ជាមួយនឹងជាតិផង ព្រោះវានាំយកនូវជីវិតទៅផង ។ ដូចជាផ្សិតក្បាលពស់នៅក្រពុំទូលយកអាចម៏ដីផុសឡើង យ៉ាងណាមិញ, សត្វទាំងឡាយតែងនាំយកនូវជរា និងមរណៈ ហើយកើតឡើងក៏យ៉ាងដូច្នោះដែរ ។ ពិតដូច្នោះមែន បដិសន្ធិចិត្តនៃសត្វទាំងឡាយនោះក៏រមែងដល់នូវសេចក្តីគ្រាំគ្រា ក្នុងលំដាប់នៃកិរិយាកើតឡើងនោះឯង ហើយបែកធ្លាយមួយអន្ទើដោយខន្ធដែលប្រកប ព្រមហើយទាំងឡាយ ដូចជាដុំថ្មដែលរមៀលធ្លាក់ចុះមកពីលើកំពូលភ្នំ(បែក) យ៉ាងនោះដែរ ។ ខណិកមរណៈមកហើយមួយអន្ទើដោយជាតិមុន យ៉ាងនេះឯង ។ តែសូម្បីមរណៈដែលលោកបំណងយកហើយក្នុងមរណសន្ទតិនេះក៏មកហើយមួយអន្ទើដោយជាតិ ព្រោះសត្វដែលកើតមកហើយ ត្រូវតែស្លាប់ មែនពិត ។ ព្រោះហេតុនោះសត្វនេះចាប់ដើមអំពីកាលដែលកើតមកហើយក៏មានមុខឆ្ពោះទៅកាន់សេចក្តីស្លាប់ទៅមិនត្រឡប់មកវិញឡើយ សូម្បីបន្ទិចបន្តិចប្រៀបបាននឹងព្រះអាទិត្យដែលរះឡើងហើយ មានមុខឆ្ពោះ

ទៅកាន់ទីតាំងនៅមិនបាន ចេះតែទៅមិនត្រឡប់វិញ អំពីទីដែលខ្លួនទៅហើយ ១ សូម្បីតែបន្ទិចបន្តិចពុំនោះសោត ប្រៀបដូចជាស្ទឹងតូចហូរធ្លាក់ចុះអំពីភ្នំមានខ្សែទឹកលៀន នាំយកនូវវត្ថុដែលគួរនាំយកទៅចេះតែហូរទៅចេះតែទ្រចាញ់ទៅតែម្យ៉ាង មិនត្រឡប់មកវិញទ្បើយ សូម្បីតែបន្ទិចបន្តិចក៏យ៉ាងនោះដែរ ។ ព្រោះហេតុនោះ ទើបព្រះអយោយកុមារពោធិសត្វពោលថា ៖

សត្វនៅក្នុងគភ៌អស់រាត្រីណាមួយជាដំបូង សត្វនោះប្រព្រឹត្តទៅ ដូចជាពពកដែលតាំងទ្បើង សត្វនោះចេះតែទៅរឿយ ១ មិនដែលត្រឡប់វិលវិញទេ ។

មួយទៀត កាលសត្វនោះ ចេះតែទៅយ៉ាងដូច្នេះ, សេចក្ដីស្លាប់ចេះតែមកជិតបង្ហើយ ដូចជាកិរិយាវ៉ីងស្ងួតនៃស្ទឹងតូចទាំងឡាយ ដែលត្រូវកំដៅថ្ងៃក្នុងគិម្ហរដូវផង ដូចជាការធ្លាក់ចុះនៃផ្លែឈើទាំងឡាយដែលមានទង ប្រព្រឹត្តទៅតាមរសនៃអាយុក្នុងពេលព្រឹកផង ដូចជាការបែកធ្លាយនៃកាជនៈដីទាំងឡាយដែលត្រូវគេវាយបំបែក ហើយដោយដំបងបួនជ្រុងផង និងដូចជាការកំចាត់បង់នូវតំណកខ្ចុំនៃទឹកសន្ទ្រើមទាំងឡាយ ដែលត្រូវស្ទ្ទ្ធ្ធ

អាទិត្យពាល់ត្រូវហើយផង ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគទ្រង់ត្រាស់គាថា ៣ ជាដំបូង និងព្រះពោធិសត្វពោលគាថាទី ៤ ថា ៖

ថ្ងៃនិងយប់ ចេះតែកន្ធងទៅ, ជីវិតចេះតែថយចុះមក, អាយុរបស់សត្វទាំងឡាយចេះតែអស់ទៅ ដូចជាទឹកស្ទឹងតូចចេះតែរីងស្ងួតទៅ យ៉ាងនោះឯង ។

ផ្លែឈើទាំងឡាយដែលទុំហើយ តែងភ័យអំពីការជ្រុះចុះចាកដើមអំពីព្រលឹម យ៉ាងណាមិញ, សត្វទាំងឡាយដែលកើតមកហើយ តែងភ័យអំពីសេចក្តីស្លាប់ អស់កាលជានិច្ច ក៏យ៉ាងដូច្នោះដែរ ។

ភាជន៍ដីដែលនាយស្មូនធ្នាំង ធ្វើហើយ ទោះតូចក្តី ធំក្តី ឆ្ងិនក្តី ឆៅក្តី សុទ្ធតែមានការបែកធ្លាយទៅជាទីបំផុតទាំងអស់យ៉ាងណាមិញ,ជីវិតរបស់សត្វទាំងឡាយ ក៏យ៉ាងដូច្នោះដែរ ។

ទឹកសន្សើមលើចុងស្មៅ តែងជ្រុះធ្លាក់ ព្រោះកិរិយារះឡើងនៃព្រះអាទិត្យ យ៉ាងណាមិញ, អាយុរបស់មនុស្សទាំងឡាយក៏យ៉ាងនោះដែរ, បពិត្រម៉ែ សូមម៉ែកុំហាមឃាត់ខ្ញុំឡើយ ។

មរណៈមកហើយជាមួយនឹងជាតិ ដូចជាពេជ្ឈឃាតមានជាវង្ការ្ទ្ធើងហើយយ៉ាងនេះ ។ មួយទៀត មរណៈនេះនោះចេះតែនាំយកនូវជីវិតទៅតែម្យ៉ាង លុះនាំយកទៅហើយ ក៏មិននាំយកមកវិញទ្ធើយ ដូចជាពេជ្ឈឃាតនោះ នាំយកជាវដាក់ត្រង់កដូច្នោះឯង ។ ព្រោះហេតុនោះសេចក្ដីស្លាប់ ឈ្មោះថា ជាធម្មជាតប្រាកដមែនពិត ដូចពេជ្ឈឃាតដែលមានជាវង្ការ្ទ្ធើងហើយ ព្រោះមរណៈមកហើយជាមួយនឹងជាតិផង ព្រោះនាំយកនូវជីវិតទៅជាមួយផងដូច្នេះឯង ។ ព្រះយោគាវចរគប្បីរលឹកសេចក្ដីស្លាប់រឿយ ៗដោយកិរិយាប្រាកដដូចជា ពេជ្ឈឃាត យ៉ាងដូច្នេះឯង ។

អធិប្បាយអាការៈទី ២

បទថា **សម្ផត្តិវិបត្តិតោ** អធិប្បាយថា ដរាបណាវិបត្តិមិនគ្រប សង្កត់នូវសម្ផត្តិនោះ ដរាបនោះ ឈ្មោះថា សម្ផត្តិក្នុងលោកនេះ តែងនៅល្អស្អាត ។ តែថា ឈ្មោះថា សម្ផត្តិដែលកន្ទងនូវវិបត្តិទៅបាននោះ ពិតជាមិនមានសោះទ្ធើយ ។ ពិតដូច្នោះមែន ៖

សូម្បីព្រះបាទអសោក ទ្រង់មានសេចក្តីសុខ ទ្រង់គ្រប់គ្រង សម្បត្តិលើផែនដីទាំងមូល ទ្រង់ចាយព្រះរាជទ្រព្យ ១០០ កោដិ ទ្រង់ដល់នូវភាពជាធំក្នុងទីបំផុតនៃវត្ថុត្រឹមតែផ្លែកន្ទួតព្រៃ ពាក់កណ្តាលប៉ុណ្ណោះ នាកាលបុណ្យមកដល់ក៏រិយាអស់ហើយ ដោយចំណងគឺរាងកាយនោះឯង ព្រះអង្គទ្រង់មានព្រះកក្រ្ពោះ ទៅរសេចក្តីស្លាប់ ទ្រង់ជួបនូវសេចក្តីសោកសៅ ។

មួយទៀត សេចក្តីមិនមានរោគទាំងអស់ មានព្យាធិ ជាទីបំផុត វ័យទាំងអស់ មានជរាជាទីបំផុត ជីវិតទាំងអស់ មានសេចក្តីស្លាប់ជាទីបំផុត លោកសន្ធិវាសទាំងអស់ហ្នឹងឯង គឺជាតិទៅតាមហើយ គឺជរាដេញតាមហើយ ត្រូវព្យាធិគ្របសង្កត់ហើយ ត្រូវមរណៈកំចាត់បង់ហើយ ។ ព្រោះហេតុដូច្នោះ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ៖

ភ្នំទាំងឡាយដែលជាថ្មតាន់ដ៏ធំ មានកំពូលខ្ពស់ទល់ នឹងអាកាស កាលបើបាក់ធ្លាក់មក ក៏គប្ជីរមៀលសង្កត់(នូវសត្វទាំងឡាយ) ដោយជុំវិញគ្រប់ទិសទាំងបួន យ៉ាងណាមិញ, ជរានិងមរណៈតែងគ្របសង្កត់នូវសត្វទាំងឡាយ ទោះជាកូរ្ត្រក្តី

ព្រាហ្មណ៍ក្តី អ្នកជំនួញក្តី អ្នកគ្រួក្តី ទោះជាមនុស្សចណ្ឌាលនិង អ្នកចោលសំរាមក្តី តែងញ៉ាំញ៉ីទាំងអស់ មិនមានលើកលែង សត្វណានីមួយសោះឡើយក៏យ៉ាងដូច្នោះឯង ។

ក្នុងជរា និងមរណៈនោះ ភូមិនៃពលដំរីមិនមានភូមិនៃ ពលរថមិនមាន ភូមិនៃពលថ្មើរជើង មិនមាន,មួយទៀត ឥត មានអ្នកណាមួយ អាចយកឈ្នះ (នូវជរានិងមរណៈនោះ) ដោយសង្គ្រាម ដោយអាចីកំចាំងឬដោយទ្រព្យបានឡើយ ។

វិបត្តិ គឺមរណៈ ជាទីបំផុតនៃសម្បត្តិគឺជីវិត ដូចពោលមក នេះ ។ ព្រះយោគាវចរ កាលកំណត់ភាវៈនៃជីវិត មានសេចក្តី ស្លាប់ជាទីបំផុតនោះ គប្បីរលឹកសេចក្តីស្លាប់រឿយ ៗដោយវិបត្តិ ចាកសម្បត្តិ ។

អធិប្បាយអាការៈទី ៣

បទថា **ឧបសំហារណាតោ** គឺដោយការប្រៀបធៀបខ្លួន ជា មួយនឹងពួកជនដទៃ ។ ក្នុងរឿងនោះព្រះយោគាវចរ គប្បីរលឹក សេចក្តីស្លាប់រឿយ ៗដោយការប្រៀបធៀបដោយអាការៈ៧ គឺ ៖

១.យសមហត្តតោ ដោយភាពជាអ្នកមានយសធំ,

ᡃ.បុញ្ញមហត្តតោ ដោយភាពជាអ្នកមានបុណ្យច្រើន,

ᡃ.ថាមមហត្តតោ ដោយភាពជាអ្នកមានកម្លាំងច្រើន,

ᡃ.ឥទ្ធិមហត្តតោ ដោយភាពជាអ្នកមានឫទ្ធិច្រើន,

ᡃ.បញ្ញាមហត្តតោ ដោយភាពជាអ្នកមានបញ្ញាច្រើន

ᡃ.បច្ចេកពុទ្ធតោ ដោយភាពជាព្រះបច្ចេកពុទ្ធ

ᡃ.សម្មាសម្ពុទ្ធមហត្តតោ ដោយភាពជាព្រះសម្មាសម្ពុទ្ធ

យសមហត្តតោ

សួរថា ព្រះយោគាវចរគប្បីរលឹកសេចក្តីស្លាប់ ដោយភាពជាអ្នកមានយសធំ យ៉ាងដូចម្តេច ? ។

ឆ្លើយថា ព្រះយោគាវចរ គប្បីរលឹកសេចក្តីស្លាប់ ដោយភាពជាអ្នកមានយសធំ យ៉ាងនេះជាមុនថា សេចក្តីស្លាប់នេះមិនមានសេចក្តីសង្ស័យឡើយ ធ្លាក់ចុះលើព្រះរាជាទាំងឡាយ ចាប់ផ្តើមអំពីស្តេចទ្រង់ព្រះនាមមហាសម្មត: ស្តេចទ្រង់ព្រះនាមមន្ធាតុ ស្តេចទ្រង់ព្រះនាមមហាសុទស្សន: ស្តេចទ្រង់ព្រះនាមនេមិ អ្នកមានយសធំមានបរិវារច្រើន មានទ្រព្យនិងមានពាហន:ច្រើនចាំ

បាច់ពោលទៅថ្វីសេចក្តីស្លាប់ទីងមិន ធ្លាក់មកលើខ្លួនអញ ។

អ្នកមានយសធំទាំងឡាយ មានស្តេចទ្រង់ព្រះនាមមហា-សម្មតៈជាដើម ជាស្តេចប្រសើរ អម្បាលយ៉ាងស្តេចទាំងនោះ គង់ដល់ហើយនូវអំណាចនៃមច្ចុ ចាំបាច់ពោលទៅថ្វី ក្នុងបុគ្គលទាំងឡាយ ប្រាកដដូចជាអញ ដូច្នេះ ។

បុញ្ញមហត្តតោ

សួរថា ព្រះយោគាវចរ គប្បីរលឹកសេចក្តីស្លាប់ ដោយភាពជាអ្នកមានបុណ្យច្រើន យ៉ាងដូចម្តេច ?

ឆ្លើយថា ព្រះយោគាវចរ គប្បីរលឹកសេចក្តីស្លាប់ ដោយភាពជាអ្នកមានបុណ្យច្រើន យ៉ាងដូច្នេះថា ៖

សេដ្ឋីទាំងឡាយនេះ គឺសេដ្ឋីឈ្មោះជោតិយៈ ឈ្មោះជដិលៈ ឈ្មោះឧគ្ត ឈ្មោះមេណ្ឌកៈ ពុំនោះសោត សេដ្ឋី ឈ្មោះបុណ្ណៈ និងជនទាំងឡាយឯទៀត ដែលសុទ្ធតែល្បី ១ថា ជាអ្នកមានបុណ្យដ៏ច្រើន ក្នុងលោកអ្នកទាំងអស់នោះ សុទ្ធតែដល់ហើយនូវសេចក្តីស្លាប់ ចាំបាច់ពោលទៅថ្វីក្នុងបុគ្គលទាំងឡាយ ប្រាកដដូចជាអញ ដូច្នេះ ។

ចាមមហាត្តគោ

សួរថា ព្រះយោគាវចរ គប្បីរលឹកសេចក្តីស្លាប់ ដោយ ភាពជាអ្នកមានកម្លាំងច្រើន យ៉ាងដូចម្តេច ?

ឆ្លើយថា ព្រះយោគាវចរគប្បីរលឹកសេចក្តីស្លាប់ ដោយ ភាពជាអ្នកមានកម្លាំងច្រើន យ៉ាងដូច្នេះថា ៖

ព្រះវាសុទេព ព្រះពលទេព ព្រះភីមសេន: ព្រះយុដ្ឋិល: សូម្បីហនុ: អ្នកចំបាប់ធំ ៗ ដល់ហើយនូវអំណាចនៃសេចក្តីស្លាប់ អ្នកទាំងនោះឯងដែលសុទ្ធតែជាអ្នកល្ប្ី ៗដល់ហើយនូវ ភាពជាអ្នកមានកម្លាំងក្នុងលោកយ៉ាងនេះ ដល់ហើយនូវសេចក្តីស្លាប់ ចាំបាច់ពោលទៅថ្ម ក្នុងបុគ្គលប្រាកដដូចអញ ដូច្នេះ ។

ឥទ្ធិមហាត្តគោ

សួរថា ព្រះយោគាវចរ គប្បីរលឹកសេចក្តីស្លាប់ ដោយ ភាពជាអ្នកមានឫទ្ធិច្រើន យ៉ាងដូចម្តេច ?

ឆ្លើយថា ព្រះយោគាវចរ គប្បីរលឹកសេចក្តីស្លាប់ដោយ ភាពជាអ្នកមានឫទ្ធិច្រើន យ៉ាងដូច្នេះថា ៖

ព្រះអគ្គសាវ័ក ទី ២ ណាជាអ្នកប្រសើរជាង បុគ្គលអ្នក

មាន ឫទ្ធិទាំងឡាយ កាលញ៉ាំងវេជយន្តប្រាសាទ មិនឱ្យកម្រើក ដោយត្រឹមតែចុងមេជើង ព្រះអគ្គសាវ័កទី ២ នោះ គង់ចូលទៅ កាន់មាត់នៃមច្ចុ ដែលគួរឱ្យព្រឺខ្លាច មួយអន្ទើដោយអ្នកមានឫទ្ធិ ទាំងឡាយ ដូចជាម្រ៉ីគ ចូលទៅកាន់មាត់នៃសីហៈចាំបាច់ពោល ទៅថ្វីក្នុងបុគ្គលទាំងឡាយ ប្រាកដដូចជាអញ ដូច្នេះ ។

បញ្ញាមហត្ត្ថោ

សួរថា ព្រះយោគាវចរ គប្បីរលឹកសេចក្តីស្ងាប់ ដោយ ភាពជាអ្នកមានប្រាជ្ញាច្រើន យ៉ាងដូចម្តេច ?

ឆ្លើយថា ព្រះយោគាវចរ គប្បីរលឹកសេចក្តីស្ងាប់ដោយ ភាពជាអ្នកមានប្រាជ្ញាច្រើន យ៉ាងដូច្នេះថា ៖

លើកលែងតែព្រះលោកនាថចេញ សត្វទាំងឡាយណា ដទៃទៀត ដែលមានសត្វទាំងឡាយនោះមិនដល់នូវចំណិតទី១៦ ដែលគេចែកហើយអស់ថាន:១៦ដង នៃបញ្ញារបស់ព្រះសារីបុត្រ, ព្រះអគ្គសាវ័កទី ១ ឈ្មោះថា ជាអ្នកមានបញ្ញាច្រើនយ៉ាងនេះ ដល់ហើយនូវអំណាចនៃសេចក្តីស្ងាប់ ចាំបាច់ពោលទៅថ្វីក្នុង បុគ្គលទាំងឡាយ ប្រាកដដូចជាអញ ដូច្នេះ ។

បច្ចេកពុទ្ធគោ

សួរថា ព្រះយោគាវចរ គប្បីរលឹកសេចក្តីស្លាប់ ដោយភាពជាព្រះបច្ចេកពុទ្ធ យ៉ាងដូចម្តេច ?

ឆ្លើយថា ព្រះយោគាវចរគប្បីរលឹកសេចក្តីស្លាប់ ដោយភាពជាព្រះបច្ចេកពុទ្ធ យ៉ាងដូច្នេះថា ៖

សូម្បីពុទ្ធបុគ្គលទាំងឡាយនោះណា ធ្វើនូវកិរិយាញ៉ាំញ៉ីសត្រូវ គឺកិលេសទាំងពួង គឺញាណ និងវិរិយៈរបស់ខ្លួន បានដល់នូវបច្ចេកសម្ពោធិ ជាព្រះសយម្ភូ ដូចជាកុយរមាស, សូម្បីពុទ្ធបុគ្គលទាំងនោះក៏មិនរួចផុតហើយអំពីសេចក្តីស្លាប់ ។

➲. ចុះយើងនឹងរួចផុតអំពីទីណាបាន ។

ព្រះមហេសីទាំងឡាយឯណា អាស្រ័យនូវនិមិត្តនោះ. ពិចារណាដល់ហើយនូវកិរិយាអស់ទៅនៃអាសវៈដោយតេជៈនៃញាណជាព្រះសយម្ភូ ប្រៀបដូចជាកុយរមាស ព្រោះកិរិយាត្រាច់ទៅនិងនៅតែម្នាក់ឯង, សូម្បីព្រះមហេសីទាំងឡាយនោះក៏កន្ងងនូវមច្ចុពុំបានឡើយចាំបាច់ពោលទៅថ្ងៃក្នុងបុគ្គលទាំងឡាយ ប្រាកដដូចជាអញ ដូច្នេះ ។

សម្ជាសម្ពុទ្ធគោ

សួរថា ព្រះយោគាវចរគប្បីរលឹកសេចក្តីស្ងាប់ ដោយ
ភាពជាព្រះសម្ជាសម្ពុទ្ធ យ៉ាងដូចម្តេច ?

ឆ្លើយថា ព្រះយោគាវចរ គប្បីរលឹកសេចក្តីស្ងាប់ដោយ
ភាពជាព្រះសម្ជាសម្ពុទ្ធយ៉ាងដូច្នេះថា ៖

សូម្បីព្រះមានព្រះភាគនោះណា មានព្រះរូបកាយវិចិត្ર
ដោយមហាបុរិសលក្ខណៈ ៣២ ប្រការ ប្រដាប់ហើយ ដោយ
អនុព្យញ្ជនៈ ៨០ មានព្រះធម្មកាយសំរេចហើយ ដោយគុណ-
រតនៈ មានសីលក្ខន្ធដ៏បរិសុទ្ធស្អាត ដោយអាការៈទាំងពួងជាដើម
ដល់ហើយនូវត្រើយនៃភាពជាអ្នកមានយសធំ ភាពជាអ្នកមាន
បុណ្យច្រើន ភាពជាអ្នកមានកម្លាំងច្រើន ភាពជាអ្នកមានឥទ្ធិច្រើន
ទ្ធិងភាពជាអ្នកមានបញ្ញាច្រើន មិនមានបុគ្គលស្មើ ស្មើដោយ
បុគ្គលមិនមានបុគ្គលស្មើ មិនមានបុគ្គលប្រៀប មានបុគ្គលប្រៀប
មិនមាន ជាព្រះអរហន្តត្រាស់ដឹងដោយប្រពៃ សូម្បីព្រះមានព្រះ
ភាគអង្គនោះ ទ្រង់ស្ងប់រម្ងាប់ហើយដោយឋានៈ ដោយកិរិយា

ធ្លាក់ចុះនៃតំណក់ទឹកភ្លៀង គឺមរណៈប្រៀបដូចជា គំនរភ្លើងដ៏ធំ រលត់ដោយកំរិយាធ្លាក់ចុះនៃគ្រាប់ភ្លៀងគឺទឹក ។

ធម្មតាសេចក្តីស្លាប់នោះណា ផ្សាយអំណាចមកដល់ ព្រះមហេសី អ្នកមានអានុភាពច្រើនយ៉ាងនេះ ដោយមិនមាន សេចក្តីខ្ជាច ដោយមិនមានសេចក្តីខ្ជាសឡើយ សេចក្តីស្លាប់នេះ នោះ ដែលមិនមានសេចក្តីខ្ជាស មិនមានកោតញញើតញ្ញាំញ្ញី នូវសត្វទាំងអស់ទីងមិនមកគ្របសង្កត់នូវសត្វប្រាកដដូចជា អញដូចម្តេចបាន ដូច្នេះ ។

កាលព្រះយោគាវចរនោះ ប្រៀបធៀបខ្លួន មួយអន្ទើ ដោយជនទាំងឡាយដទៃ ដែលបរិបូរដោយភាពជាធំ មានភាព ជាអ្នកមានយសធំជាដើម ដោយភាពជាអ្នកមានមរណៈស្មើគ្នា ដូច្នេះហើយរលឹកវ៉ៃយ ១ថា សេចក្តីស្លាប់ទីងមានដល់អញដែរ ដូចមានដល់ពួកសត្វវិសេសទាំងឡាយនោះ ១ដូច្នេះហើយកម្មដ្ឋាន ទីងដល់ឧបចារៈពិត ។ ព្រះយោគាវចរគប្បីរលឹកសេចក្តីស្លាប់ ដោយការប្រៀបធៀបយ៉ាងនេះ ។

អធិប្បាយអាការៈទី ៤

បទថា *កាយពហុសាធារណតោ* *សេចក្ដីថា* *ទូទៅដល់*
សត្វច្រើន *គឺទូទៅដល់ហ្វូងដង្កូវទាំងឡាយ ៨០ ពួក* *ដោយពិត* ។
បណ្ដាហ្វូងដង្កូវទាំងនោះ *ដង្កូវដែលអាស្រ័យនូវសម្ផ្ការស្ស្ងកថ្ងៃ*
តែងស៊ីនូវស្ស្ងក *សម្ផ្ការថ្ងៃដែលអាស្រ័យនូវស្ស្ងក* *តែងទំពា*
ស៊ីនូវស្ស្ងកដែលអាស្រ័យនូវសាច់ *តែងទំពាស៊ីនូវសាច់ដែល*
អាស្រ័យនូវសរសៃ *តែងទំពាស៊ីនូវសរសៃដែលអាស្រ័យនូវឆ្អឹង*
តែងទំពាស៊ីនូវឆ្អឹងដែលអាស្រ័យនូវក្នុងឆ្អឹង *តែងទំពាស៊ីនូវនូវក្នុង*
ឆ្អឹងរាកើតចាស់ស្ងាប់ *បន្ទោបង់ខ្ចោ:* *និងបស្សាវ:ជាក់ក្នុងសរីរ:*
ប្រទេសនោះឯង ។ *ក៏រាងកាយជាផ្ទះសំរាប់កើតជាមន្ទីរពេទ្យ*
ជាសាកសពជាព្រៃស្មសានជាបង្គន់ *និងជាស្នូកសំរាប់* *បន្ទោបង់*
បស្សាវ:នៃហ្វូងដង្កូវទាំងឡាយនោះរាងកាយនេះនោះ *រមែង*
ដល់នូវសេចក្ដីស្ងាប់ *ដោយកិរិយាកំរើកនៃហ្វូងដង្កូវទាំងឡាយ*
នោះឯង ។

មួយទៀត *កាយនេះ* *ជាទូទៅដល់ហ្វូងដង្កូវទាំងឡាយ*

៨០ ហ្ន៎ងយ៉ាងណាមិញ, (កាយនេះ)ក៏ជាទូទៅដល់បច្ច័យទាំងឡាយនៃសេចក្ដីស្លាប់ដែលប្រព្រឹត្ដទៅឲ្ជជ៏ខាងក្នុងហ្ន៎ងឯង បានដល់ភេគច្រើនរយជំពូក ដែលមានក្នុងខាងក្រៅ គឺសត្វមានពិសទាំងឡាយមានពស់ទ៎ងខ្ជយជាដើម ក៏យ៉ាងដូច្នោះដែរ ។ ប្រៀបដូចជាគ្រឿងប្រហារទាំងឡាយ មានកូនសរ លំពែង ផ្ទាប់ទ៎ងជ្ជុំជ្ជ ជាដើម ដែលមកហើយ អំពីទិសទាំងពួង រមែងធ្លាក់ចុះក្នុងវ៎ងជ្ជ គ្រឿងកំណត់ដែលគេតម្ពស់ទុកហើយ លើផ្ជូវធ៎ងបែកជាបួនយ៉ាងណា, ឧបទ្រពទាំងពួងទាំងឡាយ ក៏ធ្លាក់ចុះលើកាយ ក៏យ៉ាងដូច្នោះដែរ ។ កាយនេះនោះរមែងដល់នូវសេចក្ដីស្លាប់ ដោយកិរិយាធ្លាក់ចុះនៃឧបទ្រព្យទាំងឡាយនោះមែនពិត ។

ព្រោះហេតុនោះ បានជាព្រះមានព្រះភាគ ទ្រ៎ងត្រាស់ថា ម្ជាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កាលបើថ្ងៃកន្ទ៎ងទៅហើយ យប់មកដល់វ៎ញ តែងពិចារណាដូច្នេះថា ហេតុនៃសេចក្ដីស្លាប់របស់អាត្ម៎អញ មានច្រើនណាស់តើ (ដូចជា)ពស់ចឹកអាត្ម៎អញក្ដី ខ្ជយទ៎ចអាត្ម៎អញក្ដី ក្អែបវ៎ាអាត្ម៎អញក្ដី អាត្ម៎អញ ន៎ងស្លាប់ អន្ដ្ជាយនោះ ន៎ងមានដល់អាត្ម៎អញ ព្រោះហេតុតែ

ពស់ចឹកជាដើមនោះ អាត្មាអញភ្ជាត់ជួលក្តី ភត្តដែលអាត្មាអញ
បរិភោគហើយហាល់ក្តីប្រមាត់របស់អាត្មាអញកំរើកក្តី ស្លេស្មរបស់
អាត្មាអញកម្រើកក្តី កងខ្យល់ដូចសស្ត្រាវុធរបស់អាត្មាអញកម្រើកក្តី
ពួកមនុស្សព្យាយាមសម្លាប់អាត្មាអញក្តី ពួកអមនុស្សព្យាយាម
សម្លាប់អាត្មាអញក្តី អាត្មាអញនឹងស្លាប់ អន្តរាយនោះនឹង
មានដល់អាត្មាអញ ព្រោះហេតុតែ ភ្ជាត់ជួលជាដើមនោះ ។

ព្រះយោគាវចរ គប្បីរលឹកសេចក្តីស្លាប់រឿយ ៗ ដោយ
កាយជាទូទៅ ដល់សត្វនិងបច្ច័យនៃសេចក្តីស្លាប់ច្រើនប្រការ
យ៉ាងដូច្នេះឯង ។

អធិប្បាយអាការៈទី ៥

បទថា អាយុទុព្ពលតោ សេចក្តីថា ធម្មតាអាយុនុ៎ះមិន
មានកំឡាំង មានកំឡាំងខ្សោយ ។ ពិតដូច្នោះមែន ជីវិតរបស់សត្ត
ទាំងឡាយ ជាប់ទាក់ទងដោយខ្យល់ដកដង្ហើមចូលចេញ ១ ជាប់
ទាក់ទងដោយឥរិយាបថ ១ ជាប់ទាក់ទងដោយត្រជាក់ក្តៅ ១ ជាប់
ទាក់ទងដោយមហាភូតរូប ១ ជាប់ទាក់ទងដោយអាហារ ១ ។

ជីវិតនេះនោះ កាលបាននូវភាពប្រព្រឹត្តិទៅស្មើនៃខ្យល់ដកដង្ហើមចូល និងខ្យល់ដកដង្ហើមចេញហ្នឹងឯង ទើបប្រព្រឹត្តទៅបាន ។ ក៏ប៉ុន្តែកាលបើខ្យល់ក្នុងច្រមុះដែលចេញទៅខាងក្រៅហើយ មិនចូលមកខាងក្នុងវិញក្តី កាលបើខ្យល់ដែលចូលទៅហើយមិនចេញមកវិញក្តី បុគ្គលឈ្មោះថា ស្លាប់ហើយ ។

មួយទៀត **ជីវិតនេះ** កាលបាននូវភាពនៃកិរិយាប្រព្រឹត្តិទៅស្មើនៃឥរិយាបថទាំងឡាយបួនហ្នឹងឯង ទើបប្រព្រឹត្តទៅបាន ប៉ុន្តែព្រោះភាវៈនៃឥរិយាបថណាមួយ ១ (ប្រព្រឹត្តទៅ)ហួសប្រមាណអាយុសង្ខារ ទើបដាច់សូន្យ ។

មួយទៀត ជីវិតនេះ កាលបាននូវភាពនៃកិរិយាប្រព្រឹត្តិទៅស្មើនៃត្រជាក់ និងក្តៅទាំងឡាយហ្នឹងឯង ទើបប្រព្រឹត្តទៅបាន ប៉ុន្តែកាលបើបុគ្គលត្រូវត្រជាក់ក្រៃពេកក្តី ក្តៅក្រៃពេកក្តី គ្រប សង្កត់ហើយ រមែងវិនាស ។

មួយទៀត ជីវិតនេះ កាលបាននូវភាពនៃកិរិយាប្រព្រឹត្តិទៅស្មើនៃមហាភូតរូបទាំងឡាយហ្នឹងឯង ទើបប្រព្រឹត្តទៅបាន ប៉ុន្តែព្រោះបណ្តាបឋវីធាតុ ឬបណ្តាធាតុទាំងឡាយ មានអាបោ-

ធាតុជាដើម ធាតុណាមួយកម្រើក បុគ្គលសូម្បីបរិបូរហើយ ដោយកំឡាំង ក៏ជាអ្នកមានកាយរឹងក្រញ្ជ៉ង់ខ្លះ មានកាយរលួយ ស្ងួយសៅហ្មង ដោយអំណាចនៃរោគមានរោគធ្លាក់ឈាមជាដើមខ្លះ មានសេចក្ដីក្ដៅក្រហាយដ៏ធំគ្របសង្កត់ខ្លះ ជាអ្នកមានតំណនិងចំណងជាច់ខ្លះ រមែងដល់នូវការអស់ទៅនៃជីវិត ។

មួយវិញទៀត កាលបើបុគ្គលបាននូវកវឬង្ហ្គ្រាវហារក្នុងកាលដ៏សមគួរប៉ុណ្ណោះជីវិតទើបប្រព្រឹត្ដទៅបានប៉ុន្ដែកាលបើមិនបាននូវអាហារវាក៏ដល់នូវកិរិយាអស់ទៅតែម្ដងយ៉ាងនេះឯង ។

ព្រះយោគាវចរ គប្បីរលឹកសេចក្ដីស្ងាប់រឿយ ៗ ដោយអាយុមានកំឡាំងខ្សោយ ដូចបានរៀបរាប់មកនេះឯង ។

អធិប្បាយអាការៈទី ៦

បទថា អនិមិត្ដតោ គឺដោយមិនមានកំណត់ សេចក្ដីថា ដោយមិនមាននៃការកំណត់ ។ មែនពិត ៖

ធម៌ទាំងឆ្លាយ ៥ នេះ គឺជីវិត ១ ព្យាធិ ១ កាល ១ ក្នុងសំរាប់ដាក់ចុះនូវរាងកាយ១គតិ១ របស់សត្វទាំងឆ្លាយ

ក្នុងជីវលោកមិនមាននិមិត្ត គឺអ្នកណាមួយ ក៏ដឹងមិនបានដែរ ។

បណ្តាធម៌ទាំងឡាយ៥នោះឈ្មោះថា**ជីវិត**មិនមាន និមិត្ត ព្រោះមិនមានការកំណត់ថា សត្វគប្បីរស់នៅអស់កាល មានប្រមាណប៉ុណ្ណេះឯង មិនគប្បីរស់នៅខាងមុខ បន្ទាប់អំពីនេះទេ ដូច្នេះជាដើម ។

ជ្បិតថា សត្វទាំងឡាយ ស្លាប់ក្នុងកាលដែលខ្លួននៅជាកលល់ក៏មានក្នុងកាលនៅជាអម្ពុទ: ជាបេសិ ជាយន: នៅក្នុងគគ៌ិបាន ១ ខែ បាន ២ ខែ បាន ៣ ខែ បាន ៤ ខែ បាន ៥ ខែ និងបាន១០ខែក៏មានក្នុងសម័យដែលចេញចាកផ្ទៃក៏មាន បន្ទាប់ពីនោះមក ស្លាប់ខាងក្នុង ១០០ឆ្នាំក៏មាន ខាងក្រៅ(លើសអំពី) ១០០ឆ្នាំក៏មាន ដូចគ្នាដែរ ។

ឯព្យាធិ ឈ្មោះថា **មិនមាននិមិត្ត** ព្រោះមិនមានកិរិយាកំណត់ថា សត្វទាំងឡាយស្លាប់ដោយព្យាធិនេះតែប៉ុណ្ណោះ មិនស្លាប់ដោយព្យាធិដទៃទៀតទេ ។ ព្រោះថា សត្វទាំងឡាយ ស្លាប់ដោយរោគក្នុងភ្នែក ក៏មាន ដោយរោគណាមួយក្នុងចំណោមរោគទាំងឡាយមានរោគក្នុងត្រចៀកជាដើមក៏មាន ។

សូម្បីកាល ក៏ឈ្មោះថាមិនមាននិមិត្ត ព្រោះមិនមាន ការកំណត់យ៉ាងនេះថា សត្វគប្បីស្លាប់ក្នុងកាលនេះឯង មិនស្លាប់ក្នុងកាលដទៃទ្បើយ ។ ព្រោះថា សត្វទាំងឡាយស្លាប់ ក្នុងពេលព្រឹកក៏មាន ស្លាប់ក្នុងពេលណាមួយក្នុងចំណោម ពេលថ្ងៃត្រង់ជាដើមក៏មាន ។

ឯការដាក់ចុះនូវកាងកាយ ក៏ឈ្មោះថា មិនមាននិមិត្ត ព្រោះមិនមានការកំណត់យ៉ាងនេះថា កាលសត្វទាំងឡាយស្លាប់ទៅ ១ ១ ១

ចុះលើគោកក៏មាន ។

ឯគតិ ក៏ឈ្មោះថា មិនមាននិមិត្ត ព្រោះមិនមាន ការកំណត់ យ៉ាងនេះថា សត្វដែលច្យុតចាកគតិនេះ គប្បីកើតក្នុងគតិនេះ ។ ព្រោះថា សត្វទាំងឡាយដែលច្យុតចាកទេវលោកកើតក្នុងមនុស្សលោកក៏មាន ដែលច្យុតចាកមនុស្សលោក កើតក្នុងលោកណាមួយក្នុងចំណោមលោកទាំងឡាយ មានទេវលោកជាដើមក៏មាន ព្រោះហេតុនេះយ៉ាងដូច្នេះលោកតែងវិលវល់ទៅក្នុងគតិ ៥ ដូចជា គោដែលគេទឹមហើយ ក្នុងយន្តដើរវិលវល់ ដូច្នោះឯង ។ ព្រះយោគាវចរគប្បីរលឹកសេចក្តីស្លាប់រឿយ ៗ ដោយជីវិតមិននិមិត្ត យ៉ាងនេះឯង ។

បទថា **អទ្ធានបរិច្ឆេទោ** សេចក្តីថា ធម្មតាកាលនៃជីវិតរបស់មនុស្សទាំងឡាយ ក្នុងពេលឥឡូវនេះមានប្រមាណតិច, មនុស្សណារស់នៅអស់កាលដ៏យូរ មនុស្សនោះរស់នៅត្រឹមតែ ១០០ ឆ្នាំ រស់នៅជាង ១០០ ឆ្នាំនេះ ក៏មានខ្លះដែរ តែតិចទេ ។ ព្រោះហេតុនោះបានជាព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អាយុរបស់មនុស្សទាំងឡាយនេះតិចណាស់

សត្វដែលត្រូវទៅកាន់បរលោកគួរធ្វើកុសល គួរប្រព្រឹត្តព្រហ្ម-ចរិយធម៌ សត្វដែលកើតមកហើយឈ្មោះថា មិនស្លាប់មិនមានឡើយ,ម្នាលភិក្ខុទាំងឡាយមនុស្សណារស់នៅ អស់កាលដ៏យូរ មនុស្សនោះ រស់នៅបានត្រឹមតែ១០០ឆ្នាំ ឬថយចុះមកក៏ មានលើសជាងបន្ដិចក៏មាន ព្រោះហេតុដូច្នេះ ។

ឧគ្គហគាថា

អាយុរបស់មនុស្សទាំងឡាយ មានតិច សប្បុរសគួរខ្ចីមផ្ទើមអាយុនោះ បុគ្គលគួរទំប្រព្រឹត្ត(សុចរិត)ដូចបុគ្គលដែលភ្លើងកំពុងឆេះក្បាល (ព្រោះ)ដំណើរមិនមកនៃសេចក្ដីស្លាប់មិនមានទេ ដូច្នេះ ។

ព្រះមានព្រះភាគ ទ្រង់ត្រាស់ទៀតថា ម្នាលភិក្ខុទាំងឡាយ រឿងធ្លាប់មានមកហើយមានគ្រូឈ្មោះអរកៈដូច្នេះជាដើម ។

ព្រះសូត្រដែលប្រជាប់ដោយឧបមា ៧ ប្រការ ទាំងពួងបណ្ដិតគប្បី (នាំយកមកពណ៌នាឱ្យបានពិស្ដារ) ។

ព្រះអង្គទ្រង់ត្រាស់ព្រះសូត្រដទៃទៀតថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាចំរើនមរណសតិ ដោយសេចក្ដីត្រិះរិះយ៉ាងនេះ

ថា ធ្វើដូចម្តេចហ្ន៎ ឱ្យអាត្មាអញគប្បីរស់នៅអស់យប់ និងថ្ងៃអាត្មាអញ គប្បីធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅរបស់ព្រះមានព្រះភាគ អាត្មាអញគប្បីធ្វើកិច្ចការឱ្យបានច្រើន ដូច្នេះក្តី, ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាចំរើនមរណស្សតិ ដោយសេចក្តីត្រិះរិះយ៉ាងនេះថាធ្វើដូចម្តេចហ្ន៎ ឱ្យអាត្មាអញគប្បីរស់នៅអស់១ថ្ងៃអាត្មាអញគប្បីធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅ របស់ព្រះមានព្រះភាគ អាត្មាអញគប្បីធ្វើកិច្ចការឱ្យបានច្រើនដូច្នេះក្តី, ភិក្ខុណាចំរើនមរណ-ស្សតិ ដោយសេចក្តីត្រិះរិះយ៉ាងនេះថាធ្វើដូចម្តេចហ្ន៎ ឱ្យអាត្មាអញគប្បីរស់នៅត្រឹមឆាន់ចង្ហាន់បិណ្ឌបាតម្តង អាត្មាអញ គប្បីធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅរបស់ព្រះមានព្រះភាគ អាត្មាអញគប្បីធ្វើកិច្ចការឱ្យបានច្រើន ដូច្នេះក្តី, ភិក្ខុណាចំរើនមរណស្សតិ ដោយសេចក្តីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ ឱ្យអាត្មាអញគប្បីរស់នៅត្រឹមខណៈទំពាពំនួតបាយ ៤ ឬ ៥ ពំនួត លេបចូលទៅអាត្មាអញ គប្បីធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅរបស់ព្រះមានព្រះភាគ អាត្មាអញគប្បីធ្វើកិច្ចការឱ្យបានច្រើន ដូច្នេះក្តី, ម្នាលភិក្ខុទាំងឡាយ ភិក្ខុអម្បាលនេះហៅថា មានសេចក្តីប្រមាទនៅ

ទ្បើយ ចំរើនមរណសតិដើម្បីធ្វើឱ្យអស់ទៅនៃអាសវៈទាំងឡាយ យ៉ាងយ៉ាងដូច្នេះក្តី, ម្នាលភិក្ខុទាំងឡាយ ចំណែកភិក្ខុណាចំរើនមរណសតិដោយ សេចក្តីត្រិះរិះយ៉ាងនេះថា ធ្លាប់ដូចម្តេចហ្ន៎ ឱ្យអាត្មាអញគប្បីរស់នៅត្រឹមខណៈទំពាំនួតបាយ ១ ពំនួត លេបចូលទៅអាត្មាអញ គប្បីធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅរបស់ព្រះមានព្រះភាគ អាត្មាអញគប្បីធ្វើកិច្ចការឱ្យបានច្រើនដូច្នេះក្តី, ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាចំរើនមរណសតិ ដោយសេចក្តីត្រិះរិះយ៉ាងនេះថា ធ្លាប់ដូចម្តេចហ្ន៎ ឱ្យអាត្មាអញ គប្បីរស់នៅត្រឹមខណៈដែលដកដង្ហើមចូលហើយចេញ, ដកដង្ហើមចេញហើយចូល អាត្មាអញគប្បីធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅរបស់ព្រះមានព្រះភាគ អាត្មាអញគប្បីធ្វើកិច្ចការឱ្យបានច្រើន ដូច្នេះក្តី, ម្នាលភិក្ខុទាំងឡាយ ភិក្ខុអម្បាលនេះហៅថា មិនមានសេចក្តីប្រមាទនៅចំរើនមរណសតិ ដើម្បីឱ្យអស់ទៅនៃអាសវៈទាំងឡាយយ៉ាងឆប់រហ័ស ដូច្នេះឯង ។ កាលនៃជីវិតតិចណាស់ គឺបុគ្គលមិនគួរទុកចិត្ត ត្រឹមតែកិរិយាទំពាស៊ីនូវពំនួតបាយ ៤ ឬ ៥ ពំនួត យ៉ាងដូច្នេះឯង ។

ព្រះយោគាវចរ គប្បីរលឹកសេចក្តីស្ងាប់រៀយ ៗ ដោយជីវិតមានកាលកំណត់ យ៉ាងនេះឯង ។

អធិប្បាយអាការៈទី ៨

បទថា **ខណមត្តិ**ត្តោ សេចក្តីថា បើតាមបរមត្ថខណៈនៃជីវិតរបស់សត្វទាំងឡាយ តិចពេកណាស់ ត្រឹមតែការប្រព្រឹត្តិទៅនៃចិត្តតែមួយប៉ុណ្ណោះឯង ។ ប្រៀបដូចជាកង់រថសូម្បីកំពុងប្រព្រឹត្តទៅ តែងប្រព្រឹត្តទៅដោយប្រទេស នៃខ្នងកង់តែម្ខាងប៉ុណ្ណោះ សូម្បីកំពុងឋិតនៅក៏រមែងឋិតនៅ ដោយប្រទេសនៃខ្នងកង់ម្ខាងប៉ុណ្ណោះដែរយ៉ាងណាមិញ, ជីវិតរបស់សត្វទាំងឡាយប្រកបដោយខណៈនៃចិត្តតែមួយ ក៏យ៉ាងដូច្នោះដែរកាលបើចិត្តនោះរលត់ហើយ សត្វ គេសន្មតឱ្យឈ្មោះថា រលត់ហើយ ។ សមដូចជាព្រះមានព្រះភាគទ្រង់ត្រាស់ថា ក្នុងខណៈនៃចិត្តជាអតីត សត្វ ឈ្មោះថា រស់នៅហើយ មិនរស់នៅនឹងមិនរស់នៅ ក្នុងខណៈនៃចិត្តជាអនាគត សត្វមិនរស់នៅហើយ មិនកំពុងរស់នៅ(តែ)ឈ្មោះថានឹងរស់នៅក្នុងខណៈនៃចិត្ត ជាបច្ចុប្បន្នសត្វមិនរស់នៅហើយ(តែ)ឈ្មោះថាកំពុងរស់នៅនឹងមិនរស់នៅ ។

ជីវិត អត្តភាព សុខ និងទុក្ខ ទាំងអស់ប្រកបដោយខណៈចិត្តតែមួយ ព្រោះខណៈប្រព្រឹត្តទៅរហ័ស, ខន្ធទាំងឧ្យាយណារបស់បុគ្គលដែលស្លាប់ទៅក្តី រស់នៅក្តី រលត់ហើយក្នុងលោកនេះ ខន្ធទាំងអស់នោះ ក៏ជួចគ្នាទៅបជិសន្ធិទៀតមិនបាន, សត្វលោកមិនមែនកើតហើយ ដោយខន្ធជាអនាគត ដែលមិនទាន់កើតហើយ មិនមែនរស់នៅក្នុងបច្ចុប្បន្នទេ សត្វលោកស្លាប់ដោយការបែកឈ្លាយនៃចិត្ត(នេះគឺ) ជាបញ្ញត្តិប្រកបដោយបរមត្ត ដូច្នេះ ។

ព្រះយោគាវចរ គប្បីរលឹកសេចក្តីស្លាប់រឿយ ๆ ដោយជីវិតមានខណៈតិចតួច យ៉ាងដូច្នេះឯង ។

មរណសតិដ្ឌាន

កាលបើព្រះយោគាវចរ សូម្បីរលឹករឿយ ๆ ដោយអាការៈណាមួយក្នុងចំណោមអាការៈទាំង ៨ នេះ យ៉ាងដូច្នេះ ចិត្តរមែងបាននូវអាសេវនៈ (ការសេព)ដោយអំណាចនៃការធ្វើទុកក្នុងចិត្តរឿយ ๆ សតិដែលមានសេចក្តីស្លាប់ជាអារម្មណ៍ រមែងតាំងនៅមាំ នីវរណធម៌ទាំងឧ្យាយ រមែងស្ងប់រម្ងាប់អង្គឈានទាំង

ឡាយរមែងកើតជ្រាកជ ។ ប៉ុន្តែព្រោះអារម្មណ៍(របស់ឈាននេះ) ជាសភាវធម៌ផង ព្រោះអារម្មណ៍ជាធម្មជាត គួរសង្ខេគផង ឈានេះ ជាឈានមិនដល់នូវអប្បនា ដល់ត្រឹមតែឧបចារៈប៉ុណ្ណោះ ។ ចំណែកលោកុត្តរជ្ឌាន និងអារុប្ជជ្ឌានទី ២ និងទី ៤ ដល់អប្បនាសូម្បីក្នុងសភាវធម៌ ព្រោះជាភាវនាពិសេស ។ មែនពិត លោកុត្តរជ្ឌានដល់នូវអប្បនា ដោយអំណាចលំដាប់នៃវិសុទ្ធិ-ភាវនា ។ អារុប្ជជ្ឌានដល់អប្បនា ដោយអំណាចភាវនាដែលកន្ធងនូវអារម្មណ៍ ។ ព្រោះថា ក្នុងអារុប្ជជ្ឌាននោះ មានត្រឹមតែកិរិយាកន្ធងនូវអារម្មណ៍នៃឈាន ដែលដល់ហើយនូវអប្បនាប៉ុណ្ណោះ ។ ប៉ុន្តែក្នុងមរណាសន្ជតិនេះ វិសុទ្ធិភាវនានុក្រមៈ និងអារម្មណសមតិក្រមៈ ទាំងពីរនោះឯង មិនមាន ព្រោះហេតុនោះ ទើបជាឈានដល់ត្រឹមតែឧបចារៈប៉ុណ្ណោះ ។ ឈានេះនោះ ដល់នូវការរាប់ថា **មរណាសន្ជតិ** មែនពិត ព្រោះភាវៈនៃឈាននោះជាធម្មជាតកើតឡើងដោយកំឡាំងនៃការលឹកដល់សេចក្ដីស្លាប់ ។

អានិសង្សនៃការចំរើនមរណស្សតិ

ក៏ភិក្ខុដែលប្រកបរឿយ ១ នូវមរណស្សតិនេះ ជាអ្នកមិនប្រមាទជាប់ជានិច្ច បាននូវអនត្ថវិតិសញ្ញាក្នុងកពទាំងពួង លះបង់នូវសេចក្តីអាឡោះអាល័យក្នុងជីវិត ជាអ្នកតិះដៀលបាបជាអ្នកមិនច្រើនដោយការសន្សំជាអ្នកមានមន្ទិលគឺសេចក្តីកំណាញ់ក្នុងបរិក្ខារទាំងឡាយទៅប្រាសហើយ ។ សូម្បីអនិច្ចសញ្ញា ក៏ដល់នូវការស្ទាត់ជំនាញសំរាប់ភិក្ខុនោះ ។

មួយទៀត ទុក្ខ សញ្ញា និងអនត្តសញ្ញា រមែងប្រាកដ (ដល់ភិក្ខុនោះ) តាមលំអាននៃអនិច្ចសញ្ញានោះឯង ។ សត្វទាំងឡាយ ដែលមិនបានអប់រំអំពីសេចក្តីស្លាប់ក្នុងវេលា ជិតស្លាប់ រមែងដល់នូវសេចក្តីខ្លាច សេចក្តីតក់ស្លុត សេចក្តីវង្វេង ដូចមនុស្សដែលត្រូវម្រ៉ីគកាច យក្ខ ពស់ ចោរនិងពេជ្ឈឃាតគ្រប សង្កត់ហើយភ្លាម ១យ៉ាងណាមិញ, ភិក្ខុនោះ មិនដល់ថ្នាក់យ៉ាងនេះទេជាអ្នកមិនភ័យជាអ្នកមិនវង្វេងធ្វើមរណកាល ។ ប្រសិនបើភិក្ខុនោះមិនត្រេកអរនូវព្រះនិព្វានក្នុងបច្ចុប្បន្នហ្នឹងទេ លុះបែកធ្លាយរាងកាយ ស្លាប់ទៅជាអ្នកមានសុគតិនៅខាងមុខ ។ នេះជាកថាមុខ ដោយពិស្តារក្នុងមរណស្សតិ ។

ព្រោះហេតុនោះឯង បុគ្គលអ្នកមានប្រាជ្ញា គប្បីធ្វើនូវសេចក្តីមិនប្រមាទ ក្នុងមរណៈ ដែលមានអានុភាព ច្រើនយ៉ាងនេះ សព្វ ១ កាល ។

ចូរកុំភ្លេចខ្លួនរកធម៌អាចី

សង្ខារទាំងឡាយមិនទៀងទាត់ កើតហើយវិបត្តិវិនាសសូន្យ
កើតចាស់ឈឺស្លាប់ធម៌ទាំងបួន មានទៅគ្រប់ខ្លួនគ្រប់អាត្ម ។
គ្មានសត្វណាមួយនឹងចៀសផុត លុះដល់កំណត់ត្រូវមរណ
ព្រាត់ប្រាសគ្មានសល់សព្វសង្ខារ គ្រប់ជនជីវ៉ាទាំងអស់គ្ម ។
ចូរកុំភ្លេចខ្លួនរកធម៌អាចី ពឹងត្រៃរតនាចិត្តសទ្ធ
យកសីលសមាធិ ភាវនា ទីពឹងនេះជាសុខសាន្តអើយ ។

ហេតុនាំឱ្យកើតសេចក្តីស្រឡាញ់

ការស្រឡាញ់គ្នាទុកជាមាតាបិតាក្តី ជាស្វាមីភរិយាក្តី ជាពូ ជាមីង ជាបង ជាប្អូនប្រុសស្រីក្តី ជាមិត្តភក្តិក្តី ជាសម្លាញ់ក្តី ជាការរាប់អានគ្នាយ៉ាងស្និទ្ធស្នាល លួកលួ៉នជាមួយគ្នាក្តី ឬជាអ្នកមានអាធ្យាស្រ័យត្រូវគ្នាជាដើមក្តី ទាំងអស់នេះវាមិនមែនចេះតែប្រព្រឹត្តទៅបាននោះទេ ។ នៅក្នុងបឋមសមន្តបាសាទិកា

លោកបានមានសម្តែងអំពីរឿងនិគ្រោធសាមណេរ នឹងព្រះបាទ
ធម្មាសោកមហារាជ ។ និគ្រោធសាមណេរ មានបិតាឈ្មោះ
សុមនរាជកុមារ មាតាឈ្មោះសុមនាទេវី ដែលបិតាត្រូវជាបួន
របស់ព្រះបាទពិន្ទុសា កាលដែលព្រះបាទពិន្ទុសាមានវ័យជរា
ហើយទ្រង់ប្រឈួនធ្ងន់ ព្រះបាទអសោក បានគ្រប់គ្រងនគរទាំង
អស់ ហើយបានចាប់សុមនរាជកុមារទុក ។ ក្នុងថ្ងៃនោះឯង ព្រះ
ទេវីឈ្មោះសុមនា ជាភរិយារបស់សុមនរាជកុមារ ទ្រង់មានព្រះ
គភ៌ចាស់ហើយ ។ ព្រះនាងសុមនានោះ បានកៀសព្រះកាយ
ទៅកាន់ភូមិមនុស្សចណ្ឌាលមួយកន្លែងដែលនៅមិនឆ្ងាយ ពេល
នោះព្រះនាងបានស្តាប់សម្លេងរបស់ទេវតា ដែលអាស្រ័យនៅ
នឹងដើមនិគ្រោធមួយដើម ក្នុងទីមិនឆ្ងាយពីភូមិមនុស្សចណ្ឌាល
ទេវតានោះបាននិយាយឡើងថា បពិត្រព្រះនាងសុមនា ! សូម
ព្រះនាងស្តេចយាងមកផ្លូវនេះចុះ ព្រះនាងសុមនា ក៏បានយាង
ទៅតាមពាក្យរបស់ទេវតានោះ ។ គ្រានោះ ទេវតាបាននិម្មិត
សាលាមួយដោយអានុភាពរបស់ខ្លួន ហើយថ្វាយថា សូមព្រះ
នាង ចូរប្រថាប់នៅក្នុងសាលានេះចុះ ។ ព្រះទេវីនោះបានស្តេច

យាងចូលទៅក្នុងសាលានោះហើយ ។ ក្នុងថ្ងៃដែលព្រះនាងស្តេចយាងចូលទៅនោះ ក៏បានប្រសូតព្រះឱរសទៅ ។ ព្រោះហេតុតែព្រះឱរសនោះ ត្រូវទេវតាដែលស្ថិតនៅនឹងដើមនិគ្រោធរក្សាទុក ព្រះនាងក៏បានថ្វាយនាមថា **និគ្រោធ** ។ អ្នកភូមិចណ្ឌាលបានចាត់ទុកព្រះទេវីជួចជាធីតារបស់ខ្លួន តាំងពីដែលខ្លួនបានឃើញហើយ ទើបថែរក្សាព្រះនាងទុក ។ ព្រះនាងសុមនាបានរស់នៅក្នុងទីនោះអស់ ៧ ឆ្នាំ ។ ចំណែកនិគ្រោធកុមារក៏មានព្រះជន្ម ៧ ឆ្នាំដែរ ។

ថ្ងៃមួយ មានព្រះថេរៈមួយអង្គ ឈ្មោះមហាវុណាត្ថេរៈ ជាព្រះអរហន្ត បានឃើញសេចក្ដីដល់ព្រមនៃហេតុរបស់ទារក ទ្រង់គិតថា ឥឡូវនេះ ទារកមានព្រះជន្ម ៧ ឆ្នាំហើយ ។ ជាកាលសមគួរនឹងបួសបាន ហើយលោកក៏បានទូលព្រះរាជធីតាឱ្យទ្រង់ជ្រាប ហើយសូមឱ្យនិគ្រោធកុមារបួស ។ ក្នុងវេលាកោរសក់រួចនោះឯង ព្រះកុមារបានសម្រេចជាព្រះអរហន្តអស់អាសវៈកិលេសទៅ ។ ថ្ងៃមួយ និគ្រោធសាមណេរ បានជំរះព្រះកាយពីព្រឹក ធ្វើអាចារិយវត្តនឹងឧបជ្ឈាយវត្តរួចហើយ ក៏

បានកាន់ជាត្រៃនឹងចីវរ ដោយគិតថា អាត្មាអញនឹងនិមន្តទៅកាន់ផ្ទះរបស់មាតា ហើយក៏ចេញទៅ ។ ក៏ផ្ទះរបស់មាតានៅទិសទក្សិណ ត្រូវនិមន្តកាត់ព្រះនគរទៅកាន់ទិសបូរាណ ទើបដល់ ។ ក៏សម័យនោះ ព្រះបាទអសោកមហារាជ ទ្រង់ស្តេចចង្ក្រមនៅត្រង់សីហបញ្ជរ (លើប្រាសាទ) បែរព្រះភ័ក្ត្រទៅកាន់ទិសបូរាណ ។ ខណៈនោះឯង និគ្រោធសាមណេរ មានឥន្ទ្រិយសង្រ្ចម មានចិត្តសង្រ្ចម ក្រឡេកមើលត្រឹមតែមួយជួរនឹម និមន្តទៅដល់លានព្រះលាង ។ គ្រាព្រះអង្គទតព្រះនេត្រឃើញហើយ ទ្រង់បានត្រិះរិះថា មនុស្សទាំងអស់នេះ មានចិត្តរវើរវាយ មានចិត្តដូចជាម្រ៉ីគដែលរត់ទៅ, ចំណែកសាមណេរនេះ មិនមានចិត្តរវើរវាយឡើយ,កាលក្រឡេកមើល ការបែរមើល ការដាក់ ដៃ និងការឈានជើងរបស់លោកល្អណាស់ ។ លោកច្បាស់ ជាបានសម្រេចនូវលោកុត្តរធម៏ហើយ ដូច្នេះ ព្រមនឹងការទតព្រះនេត្រឃើញរបស់ព្រះរាជានោះឯង ព្រះហឫទ័យក៏ជ្រះថ្លាក្នុងនិគ្រោធសាមណេរ, **សេចក្ដីស្រឡាញ់ក៏បានកើតឡើង** ។

សួរថា ហេតុអ្វី ?

ឆ្លើយថា ព្រោះបានឮថា ក្នុងភពមុន ក្នុងវេលាធ្វើបុណ្យ

និគ្រោធសាមណេរនេះ **បានជាបង្ហ**ប្រុសរបស់ព្រះរាជា ។

សមពិត ដូចជាព្រះតម្រាស់របស់ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ថា ៖

បុព្ពេ ០ សន្ធិវាសេន បច្ចុប្បន្ន**ហិ**តេ**ន ០ វា**

ឯត**ន្តំ ជ**ាយ**តេ ០ ០ ០

ផ្លូវនៃសេចក្ដីមិនស្លាប់ ។

លើកវៀងនិគ្រោធសាមណេរ នឹងព្រះបាទអសោកមហា- រាជមកប៉ុណ្ណោះ សបញ្ជាក់ឱ្យឃើញថា ហេតុនាំឱ្យកើតសេចក្ដីស្រឡាញ់មាន ២ យ៉ាងនេះឯង មិនមែនចេះតែឃើញស្រឡាញ់ដោយគ្មានឧបនិស្សយ ជាមួយគ្នាពីមុននោះទេ ។

ឧលហវិវាទសូត្រ

នៅក្នុងបិដកលេខ ៥៤, ទំព័រ ២៩០ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ត្រាស់អំពី [**ហេតុកើតពីរបស់ជាទីស្រឡាញ់**] ដោយការឆ្លើយតបនឹងសំនួរបស់ព្រះពុទ្ធនិម្មិត្ត មានសេចក្ដីថា ៖

(**ព្រះពុទ្ធនិមិត្ត ត្រាស់សួរព្រះសម្ពុទ្ធថា បពិត្រព្រះអង្គ**) ការឈ្លោះការទាស់ទែងគ្នា ការវ្រ៉ែកវ្ជូល ការសោកស្តាយនឹងសេចក្ដីកំណាញ់ ការប្រកាន់ ការមើលងាយ នឹងការញុះញង់កើតមកពីណា កិលេសធម៏ទាំងនោះ បណ្ដាមកពីណាសូមព្រះអង្គសម្ដែងសេចក្ដីនោះឱ្យទាន ។

(**ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា**) ការឈ្លោះ ការទាស់ទែងគ្នា

ការខ្ជឹកខ្ជួល ការសោកស្តាយ នឹងសេចក្តីកំណាញ់ ការប្រកាន់ ការមើលងាយ នឹងកការញុះញង់ កើតមកអំពីរបស់ជាទីស្រ-ឡាញ់ ឯកិលេសធម៌ មានឈ្លោះនឹងការជជែកគ្នា(ជាដើម) ប្រកបក្នុងសេចក្តីកំណាញ់ កាលបើសេចក្តីទាស់ទែងគ្នាកើតឡើងហើយ ពាក្យញុះញង់ក៏កើតឡើងដែរ ។

(**ព្រះពុទ្ធនិមិត្តសួរថា**) សេចក្តីស្រឡាញ់ក្នុងលោក ឬលោភៈរបស់ពួកសត្វ ដែលត្រូវលោភៈគ្របសង្កត់ ត្រាច់រង្គាត់ទៅក្នុងលោកកើតមកអំពីអ្វី សេចក្តីប៉ុនប៉ងនឹងការសម្រេច(នៃសេចក្តីប៉ុនប៉ង) នឹងធម៌ដែលមានក្នុងបរលោករបស់សត្វ កើតមកអំពីអ្វី ។

(**ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា**) សេចក្តីស្រឡាញ់ក្នុងលោកឬលោភៈរបស់ពួកសត្វ ដែលត្រូវលោភៈគ្របសង្កត់ កើតមកអំពីឆន្ទៈ សេចក្តីប៉ុនប៉ងនឹងការសម្រេច(នៃសេចក្តីប៉ុនប៉ង)នឹងធម៌ដែលមានក្នុងបរលោករបស់សត្វ ក៏កើតមកអំពីឆន្ទៈដែរ ។

(**ព្រះពុទ្ធនិមិត្តសួរថា**) ឆន្ទៈក្នុងលោក កើតមកអំពីអ្វីមួយទៀត វិនិច្ឆ័យ(ការចូលចិត្តក្នុងតណ្ហានឹងទិដ្ឋិ) កើតមក

អំពីការក្រៀវក្រោធ ការនិយាយមោសា នឹងសេចក្តីសង្ស័យ ឬអកុសលធម៌ទាំងឡាយ ដែល(ប្រកបដោយការក្រៀវក្រោធ ជាដើម) តើព្រះសមណៈសម្តែងហើយថា កើតពីអ្វី ។

(**ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា**) អ្នកប្រាជ្ញទាំងឡាយ ក្នុងលោក បានសម្តែងហើយនូវអារម្មណ៍ណាថាជាទីត្រេកអរ នឹងមិនជាទីត្រេកអរ ឆន្ទៈតែងកើតឡើង ព្រោះអាស្រ័យអារម្មណ៍នោះ សត្វក្នុងលោកឃើញសេចក្តីវិនាសនឹងសេចក្តីចំរើន ក្នុងរូបទាំងឡាយ ទើបធ្វើនូវវិនិច្ឆ័យ(ក្នុងតណ្ហានឹងទិដ្ឋិ) ។ ការក្រៀវក្រោធ ការពោលពាក្យមោសា សេចក្តីសង្ស័យធម៌ទាំង ៣ នេះ ឯង កាលបើអារម្មណ៍ជាទីត្រេកអរនឹងមិនជាទីត្រេកអរទាំង ២ ប្រការនោះនៅមាន ទើបកើតមានឡើងបាន បុគ្គលអ្នកមានសេចក្តីសង្ស័យ គប្បីសិក្សាក្នុងគន្ថនៃការដឹង ឯធម៌ទាំងឡាយ ព្រះសមណៈសម្តែងហើយ ព្រោះដឹង ។

(**ព្រះពុទ្ធនិមិត្តសួរថា**) អារម្មណ៍ជាទីត្រេកអរនឹងមិនជាទីត្រេកអរកើតមកអំពីអ្វី កាលបើធ្វើមិនមាន ទើបអារម្មណ៍ទាំងនោះមិនមានដែរ អត្ថគឺសេចក្តីវិនាសនឹងសេចក្តីចំរើន(នៃអារម្មណ៍

ជាទីត្រេកអរនឹងមិនជាទីត្រេកអរ)ណា អត្តនោះ កើតមកអំពីធម៏ណា សូមព្រះអង្គសម្តែងប្រាប់ដល់ខ្ញុំឱ្យ១ាន ។

(**ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា**) អារម្មណ៍ជាទីត្រេកអរនឹងមិនជាទីត្រេកអរកើតមកអំពីផស្ស: កាលបើផស្ស:មិនមាន ទើបអារម្មណ៍ទាំងនោះមិនមាន អត្តគឺសេចក្តីវិនាស នឹងសេចក្តីចំរើន (នៃអារម្មណ៍ជាទីត្រេកអរនឹងមិនជាទីត្រេកអរ)ណា អត្តនោះកើតមកអំពីផស្ស:នេះ តថាគតសម្តែងប្រាប់ដល់អ្នក(ដូច្នេះ) ។

(**ព្រះពុទ្ធនិមិត្តសួរថា**) ចុះផស្ស:ក្នុងលោកកើតមកអំពីអ្វីមួយទៀតសេចក្តីហួងហែងកើតមកអំពី អ្វីកាលបើមិនមានសេចក្តីប្រកាន់ថា របស់អញ ១ ទើបមិនមាន កាលបើអ្វីមិនមានផស្ស:ទាំងឡាយ ទើបមិនពាល់ត្រូវ ។

(**ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា**) ផស្ស:(កើតឡើង) ព្រោះអាស្រ័យនាមនឹងរូប សេចក្តីហួងហែង កើតមកអំពីឥច្ឆា កាលឥច្ឆាមិនមាន សេចក្តីប្រកាន់ថា របស់អញ ១ក៏មិនមាន កាលបើរូបមិនមាន ផស្ស:ទាំងឡាយ ក៏មិនពាល់ត្រូវ ។

(**ព្រះពុទ្ធនិមិត្តសួរថា**) កាលបុគ្គលប្រតិបត្តិដូចម្តេច

ទើបរូបវិនាសទៅមួយទៀត រូបជាសុខ (រូបគួរប្រាថ្នា) នឹងរូបជាទុក្ខ (រូបដែលមិនជាទីប្រាថ្នា)វិនាសទៅវិញ ដោយប្រការដូចម្តេច សូមព្រះអង្គសម្តែងរូបដែលជាសុខនឹងជាទុក្ខនោះដល់ខ្ញុំ រូបដែលជាសុខ នឹងជាទុក្ខវិនាសទៅដោយហេតុណា ខ្ញុំដឹងនូវហេតុនោះ ខ្ញុំមានចិត្តត្រិះរិះដូច្នេះ ។

(**ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា**) បុគ្គលមិនមែនជាសញ្ញាសញ្ញី បុគ្គលមិនមែនជាវិសញ្ញាសញ្ញី បុគ្គលមិនមែនជាអសញ្ញី បុគ្គលមិនមែនជាវិភូតសញ្ញី កាលបុគ្គលប្រតិបត្តិយ៉ាងនេះ រូបទើបវិនាសបាន មានសញ្ញាជាហេតុ ។

(**ព្រះពុទ្ធនិមិត្តពោលថា**) ខ្ញុំបានសួរនូវធម៌ណា ព្រះអង្គក៏បានសម្តែងនូវធម៌នោះដល់ខ្ញុំរួចហើយ ខ្ញុំសូមសួរធម៌ផ្សេងទៀត សូមព្រះអង្គសម្តែងធម៌នោះដល់ខ្ញុំឱ្យទាន (បពិត្រព្រះអង្គ) ចុះសមណៈព្រាហ្មណ៍ ជាបណ្ឌិតពួកខ្លះ ក្នុងលោកនេះសម្តែងនូវសេចក្តីបរិសុទ្ធដ៏ប្រសើររបស់សត្វថា បំផុតត្រឹមប៉ុណ្ណោះឬ ឬក៏សម្តែងនូវសេចក្តីបរិសុទ្ធដទៃជាងអ្ករូបសមាបត្តិនេះទៅទៀត ។

(**ព្រះសម្ពុទ្ធត្រាស់តបថា**) ពួកសមណៈព្រាហ្មណ៍ ជា

បណ្ឌិតពួកខ្លះ សម្តែងនូវអ្ករបសមាបត្តិទាំងនោះថា ជាធម៌បរិសុទ្ធ ដ៏ប្រសើររបស់សត្វតែប៉ុណ្ណោះ បណ្តាសមណព្រាហ្មណ៍ទាំងនោះ សមណព្រាហ្មណ៍ពួកខ្លះទៀត (ជាឧច្ឆេទវាទ) ជាអ្នកពោលលើកខ្ជួនថា ឆ្លៀវឆ្លាសក្នុងអនុបាទិសេសនិព្វាន តែងប្រកាន់ពោលនូវលទ្ធិ គឺសេចក្តីជាច់សូន្យថា (ជាធម៌ដ៏បរិសុទ្ធប្រសើររបស់សត្វ) ។ ព្រះពុទ្ធជាវីមំសីបណ្ឌិត ទ្រង់ជ្រាបនូវពួកសមណ-ព្រាហ្មណ៍ ទាំងនោះថា ជាអ្នកអាស្រ័យនៅ(របស់ពួកសមណ-ព្រាហ្មណ៍ទាំងនោះ)ផង ជ្រាប(នូវធម៌ទាំងឧ្យាយថា ជាទុក្ខមិនទៀងជាដើម) ហើយបានរួចស្រឡះផង ទើបមិនដល់នូវការទាស់ទែង អ្នកប្រាជ្ញតែងមិនមកដើម្បីកើតទៀត ១ឡើយ ។

អដ្ឋកថា

កលហវិវាទសូត្រ មានពាក្យចាប់ផ្តើមថា *ក្ការ*ណោ *ប*ហូ*តា* *ក*លរ*ក* *វ*ិវ*ាទ*ា **ការណ្ហោ សេចក្តីវិវាទ** *ក*ើ*ត*ពី*អ*ី*ដ*ូ*ច*ច*េ*ះ*ជ*ា*ដ*ើ*ម ។ ព្រះ*ស*ូ*ត*្រ*ន*េ*ះ*ម*ា*ន*ក*ា*រ*ក*ើ*ត*ឡ*ើ*ង*យ*ា*ង*ណ*ា ? *ក*្ន*ុ*ង*ម*ហ*ា*ស*ម*័*យ*ន*ោ*ះ*ឯ*ង ព្រ*ះ*ម*ា*ន*ព*្រ*ះ*ភ*ា*គ*ត្រ*ា*ស*់*ព*្រ*ះ*ស*ូ*ត*្រ*ស*ូ*ម*្ប*ី*ន*េ*ះ

ដើម្បីទ្រង់ធ្វើឱ្យច្បាស់ដល់ធម៌ទាំងនោះដល់ទេវតាពួកខ្លះ មានចិត្តកើតឡើងថា ធម៌ទាំងឡាយ ៨ ប្រការមានការ ឈ្លោះគ្នាជាដើម កើតពីហេតុណាហ្ន៎ ទើបឱ្យព្រះពុទ្ធនិម្មិតត្រាស់សួរព្រះអង្គដោយន័យមុននុ៎ះឯង ។

ក្នុងព្រះសូត្រនោះ គាថាទាំងអស់មានការភ្ជាប់សេចក្តីប្រាកដច្បាស់ហើយ ព្រោះនៅតាមលំដាប់របស់ការសួរ និងការតប ។ តែគប្បីជ្រាបដល់ការពណ៌នាបទ ដែលលំបាករបស់គាថាទាំងនោះដូចតទៅនេះ ។ បទថា ក្យុតោ បហូតា ឥលតា ១ វ៉ាធ ១ បានដល់ ធម៌ជាគ្រឿងសៅហ្មងទាំងនេះ គឺការឈ្លោះ និងសេចក្តីវ៉ាទ ដែលជាខាងដើមរបស់ការឈ្លោះនោះកើតពីអ្វី ។ បទថា ២ បរិទេវសោកា ១ សហ ១ ១ ១

យ៉ាង សូម្បីទាំងអស់ទាំងនោះ ។ បទថា តធិច្ឆ ត្វហិ គឺសូមព្រះអង្គចូរត្រាស់ប្រាប់សេចក្តីដែលខ្ញុំព្រះអង្គ សួរនោះចុះ គឺខ្ញុំព្រះអង្គសូមអង្វរ បទថា ឥច្ឆ ជានិបាត មានសេចក្តីថា សូមអង្វរ ។ បទថា ឋិយឋ្ឍហូតា គឺកើតអំពីវត្ថុជាទីស្រឡាញ់ ។ ជាការដែលព្រះសារីបុត្រគ្ពោរពោលទុក ហើយក្នុងមហានិទ្ទេសនុ+ះឯង ។ បទថា មច្ចេរយុត្តា ឥលរកេ វិវាទា ការឈ្លោះសេចក្តីវិវាទប្រកបចូលហើយ ដោយសេចក្តីកំណាញ់ ព្រះមានព្រះភាគទ្រង់សម្តែងថា មិនមែន វត្ថុជាទីស្រឡាញ់តែម្យ៉ាងប៉ុណ្ណោះ សូម្បីសេចក្តីកំណាញ់ក៏ ជាហេតុនៃការឈ្លោះនិងសេចក្តីវិវាទដោយបទនេះ ។ គប្បីជ្រាបថាធម៌ទាំងនោះទាំងអស់ ព្រះមានព្រះភាគត្រាស់ដោយក្បាលប្រការនៃការឈ្លោះ សេចក្តីវិវាទក្នុងបទនេះ ។ សេចក្តីវិវាទជាហេតុនៃពាក្យស៊ីកសៀត ដូចសេចក្តីកំណាញ់ជាហេតុ នៃការឈ្លោះសេចក្តីវិវាទ ដូច្នោះ ។ ដោយហេតុនោះព្រះមានព្រះភាគទើបត្រាស់ថា វិវាទជាតេសុ ច ឋេសុណានិ ក៏កាលសេចក្តីវិវាទកើតឡើងហើយ ពាក្យស៊ីក

សៀត រមែងកើត ។ បទថា ឋិយា សុ លោកសមឺ
ក្ខុតោនិធានា យេ វាបិ លោភាវិចរន្តិ លោកេ សេចក្តី
ស្រឡាញ់ក្នុងលោកមានអ្វីជាហេតុ សូម្បីមួយទៀត ជនពួកណា
មានសេចក្តីលោភត្រាច់ទៅក្នុងលោក សេចក្តីថា ព្រះមានព្រះភាគ
ត្រាស់ទុកក្នុងបទនេះថា សេចក្តីឈ្លោះកើតពីសេចក្តីស្រឡាញ់
សេចក្តីស្រឡាញ់នោះ ក្នុងលោកមានអ្វីជាហេតុ ។ ព្រះពុទ្ធនិមិត្ត
ត្រាស់សួរសេចក្តីទាំងពីរដោយគាថាតែមួយថា មិនមែនសេចក្តី
ស្រឡាញ់តែម្យ៉ាង មួយទៀត ជនពួកណាមានកម្សត្រិយ៍ជាដើម
មានសេចក្តីលោភ ត្រាច់ទៅ គឺត្រាច់ទៅព្រោះសេចក្តីលោភជា
ហេតុ ព្រោះត្រូវសេចក្តីលោភគ្របសង្កត់ សេចក្តីលោភរបស់
ជនមានកម្សត្រិយ៍ជាដើមទាំងនោះ មានអ្វីជាហេតុ ។ បទថា
អាសា ច និដ្ឋា ចសេចក្តីប្រាថ្នានិងសេចក្តីសម្រេច គឺសេចក្តី
ប្រាថ្នានិងសេចក្តីសម្រេច ព្រោះសេចក្តីប្រាថ្នានោះ ។ បទថា
យេ សមមបាយាយនរស្ស ហោន្តិ គឺសេចក្តីប្រាថ្នា និង
សេចក្តីសម្រេច របស់នរជនដែលមានក្នុងសម្បាយកពលោក

អធិប្បាយថា ភាពជាទីទៅក្នុងខាងមុខ ។ ពាក្យសួរនេះ ក៏ដូចគ្នា ។ បទថា ឆន្ទានិ ធានានិ សេចក្តីស្រឡាញ់មានសេចក្តីពេញចិត្តជាហេតុ គឺសេចក្តីស្រឡាញ់មានសេចក្តីពេញចិត្តក្នុងកាមជាដើមជាហេតុ ។ បទថា យេ វាបិ លោភា ១ ជនពួកណា មានសេចក្តីលោភត្រាច់ទៅ ព្រះមានព្រះភាគទ្រង់ដោះស្រាយសេចក្តីសូម្បីទាំងពីរ ដោយសេចក្តីជាយ៉ាងតែមួយ ១ មួយទៀត ជនពួកណាមានកម្ម្រតិ្យ៍ជាដើម មានសេចក្តីលោភត្រាច់ទៅ សូម្បីសេចក្តីលោភរបស់ជនមានកម្ម្រតិ្យ៍ជាដើមទាំងនោះ ក៏មានសេចក្តីពេញចិត្តជាហេតុ ។ បទថា ឥតោនិទានា លោកអធិប្បាយថា មានសេចក្តីពេញចិត្តជាហេតុដូចគ្នា ។ គប្បីជ្រាបសេចក្តីសម្រេចនៃសព្ទក្នុងបទទាំងពីរថា កុតោនិទានា មានអ្វីជាហេតុ និង ឥតោនិទានា មានសេចក្តីពេញចិត្តនេះជាហេតុដោយន័យដូចពោលហើយក្នុងសូចិលោមសូត្រនោះឯង ។

បទថា ១ និច្ចយា ១ ១ ១

វុត្ថា មួយទៀត ធម៌ពួកណាដែលព្រះសមណៈត្រាស់ហើយ សេចក្តីថា ធម៌សូម្បីដទៃពួកណាជាអកុសលសម្បយុត្តដោយ សេចក្តីក្រោធជាដើម ដែលព្រះពុទ្ធសមណៈត្រាស់ហើយធម៌ ទាំងនោះកើតអំពីណា ។

បទថា ឥមូបនិសជ្ជាយ បហោតិ ឆន្ទោ សេចក្តីពេញ ចិត្ត រមែងកើតព្រោះអាស្រ័យសេចក្តីត្រេកអរនិងសេចក្តីមិន ត្រេកអរ ដែលបានដល់ វត្ថុពីរយ៉ាងគឺ សុខវេទនានិងទុក្ខវេទនានោះ ដោយ ប្រាថ្នាសេចក្តីនៅរួមគ្នានិងសេចក្តីរបូតប្រាសចាកគ្នា ដោយហេតុ ត្រឹមតែប៉ុណ្ណោះ ជាការព្រះមានព្រះភាគទ្រង់ដោះស្រាយបញ្ជាថា សេចក្តីពេញចិត្តក្នុងលោកមានអ្វីជាហេតុ ដូច្នេះ ។

បទថា រូបេសុ ឧិស្សា ១ ១ ១

កើតហើយ ។ សេចក្តីសម្គាល់ដែលត្រូវព្រះសារីបុត្រពោលទុកក្នុងមហានិទ្ទេសហើយនេះ ។ ដោយហេតុត្រឹមតែប៉ុណ្ណោះ ជាការព្រះមានព្រះភាគទ្រង់ដោះស្រាយបញ្ហានេះថា មួយទៀត សេចក្តីវិនិច្ឆ័យកើតពីអ្វីដូច្នេះ ។ បទថា ឯតេបិ ធម្មា ពួកមេវ សន្តេ កាលសេចក្តីត្រេកអរនិងសេចក្តីមិនត្រេកអរទាំងពីរយ៉ាងនោះឯង មាននៅក្នុងធម៌សូម្បីទាំងនេះក៏រមែងកើតបានគឺ ធម៌មានសេចក្តីក្រោធជាដើម សូម្បីទាំងនេះ រមែងកើតឡើងបាន ។ មួយទៀត ព្រះមានព្រះភាគត្រាស់វិធីកើតរបស់សុខវេទនានិងទុក្ខវេទនានោះទុកហើយ ក្នុងនិទ្ទេសនុ៎ះឯង ។

ដោយហេតុត្រឹមតែប៉ុណ្ណោះ ជាការព្រះមានព្រះភាគត្រាស់ដោះស្រាយសូម្បីបញ្ហាទីបីហើយ ។

ឥឡូវនេះ ព្រះមានព្រះភាគកាលនឹងទ្រង់សម្តែងដល់ឧបាយលះសេចក្តីសង្ស័យរបស់ព្រះពុទ្ធនិមិត្ត ដែលសង្ស័យក្នុងបញ្ហាទាំងនេះ ដែលព្រះអង្គដោះស្រាយយ៉ាងនេះហើយ ទើបត្រាស់ថា ឥមំ ឥមាញ្ចាណាបថាយ សិក្ខេ អ្នកមានសេចក្តី

សង្រ្ទាយគប្បីសិក្សាដើម្បីផ្លូវនៃញាណដូច្នេះ ។ លោកអធិប្បាយ ទុកថា គប្បីសិក្សាសិក្ខា ៣ ដើម្បីសម្រេចញាណគឺ ញាណ-ទស្សនៈ ព្រោះហេតុណា ព្រោះលោកអ្នកជាសមណៈ ដឹងហើយ ទើបពោលធម៌ទាំងឡាយ គឺព្រះពុទ្ធសមណៈដឹងហើយ ទើប ពោលធម៌ សេចក្តីមិនដឹងក្នុងធម៌ទាំងឡាយ រមែងមិនមានដល់ ព្រះពុទ្ធសមណៈនោះ កាលមិនដឹងធម៌ទាំងនោះ មិនគប្បីដឹង ព្រោះមិនមានញាណរបស់ខ្លួន មិនគប្បីដឹង ព្រោះទោសនៃការ សម្តែងដូច្នោះ អ្នកសង្រ្ទាយគប្បីសិក្សាដើម្បីផ្លូវនៃញាណលោក អ្នកជាសមណៈដឹងហើយ ទើបទ្រង់ពោលធម៌ទាំងឡាយ ។

បទថា សាតាសាតំ ក្នុងបទនេះថា សាតំ អសាតញ្ចុ ភុតោនិធានា សេចក្តីត្រេកអរនិងសេចក្តីមិនត្រេកអរមានអ្វី ជាហេតុ ទ្រង់ប្រាថ្នាយកសុខវេទនា និងទុក្ខវេទនានុ៎ះឯង ។ បទ-ថា ន ភវន្តិ ហេតេ គឺធម៌ទាំងនោះនឹងមិនមាន ។ បទថា ទ្វៃ ភវ ចាបិ យមេតមតថំ ឯតំ មេ ២ ព្រ្ទូហិ យតោនិធានំ គឺសូមព្រះអង្គចូរត្រាស់ប្រាប់អត្ថ គឺ ទាំងសេចក្តីសាបសូន្យទៅ និងទាំងការកើតឡើងនៃសេចក្តីត្រេកអរ និងសេចក្តីមិនត្រេកអរ

ថា មានអ្វីជាហេតុដល់ខ្ញុំព្រះអង្គ ។ ក្នុងបទនេះ លោកផ្ទាស់លិង្គ ។ បទនេះ មានអធិប្បាយថា សាតាសាតានំ វិកវោ ភវោ ច សេចក្តីសាបសូន្យនិងការកើតរបស់សេចក្តីត្រេកអរ និងសេចក្តីមិនត្រេកអរទាំងឡាយ គប្បីជ្រាបសេចក្តីក្នុងបទនេះថា សូមព្រះអង្គចូរត្រាស់ប្រាប់ ទាំងសេចក្តីសាបសូន្យ និងការកើតនោះថា មានអ្វីជាហេតុគឺសេចក្តីសាបសូន្យ និងការកើតដែលជាវិភវទិដ្ឋិ សេចក្តីឃើញថា សាបសូន្យនិងភវទិដ្ឋិ សេចក្តីឃើញថា កើតដែលជាវត្ថុនៃគ្រាមសាបសូន្យនិងការកើត ។ ពិតយ៉ាងនោះ ក្នុងចំណែកដោះស្រាយបញ្ហានេះ លោកពោលទុកក្នុងនិទ្ទេសថា ភវទិដ្ឋិក្តី វិភវទិដ្ឋិក្តី សុទ្ធមាន ផស្សៈជាហេតុ ។

បទថា ឥតោនិទានំ គឺមានផស្សៈជាហេតុ ។ បទថា កិសមឺ វិភូតេ ឧជុសនតិ ជសច្ច កាលធម៌អ្វីមិនមានផស្សៈ ទើបមិនត្រឹមត្រូវ គឺកាលធម៌អ្វីកន្លងទៅហើយ ផស្សៈ ៥ មាន នឹងសម្ជស្សជាដើម ទើបមិនមាន ។ បទថា នាមចរូប ច បដិច្ច អាស្រ័យនាមនិងរូបគឺ អាស្រ័យនាមដែលសម្បយុត្តគ្នា

ចូល និងអាស្រ័យវត្ថុនឹងរូបដែលជាអារម្មណ៍ ។ បទថា រូបេ ១ភ្ជូតេ ន ផុសនតិ ជសញ្ញា គឺកាលរូបកន្ធងទៅផស្ស: ៥ ទើប មិនត្រឹមត្រូវ ។

បទថា ១ កជំសមេតសញ្ញ គឺ កាលបុគ្គលបដិបត្តិយ៉ាងណា ។ បទថា ១ ១ ១

មិនមែនគឺ ជាអ្នកឈានកន្លងមានសញ្ញាកន្លងហើយដោយន័យជាដើមថា ឈានកន្លងរូបសញ្ញាដោយប្រការទាំងពួង ជាអ្នកបានអរូបឈានក៏មិនមែន ។ បទថា ឯវំ សមេតសញ្ញីភោតិ រូបំ បុគ្គលកាលបដិបត្តិយ៉ាងនេះ រូបទើបមិនមានគឺ បុណ្យអ្នកបានអរូបសមាបត្តិ កាលមិនតាំងនៅក្នុងសេចក្តីជាអ្នកមានសញ្ញានិងមិនមានសញ្ញាជាដើមនេះហើយបដិបត្តិដូច ដែលលោកពោលទុកថា កាលចិត្តតាំងមាំហើយយ៉ាងនេះ ។ ល ។ បុគ្គលនោះរមែងនាំចិត្តទៅដើម្បីបានអាកាសានញ្ចាយតនសមាបត្តិរូប ទើបមិនមាន ។

បទថា សានិទានា ហិ បមាទសន្ធា ព្រោះថា ធម្ម៌ជាចំណែកនៃសេចក្តីយឺតយូរមានសញ្ញាជាហេតុ ព្រះមានព្រះភាគទ្រង់សម្តែងថា សូម្បីកាលបដិបត្តិយ៉ាងនេះហើយ ធម្ម៌ជាចំណែកនៃសេចក្តីយឺតយូរ គឺតណ្ហានិងទិដ្ឋិដែលមានសញ្ញានោះជាហេតុនៅលះមិនបានតែម្តង ។ ច្រើនបទថា ឯត្ថ តាវ ឯកតំ ។បេ ។ ១ ១ ១

លោកនេះ រមែងពោលសេចក្តីបរិសុទ្ធិរបស់សត្វថា ជាកំពូលដោយហេតុត្រឹមតែប៉ុណ្ណោះឬថា រមែងពោលសេចក្តីបរិសុទ្ធិយ៉ាងដទៃដែលក្រៃលែងទៅជាងនេះ ។ ព្រះពុទ្ធនិមិត្ត ត្រាស់សួរថា សមណព្រាហ្មណ៍អ្នកជាបណ្ឌិត រមែងពោលសេចក្តីបរិសុទ្ធិរបស់សត្វថា ជាកំពូលដោយហេតុត្រឹមតែប៉ុណ្ណោះ ឬថា រមែងពោលសេចក្តីបរិសុទ្ធិយ៉ាងដទៃ ដែលក្រៃលែងទៅជាងអរូបសមាបត្តិនេះ ។

បទថា ឯត្តាវតកមុតបិ វទន្តិ ហេកេ សមណ-ព្រាហ្មណ៍ពួកមួយ រមែងពោលសេចក្តីបរិសុទ្ធិថា ជាកំពូលដោយហេតុត្រឹមតែប៉ុណ្ណោះគឺ សមណព្រាហ្មណ៍អ្នកមានវាទៈថាទៀងពួកមួយ ប្រកាន់ខ្ជួនថាជាបណ្ឌិត រមែងពោលអរូបសមាបត្តិនេះថាជាសេចក្តីបរិសុទ្ធិយ៉ាងកំពូល សូម្បីដោយហេតុត្រឹមតែប៉ុណ្ណោះ ។ បទថា តេសំ ឫនេកេ សមយំ វទន្តិ សមណ-ព្រាហ្មណ៍មួយពួកទៀត រមែងពោលដល់លទ្ធិរបស់សមណ-ព្រាហ្មណ៍ទាំងនោះ គឺសមណព្រាហ្មណ៍អ្នកមានវាទៈជាច់សូន្យពួកមួយ រមែងពោលដល់លទ្ធិគឺ សេចក្តីជាច់សូន្យរបស់សមណ-

ព្រាហ្មណ៍ទាំងនោះ ។ បទថា អនុត្តរាធិសេសេ ឥសុសលាវធានា គឺអ្នកមានវាទៈថា ខ្លួនជាអ្នកឆ្លាតក្នុងអនុត្តរាទិសេសនិព្វាន ។ បទថា ឯតេ ច តវ ឧបនិស្សិតា គឺ ចំណែកលោកអ្នកជាមុនីដ៏ងបុគ្គលដែលជាម្ចាស់ទិដ្ឋិទាំងនោះថា ជាអ្នកអាស្រ័យសស្សតៈ-ទិដ្ឋិ និងឧច្ឆេទទិដ្ឋិ ។ បទថា តវ មុនី និស្សយេ សោ ១ មំ សី លោកអ្នកជាមុនីនោះពិចារណា ដ៏ងអ្នកអាស្រ័យទិដ្ឋិទាំងឡាយគឺ ព្រះពុទ្ធមុនីអ្នកជាបណ្ឌិត ពិចារណាដ៏ងអ្នកអាស្រ័យនុ៎ះឯង ។ បទថា តវ ១ មុត្តោ ដ៏ង...រួចផុតគឺដ៏ងធម៏ដោយសេចក្ដីជាទុក្ខនិងមិនទៀងជាដើម រួចផុតហើយ ។ បទថា ភវាភវាយ ន សមេតិ គឺរមែងមិនមកដើម្បីកើតរៀយ ១ ។ ព្រោះដ៏ព្រះមានភាគទ្រង់បញ្ចប់ដោយទេសនាជាធម៏កំពូល គឺព្រះអរហត្ត ។

កាលចប់ទេសនា បានមានអ្នកសម្រេចដូចគ្នានឹងដែលពោលហើយក្នុងបុរាណេទសូត្រនុ៎ះឯង ។

ធ្វើអ្វីទៅតាមតែតណ្ហា នឹងជួបសោកាមហាទ្ធាយទ្ធាល់
ធ្វើអ្វីទៅតាមបញ្ញាយល់ នឹងបានអស់ទ្ធាល់សល់តែសុទ្ធ ។

សាកេតជាតក

នៅក្នុងអដ្ឋកថាភាគ ៥៧,ទំព័រ ៣៥១ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់ព្រះជាតកមួយដែលនិយាយអំពី **[*ហេតុនាំឱ្យកើតសេចក្តីស្រឡាញ់*]** *មានសេចក្តីថា ៖*

ព្រះសាស្តា កាលគង់នៅក្រុងសាកេត ទ្រង់ប្រារព្ធសាកេតព្រាហ្មណ៍ ត្រាស់ព្រះធម្មទេសនានេះថា **បពិត្រព្រះមានព្រះភាគហេតុអ្វីហ្ន៎** (*កោ នុ ខោ ភគវា ហេតុ*) *ជូរច្នេះ ។*

ក្នុងវេលាដែលព្រះមានព្រះភាគ ស្តេចយាងទៅកាន់ព្រះវិហារ ភិក្ខុទាំងឡាយទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ឈ្មោះថា សេចក្តីស្រឡាញ់នេះ តាំងនៅបានយ៉ាងណា ពោលគាថាជំបូងថា ៖

កោ នុ ខោ ភគវา ហេតុ ឯកច្ចេ ឥធ បុគ្គលេ
អតីវ ហាទយំ និញ្ជានិ ចិត្តញ្ចាបិ បសីទតិ ។

បពិត្រព្រះមានព្រះភាគ ហេតុអ្វីហ្ន៎ ហាឫទ័យត្រជាក់យ៉ាងក្រៃលែងទាំងចិត្តក៏ជ្រះថ្លាក្នុងបុគ្គលពួកខ្លះក្នុងលោក ។

សេចក្តីនៃគាថានោះថា អ្វីហ្ន៎ ជាហេតុឱ្យបុគ្គលពួកខ្លះក្នុង

លោកនេះ គ្រាន់តែឃើញគ្នាត្រឹមតែមួយភ្លេតប៉ុណ្ណោះ ក៏មានចិត្តស្និទ្ធស្នាល ចូលចិត្តគ្នា ប្រៀបដូចជាការទឹកក្រអូប ១,០០០ ឆ្នាំង ស្រោចលើ, បុគ្គលពួកខ្លះទៀត មិនចូលចិត្តគ្នា, តែចំពោះបុគ្គលពួកខ្លះ ត្រឹមតែឃើញគ្នាភ្លាម ក៏មានចិត្តជ្រះថ្លាចំពោះគ្នា ដោយអំណាចសេចក្តីស្រឡាញ់,បុគ្គលខ្លះទៀតមិនចូលចិត្តគ្នា ។

លំដាប់នោះ ព្រះសាស្តាកាលនឹងទ្រង់សម្តែងហេតុនៃសេចក្តីស្រឡាញ់ដល់ភិក្ខុទាំងនោះទើបត្រាស់គាថាទីពីរថា ៖

បុព្វេ សន្ធិវាសេន បច្ចុប្បន្នហិតេន វា

ឯវន្តំ ជាយតេ បេមំ ឧបលំវ យថោទកេតិ ។

ព្រះសាស្តាទ្រង់ត្រាស់ថា សេចក្តីស្រឡាញ់នោះ រមែងកើតដោយហេតុ ២ យ៉ាង គឺដោយធ្លាប់នៅរួមគ្នាក្នុងកាលមុន ១ ដោយការទំនុកបម្រុងគ្នាក្នុងបច្ចុប្បន្ននេះ ១ ដូចជាឧប្បលដែលដុះក្នុងទឹកដោយហេតុពីរយ៉ាងគឺទឹក ១ ភក់ ១ ។

សេចក្តីនៃព្រះគាថានុ៎ះថា ភិក្ខុទាំងឡាយ ធម្មតាសេចក្តីស្រឡាញ់នេះ រមែងកើតដោយហេតុ ២ ប្រការ គឺបានជា មាតា

បិតា ធីតា បុត្រ បងប្អូនប្រុស បងប្អូនស្រី ស្វាមី ភរិយា សម្លាញ់ ឬជាមិត្តភក្តិ ក្នុងភពមុន ធ្លាប់រស់នៅរួមគ្នាមក សេចក្តីស្រឡាញ់នោះរមែងមិនដាច់ នៅតែជាប់តាមទៅសូម្បីក្នុងភពដទៃ ព្រោះការរស់នៅជាមួយគ្នាក្នុងកាលមុនតែម្យ៉ាង មួយទៀត សេចក្តីស្រលាញ់នោះ រមែងកើតព្រោះសេចក្តីអើពើក្នុងបច្ចុប្បន្ន កាលដែលធ្វើក្នុងអត្តភាពនេះ ។ សេចក្តីស្រឡាញ់នោះកាលកើត រមែងដោយហេតុ ២ ប្រការដូច្នេះ ។ សួរថា ដូចយ៉ាងណា ? ឆ្លើយថា ប្រៀបដូចជាផ្កាឧប្បលក្នុងទឹកដូច្នោះ ។ លោកធ្វើ ១ អក្សរឱ្យមានសម្លេងលាន់ញ ១ អក្សរនោះ លោកពោលទុកក្នុងសមុច្ចយត្ថ:(រួម) ដូច្នោះ ផ្កាឧប្បលនឹងបុប្ផជាតិ ដែលកើតក្នុងទីផ្សេង ១ កាលកើតរមែងកើតព្រោះអាស្រ័យហេតុ ២ យ៉ាងគឺ ទឹកនឹងភក់យ៉ាងណា សេចក្តីស្រឡាញ់ រមែងកើតដោយហេតុ ២ ប្រការ ដូច្នោះ ។ គប្បីជ្រាបសេចក្តីនេះ ដូច្នេះ ។

២ មេមសូត្រ

នៅក្នុងបិដកលេខ ៤៣, ទំព័រ ១៨៣ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់អំពី[**ធម្មជាត ៤ ប្រការ**] មានសេចក្តីថា ៖

ម្នាលភិក្ខុទាំងឡាយ ធម្មជាត ៤ យ៉ាង រមែងកើតមាន ។ **ធម្មជាត ៤ យ៉ាង តើដូចម្តេច ។**

១- បេមា បេមំ ជាយតិ សេចក្តីស្រឡាញ់កើតព្រោះសេចក្តីស្រឡាញ់ ។

២- បេមា ទោសោ ជាយតិ សេចក្តីប្រទុស្តកើតព្រោះសេចក្តីស្រឡាញ់ ។

៣- ទោសា បេមំ ជាយតិ សេចក្តីស្រឡាញ់កើតព្រោះសេចក្តីប្រទុស្ត ។

៤- ទោសា ទោសោ ជាយតិ សេចក្តីប្រទុស្តកើតព្រោះសេចក្តីប្រទុស្ត ។

១. ម្នាលភិក្ខុទាំងឡាយ **សេចក្តីស្រឡាញ់កើតព្រោះសេចក្តីស្រឡាញ់** តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលក្នុងលោកនេះ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្តរបស់បុគ្គលពួកជនអ្នកហៅរកចំពោះបុគ្គលនោះ ដោយសេចក្តីប្រាថ្នា សេចក្តីត្រេកអរ សេចក្តីពេញចិត្ត ។ បុគ្គល(អ្នកចូលចិត្ត) នោះ

មានសេចក្តីត្រិះរិះយ៉ាងនេះថា បុគ្គលណាដែលជាទីប្រាថ្នាជាទីត្រេកអរ ជាទីពេញចិត្តរបស់អាត្មាអញ ពួកជនដទៃក៏ហៅ រកចំពោះបុគ្គលនោះ ដោយសេចក្តីប្រាថ្នា សេចក្តីត្រេកអរសេចក្តីពេញចិត្តដែរ បុគ្គលនោះក៏ធ្វើសេចក្តីស្រឡាញ់ឱ្យកើតក្នុងពួកជនដទៃនោះ ។ ម្នាលភិក្ខុទាំងឡាយ **សេចក្តីស្រឡាញ់ កើតព្រោះសេចក្តីស្រឡាញ់** យ៉ាងនេះឯង ។

១. ម្នាលភិក្ខុទាំងឡាយ **សេចក្តីប្រទុស្តកើតមាន ព្រោះសេចក្តីស្រឡាញ់** តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលក្នុងលោកនេះ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្តរបស់បុគ្គលពួកជនអ្នកហៅរកចំពោះបុគ្គលនោះ ដោយសេចក្តីមិនប្រាថ្នា មិនជាទីត្រេកអរ មិនជាទីពេញចិត្ត ។ បុគ្គល(អ្នកចូលចិត្ត)នោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា បុគ្គលណាដែលជាទីប្រាថ្នា ជាទីត្រេកអរ ជាទីពេញចិត្តរបស់អាត្មាអញ ពួកជនដទៃក៏ហៅរកចំពោះបុគ្គលនោះ ដោយសេចក្តីមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីពេញចិត្តសោះ បុគ្គលនោះក៏ធ្វើសេចក្តីប្រទុស្តឱ្យកើតឡើងក្នុងពួកជនដទៃនោះ ក្នុងពួកជនដទៃនោះ ។

ម្នាលភិក្ខុទាំងឡាយ **សេចក្តីប្រទុស្តកើតមាន ព្រោះសេចក្តីស្រឡាញ់** យ៉ាងនេះឯង ។

១. ម្នាលភិក្ខុទាំងឡាយ **សេចក្តីស្រឡាញ់កើត ព្រោះសេចក្តីប្រទុស្ត** តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលក្នុងលោកនេះ មិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីពេញចិត្ត របស់ពួកជនដទៃក៏ហៅរកចំពោះបុគ្គលនោះ ដោយសេចក្តីមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីពេញចិត្ត ។ បុគ្គល(អ្នកមិនពេញចិត្ត)នោះមានសេចក្តីត្រិះរិះយ៉ាងនេះថា បុគ្គលណាមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីពេញចិត្តរបស់អាត្មាអញពួកជនដទៃក៏ហៅរកចំពោះបុគ្គលនោះ ដោយសេចក្តីមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីពេញចិត្តដែរ បុគ្គលនោះក៏ធ្វើសេចក្តីស្រឡាញ់ឱ្យកើត ក្នុងពួកជនដទៃនោះ ។ ម្នាលភិក្ខុទាំងឡាយ **សេចក្តីស្រឡាញ់កើត ព្រោះសេចក្តីប្រទុស្ត** យ៉ាងនេះឯង ។

១. ម្នាលភិក្ខុទាំងឡាយ **សេចក្តីប្រទុស្តកើត ព្រោះសេចក្តីប្រទុស្ត** តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលក្នុងលោកនេះ មិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីពេញចិត្ត

របស់បុគ្គល ពួកជនដទៃក៏ហៅរកចំពោះបុគ្គលនោះ ដោយសេចក្តីប្រាថ្នា សេចក្តីត្រេកអរ សេចក្តីពេញចិត្ត ។ បុគ្គល(អ្នកមិនពេញចិត្ត)នោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា បុគ្គលណាមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីពេញចិត្តរបស់អាត្មាអញ ពួកជនដទៃក៏ហៅរកចំពោះបុគ្គលនោះ ដោយសេចក្តីប្រាថ្នាសេចក្តីត្រេកអរ សេចក្តីពេញចិត្តទៅវិញ បុគ្គលនោះក៏ធ្វើសេចក្តីប្រទុស្តឱ្យកើតក្នុងពួកជនដទៃនោះ ។ ម្នាលភិក្ខុទាំងឡាយ **សេចក្តីប្រទុស្ត**
កើតព្រោះសេចក្តីប្រទុស្តយ៉ាងនេះឯង តែងកើតមាន ។

ស្រឡាញ់ខ្លួនឯងជាងស្រឡាញ់បុគ្គលដទៃ

នៅក្នុងលោកនេះ មានមនុស្សមួយចំនួន គេតែងពោល ថា ខ្ញុំស្រឡាញ់មាតាបិតារបស់ខ្ញុំជាងខ្លួនខ្ញុំ មានបុគ្គលខ្លះទៀត គេពោលថា ខ្ញុំស្រឡាញ់បងប្អូនរបស់ខ្ញុំជាងខ្លួនខ្ញុំ, មានបុគ្គលមួយចំនួនទៀត គេពោលថា ខ្ញុំស្រឡាញ់ខ្លួនរបស់ខ្ញុំជាងគេ, ព្រះសម្មាសម្ពុទ្ធជាម្ចាស់ព្រះអង្គទ្រង់ត្រាស់ថា **នត្ថិ អត្ត សមំ បេមំ** ស្រឡាញ់អ្វីឱ្យស្មើនឹងខ្លួនមិនមានឡើយ បុគ្គលអ្នកត្រូវសេចក្តីទុក្ខគ្របសង្កត់ហើយ ហ៊ានលះបង់ទ្រព្យសម្បត្តិដើម្បីការពារជីវិត

ហើយបើលះបង់ទ្រព្យការពារជីវិតមិនបាន ក៏ហ៊ានលះបង់អាយុ: មានដៃនិងជើងជាដើម ដើម្បីការពារជីវិតដូច្នេះសបញ្ជាក់ឱ្យឃើញ ថាមនុស្សយើងម្នាក់ ១ស្រឡាញ់ជីវិត ខ្លួនឯងជាងបុគ្គលណា ១ ទាំងអស់ មិនថាអ្នកនោះជាមាតាបិតានោះទេព្រោះហេតុនេះហើយ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់នៅក្នុងសុត្តន្តបិដក សំយុត្ត-និកាយ សគាថវគ្គ ត្រង់បិយសូត្រថា ៖

➲. បើបុគ្គលដឹងថាខ្លួនជាទីស្រឡាញ់ហើយ កុំធ្វើបាប

➲. បុគ្គលអ្នកធ្វើអំពើអាក្រក់ រមែងមិនបានទទួលសេចក្ដីសុខឡើយ

➲.បុគ្គលដែលត្រូវសេចក្ដីស្លាប់គ្របសង្កត់ លះបង់ភពជារបស់នៃមនុស្សទៅហើយ បុគ្គលនោះ មានអ្វីជារបស់ខ្លួនបុគ្គលនោះកាន់យកអ្វីទៅ អ្វីទៅតាមបុគ្គលនោះបានដូច ជាស្រមោលអន្ទោលតាមជ្រាណ

➲. អ្នកដែលកើតមកហើយ នឹងត្រូវស្លាប់ទៅវិញ ធម្ម-ជាតិទាំងពីរ គឺបុណ្យនិងបាប រមែងជាប់តាមបុគ្គលនោះ សត្វធ្វើអំពើណាទុកក្នុងលោកនេះ បុគ្គលនោះមានអំពើនោះ ជារបស់

ខ្លួន បុគ្គលនោះកាន់យកអំពើនោះទៅ អំពើនោះទៅតាមបុគ្គលនោះ ដូចជាស្រមោលអន្ទោលតាមប្រាណ

១. ព្រោះហេតុនោះ បុគ្គលគួរធ្វើកុសល ដែលប្រព្រឹត្តទៅក្នុងបរលោកឱ្យចំរើនឡើង ព្រោះបុណ្យទាំងឡាយ រមែងជាទីពឹងរបស់ពួកសត្វក្នុងបរលោក ។

មល្លិការសូត្រ

នៅក្នុងបិដកលេខ ២៩, ទំព័រ ២០៥ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់អំពី [**ស្រឡាញ់បុគ្គលដទៃឱ្យក្រៃលែងជាងខ្លួនមិនមាន**] មានសេចក្ដីថា ៖

ជិតក្រុងសាវត្ថី... សម្ព័យនោះព្រះបាទបសេនទិកោសលគង់ក្នុងប្រាសាទដ៏ប្រសើរជាន់ខាងលើ ជាមួយនឹងព្រះនាងមល្លិ-កាទេវី ។ គ្រានោះ ព្រះបាទបសេនទិកោសលមានព្រះបន្ទូលនឹងព្រះនាងមល្លិកាទេវីដូច្នេះថា ម្នាលនាងមល្លិកា បុគ្គល ដទៃណាដែលជាទីស្រឡាញ់ ដោយវិសេសជាងខ្លួននាងទៅទៀតមានដែរឬ ។ បពិត្រមហារាជ បុគ្គលដទៃណាដែលជាទីស្រឡាញ់ដោយវិសេសជាងខ្លួនខ្ញុំម្ចាស់មិនមានទេ បពិត្រមហារាជ ចុះបុគ្គលដទៃ

នីមួយដែលជាទីស្រឡាញ់ ដោយវិសេសជាងខ្លួននាងទៅទៀត មានដែរឬ ។ ម្នាលនាងមល្លិកា បុគ្គលដទៃនីមួយ ដែលជាទីស្រឡាញ់ ដោយវិសេសជាងខ្លួន យើងទៅទៀតមិនមានទេ ។

លំដាប់នោះ ព្រះបាទបសេនទិកោសល ទ្រង់ចុះអំពីប្រាសាទ ហើយស្តេចចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយគង់នៅក្នុងទីសមគួរ ។ លុះព្រះបាទបសេនទិកោសល គង់ក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនៅក្នុងប្រាសាទដ៏ប្រសើរជាន់ខាងលើជាមួយនឹងព្រះនាងមល្លិកាទេវីក្នុងទីឯណោះ បានសួរនាងមល្លិកាទេវីដូច្នេះថា ម្នាលនាងមល្លិកា បុគ្គលដទៃណាដែលជាទីស្រឡាញ់ ដោយវិសេសជាងខ្លួននាងទៅទៀតមានដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើនកាលដែលខ្ញុំព្រះអង្គសួរយ៉ាងនេះហើយ នាងមល្លិកាទេវីក៏តបមកនឹងខ្ញុំព្រះអង្គដូច្នេះថា បពិត្រមហារាជ បុគ្គលដទៃណាដែលជាទីស្រឡាញ់ ដោយវិសេសជាងខ្លួនខ្ញុំ ម្ចាស់ទៅទៀតមិនមានទេ បពិត្រមហារាជ ចុះបុគ្គលដទៃនីមួយ ដែលជាទីស្រឡាញ់

ដោយវិសេសជាងខ្លួននាងទៅទៀតមានដែរឬ ។

លំដាប់នោះ ព្រះមានព្រះភាគជ្រាបច្បាស់នូវសេចក្តីនេះ ហើយ ក៏ត្រាស់នូវគាថានេះ ក្នុងវេលានោះថា ៖

សព្វា ទិសា អនុបរិគម្ម ចេតសា

នេវជ្ឈគា បិយតរមត្តនោ ក្វចិ

ឯវំ បិយោ បុថុ អត្តា បរេសំ

តស្មា ន ហឺសេ បរំ អត្តកាមោតិ ។

បុគ្គលមានចិត្តរំពឹងគិតសព្វទិស រមែងរកមិនឃើញនូវ បុគ្គលជាទីស្រឡាញ់ជាងខ្លួនក្នុងទិសណាមួយទេ ខ្លួនទើបជាទី ស្រឡាញ់ច្រើនជាងបុគ្គលដទៃយ៉ាងនោះឯង ព្រោះហេតុនោះ បុគ្គលដែលស្រឡាញ់ខ្លួន មិនគប្បីបៀតបៀនបុគ្គលដទៃឡើយ ។

អដ្ឋកថា

ព្រោះហេតុអ្វី ព្រះបាទបសេនទិកោសលទើបត្រាស់សួរថា "ម្នាលនាងមល្លិកា បុគ្គលដទៃណា ដែលជាទីស្រឡាញ់ ដែល វិសេសជាងខ្លួននាងទៅទៀត មានដែរឬ" ។ បានញ្ញថា ព្រះនាង

មល្លិកានេះ ជាធីតារបស់ជាងធ្វើផ្ការ្ក១ត់ ថ្ងៃមួយ កាន់នំអំពីផ្ការ
គិតថា នឹងទៅសួនផ្ការ្ក១ហើយសីមសុីនំ, ដើរទៅជួប ព្រះមានព្រះ
ភាគមានភិក្ខុជាបរិវារស្តេចចូលទៅស្វែងរ្ក១ភអាហារ ស្រេបផ្ការ្ក១ភ
 មានចិត្តជ្រះថ្លា បានថ្វាយនំនោះដល់ព្រះមានព្រះភាគ ព្រះមាន
ព្រះភាគទ្រង់សម្តែងអាការ:នឹងគង់ប្រថាប់ ។ ព្រះអានន្ទ្ធ្ត្ថ
ទើបបានក្រាលសំពត់ថ្វាយ ។

ព្រះមានព្រះភាគ ទ្រង់គង់ប្រថាប់ក្នុងទីនោះហើយសោយនំ
លាងព្រះឱ្ស្ហហើយ បានទ្រង់ធ្វើការញ្ញាមព្រះឱ្ស្ហ ឱ្យ ្ក១ ។
ព្រះថេ:ទូលសួរថា "បពិត្រព្រះអង្គដ៏ចម្រើនដោយការថ្វាយនំនេះ
នឹងមានផលអ្វី ?" ព្រះមានព្រះភាគ ្ត១ ្ស ់ថា "ម្នាលអានន្ទ ថ្ងៃ
នេះ នាងមល្លិការនោះបានថ្វាយ ្ក១ ជនដល់ ្ត១ ្ត១ ្ត១ ជ ជ ្ម ្ម ្ម

ជ្ជាក្នុងការបដិបត្តិរបស់នាង ទើបបង្គាប់ឱ្យនាំនាងចូលទៅខាងក្នុងព្រះនគរទ្រង់ស្ថាបនានាងទុកក្នុងតំណែងព្រះអគ្គមហេសី ។

តមកថ្ងៃមួយ ព្រះបាទបសេនទិកោសល ទ្រង់ព្រះត្រិះរិះថា "យើងឱ្យតសរិយយសយ៉ាងធំ ដល់ធីតារបស់ត្រកូលដែលក្រខ្សត់នេះ បើដូច្នោះ យើងនឹងគួរសួរនាងថា 'អ្នកណាជាទីស្រឡាញ់របស់នាង' ។ នាងនឹងឆ្លើយថា 'ព្រះមហាវាជ ព្រះអង្គទ្រង់ជាទីស្រឡាញ់របស់នាងខ្ញុំ' ហើយនឹងសួរយើងបន្ទាប់ពីនោះ យើងនឹងប្រាប់ដល់នាងថា 'នាងម្នាក់ជាទីស្រឡាញ់របស់យើង'ដូច្នេះ ។ ព្រះបាទបសេនទិកោសល នោះកាលនឹងត្រាស់ព្រះវាចាដែលរីករាយ ដើម្បីឱ្យកើតសេចក្តីស្និទ្ធស្នាលចំពោះគ្នាទើបសួរ ។ ចំណែកព្រះនាងមល្លិកាទេវីនោះ ជាបណ្ឌិតជាឧបដ្ឋាយិការបស់ព្រះពុទ្ធ ជាឧបដ្ឋាយិកា របស់ព្រះសង្ឆ មានបញ្ញាច្រើន ព្រោះដូច្នោះ ព្រះនាងទើប ត្រិះរិះយ៉ាងនេះថា "យើងមិនគប្បីឃើញដល់មុខព្រះរាជា តបបញ្ហានេះ" ។ គ្រាត្រាស់តបតាមសេចក្តីឃើញរបស់ខ្លួនហើយ ក៏ទូលសួរព្រះរាជាខ្លះ ។ ព្រះរាជាកាលទ្រង់តាំងព្រះអង្គមិនទាន់ ព្រោះព្រះនាងត្រាស់តាម

សេចក្តីយើញរបស់ព្រះនាងនោះឯង សូម្បីព្រះអង្គឯងក៏ត្រាស់តាមសេចក្តីយើញ(របស់នាង)ដូចគ្នា ទ្រង់ព្រះត្រិះរិះថា" ហេតុនេះ ល្អណាស់ យើងក្រាបទូលហេតុនេះចំពោះព្រះតថាគត" ដូច្នេះហើយក៏ស្តេចទៅក្រាប ទូលចំពោះព្រះមានព្រះភាគ ។

បទថា នេវជ្ឈគា **មិនឃើញ** គឺមិនជួប ។

បទថា ឯវំ ចិយោ បុថុ អត្តា បរេសំ **ខ្លួនទើបជាទីស្រឡាញ់របស់ខ្លួនជាងបុគ្គលដទៃ** សេចក្តីថា ខ្លួនជាទីស្រឡាញ់របស់ខ្លួនប៉ុណ្ណោះយ៉ាងណា អ្នកដទៃក៏ជាទីស្រឡាញ់របស់អ្នកដទៃ ។ សូម្បីជាច្រើន ដូច្នោះ ។

បរមត្ថទីបនី អដ្ឋកថារាជសូត្រ ភាគ ៤៤ ពន្យល់ថា÷

សព្វា ទិសា អនុបរិគម្ម ចេតសា

នេវជ្ឈគា ចិយតរមត្តនោ ក្វចិ

ឯវំ ចិយោ បុថុ អត្តា បរេសំ

តស្មា ន ហីសេ បរំ អត្តកាមោតិ ។

បុគ្គលមានចិត្តរំពឹងរកគ្រប់ទិស ក៏មិនបានបុគ្គលជាទី

ស្រឡាញ់ជាងខ្លួនក្នុងទីណាឡើយ ចំណែកខ្លួននោះទើបជាទីស្រឡាញ់ច្រើនជាងបុគ្គលដទៃ យ៉ាងនេះ ព្រោះហេតុនោះ បុគ្គលអ្នកស្រឡាញ់ខ្លួន មិនត្រូវបៀតបៀនបុគ្គលដទៃទេឡើយ[1] ។

សេចក្តីនៃរាជសូត្រនេះ ខ្ញុំព្រះករុណាមិនបានលើកមកទេ ព្រោះសេចក្តីនៃព្រះសូត្រនេះ ដូចមល្លិកាសូត្រដែរ ទុសតែសេចក្តីពន្យល់ក្នុងអដ្ឋកថាតិចតួចប៉ុណ្ណោះ ។

បទថា **មល្លិកា ទេវិយា** សន្ធិ សេចក្តីថា នឹងព្រះមហេសីរបស់ព្រះអង្គទ្រង់ព្រះនាមថា **មល្លិកា** ។ បទថា **ឧបរិបាសាទវរគតោ** បានដល់ នៅជាន់លើប្រាសាទដ៏ ប្រសើរ ។ បទថា **កោចញ្ញោ អត្តនា ២ យតរោ** សេចក្តីថា អ្នកណា ៗ ដទៃ ដែលនាងនឹងគប្បីស្រឡាញ់ក្រៃលែងជាងខ្លួនមានដែរឬ ?

ព្រោះហេតុអ្វី ព្រះរាជាទើបត្រាស់សួរ ។ ព្រោះព្រះនាងមល្លិកានេះ ជាធីតារបស់នាយមាលាការ អ្នកក្រខ្សត់ក្នុងក្រុងសាវត្ថី ថ្ងៃមួយ ទិញនំពីផ្សារទៅកាន់សួនផ្កាឈើ គិតថានឹង

---

១. សុត្តន្តបិដក ខុទ្ទកនិកាយ ឧទាន ភាគ ៥២, ទំព័រ ២២៦

បរិភោគ ទើបដើរទៅជួបព្រះមានព្រះភាគ រៀហាមដោយភិក្ខុ
សង្ឆកំពុងចូលទៅបិណ្ឌបាត គ្រានោះឯង (នាង)មានចិត្ត
ជ្រះថ្លាបានថ្វាយនំនោះចំពោះព្រះមានព្រះភាគ ។ ព្រះសាស្តា
ទ្រង់សម្តែងអាការប្រថាប់ គង់ក្នុងទីសភាពបែបនោះឯង ។
ព្រះអានន្ទត្តេរបានក្រាលចីវរថ្វាយ ។ ព្រះមានព្រះភាគប្រថាប់
គង់ក្នុងទីនោះ ទ្រង់សោយនំហើយខ្ទរព្រះឱស្ថ ទ្រង់ធ្វើការញញឹម
ឱ្យប្រាកដ ។ ព្រះថេរៈទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន វិបាក
នៃទានរបស់ស្រីនេះ នឹងជាយ៉ាងណា ។ ព្រះមានព្រះភាគត្រាស់
ថា អានន្ទថ្ងៃនេះនាងបានថ្វាយភោជនដល់តថាគតជាគ្រាដំបូង
ក្នុងថ្ងៃនេះឯងនាងនឹងបានជាអគ្គមហេសី ជាទីស្រឡាញ់ ជាទី
ប្រាសប្រាណរបស់ព្រះបាទបសេនទិកោសល ។ ក៏ក្នុងថ្ងៃនេះ
ឯង ព្រះរាជាច្បាំងនឹងក្ងួយក្នុងកាសិគ្រាម ចាលចាញ់គេចជៀស
មកចូលក្រុង ដោយប្រាថ្នាថានឹងបានរួចពី(ទ័ព) ទើបស្តេច
ចូលទៅកាន់សួនផ្លាឈើនោះ ។ នាងមល្លិកានោះ ឃើញព្រះ
រាជាស្តេចមក ទើបប្រណិបត្តិស្តេច ។ ព្រះរាជាទ្រង់ពេញចិត្ត
ក្នុងការប្រណិបត្តិរបស់នាងហើយ ទទួលបង្គាប់ឱ្យហៅបិតាមក

ទ្រង់ប្រទានឥស្សរិយយសជាច្រើន ហើយនាំនាងចូលមកកាន់ខាងក្នុងព្រះរាជវាំង ទ្រង់ស្ថាបនាទុកក្នុងតំណែងអគ្គមហេសី ។ ខាងក្រោយថ្ងៃមួយ ព្រះរាជាទ្រង់ត្រិះរិះថា យើងឱ្យឥស្សរិយ-យស ជាច្រើនដល់នាង បើសិនណា យើងគប្បីសួរនាងថា អ្នកណាជាទីស្រឡាញ់របស់នាង, នាងទូលថា បពិត្រមហារាជ ព្រះអង្គជាទីស្រឡាញ់របស់នាងខ្ញុំ ហើយបើសិននាងសួរយើងកាលជាដូច្នេះ យើងនឹងតបដល់នាងវិញថា នាងប៉ុណ្ណោះជាទីស្រឡាញ់របស់យើង ។ ដូចនោះ ព្រះរាជាកាលនឹងទ្រង់ធ្វើសម្មោទនីយ:ដើម្បីឱ្យកើតសេចក្ដីស្និទ្ធស្នាលគ្នានិងគ្នា ទើបត្រាស់សួរ ។ ក៏ព្រះទេវី ជាបណ្ឌិតជាឧបដ្ឋាយិការបស់ព្រះ ពុទ្ធ ជាឧបដ្ឋាយិការបស់សង្ឆ ទ្រង់ត្រិះរិះថា បញ្ហានេះមិនគួរយើញ ដល់មុខក្រាបទូលព្រះរាជា កាលនឹងទូលតាមសេចក្ដីពិតនោះឯង ទើបទូលថា ព្រះអង្គ **នាងខ្ញុំមិនមានអ្នកណាជទ្ទៃដែលនិងជាទីស្រឡាញ់ក្រៃលែងទៅជានងខ្លួនខ្ញុំម្ចាស់ទេ** ។ ព្រះទេវីសូម្បីត្រាស់ហើយប្រាជ្ញានឹងធ្វើអត្ថ ដែលខ្លួនអះអាងឱ្យប្រចក្ស ដល់ព្រះរាជាដោយឧបាយ ទើបទូលសួរព្រះរាជាដូចដែលព្រះរាជា

ត្រាស់សួរខ្ញុំនឯងថា ព្រះអង្គ ក៏ព្រះអង្គមានអ្នកណាដទៃ ជាទីស្រឡាញ់ក្រៃលែងជាងខ្ញុំនឬទេ ។ ចំណែកព្រះរាជា មិនអាចត្រឡប់(សេចក្ដី)បាន ព្រោះព្រះទេវីត្រាស់ដោយលក្ខណៈ ព្រមទាំងកិច្ច សម្បីព្រះអង្គខ្ញុំនឯងក៏ត្រាស់ដោយលក្ខណៈ ព្រមទាំងកិច្ច ទើបត្រាស់បញ្ជាក់ច្បាស់ដូចព្រះទេវីត្រាស់ ។

ក៏ត្រាត្រាស់បញ្ជាក់ច្បាស់ហើយ ព្រោះសេចក្ដីដែលព្រះអង្គមានបញ្ញាទន់ខ្សោយ ទើបទ្រង់ត្រិះរិះយ៉ាងនេះថា យើងជាព្រះរាជាអ្នកជាធំក្នុងផែនដី គ្រប់គ្រងយុំគ្រងបបរីមណ្ឌលធំ ការនឹងបញ្ជាក់ច្បាស់ថា យើងមិនឃើញបុគ្គលដទៃដែលជាទីស្រឡាញ់ឱ្យក្រៃលែងជាងខ្ញុំ ដូច្នេះ មិនសមគួរដល់យើងឡើយ តែនាងនេះជាស្រីបោកទាប ជាតិអាក្រក់យើងតាំងទុកក្នុងតំណែងខ្ពស់ ក៏មិនទាន់ស្រឡាញ់យើងអ្នកជាស្វាមីយ៉ាងពិតមែន នៅពោលចំពោះមុខយើងថា ខ្ញុំប៉ុណ្ណោះជាទីស្រឡាញ់ដល់ខ្ញុំ ដូច្នេះ ហើយទើបមិនពេញព្រះទ័យពោលថា នាងស្រឡាញ់ព្រះរតនត្រ័យច្រើនជាងឬ ។ ព្រះទេវីក្រាបទូលថា ព្រះអង្គខ្ញុំម្ចាស់ប្រាថ្នាសុខក្នុងសួគ៌ និងសុខក្នុងមគ្គដើម្បីខ្ញុំ សម្បីព្រះរតនត្រ័យ

ខ្ញុំម្ចាស់ក៏ស្រឡាញ់ព្រោះដូច្នោះខ្លួនឯងនុ៎ះឯង ទើបជាទីស្រឡាញ់ក្រៃលែងរបស់ខ្ញុំម្ចាស់ ។ ក៏សត្វលោកទាំងអស់នេះ ស្រឡាញ់អ្នកដទៃក៏ដើម្បីប្រយោជន៍ខ្លួនឯងប៉ុណ្ណោះ សូម្បីកាលប្រាថ្នាបុត្រ ក៏ប្រាថ្នាថា បុត្រនេះនឹងចិញ្ចឹមរក្សាយើងក្នុងវ័យចាស់ កាលប្រាថ្នាធីតា ក៏ប្រាថ្នាថាត្រកូលរបស់យើង នឹងចម្រើនឡើងកាលប្រាថ្នាភរិយា ក៏ប្រាថ្នាថា នឹងបម្រើជើងយើង កាលប្រាថ្នាសូម្បីអ្នកដទៃនឹងជាញាតិមិត្ត ឬពួកត្រូវគ្នា ក៏ប្រាថ្នាជាប់ដោយកិច្ចនោះ ។ ដូចនោះ សត្វលោក ជាអ្នកយើញតែប្រយោជន៍ខ្លួនប៉ុណ្ណោះ ទើបស្រឡាញ់អ្នកដទៃ រួមសេចក្តីថា ព្រះទេវីមានសេចក្តីប្រាថ្នាយ៉ាងនេះឯង ។

លំដាប់នោះ ព្រះរាជាទ្រង់ព្រះត្រិះរិះថា នាងមល្លិកានេះជាអ្នកឆ្លាត ជាបណ្ឌិត វាងវៃ ពោលថា ខ្លួនឯងនុ៎ះឯង ជាទីស្រឡាញ់ក្រៃលែងដល់យើង សូម្បីខ្លួនរបស់យើងនោះឯង ក៏ប្រាកដថាជាទីស្រឡាញ់ ណ្ហើយចុះ យើងនឹងក្រាបទូលរឿងនេះចំពោះព្រះសាស្តា យើងនឹងចាំទុកតាមដែលព្រះសាស្តាទ្រង់ព្យាករណ៍ដល់យើងទុក ។ ក៏គ្រាទ្រង់ត្រិះរិះយ៉ាងនេះហើយទើប

ស្តេចទៅគាល់ព្រះសាស្តាក្រាបទូលសេចក្តីនោះ ។ ដោយហេតុនោះ លោកទើបពោលថា អថ ខោ រាជា បសេនទិ កោសលោ ។បេ ។ បិយតរោ ដូច្នេះជាដើម ។

បទថា ឯតមត្ថំ វិទិត្វា សេចក្តីថា ព្រះសាស្តាទ្រង់ជ្រាបដោយប្រការទាំងពួងនៅសេចក្តីនេះ គឺដែលព្រះរាជាត្រាស់ថា សព្វសត្វក្នុងលោក ដែលមានខ្លួនជាទីស្រឡាញ់ក្រៃលែងរបស់ខ្លួន ទើបថ្លែងឧទាននេះ ដែលសម្តែងដល់សេចក្តីនោះ ។

បណ្តាបទទាំងនោះ បទថា សព្វា ទិសា អនុបរិគម្ម ចេតសា សេចក្តីថា បញ្ជូនចិត្តទៅដោយអំណាចការស្វែងរកទូទៅអស់ទាំង ១០ ទិស ។ បទថា នេវជ្ឈគា បិយតរមត្តនា ក្វចិ សេចក្តីថា បុគ្គលខ្លះ មានសេចក្តីឧស្សាហ៍យ៉ាងខ្លាំងស្វែងរកបុគ្គលដទៃ អ្នកជាទីស្រឡាញ់ក្រៃលែងដល់ខ្លួន មិនគប្បីជួប គឺមិនគប្បីប្រសព្វក្នុងទីណានីមួយ គឺក្នុងគ្រប់ទិស ។ បទថា ឯវំ បិយោ បុថុ អត្តា បរេសំ សេចក្តីថា សត្វទាំងនោះ ។ ក៏មានខ្លួនជាទីស្រឡាញ់ច្រើន គឺជាពួក ។ ដូចយ៉ាងនោះ គឺនឹងរក

អ្នកណា ១ អ្នកជាទីស្រឡាញ់ក្រៃលែងជាងខ្លួនមិនបាន ។ បទថា ตสฺสาน ហ៊ីសេ បរមត្តកាមោ សេចក្តីថា ព្រោះហេតុដែលសត្វទាំងអស់ស្រឡាញ់ត្លួងឯងគឺស្រឡាញ់សុខ ស្អប់ទុក្ខយ៉ាងនេះដូច្នោះ អ្នកស្រឡាញ់កាលប្រាថ្នាហិតសុខដើម្បីខ្លួន ទើបមិនគួរបៀតបៀន មិនសម្លាប់សត្វដទៃ ដោយទីបំផុត ស្រមោចខ្ទៀ ស្រមោចក្រហម ទាំងមិនបៀតបៀនដោយបហារណាវត្ថុ មានបាតដៃជុំដីនិងកំណាត់ឈើជាដើម ។ ពិតមែនកាលខ្លួនធ្វើទុក្ខឱ្យដល់បុគ្គលដទៃ ទុក្ខនោះដូចជាឈានចេញមកពីកម្មដែលខ្លួនធ្វើទុកហើយនោះនឹងប្រាកដក្នុងខ្លួនវេលាជិតស្លាប់ ។ ក៏សេចក្តីនេះជាធម្មតារបស់កម្មនុ៎ះឯង ។

ឆត្តិបុត្តសមសូត្រ

នៅក្នុងបិដកលេខ ២៩, ទំព័រ ១៤ ព្រះសម្មាសម្ពុទ្ធ ជាម្ចាស់ទ្រង់ត្រាស់អំពី [**ស្រឡាញ់អ្វីឱ្យស្នើនឹងកូនមិនមាន**] មានសេចក្តីថា ៖

សាវត្ថិនិទាន ។ លុះទេវតានោះឈរក្នុងទីដ៏សមគួរហើយ ទើបពោលគាថានេះក្នុងសំណាក់នៃព្រះមានព្រះភាគថា ៖

ន ត្ថិ បុត្តសមំ បេមំ ន ត្ថិ គោ សមិ កំ ធនំ

ន ត្ថិ សុ រិ យ សមា អា ភា សមុ ទ្ទ ប រមា សរ តិ ។

សេចក្តីស្រឡាញ់ស្មើនឹងកូនមិនមាន ទ្រព្យស្មើនឹងគោមិនមាន ពន្លឺស្មើនឹងព្រះអាទិត្យមិនមាន ស្រះទាំងឡាយប្រសើរជាងសមុទ្រ ។

ព្រះអង្គត្រាស់ថា ៖

ន ត្ថិ អ ត្ត សមំ បេមំ ន ត្ថិ ធ ញ្ញ សមំ ធនំ

ន ត្ថិ ប ញ្ញា សមា អា ភា រុ ដ្ឋិ រ ប ម សរ តិ ។

សេចក្តីស្រឡាញ់ស្មើនឹងខ្លួនមិនមាន ទ្រព្យស្មើនឹងស្រូវមិនមាន ពន្លឺស្មើនឹងប្រាជ្ញាមិនមាន ទឹកភ្លៀងហ្នឹងឯង ទុកជាស្រះប្រសើរជាង ។

អដ្ឋកថា

បាទគាថាថា ន ត្ថិ បុ ត្ត សមំ បេមំ ***សេចក្តីស្រឡាញ់ស្មើនឹងកូនមិនមាន*** *សេចក្តីថា* *បុត្រទាំងឡាយរបស់ខ្លួនសូម្បីពិការ* *មាតាបិតាក៏នៅសម្គាល់ដូចជុំមាស* *មានការធ្វើការជនួ*

ជន្ទេញត្រង់សីស:ជាដើម ហាក់ប៉ីដូចជា កម្រងផ្ការ៉ៃ បុត្រទាំងនោះសូម្បីដែលមាតាបិតាជម្រះរាងកាយហើយ ក៏នាំមកគ្រប ដណ្ដប់ទុកហើយក៏កើតសោមនស្ស ដូចបុគ្គលខ្ជប់នូវបស់ ក្រអូបនិងគ្រឿងលាបស្រឡាបដូច្នោះ ព្រោះហេតុនោះឯង ទើប ទេវតាពោលថា សេចក្ដីស្រឡាញ់ស្នេហ៍ងកូនមិនមាន គឺដែល ឈ្មោះថា សេចក្ដីស្រឡាញ់ដទៃស្នេជោយសេចក្ដីស្រឡាញ់កូន មិនមានទេ ដូច្នេះ ។

បទថា គោសមិកំ **ទ្រព្យស្នេហ៍ងគោ** គឺស្នេជោយគោ ទាំងឡាយ ទេវតាក្រាបទូលថា បពិត្រព្រះមានព្រះភាគ ធម្មតាថា ទ្រព្យដទៃដូចនឹងគោ រ៉ៃមងមិនមាន ដូច្នេះ ។

បទថា សុរិយសមា អាភា **ពន្លឺស្នេហ៍ងព្រះអាទិត្យ នេះ** ទេវតាក្រាបទូលថា ឈ្មោះថា ពន្លឺដទៃដែលស្នេជោយពន្លឺព្រះ អាទិត្យ រ៉ៃមងមិនមាន ដូច្នេះ ។

បទថា សមុទ្ទបរមា **ប្រសើរជាងសមុទ្រ** សេចក្ដីថា ឈ្មោះថា ស្រះទាំងឡាយពួកដទៃយ៉ាងណាមួយ ស្រះទាំងអស់

ទាំងនោះ មានសមុទ្រ (សមុទ្រ)ជាយ៉ាងក្រៃលែងគឺ សមុទ្ររ ប្រសើរជាង ស្រះទាំងអស់ទាំងនោះ ទេវតាទូលថា បពិត្រព្រះ មានព្រះភាគ ឈ្មោះថា ដែលជាទីកើតប្រភពទឹកដទៃដូចនឹង ដោយសមុទ្រ មិនមានទេដូច្នេះ ។

ក៏ដែលឈ្មោះថា សេចក្តីស្រឡាញ់ស្មើដោយខ្លួនមិនមាន នោះ មានអធិប្បាយថា សត្វទាំងឡាយលះចោលបិយជនទាំង ឡាយមានមាតាបិតាជាដើមក៏មាន លះចោលបុត្រធីតាជាដើមឱ្យ ពំនាក់ រមែងរកចិញ្ចឹមជីវិតខ្លួនទ្ញុះឯងក៏មាន ។ ក៏ឈ្មោះថា ទ្រព្យ ស្មើដោយស្រូវ រមែងមិនមាន អធិប្បាយថា ជនទាំងឡាយ រមែង ទៅកាន់សំណាក់របស់ម្ចាស់ទ្រព្យ ហើយទើបកាន់យកវត្ថុទាំង ឡាយមានប្រាក់និងមាសជាដើមខ្លះ និងកាន់យកគោនិងក្របីជា ដើមខ្លះ ក៏ដើម្បីកាន់យកស្រូវទ្ញុះឯង ។ ឈ្មោះថា ពន្លឺស្មើដោយ បញ្ញា រមែងមិនមាន សូម្បីជាព្រះអាទិត្យជាដើម ក៏រមែងបំភ្លឺ ពន្លឺតែម្យ៉ាងប៉ុណ្ណោះ គឺរមែងកម្ចាត់សេចក្តីងងឹតដែលជាបច្ចុប្បន្ន ប៉ុណ្ណោះ ។ ចំណែកបញ្ញារមែងអាចដើម្បីធ្វើលោកធាតុតាំងម៉ឺន ឱ្យជាពន្លឺដ៏ប្រសើរ មិនមានវត្ថុដទៃស្មើ ទាំងរមែងកម្ចាត់សេចក្តី

ផ្ទឹតដែលបិទបាំង ក្នុងកាលដែលជាចំណែកនៃអតីតជាដើម បានផង ។ ឈ្មោះថាស្រះស្ងើដោយភ្លៀងរមែងមិនមាន ។ សូម្បីទន្លេ ឬត្រពាំងទឹក ឬសមុទ្រសាបជាដើមក៏ដោយ ទីដែលឈ្មោះថាស្រះហើយ ដែលនឹងស្ងើដោយភ្លៀង រមែងមិនមាន ព្រោះកាលភ្លៀងកាត់ដាច់ហើយ ទឹកសូម្បីត្រឹមតែមួយថ្នាំងដៃ ឱ្យសើមក្នុងមហាសមុទ្រ រមែងមិនមាន ។ តែកាលភ្លៀងធ្លាក់ហើយប្រព្រឹត្តទៅ ទឹកក៏ជាប់តគ្នា រមែងមានជល់ពិភពនៃព្រហ្មជាន់អាភស្សរ ព្រោះហេតុនោះ ព្រះមានព្រះភាគ កាលនឹងត្រាស់តបពាក្យរបស់ទេវតា ទើបត្រាស់ព្រះគាថាថា ៖

ន ត្ថិ អត្តសមំ ឃេមំ ន ត្ថិ ធញ្ញសមំ ធនំ
ន ត្ថិ បញ្ញាសមា អាភា ១ ១ ១

ចំណុចបដិបត្តិ

អ្នកដែលបានធ្វើព្រះនិព្វានឱ្យច្បាស់ហើយ នៅពេលចិត្តលោកបញ្ជូនទៅកាន់ព្រះនិព្វាន ហើយសេចក្តីស្រឡាញ់ចូលទៅរំខានលោកមិនបានឡើយ លោកបាន កាត់សេចក្តីស្រឡាញ់បានហើយ ព្រោះហេតុនោះ បានជាលោកមិនមានសេចក្តីសោក ឬ សេចក្តីក្រៀមក្រំចិត្ត ។

ចំណែកពួកបុថុជ្ជនយើងវិញ សូម្បីនៅមិនអាចកាត់នៅសេចក្តីស្រឡាញ់បានយ៉ាងណាក៏ដោយ តែបើវិតវំព្យាយាមចម្រើនឫសមាធិ ចម្រើនឫមរណសតិជាប្រចាំរាល់ថ្ងៃទៅ ក៏នឹងមានឫសេចក្តីសោកតិចជាងមនុស្ស ដែលមិនបានចម្រើនឫមរណសតិ មានអាការមិនធ្ងន់ ព្រោះគេបាននឹកឃើញដល់សេចក្តីស្លាប់ ហើយធ្វើឱ្យគេមានការដកចិត្តអំពីសេចក្តីស្រឡាញ់ ដែលជាដើមហេតុនៃសេចក្តីសោក ដោយគេគិតថា យើងខ្លួនឯងក៏ត្រូវស្លាប់ ហើយថែមទាំងមិនដឹងថា និងស្លាប់នៅពេលណាទេកាលដែលគេបានគិតយ៉ាងនេះហើយ សេចក្តីសោក សេចក្តីស្រឡាញ់ក៏និងអាចអស់ទៅអំពីសន្ធានចិត្តបាន បើគេមានការពិចារណាយ៉ាងនេះហើយ រមែងជាអ្នកមិនប្រមាទ មានព្យាយាមក្នុងការ

សាងសេចក្ដីល្អហើយ បើគេតាំងចិត្ដវិតវំចម្រើនទូវសមាធិភាវនា ឱ្យខ្ជាំងក្លា ក៏និងអាចសម្រេចនូវព្រះ និព្វានបាន ។

ចំណុចជាស់ត្បឿនចិត្ត

សេចក្ដីសោកសេចក្ដីទុក្ខដ៏ច្រើនយ៉ាងនេះ មាននៅក្នុងលោក ក៏ព្រោះអាស្រ័យសត្វនិងសង្ខារជាទីស្រឡាញ់ ។

បើមិនមានសត្វ និងសង្ខារជាទីស្រឡាញ់ហើយសេចក្ដីសោក សេចក្ដីទុក្ខ ពួកនេះក៏មិនមានដែរ ។

អ្នកណាមិនមានសត្វ និងសង្ខារជាទីស្រឡាញ់ហើយ អ្នកនោះ រមែងមានតែសេចក្ដីសុខប្រាសចាកសេចក្ដីសោក ។

ព្រោះហេតុនោះ អ្នកប្រាជ្ញានូវសេចក្ដីមិនសោក មិនគប្បីធ្វើសត្វនិងសង្ខារណាក្នុងលោកឱ្យជាទីស្រឡាញ់ឡើយ ។

អសោកំ ឯតម្ងគ្គលមុត្ដំ ។

☝. មិនមានសេចក្ដីសោក នេះជាមង្គលដ៏ឧត្ដម ។

មង្គលកថាមង្គលទី ៣៦ ចប់

គម្ពីរជាឧបករណ៍ក្នុងការរៀបរៀងសៀវភៅនេះ

-គម្ពីរព្រះត្រៃបិដករបស់ពុទ្ធសាសនបណ្ឌិត ព.ស. ២៤៩៩

-អដ្ឋកថាពន្យល់សេចក្ដីនៃគម្ពីរព្រះត្រៃបិដក ព.ស. ២៥២២

- មង្គលត្ថទីបនី ភាគ ៤ របស់ព្រះមហាយ៉ិន ឌឿន ព.ស. ២៥៣៨
- គម្ពីរឃ្លាំងបរិយត្តិភាគ ១-២ ព.ស. ២៥៤៧
- គម្ពីរធម្មាវលី របស់ភិក្ខុ ធម្មវរាចារ្យ
- វចនានុក្រម សម្ដេចព្រះសង្ឆរាជ ជួន ណាត ព.ស. ២៥១១
- ព្រមទាំងឯកសារមួយចំនួនទៀត ។

ថ្ងៃល្អនៃជីវិត

នៅក្នុងបិដកលេខ ៤១ ទំព័រ ៤៧៥ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់ជាមួយនឹងភិក្ខុថាម្នាលភិក្ខុទាំងឡាយសត្វទាំងឡាយណា ប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិត ដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្ត ក្នុងវេលាព្រឹក វេលាថ្ងៃ វេលាល្ងាច សត្វទាំងនោះឈ្មោះថា មានវេលាព្រឹត្តដ៏ល្អវេលា ថ្ងៃដ៏ល្អវេលាល្ងាចដ៏ល្អ។ សមដូចព្រះគាថាថា៖

សុនក្ខត្តំ សុមង្គលំ សុបភាតំ សុហុដ្ឋិតំ
សុខណោ សុមុហុត្តោ ច សុយិដ្ឋំ ព្រហ្មចារិសុ។

ថ្ងៃណាដែលសត្វទាំងឡាយ ប្រព្រឹត្តល្អដោយកាយ វាចា ចិត្ត ថ្ងៃនោះឈ្មោះថា នក្ខត្តបឫក្សល្អ មង្គលល្អ ថ្ងៃភ្ញីស្វាងល្អ ថ្ងៃនៃអរុណរះឡើងល្អ ខណៈល្អ យាមល្អ (ទានដែលបុគ្គលបូជាហើយ)ដល់ព្រហ្មចារីបុគ្គលទាំងឡាយ (ក្នុងពេលនោះឈ្មោះថាជាគ្រឿងបូជាល្អ។